# ការវាយតំលៃបញ្ហាសង្គមពាក់ព័ន្ធ នឹងដីធ្លីនៅកម្ពុជា

## អង្កេតនៅតាមមូលដ្ឋាន

ឯកសារពិភាក្សាលេខ ២០

សុ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រ័ត្នមុនី
Brett Ballard និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ ខែមីនា ឆ្នាំ២០០២

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឡើយ ។

ISSN 1560 9812

**ការវាយតំលៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា: អង្កេតនៅតាមមូលដ្ឋាន_ ឯកសារពិភាក្សាលេខ ២០ ខែមីនា ឆ្នាំ២០០២**

*សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-វ័ឌ្ឍមុនី* ***Brett Ballard* និង *Sarthi Acharya***

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះ បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែល: **cdri@camnet.com.kh website: http://www.cdri.org.kh**

បកប្រែដោយ: យូ សិទ្ធីរិទ្ធ
កែសម្រួល និងរចនាដោយ: អ៊ុំ ចាន់ថា

# មាតិកា


សេចក្តីថ្លែងអំណរគុណ....................i
បញ្ជីអក្សរកាត់....................iii
សេចក្តីសង្ខេប....................១

**ជំពូក១. សេចក្តីផ្តើម**....................៧
១.១. គោលបំណង....................៧
១.២. សារៈតារ និងតំរូវការនៃការសិក្សា....................៧
១.៣. គោលដៅ....................៩
១.៤. វិធីសាស្ត្រ....................៩
១.៥. ទំរង់របាយការណ៍....................១០

**ជំពូក២. ស្ថានភាពដីធ្លីនៅក្នុងប្រទេសកម្ពុជា**....................១៣
២.១. ការកំណត់ស្ថានភាពដីធ្លីតាមទ្រឹស្តី....................១៣
២.២. ប្រវត្តិសង្ខេបអំពីដីធ្លីនៅកម្ពុជា....................១៤
២.៣. ក្តីកង្វល់ធំៗមួយចំនួនចំពោះស្ថានភាពដីបច្ចុប្បន្ន....................១៥
២.៤. សេចក្តីសង្ខេប....................១៩

**ជំពូក៣. ស្ថានភាពដីធ្លី**....................២១
៣.១. លំនាំនៃការប្រើប្រាស់ដីធ្លី....................២១
៣.២. ការផ្ទេរ និងលទ្ធកម្មដី....................២៣
៣.៣. ការផ្តល់ប័ណ្ណប្លង់ដី និងប័ណ្ណប្លង់ដី....................២៤
៣.៤. ទិដ្ឋភាពនៃតួនាទីបុរស-ស្ត្រី ក្នុងការប្រើប្រាស់ដី និងកម្មសិទ្ធិដីធ្លី....................២៦
៣.៥. អំពីតុល្យភាពរវាងប្រជាជន និងធនធាន....................២៧
៣.៦. សេចក្តីសង្ខេប....................២៧

**ជំពូក៤. រចនាសម្ព័ន្ធអភិបាលកិច្ចដីធ្លី** ..... ២៩
៤.១. សេចក្តីផ្តើម ..... ២៩
៤.២. ប្រព័ន្ធផ្តល់កម្មសិទ្ធិ ..... ២៩
៤.៣. អ្វីទៅជាប័ណ្ណប្លង់ដី? ..... ៣១
៤.៤. បញ្ហានានាដែលអាជ្ញាធរត្រូវប្រឈមមុខ ក្នុងការផ្តល់ប័ណ្ណប្លង់ដី និងការចុះបញ្ជី ..... ៣៤
៤.៥. អំពីសមត្ថភាព ..... ៣៧
៤.៦. សេចក្តីសង្ខេប ..... ៣៧

**ជំពូក៥. ទំនាស់ និងយន្តការដោះស្រាយទំនាស់** ..... ៣៩
៥.១. សេចក្តីផ្តើម ..... ៣៩
៥.២. ទំនាស់ដីធ្លី ..... ៣៩
៥.៣. ការដោះស្រាយទំនាស់ដីធ្លី ..... ៤២
៥.៤. ការកត់សំគាល់ ..... ៤៥
៥.៥. សេចក្តីសង្ខេប ..... ៤៨

**ជំពូក៦. គោលនយោបាយ និងអនុសាសន៍នានា** ..... ៤៩
៦.១. សេចក្តីផ្តើម ..... ៤៩
៦.២. ការផ្តល់ប្លង់ដីទៅតាមច្បាប់ និងការកំណត់លំដាប់សកម្មភាព ..... ៤៩
៦.៣. ការពង្រឹង និងការធ្វើវិមជ្ឈការអាជ្ញាធរអភិបាលកិច្ចដីធ្លី ..... ៥១
៦.៤. ការដោះស្រាយវិវាទ ..... ៥២
៦.៥. ការកំណត់គោលនយោបាយថ្មីស្តីពីទីជំរក និងការផ្លាស់ទីលំនៅ ..... ៥៤
៦.៦. ការទទួលស្គាល់សិទ្ធិប្រជាជនដើម ..... ៥៥
៦.៧. ការទទួលស្គាល់សិទ្ធិស្ត្រី ..... ៥៦
៦.៨. ការធ្វើតាមបទពិសោធន៍ល្អបំផុត ..... ៥៧
៦.៩. ការធ្វើហិរញ្ញប្បទានដល់ដំណើរការធ្វើប្លង់ដី ..... ៥៨
៦.១០. ការបង្កើតទិន្នន័យ និងពត៌មាន និងការពង្រីកការអប់រំអំពីបញ្ហាដីធ្លី ..... ៥៩

**ជំពូក៧. ការសន្និដ្ឋានរួម** ..... ៦១

**ករណីសិក្សា** ..... ៦៥
១. ករណីសិក្សានៅភូមិកំពង់ព្រីង ក្នុងខេត្តកណ្តាល ..... ៦៥
២. ករណីសិក្សានៅភូមិកំពង់ត្នោត ក្នុងខេត្តកំពត ..... ៦៩
៣. ករណីសិក្សានៅភូមិបាបោង ក្នុងខេត្តព្រៃវែង ..... ៧៣
៤. ករណីសិក្សានៅ ភូមិ៤ ក្នុងខេត្តកំពង់ស្ពឺ ..... ៧៧

៥. ករណីសិក្សានៅភូមិផ្សាក់ និងភូមិតាអងក្នុងខេត្តរតនគិរី ......... ៨១
៦. ករណីសិក្សានៅតំបន់អណាធិបតេយ្យក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ......... ៨៤
៧. របាយការណ៍សិក្ខាសាលាអ្នកពាក់ព័ន្ធ: ការតាំងលំនៅក្នុងទីក្រុង ......... ៨៨

**សេចក្តីណែនាំសំរាប់ធ្វើសំភាសន៍គុណភាព** ......... ៩៣

**ឯកសារយោង** ......... ១០៥

**ឯកសារពិភាក្សាបោះពុម្ពផ្សាយដោយ វបសអ** ......... ១០៧

# សេចក្តីថ្លែងអំណរគុណ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) សូមថ្លែងអំណរគុណចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃរាជរដ្ឋាភិបាលកម្ពុជា ចំពោះឱកាសដ៏មានតំលៃ ដែលបានផ្តល់ឱ្យវិទ្យាស្ថាន ដើម្បីធ្វើការសិក្សានេះ ។ ការសិក្សាបានទទួលមូលនិធិពីគំរោងអភិវឌ្ឍន៍ធនធានមនុស្ស និងគោលនយោបាយរបស់ធនាគារពិភពលោកដែលប្រើប្រាស់ជំនួយឥតចំណងរបស់រាជរដ្ឋាភិបាលជប៉ុន ។

ការសិក្សានេះត្រូវបានធ្វើឡើងជាបឋម ដោយមានកិច្ចសហប្រតិបត្តិការពីសំណាក់ប្រជាពលរដ្ឋសាមញ្ញនៃប្រទេសកម្ពុជា មានជាអាទិ៍ កសិករ ពលករ ជនចំណាកស្រុក ប្រជាជនដើម ស្ត្រី អ្នកតាំងទីលំនៅខុសច្បាប់ និងក្រុមជាច្រើនទៀតដែលយើងបានជួបនៅតាមភូមិ តាមដងផ្លូវ តាមតំបន់តាំងទីលំនៅមានប្រាក់ចំនូលទាបនៅក្នុងក្រុង ។ បើសិនជាពួកគេមិនអបអរសាទរ និងមិនផុសផុលលះបង់ពេលវេលាជួយទេ យើងក៏មិនអាចប្រមូលពត៌មានបានដែរ ។ ដូច្នេះដំបូងបង្អស់យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ៗគ្នាដូចរៀបរាប់ខាងលើ ។ នៅថ្នាក់ភូមិ ប្រធានភូមិនានាបានជួយជ្រោមជ្រែងកិច្ចការនេះយ៉ាងច្រើនបំផុត ហើយនៅតាមឃុំ ប្រធានឃុំ និងបុគ្គលិកឃុំ ក៏បានជួយខ្នះខ្នែងខ្លាំងណាស់ដែរ ។

នៅថ្នាក់ស្រុក គេបានផ្តល់ពត៌មានថ្នាក់កណ្តាលដ៏មានសារៈសំខាន់ចំពោះការសិក្សា ។ បុគ្គលិកការិយាល័យខ្សែបណ្តោយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និងសមាជិកនៃគណៈកម្មការដោះស្រាយបាតុភាពដីធ្លី ដែលមានជាអាទិ៍ អភិបាល និងអភិបាលស្រុករង បានជួយផ្តល់ចំលើយយ៉ាងច្រើនចំពោះសំនួរនានារបស់យើង ។ ពួកគេក៏បានផ្តល់ពត៌មានលំអិតស្តីពីតំបន់នីមួយៗក្នុងស្រុករបស់ខ្លួនផងដែរ ហើយពត៌មានទាំងនេះមានប្រយោជន៍យ៉ាងច្រើន សំរាប់ការការរៀបចំភូមិគំរូតាងទាំងឡាយ ។ មន្ត្រីថ្នាក់ខេត្តនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, មន្ទីរកសិកម្ម, មន្ទីរអភិវឌ្ឍន៍ជនបទ, មន្ទីរពន្ធដារ, ប្រធាន/អនុប្រធានតុលាការ, ទាំងអស់គ្នាផុសផុលណាស់ក្នុងការផ្តល់ចំលើយចំពោះសំនួររបស់ក្រុមស្រាវជ្រាវ ។ មួយចំណែកទៀត សូមថ្លែងអំណរគុណ ចំពោះសមាជិកនៃគណៈកម្មការដោះស្រាយបាតុភាពដីធ្លី ជាពិសេសឯកឧត្តមអភិបាលខេត្តរងនានាដែលបានចំណាយពេលវេលាចែករំលែកបទពិសោធន៏ និងផ្តល់ពត៌មានស្តីពីការលំបាកផ្សេងៗដល់យើងខ្ញុំ ។

មន្ត្រីសង្កាត់ មន្ត្រីខ័ណ្ឌ និងមន្ត្រីសាលាក្រុងភ្នំពេញ មិនត្រឹមតែបានផ្តល់ពត៌មានទាក់ទិននឹងរាជធានីឱ្យយើងខ្ញុំណ្ណោះទេ ប៉ុន្តែ បានចំណាយពេលពេញមួយថ្ងៃចូលរួមក្នុងសិក្ខាសាលាសំរាប់អ្នកពាក់ព័ន្ធ ដើម្បីចែករំលែកនូវការសង្កេតផ្សេងៗរបស់ខ្លួនអំពីបញ្ហាដីធ្លីនៅតំបន់ទីក្រុង ។ យើងខ្ញុំសូមថ្លែងអំណរគុណជ ាពិសេសចំពោះ ឯកឧត្តម ចេវ គឹមហេង អភិបាលរងរាជធានីភ្នំពេញដែលបានចូលរួមក្នុងសិក្ខាសាលានេះដែរ ។

យើងសូមថ្លែងអំណរគុណចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានបញ្ជូនបុគ្គលិកពីររូបគឺ លោក អ៊ុច ឧទេយ្យ និងលោក ស៊ី រ័ត្នមុនី ឱ្យមកចូលរួមក្នុងក្រុមស្រាវជ្រាវរបស់យើងខ្ញុំ ។ យើងសូមអរគុណចំពោះ លោកស្រី Mary Judd មកពីធនាគារពិភពលោកដែលបានផ្តល់យោបល់ចំពោះរបាយការណ៍បណ្តោះអាសន្ន និងរបាយការណ៍លើកដំបូង ។ យើងសូមថ្លែងអំណរគុណចំពោះបណ្ឌិត អ៊ូ វិឌ្ឍី មកពីក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាងដល់ក្រុមស្រាវជ្រាវ ។ យើងសូមថ្លែងអំណរគុណឯកឧត្តម សេក សេដ្ឋា ប្រធានការិយាល័យសុរិយោដីកណ្តាលដែលបានណែនាំយើងខ្ញុំពីការងារបច្ចេកទេសលំអិតក្នុងផ្តល់កម្មសិទ្ធិ ។ យើងសូមថ្លែងអំណរគុណចំពោះឯកឧត្តម ទី យ៉ាវ និងលោក សរ សុវណ្ណ ដែលបានរៀបចំគំរោងសិក្សាស្រាវជ្រាវទូលំទូលាយ ហើយបើសិនគ្មានការរួមវិភាគទានបែបនេះទេ ការសិក្សាមិនអាចទៅហួសពីជំពូកទីមួយឡើយ ។ យើងសូមថ្លែងអំណរគុណចំពោះឯកឧត្តម អ៊ឹម ឈុនលឹម ដែលបានផ្តល់ការណែនាំតាំងពីដើមដំបូងថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានគោលដៅផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមស្រាវជ្រាវសូមថ្លែងអំណរគុណផងដែរ ចំពោះតំណាងអង្គការ GTZ និង FInnMap ដែលបានចូលរួមមតិជាច្រើនស្តីពីការចុះបញ្ជីដីធ្លីតាមលក្ខណៈជាប្រព័ន្ធ ។

ការសិក្សានេះប្រហែលមិនអាចប្រព្រឹត្តទៅបានទេ បើសិនក្រុមស្រាវជ្រាវមិនបានទទួលការណែនាំជាប្រចាំពី លោកស្រី អេវ៉ា មីស្លីវិក នាយិកា វបសអ នៅក្នុងដំណាក់កាលនៃការរៀបចំគំរោងតាំងពីដំបូង ការចុះសិក្សាដល់ទីកន្លែង ក៏ដូចជាការតាក់តែងឯកសារនេះ ។ បទពិសោធន៍ និងការយល់ឃើញនានា ព្រមទាំងមតិរបស់លោកស្រីនាយិកា ចំពោះពង្រាងឯកសារដំបូង និងពង្រាងក្រោយៗមកទៀត បានអនុញ្ញាតអោយយើងខ្ញុំអាចបញ្ចប់ការសិក្សានេះក្នុងរយៈពេលដ៏ខ្លីត្រឹមតែប្រាំបីសប្តាហ៍ប៉ុណ្ណោះ ។

*រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០០១*

*សូ-សុវណ្ណរិទ្ធិ អ៊ុច-ឧទេយ្យ ស៊ី-រ័ត្នមុនី*

*Brett Ballard និង Sarthi Acharya*

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ACLEDA | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (Association of Cambodian Local Economic Development Agencies) |
| Baseline Survey | អង្កេតមូលដ្ឋាន |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CMAC | មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (Cambodian Mines Action Centre) |
| DLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (Department of Land Management, Urban Planning, Construction, and Cadastre) |
| FinnMap | ទីភ្នាក់ងារហ្វាំងឡង់ប្រចាំនៅកម្ពុជា (Finnish Agency in Cambodia) |
| GTZ | ទីភ្នាក់ងារសហការបច្ចេកទេសអាល្លឺម៉ង់ (German Agency for Technical Co-operation) |
| ILO | អង្គការពលកម្មអន្តរជាតិ (International Labour Organisation) |
| LDSC | គណៈកម្មការដោះស្រាយបាតុភាពដីធ្លី (Land Dispute Settlement Commission) |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Ministry of Land Management, Urban Planning and Construction) |
| MRC | គណៈកម្មការទន្លេមេគង្គ (Mekong River Commission) |
| NGO | អង្គការក្រៅរដ្ឋាភិបាល (Non-Governmental Organisation) |
| NTFP | អនុផលព្រៃឈើ (Non-Timber Forest Products) |
| OLMUPCL | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល (Office of Land Management, Urban Planning, Construction and Land) |
| PET | អង្កេតមុខសញ្ញាសង្គ្រោះបន្ទាន់រយៈពេលយូរ (Protracted Emergency Target Survey) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| SES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (Socio-economic Survey) |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Swedish International Development Agency) |
| UNICEF | មូលនិធិសំរាប់កុមារនៃអង្គការសហប្រជាជាតិ (United Nations Children's Fund) |
| UNTAC | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា (United Nations Transitional Authority in Cambodia) |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ (Village Development Committee) |
| WFP | អង្គការស្បៀងអាហារពិភពលោក (World Food Programme) |

# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកម្មវិធីកំណែទំរង់សំខាន់ៗ ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចមានចីរភាព កាត់បន្ថយភាពក្រីក្រ និងពង្រឹងសន្តិភាព ។ ជាការចាប់ផ្តើមចំពោះកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ និងចុះបញ្ជីដីធ្លី ជាបឋមរដ្ឋាភិបាលបានសំរេចធ្វើការវាយតំលៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លី ដើម្បីបានរបាយការណ៍មួយស្តីពីស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន ទាក់ទងនឹងការគ្រប់គ្រងដីធ្លី ទំនាស់ដីធ្លី និងសមត្ថភាពរបស់អាជ្ញាធរក្នុងការគ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លីឱ្យមានប្រសិទ្ធិភាព ។ កម្មវត្ថុចំបងនៃការវាយតំលៃបញ្ហាសង្គមនេះមាន: ១. ការកំនត់អ្នកពាក់ព័ន្ធនឹងដីធ្លី និងគំរោង ២.ការពិនិត្យពីសមត្ថភាពរបស់សង្គម និងស្ថាប័ននៅតាមមូលដ្ឋានសំរាប់ការគ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី ៣. ព្យាករណ៍ពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានដល់កម្មវិធី និង ៤. ការផ្តល់អនុសាសន៍ស្តីពីគោលនយោបាយពាក់ព័ន្ធនានា ។

ការសិក្សានេះ ជារបៀបវិភាគគុណភាព ដោយផ្អែកជាសំខាន់លើករណីសិក្សាចំនួន ៥ ដែលបានធ្វើឡើងនៅក្នុង ៥ភូមិ (ភូមិមួយក្នុងខេត្តមួយ) នៃខេត្តកណ្តាល ព្រៃវែង កំពត កំពង់ស្ពឺ និងរតនគិរី និងករណីសិក្សាពីទីប្រជុំជនមួយនៅក្រុងភ្នំពេញ ។ ភូមិសិក្សានីមួយៗមានបរិស្ថានកសិកម្ម-អេកូឡូស៊ីខុសៗគ្នា រីឯការសិក្សានៅភ្នំពេញផ្តោតទៅលើតំបន់អនាធិបតេយ្យ ។ ដូច្នេះហើយ ការសិក្សានេះប្រហែលជាមិនអាចតំណាងឱ្យស្ថានភាពទូទៅក្នុងប្រទេសកម្ពុជាបានទេ ។ វិធីសាស្រ្តវិភាគគុណភាពផ្សេងៗ ដូចជាការពិភាក្សាជាក្រុមតូចៗ និងការសំភាសន៍ជាមួយគ្រួសារ កសិករ ជនចំណាកស្រុក យោធិនរំសាយ ក្រុមនារីផ្សេងៗ និងមន្រ្តីមូលដ្ឋាន ត្រូវបានប្រើប្រាស់ដើម្បីចងក្រងករណីសិក្សាទាំងអស់នេះ ។ ក្រុមអ្នកស្រាវជ្រាវក៏បានសំភាសថ្នាក់ដឹកនាំនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីថ្នាក់ខេត្ត និងស្រុក, មន្រ្តីនៃគណៈកម្មការដោះស្រាយបាតុភាពដីធ្លី, ប្រធានតុលាការខេត្ត មន្រ្តីពន្ធដារ មេភូមិ មេឃុំ និងអភិបាលស្រុក ហើយនៅខេត្តខ្លះ ក្រុមបានជួបសំភាសន៍ជាមួយអភិបាលរងខេត្តថែមទៀតផង ។ នៅភ្នំពេញ សិក្ខាសាលាមួយមានរយៈពេលមួយថ្ងៃដែលមានការចូលរួមពីសំណាក់មន្រ្តីនៃសាលាក្រុង ខ័ណ្ឌ សង្កាត់ និង NGOs ត្រូវបានរៀបចំឡើងដើម្បីដកស្រង់ពត៌មានស្តីពីបញ្ហាដីធ្លីនៅក្នុងក្រុងភ្នំពេញ ។ ក្រុមស្រាវជ្រាវបានជួបសំភាសន៍ផងដែរជាមួយមន្រ្តីនៃនាយកដ្ឋានសុរិយោដីនៅភ្នំពេញ ។ កំនត់សង្កេតទាំងអស់ដែលមាននៅក្នុងការសិក្សា គឺផ្អែកទៅលើចម្លើយស្រង់បានពីការចុះសំភាសដល់ទីកន្លែងទាំងនេះ ។

ប្រទេសកម្ពុជាបានធ្វើឯកជននីយកម្មដីធ្លីនៅឆ្នាំ១៩៨៩ ហើយជាទូទៅគេមានជំនឿថា នៅពេលនោះការបែងចែកដីធ្លីមានសមភាព ទាំងចំពោះដីកសិកម្ម និងដីលំនៅដ្ឋាន ។ គ្រួសារមានរបរចំបងធ្វើកសិកម្ម បានទទួលរបបដីតាមចំនួនសមាជិកគ្រួសារ ។ ប៉ុន្តែដោយសារកង្វះធនធានមនុស្ស និងហិរញ្ញវត្ថុ, ការធ្វើផែនទីសុរិយោដី និងបញ្ជាក់ឈ្មោះម្ចាស់កម្មសិទ្ធិដី មិនអាចធ្វើសំរេចទាំងអស់នៅពេលនោះទេ ។ ដូច្នេះហើយប្រជាជនបន្តអនុវត្តតាមរបៀបជាប្រពៃណី ឬតាមទំលាប់នៅក្នុងមូលដ្ឋានក្នុងការគ្រប់គ្រង សិទ្ធិកាន់កាប់ដីធ្លី ដោយផ្អែកលើការប្រើប្រាស់ដីសំរាប់ផលិតកម្ម ។ ក្នុងមួយទសវត្សរ៍កន្លងមកនេះ មានការប្រែ

ប្រែប្រួលគួរឱ្យកត់សំគាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច (ឧទាហរណ៍ មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន, ការកកើតទីផ្សារ និងនគរូបនីយកម្ម, កំណើនប្រជាជន) ដែលបានបង្កើនតំរូវការដីធ្លីផ្សេងៗ ។ ជាលទ្ធផល សមាសភាពអ្នកពាក់ព័ន្ធនឹងដីធ្លី មានលក្ខណៈមិនដូចគ្នាទេ ។ អាស្រ័យដោយកត្តាទីផ្សារ គេឃើញមានតំរូវការខ្ពស់នូវដីពាណិជ្ជកម្ម ដីនៅជិតផ្លូវ ដីមានសក្តានុពលផលិតកម្មខ្ពស់ ដីនៅក្នុងទីក្រុង... ។ ប្រជាជនណាដែលមិនអាចសំរបខ្លួនទៅតាមការប្រែប្រួល ដោយសារមូលហេតុអ្វីមួយ អ្នកនោះមិនបានទទួលអត្ថប្រយោជន៍ពីដំណើរការនេះទេ ហើយក្នុងករណីជាច្រើន គឺបែរជាទទួលឥទ្ធិពលអាក្រក់ទៅវិញ ។ ប្រជាជនទាំងនេះមានជាអាទិ៍ ក្រុមជនងាយរងគ្រោះ (ឧទាហរណ៍ អ្នកក្រីក្រនៅជនបទ, ស្ត្រីជាមេគ្រួសារ...) ។ ក្នុងស្ថានភាពបែបនេះ គេឃើញមានបញ្ហាចំបងៗយ៉ាងតិច ៥ ដែលត្រូវពិចារណា: ១. វិសមភាពក្នុងការកាន់កាប់ដីធ្លី ២. អ្នកគ្មានដីធ្លី ៣. អសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ៤. ទំនាស់ដីធ្លី និង ៥. ការចាប់យកដីសាធារណៈក្នុងទីក្រុងដោយអ្នកតាំងទីលំនៅមិនស្របច្បាប់ ។

លំនាំនៃការប្រើប្រាស់ដីធ្លីបានប្រែប្រួលយ៉ាងខ្លាំង ជាពិសេសនៅតាមតំបន់ពាណិជ្ជកម្មនានា ហើយវាជាប់ទាក់ទងទៅនឹងកំណើននៃតំរូវការដីធ្លីពីសំណាក់ក្រុមនានាដែលមានផលប្រយោជន៍ខុសៗគ្នា ដូចជា ក្រុមហ៊ុនឯកជន ស្ថាប័នរដ្ឋ បុគ្គលមានតួនាទី និងសិទ្ធិអំណាចធំ ដូចជា មន្ត្រីរដ្ឋាភិបាល មន្ត្រីយោធា... ។ តំរូវការដីធ្លីក៏បានកើនឡើងក្នុងចំណោមកសិករផងដែរ ដោយសារកំណើននៃការរំលែកចែកដីជាចំណែកតូចៗ និងការហាមឃាត់ផ្សេងៗ ចំពោះលទ្ធភាពដែលអាចទាញយកផលពីធនធានព្រៃឈើ និងនេសាទ ។ ការប្រែប្រួលលំនាំនៃការប្រើប្រាស់ដីធ្លី បានកើតឡើងស្របគ្នានឹងការផ្លាស់ប្តូរការយល់ឃើញរបស់ប្រជាជនចំពោះសិទ្ធិកាន់កាប់ដីធ្លី ។ បច្ចុប្បន្ន សំរាប់កម្មសិទ្ធិ និងការត្រួតត្រាដី មានវិធីអនុវត្តពីរបែបដែលគេបានប្រើប្រាស់កាន់តែញឹកញាប់នៅពេលដែលមានប្រជាជន និងស្ថាប័នមកពីខាងក្រៅសហគមន៍នៅមូលដ្ឋាន មកទិញដីយកទៅបំរើគោលដៅផ្សេងទៀតក្រៅពីការធ្វើកសិកម្មជីវព្រឹត្តិ (subsistence farming) ។ ក្នុងវិធីទី១ គឺប្រជាជននៅក្នុងសហគមន៍កសិករទទួលស្គាល់សិទ្ធិប្រើប្រាស់ដីតាមបែបបទជាប្រពៃណី និងទំនៀមទំលាប់របស់ខ្លួន ។ ក្នុងវិធីទី២ ប្រជាជនមកពីខាងក្រៅសហគមន៍ទទួលស្គាល់សិទ្ធិជាម្ចាស់ទៅតាមច្បាប់ និងបែបបទជាផ្លូវការរបស់រដ្ឋ ។ វិធីអនុវត្តមានពីរបែបដូច្នេះ មិនអាចដំណើរការបានរលូនល្អទេ ហើយជាក់ស្តែងមានការចំរូងចំរះគ្នាជាញឹកញាយ ពីព្រោះអ្នកមានអំណាចអាចឆ្លៀតយកប្រៀបលើអ្នកទន់ខ្សោយជាងខ្លួន ។ ដោយមូលហេតុនេះ ប្រជាជនតែងតែស្វែងរកមធ្យោបាយ និងប្រើវិធីផ្សេងៗដើម្បីលើកកំពស់ផលប្រយោជន៍ផ្ទាល់ខ្លួន ។

ការលក់ដូរដីធ្លីប្រព្រឹត្តទៅយ៉ាងសកម្មក្នុងតំបន់នានានៅតាមដងផ្លូវ, នៅជិតទីប្រជុំជន និង/ឬទីផ្សារ ។ នៅតំបន់ទាំងនេះ តំរូវការឯកសារផ្លូវការបញ្ជាក់សិទ្ធិកាន់កាប់ដី ដូចជា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីជាដើម គឺមានកំរិតខ្ពស់ ដើម្បីសំរួលដល់ការផ្ទេរសិទ្ធិ ការបញ្ជាក់ព្រំដី និងបង្ការទំនាស់ ។ ប៉ុន្តែដោយសារការធ្វើប័ណ្ណសំគាល់សិទ្ធិដីធ្លីមានតំលៃខ្ពស់ (ភាគច្រើនជាកំរៃត្រូវបង់ក្រៅផ្លូវការ) ការលក់ដូរដីធ្លី ច្រើនតែត្រូវបានដោះស្រាយសំរួលនៅរដ្ឋបាលកំរិតទាប តាមរយៈការប្តូរឈ្មោះលើចុងសន្លឹកសុំកាន់កាប់ដីធ្លី ឬក៏ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ រវាងអ្នកទិញ និងអ្នកលក់ដែលមិនសូវត្រឹមត្រូវស្របតាមច្បាប់ទេ ។ មានតែប្រជាជនមានធនធានគ្រប់គ្រាន់ និង/ឬមានអំណាចប៉ុណ្ណោះ ដែលមានលទ្ធភាព និងសុខចិត្តធ្វើប័ណ្ណសំគាល់សិទ្ធិ ។ នៅតាមតំបន់កសិកម្មជីវព្រឹត្តនៅឆ្ងាយពីផ្លូវ ទីប្រជុំជន ឬទីផ្សារ ប្រជាជនប្រើចុងសន្លឹកសុំកាន់កាប់ដីធ្លី ឬពឹងផ្អែកលើបណ្តាស្ថាប័នសង្គមក្រៅផ្លូវការនានា ដើម្បីបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន ។ ប៉ុន្តែនៅទីនោះតំរូវការឯកសារជាលាយលក្ខណ៍អក្សរក៏កំពុងកើនឡើងដែរ ពីព្រោះប្រជាជនចង់ធានាសុវត្ថិភាពដល់ការផ្ទេរមរតក និងសិទ្ធិកាន់កាប់ដីធ្លី ទៅអោយកូនចៅរបស់ខ្លួន ។

ឋានានុក្រមដ៏ស្មុគស្មាញមួយនៃមន្ត្រីរដ្ឋាភិបាល និងអ្នកតំណាងជ្រើសតាំងឡើងតាមការបោះឆ្នោត គឺជាអ្នកមានសមត្ថកិច្ចគ្រប់គ្រងដីធ្លី ។ ពាក្យសុំធ្វើប័ណ្ណសំគាល់សិទ្ធិមួយ ត្រូវឆ្លងកាត់យ៉ាងតិច ៨-១០ការិយាល័យ ចាប់ពីថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត ដល់ក្រសួងថ្នាក់ជាតិ ។ ការអង្កេត និងវាស់វែងស៊ីពេលអស់ច្រើនណាស់ ហើយដំណើរការរឹតតែអូសបន្លាយ ដោយសារកង្វះធនធានមនុស្ស និងសំភារៈ ។ ប្រជាជននៅជនបទ ទាំងកសិករ និងមិនមែនកសិករ មិនសូវចុះស្មានឹងប្រព័ន្ធរដ្ឋបាលទេ ។ ពួកគេតែងចៀសវាងប្រព័ន្ធផ្លូវការ ដោយបែរទៅប្រើបែបបទតាមប្រពៃណី និងទំនៀមទំលាប់វិញ និងដោយទាក់ទងតែជាមួយស្ថាប័ននៅ

មូលដ្ឋានប៉ុណ្ណោះ ។ ប៉ុន្តែ ក៏មានមនុស្សមួយចំនួនដែលគេចវេសពីប្រព័ន្ធផ្លូវការ ដោយសារមិនចង់បង់ពន្ធត្រឹមត្រូវជូនរដ្ឋ ។ មួយចំណែកទៀតប្រព័ន្ធគ្រប់គ្រងដីធ្លីមិនគ្រាន់តែមានពីររបៀបប៉ុណ្ណោះទេ ប៉ុន្តែតួអង្គក្នុងជួររដ្ឋាភិបាលខ្លួនឯង ជាពិសេសនៅថ្នាក់ក្រោម (ដូចជា ប្រធានភូមិ និងឃុំ) គឺជាអ្នករួមចំណែកធ្វើអោយការអនុវត្តន៍បែបនេះមានដំណើរការជានិរន្តរ៍ ។ អ្នកជាប់ពាក់ព័ន្ធផ្សេងគ្នា មានការយល់ដឹងខុសគ្នាពីប័ណ្ណកម្មសិទ្ធិដីធ្លី ហើយអ្នកការពារច្បាប់ ដូចជាតុលាការ និងគណៈកម្មការដោះស្រាយបាតុភាពដីធ្លីជាដើម ក៏ពុំមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ និងបទបញ្ញត្តិផ្សេងៗដូចគ្នាដែរ ។ ការទទួលស្គាល់ជាលក្ខណៈជាក់ស្តែងចំពោះបែបបទនៃការអនុវត្តន៍ខុសៗគ្នាក្នុងការគ្រប់គ្រងដីធ្លី បានធ្វើឱ្យច្បាប់ពិតប្រាកដអនុវត្តមិនបានពេញលេញទេ ។ បទប្បញ្ញត្តិជាច្រើនដែលមានន័យមិនច្បាស់លាស់ និងអនុវត្តបានច្រើនបែបយ៉ាង (ក្នុងការលក់ដូរដី) បានរួមចំណែកធ្វើឱ្យអំពើពុករលួយកើនឡើង ហើយប្រាក់បៀវត្សរ៍មិនប្រាកដនិយមរបស់មន្ត្រីរាជការ បានញ៉ាំងឱ្យបញ្ហានេះរិតតែធ្ងន់ធ្ងរថែមទៀត ។ ក្នុងតំបន់ជាច្រើន ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវមួយអាចអស់សោហ៊ុយដល់ទៅ ៣០០-៤០០ដុល្លារ ដែលសឹងតែទាំងអស់ គឺជាការបង់ប្រាក់ក្រៅផ្លូវការទៅឱ្យមន្ត្រី និងអ្នកតំណាងនៅតាមមន្ទីរក្រសួងផ្សេងៗ ។ ដូចយើងអាចស្មានបាន ប្រជាជនក្រីក្រកំរ ឬមិនដែលបានប័ណ្ណត្រឹមត្រូវទេ ពីព្រោះពួកគេពុំមានការគាំទ្រខាងផ្លូវច្បាប់ ហើយក៏ពុំមានធនធាន ដើម្បីដោះស្រាយរំលងច្បាប់ដែរ ។ ក្នុងនេះស្ត្រីងាយរងគ្រោះខ្លាំងណាស់ ពីព្រោះមិនសូវមានធនធានសំរាប់យកមកប្រើប្រាស់ការពារសិទ្ធិរបស់ខ្លួន ។

ចំនួន និងប្រភេទនៃទំនាស់ដីធ្លី កំពុងបន្តកើនឡើង ពីព្រោះអ្នកមានផលប្រយោជន៍ផ្សេងៗគ្នាកំពុងប្រជែងដណ្តើមដី ។ បច្ចុប្បន្ននេះ ទំនាស់ដីធ្លីកើតមានកាន់តែច្រើនឡើងរវាងអ្នកភូមិ និងអ្នកមកពីក្រៅសហគមន៍ (ក្រុមហ៊ុនឯកជន ស្ថាប័នរដ្ឋ...) ហើយវាទាមទារស្ថាប័នផ្លូវការសំរាប់សំរុះសំរួល ឬកាត់ក្តីកាន់តែច្រើនឡើងដែរ ។ ការប្រឹងប្រែងសាជាថ្មីក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ នឹងបង្កើនតំរូវការដោះស្រាយវិវាទថែមទៀត ទាំងតាមរយៈប្រព័ន្ធផ្លូវការ និងតាមយន្តការគ្រប់គ្រងជាប្រពៃណីរបស់សហគមន៍ ។ តាមមើលទៅកំណើនតំរូវការនេះ វាធំលើសលុបពេកចំពោះយន្តការរដ្ឋដែលសព្វថ្ងៃកំពុងរត់មិនទាន់កំណើនសំណុំរឿងពាក្យបណ្តឹងស្រាប់ទៅហើយៗឧបសគ្គចំបងក្នុងការរត់មិនទាន់នេះគឺ កង្វះខាតថវិកា និងធនធានមនុស្ស (ដែលទាមទារឱ្យមានការបណ្តុះបណ្តាលទាំងខាងច្បាប់ និងនីតិវិធី) ។ មួយចំណែកទៀត គ្មានអ្វីចំលែកសោះដែលមហាជន ជាពិសេសប្រជាជនក្នុងសហគមន៍កសិករនៅជនបទ គេច្រើនយល់ឃើញថា ទាំងតុលាការខេត្ត និងគណៈកម្មការដោះស្រាយបាតុភាពដីធ្លីពុំមានលក្ខណៈយុត្តិធម៌ល្អទេ ពីព្រោះវាលំអៀងទៅខាងជនដែលមានធនធាន និងអំនាច ព្រមទាំងរាំងស្ទះដល់ការចូលរួមពេញលេញនិងស្មើភាពពីសំណាក់ប្រជាជនទន់ខ្សោយ (ដូចជា អ្នកក្រ ស្ត្រី ប្រជាជនដើម) ទៀតផង ។ ជំនឿរបស់ប្រជាជន ចំពោះប្រព័ន្ធផ្លូវការបានចោទបញ្ហាមួយចំណែកគឺដោយសារពួកគេមានពត៌មាន និងការយល់ដឹងមិនគ្រប់គ្រាន់ពីច្បាប់ និងនីតិវិធីដែលគ្រប់គ្រងដីធ្លី ។ វិបត្តិនៃទំនុកចិត្ត ចំពោះដំណើរការដោះស្រាយវិវាទ ដូចដែលកំពុងកើតមានសព្វថ្ងៃ គឺជាបញ្ហាដ៏ធំមួយចំពោះអភិបាលកិច្ច ។

អនុសាសន៍ធំៗមួយចំនួនមានដូចខាងក្រោមៈ

*ការផ្តល់ប័ណ្ណកម្មសិទ្ធិដោយអនុលោមតាមច្បាប់ និងលំដាប់នៃសកម្មភាពៈ* ភាពមិនប្រក្រតីផ្សេងៗក្នុងការត្រួតត្រាដីធ្លីត្រូវដោះស្រាយឱ្យអស់តាមច្បាប់ថ្មី មុននឹងចាប់ផ្តើមផ្តល់ប័ណ្ណប្លង់ដី ។ ត្រូវដាក់អនុវត្តបទប្បញ្ញត្តិច្បាប់ផ្សេងៗ ដូចគ្នាចំពោះបុគ្គល ក្រុមហ៊ុន អង្គភាពផ្សេងទៀត ព្រមទាំងស្ថាប័នរដ្ឋាភិបាលផងដែរ ។ ចំពោះកម្មវិធីថ្មីនៃការផ្តល់ប័ណ្ណប្លង់ដី គួរកំណត់ផងដែរនូវលំដាប់នៃកិច្ចដំណើរការ ។ លំដាប់មួយដែលអាចអនុវត្តបានគឺ ដំបូងផ្តល់ប័ណ្ណប្លង់ដីចំពោះដីលំនៅដ្ឋាន បន្ទាប់មកដីស្រែដីចំការ (សំរាប់ដំណាំមិនមែនស្រូវ ដំណាំសំរាប់លក់) និងចុងក្រោយគឺដីសាធារណៈ ដូចជា ឆ្នេរសមុទ្រ បឹង ព្រៃឈើ ផ្លូវលំ និងផ្លូវជាតិ ។ ភាពត្រឹមត្រូវនៃលំដាប់នេះ គឺវាស្របតាមគោលការណ៍ដែលថា ទីជំរក និងជីវភាពរបស់ប្រជាជនក្រីក្រ គួរមានអាទិភាពទី១ ។

*ពង្រឹងការគ្រប់គ្រងដីធ្លីតាមបែបវិមជ្ឈការ:* ច្បាប់គួរមានអត្ថន័យច្បាស់លាស់មិនអាចបកស្រាយបានច្រើនបែប និងគួរដាក់អនុវត្តតាមបែបវិមជ្ឈការ ដើម្បីធានាថា គ្រប់និតិវិធីវាមានតម្លាភាព ធ្វើបានឆាប់ និងមានតំលៃថោកដែលប្រជាជនទាំងអស់មានលទ្ធភាពបង់ ។ ប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិ និងចុះបញ្ជីដីធ្លីបច្ចុប្បន្ន គួរតែធ្វើវិមជ្ឈការ ។ បើអាចធ្វើកើត ថ្នាក់ស្រុកគួរតែជាដំណាក់កាលចុងបញ្ចប់នៃការចុះបញ្ជីដីធ្លី ដោយហេតុថាស្រុកនៅជិតថ្នាក់មូលដ្ឋានជាង ។ ការពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងការបង្កើតគណៈកម្មការកំរិតភូមិ/ឃុំ (អាចមាន NGO ចូលរួមផង) គឺជាសមាសធាតុដ៏ចាំបាច់មួយនៃការអនុវត្តន៏វិមជ្ឈការនេះ ។ ដើម្បីអោយដំណើរការចុះបញ្ជីដីធ្លីអាចចាប់ផ្តើមបាន ការលក់ដូរ ឬការផ្ទេរដីធ្លីពីមុនទាំងអស់ គួរតែបញ្ជាក់អោយបានត្រឹមត្រូវ និងផ្តល់ការទទួលស្គាល់ ដរាបណាប្រតិបត្តិការទាំងនោះមិនបានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៏របស់អ្នកទន់ខ្សោយក្នុងសង្គមទេ ។

*ការដោះស្រាយទំនាស់:* ករណីវិវាទដីធ្លីទាំងអស់គួរតែដោះស្រាយឱ្យបានស្របទៅតាមស្មារតី និងខ្លឹមសារនៃច្បាប់នានាដែលពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី ។ ដំណើរការដោះស្រាយវិវាទដីធ្លីគួរតែធ្វើវិមជ្ឈការ ដើម្បីឱ្យវាស្របគ្នានឹងដំណើរការផ្តល់ប័ណ្ណប្លង់ដី ។ គួរប្រឹងប្រែងជាអតិបរមាក្នុងការដោះស្រាយករណីវិវាទ ដោយប្រើយន្តការរបស់មូលដ្ឋាន/សហគមន៏ ក្នុងនេះមានទាំងករណីជាប់ពាក់ព័ន្ធនឹងអាជ្ញាធរ និងក្រុមហ៊ុននានាផង ។ សិទ្ធិអំនាចរបស់អ្នកដឹកនាំភូមិ/ឃុំ គួរត្រូវបានគោរព និងជ្រោងខ្ពស់ជាអតិបរមា ។ រាល់ករណីដែលមិនអាចដោះស្រាយបាននៅមូលដ្ឋាន ត្រូវតែមានច្រកច្បាស់លាស់សំរាប់ប្តឹងតវ៉ាតទៅទៀត ។ សមាជិកនៃគណៈកម្មការដោះស្រាយបាតុភាពដីធ្លី គួរតែកុំឱ្យមានជំហរប្រកាន់បក្ស និងគួរជាជនស៊ីវិលសុទ្ធសាធ ។ គួរផ្តល់ថវិកា និងធនធានមនុស្សច្រើនថែមទៀត ក្នុងនេះមានទាំងការបណ្តុះបណ្តាលអោយដល់ថ្នាក់មូលដ្ឋានផង ។

*កំនត់គោលនយោបាយថ្មីស្តីពីការតាំងលំនៅ និងលំនៅដ្ឋាន:* ការប្រឹងប្រែងជួយដល់ការតាំងទីលំនៅរបស់ជនភៀសសឹក អ្នកគ្មានដី និងជនចំណាកស្រុកមកទីក្រុង អាចជួយពង្រឹងសន្តិភាព និងស្ថិរភាព និងជួយកាត់បន្ថយភាពក្រីក្រ ។ នៅជនបទដីធ្លីមានគ្រប់គ្រាន់សំរាប់ដោះស្រាយតំរូវការរបស់អ្នកអត់ដី ។ នៅភ្នំពេញ មានតំរូវការផ្តល់កន្លែងថ្មីជាបន្ទាន់សំរាប់ការរុះរើតាំងទីលំនៅឡើងវិញ ឬការធ្វើអោយស្របច្បាប់នូវការតាំងទីលំនៅបច្ចុប្បន្នរបស់ប្រជាជន ។ គោលនយោបាយថ្មីមួយស្តីពីការរុះរើតាំងទីលំនៅឡើងវិញ និងលំនៅដ្ឋាន គួរតែត្រូវបានកសាងឡើង និងដាក់ឱ្យអនុវត្ត ដោយរក្សាតុល្យភាពល្អរវាងតំរូវការរបស់ប្រជាជន និងគោលដៅអភិវឌ្ឍន៏រយៈពេលវែងនៃទីក្រុងឱ្យបាន ។

*ការទទួលស្គាល់សិទ្ធិរបស់ប្រជាជនដើម:* ដំណោះស្រាយសមស្របមួយ គួរត្រូវបានបង្កើតឡើង សំរាប់ការពារសិទ្ធិជាប្រពៃណីរបស់ប្រជាជនដើមក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីសមូហភាព ដោយបំពេញគោលដៅអភិវឌ្ឍន៏ទូលំទូលាយរបស់រដ្ឋដែលសំដៅលើកកំពស់កំរិតជីវភាពក្នុងតំបន់ទាំងនេះឱ្យបានផងដែរ ។ និតិវិធីផ្តល់ប័ណ្ណប្លង់ដីសមូហភាព នឹងទាមទារអោយមានកិច្ចសហការពីសំណាក់រដ្ឋ វិស័យឯកជន ព្រមទាំង NGOs ដែលមានបទពិសោធន៏សមស្របនៅក្នុងតំបន់ទាំងនេះផង ។

*ទទួលស្គាល់សិទ្ធិនារី:* គួរមានការខិតខំជាពិសេសសំដៅពង្រឹងលទ្ធភាពរបស់ស្ត្រី ក្នុងការមានកម្មសិទ្ធិដីធ្លី និងមានច្រកដោះស្រាយទំនាស់ ។ ត្រូវកសាងច្បាប់សំរាប់ធានាឱ្យនារីមានសិទ្ធិទទួលបានការបែងចែកដីធ្លីដោយយុត្តិធម៌ និងស្មើភាព ជាបន្ទាន់ក្នុងករណីមានការលែងលះ ឬការផ្ទេរមរតក ។ ស្ត្រីត្រូវមានការធានាមួយចំនួនខាងផ្លូវច្បាប់ ដើម្បីឱ្យពួកគេអាចទទួលបាននូវការដោះស្រាយទំនាស់ប្រកបដោយយុត្តិធម៌ និងមិនលំអៀង ។ ត្រូវមានកិច្ចសហការយ៉ាងសកម្មរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីផ្តល់ពតិមានឱ្យស្ត្រីស្តីពីសិទ្ធិរបស់នារីដែលមានចែងក្នុងច្បាប់ភូមិបាលថ្មី និងជួយទ្រទ្រង់ដល់ការអនុវត្តសិទ្ធិរបស់ពួកគេ ។

*ដើរតាមបទពិសោធន៏អនុវត្តន៏ល្អៗ:* បទពិសោធន៏បានជោគជ័យល្អមួយចំនួននៅក្នុង និងក្រៅប្រទេសអាចផ្តល់ជាមេរៀនសំរាប់កម្មវិធីថ្មីផ្តល់ប័ណ្ណប្លង់ដី ។ កម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធរបស់រដ្ឋាភិបាល ដែលឧបត្ថម្ភដោយ GTZ និងរដ្ឋាភិបាល

ហ្វាំងឡង់ បានប្រើប្រាស់ផែនទីគូរតាមរូបថតពីលើអាកាស ដើម្បីផលិតរូបភាពព្រំដីអោយបានច្បាស់ ។ វិធីសាស្ត្រនេះ មិនគ្រាន់តែមានប្រសិទ្ធិភាពខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានតំលៃថោកទៀតផង ។ គំរោងកម្មវិធីនេះបានប្រើវិធីសាស្ត្រនានា ដូចជាការប្រជុំក្នុងភូមិ និងការពិគ្រោះយោបល់ផ្សេងៗ ដើម្បីដោះស្រាយទំនាស់ព្រំដី ។ គំរោងក៏មានប្រយោជន៏សំរាប់ការវាយតំលៃថា តើវិធីសាស្ត្របែបនេះអាចយកទៅអនុវត្តទូលំទូលាយនៅច្រើនកន្លែងទៀតបានឬទេ ។

*ផ្តល់ថវិកាសំរាប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ:* ថវិកាដំណើរការការងារ សំរាប់គ្រប់ស្ថាប័នរដ្ឋបាលដែលពាក់ព័ន្ធនឹងការធ្វើប័ណ្ណប្លង់ដី គួរតែពង្រឹងតាមរយៈការផ្ទេរថវិកាអន្តរៈក្រសួង និងថវិកាបន្ថែមបានមកពីការបង់ថ្លៃសេវារបស់អតិថិជន ។ ថ្លៃសេវាគួរតែដូចគ្នាទាំងអស់ និងមានការផ្សព្វផ្សាយជាសាធារណៈ ។ ពន្ធលើការលក់ដី និងការផ្ទេរកម្មសិទ្ធិ ត្រូវទូទាត់ឱ្យស្រេចមុននឹងចេញសេចក្តីសំរេចឱ្យផ្ទេរកម្មសិទ្ធិ ។ ក្រុមហ៊ុន និងបុគ្គលនានា ដែលមានដីច្រើនជាង ៥ហិកតា គួរតែជាប់ពន្ធតាមអត្រាមួយ (គិតជាភាគរយនៃថ្លៃលក់ដី) ខ្ពស់ជាងអត្រាពន្ធសំរាប់ដីចាប់ពី ៥ហិកតាចុះ ។

*បង្កើតទិន្នន័យ និងការផ្សព្វផ្សាយពត៌មានស្តីពីសិទ្ធិកាន់កាប់ដីធ្លី:* ការបង្កើតការិយាល័យស្ថិតិសំរាប់បំរើក្រសួង និងនាយកដ្ឋានពាក់ព័ន្ធទាំងអស់ គឺជាវិធានការមួយដ៏មានប្រយោជន៏ដើម្បីពង្រឹងមូលដ្ឋានទិន្នន័យខាងសេដ្ឋកិច្ច ។ ការិយាល័យនេះក៏អាចស្រង់ និងច្របាច់បញ្ចូលគ្នានូវទិន្នន័យផលិតដោយក្រសួងផ្សេងៗថែមទៅលើការងារប្រមូលទិន្នន័យដោយខ្លួនឯង ។ ចំនែកឯប្រជាជន ក៏គួរតែដឹង និងយល់ពីច្បាប់ អនុក្រឹត្យ បទប្បញ្ញត្តិ និងនិតិវិធីផ្សេងៗដែលត្រូវបានអនុម័តចេញជាបន្តបន្ទាប់ ។ ការប្រើប្រាស់ទូរទស្សន៏ និងវិទ្យុ អាចមានប្រយោជន៏ខ្លាំងក្នុងការផ្សព្វផ្សាយ ពីព្រោះសំភារៈទាំងនេះ គេឃើញមានប្រជាជនប្រើប្រាស់វាច្រើនណាស់ ទាំងនៅក្នុងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជាក៏មានដែរ ។

# ជំពូក ១

# សេចក្តីផ្តើម

## ១.១ គោលបំណង

រដ្ឋាភិបាលកម្ពុជា បានអនុវត្តរបៀបវារៈកំនែទំរង់មួយសំដៅសំរេចអោយបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច មានចីរភាព ការកាត់បន្ថយភាពក្រីក្រ និងសន្តិភាព ។ ក្របខ័ណ្ឌនៃនយោបាយដីធ្លី គឺជាគំនិតផ្តួចផ្តើមខាងគោលនយោបាយ ដ៏សំខាន់បំផុតមួយនៅក្នុងរបៀបវារៈនេះ ហើយវាមានជាអាទិ៍ ការផ្តល់កម្មសិទ្ធិដីធ្លី ការបង្កើតក្របខ័ណ្ឌច្បាប់ដើម្បីដាក់អនុវត្ត សិទ្ធិដីធ្លី ការបង្កើតផែនការមេខាងដីធ្លី និងការបង្កើតវិធានបែងចែកដីជាតំបន់ ។ ច្បាប់ភូមិបាលថ្មីមួយដែលតាក់តែងឡើង សំរាប់ជំនួសច្បាប់ភូមិបាលឆ្នាំ១៩៩២ កំពុងដាក់ជូនសភាអនុម័ត[១] ។ គំរោងគ្រប់ជ្រុងជ្រោយមួយសំរាប់ការផ្តល់ប័ណ្ណប្លង់ដី និង ចុះបញ្ជីដីធ្លី ត្រូវបានដាក់ដំណើរការជាចំណែកមួយនៃគោលនយោបាយដីធ្លីនេះ ។ ឯកសារនេះនឹងធ្វើការវាយតំលៃខាងសង្គម កិច្ចអំពីស្ថានភាពដីធ្លី ដើម្បីផ្តល់ពត៌មានចំពោះគំរោង ។

## ១.២ សាវតារ និងតំរូវការនៃការសិក្សា

នៅកម្ពុជា កសិកម្មគឺជាវិស័យមួយដែលមានការអភិវឌ្ឍន៏តិចតួចបំផុតនៅអាស៊ី ហើយដីធ្លី និងពលកម្មនៅកម្ពុជា ទំនង ជាមានផលិតភាពទាបបំផុតនៅអាស៊ីអគ្នេយ៏ ។ ទិន្នផលស្រូវដែលបានត្រឹម ១,៣-១,៥តោន/ហិកតា គ្មានការប្រែប្រួលទេ ក្នុងរយៈពេលច្រើនទសវត្សរ៏កន្លងមក[២] ដូច្នេះហើយក្នុងតំបន់ជនបទដែលមានប្រជាជនកម្ពុជាជាងបីភាគបួនរស់នៅ ជីវភាពដ៏ សមរម្យមួយកាន់តែពិបាកធានាបានហើយ ។ អត្រាកំណើនប្រជាជនជាលក្ខណៈធម្មជាតិមានកំរិតជាង ២,៥%ក្នុងមួយឆ្នាំ ហើយ កន្លងមកសឹងតែគ្មានការធ្វើពហុកម្មលើមុខរបរក្រៅពីកសិកម្មសោះ សូម្បីតែក្នុងប៉ុន្មានឆ្នាំថ្មីៗដែលសេដ្ឋកិច្ចមានសន្ទុះគួរសម ក៏ដោយ[៣] ។ សំរាប់វិស័យកសិកម្ម គឺមានតំរូវការកាន់តែធំហើយក្នុងការបង្កើនទិន្នផល និងការពង្រីកចំនួនមុខសកម្មភាព[៤] ។

១ សេចក្តីបញ្ជាក់សង្ខេបពីព្រឹត្តិការណ៏ថ្មីៗ និងខ្លឹមសារនៃគោលនយោបាយដីធ្លី មានចុះក្នុងរបាយការណ៏របស់ Sida (2000) ។ ក្នុងឯកសារនេះពាក្យ "ដីធ្លី" សំដៅដល់ដីគ្រប់ប្រភេទទាំងអស់ រួមទាំង ដីកសិកម្ម និងដីលំនៅដ្ឋាន ។

២ ទោះបីមាននិន្នាការវិជ្ជមានខ្លះៗក្នុងទសវត្សរ៏១៩៩០ ក៏ដោយ ក៏ការប្រៀបធៀបក្នុងរយៈពេលវែងបានបង្ហាញថា ផលិតភាពកំរិតប្រហាក់ប្រហែល នេះ កើតមានតាំងពីក្នុងទសវត្សរ៏១៩៦០ មកម្លេះ ។

៣ មានកម្មករប្រមាណ ១៣០.០០០នាក់ ធ្វើការនៅក្នុងឧស្សហកម្មកាត់ដេរ ដែលបានចាប់ផ្តើមរីកចំរើននៅពាក់កណ្តាលទសវត្សរ៏១៩៩០ ។ តាមការ សិក្សារបស់ វិបសអ ផលប៉ះពាល់នៃឧស្សាហកម្មនេះទៅលើរចនាសម្ព័ន្ធកំលាំងពលកម្មមានតិចតួចទេ ។

៤ រឿងនេះអាចឃើញយ៉ាងច្បាស់តាមប្រការដែលថា ទោះបីសេដ្ឋកិច្ចមានកំណើនលឿនជាច្រើនឆ្នាំក្នុងទសវត្សរ៏១៩៩០ ក៏ដោយ ក៏ផលប៉ះពាល់របស់ វាមកលើភាពក្រីក្រ មានតិចតួចទេ ។ ចំពោះពត៌មានលំអិត សូមអានឯកសាររបស់ Acharya (2001); and Godfrey *et al* (2001) ។

កាលពីមុន កម្ពុជាធ្លាប់ជាប្រទេសមួយដែលផលិតស្រូវគ្រប់គ្រាន់សំរាប់ហូប និងសំរាប់នាំចេញទៅបរទេសទៀតផង ប៉ុន្តែឥឡូវនេះបែរជាត្រូវនាំចូលស្បៀងទៅវិញ ។ ប្រជាជនជាច្រើន (ប្រមាណ ៣៥០ឃុំ ក្នុងចំណោមឃុំទាំងអស់ ១.៦០០ឃុំ) ត្រូវពឹងផ្អែកលើកម្មវិធីជំនួយម្ហូបអាហារពហុភាគី ។ បញ្ហានានាដែលបានរៀបរាប់ខាងលើបង្ហាញពីតំរូវការកម្មវិធីដីធ្លីមួយ ដើម្បីពង្រឹងសន្តិសុខស្បៀងជាបន្ថែមទៅលើការបង្កើតក្របខ័ណ្ឌច្បាប់ និងរដ្ឋបាល ដើម្បីសំរេចបាននូវសុខសន្តិភាព និងយុត្តិធម៌ ។

ការពិនិត្យត្រួសៗអំពីស្ថានភាពដីធ្លីក្នុងពេលបច្ចុប្បន្ន គឺជាចំណុចចាប់ផ្តើមមួយដ៏មានសារៈប្រយោជន៍ ។ កម្ពុជាមានផ្ទៃដីសរុបប្រមាណ ១៨លានហិកតា ក្នុងនេះ ៨លានហិកតាជាដីសម្បទាន, ៣,៣លានហិកតាជាដីព្រៃបំរុង, ២,៧លានហិកតាជាដីដាំដុះ (ភាគច្រើនដីស្រែ)[៥] ។ ចំណែកដីនៅសល់ គឺមានដីព្រៃរបោះ ផ្លូវទឹក ដីឡើងទួលចុះទួល ដីទុកចោលមិនប្រើប្រាស់តំបន់ទីក្រុង និងដីមានគ្រាប់មីន ។ ការកំណត់ព្រំដីតាមរយៈកម្មសិទ្ធិភាព និងការប្រើប្រាស់ដី ទាំងនៅកំរិតប្រទេស ក៏ដូចជានៅកំរិតឯកត្តជនម្នាក់ៗ ជាទូទៅ គឺមានលក្ខណៈជាផលុបភោគ (usufructory) ច្រើនជាងលក្ខណៈជាផ្លូវការ (formal) ជាពិសេសនៅតាមតំបន់ជនបទ ។ គេមិនឃើញមានការបញ្ជាក់អំពីកម្មសិទ្ធិឯកជនក្នុងទ្រង់ទ្រាយធំដែលមានការធានាអំពីរដ្ឋ និងច្បាប់ ហើយក៏គ្មានផែនទីសុរិយោដី ឬពត៌មានលំអិតពីព្រំដីទេ (លើកលែងតែចំពោះផ្ទៃដីតូចៗ) ។ ប្រព័ន្ធនៃសិទ្ធិប្រើប្រាស់ដី មានដំណើរការល្អនៅពេលប្រជាជនកម្ពុជាមានត្រឹម ៤-៥លាននាក់ និងរស់នៅឆ្ងាយៗពីគ្នា ។ ប្រទេសភាគច្រើនដែលមានប្រព័ន្ធដីធ្លីស្រដៀងគ្នានឹងកម្ពុជា គេបានកសាងប្រព័ន្ធកម្មសិទ្ធិជាផ្លូវការនៅក្នុង ៥០ឆ្នាំចុងក្រោយនៃសតវត្សរ៍ទី២០ ។ ប្រការនេះត្រូវបានគេអនុវត្តតាមរយៈការធ្វើទំនើបភាវូបនីយកម្ម និងការសំរបខ្លួនជាបណ្តើរៗទៅតាមសេដ្ឋកិច្ចទីផ្សារ ។ ប៉ុន្តែកម្ពុជាមិនបានឆ្លងកាត់ដំណាក់កាលនេះទេ ពីព្រោះត្រូវមានសង្គ្រាមអស់ជិតបីទសវត្សរ៍ ។ នៅដើមទសវត្សរ៍១៩៩០ កម្ពុជាត្រូវជួបប្រទះភ្លាមៗ នឹងសេដ្ឋកិច្ចទីផ្សារ និងបរិស្ថានសេដ្ឋកិច្ចសាកលដោយមិនបានត្រៀមខ្លួនឱ្យបានសមស្របទេ[៦] ។ ជាលទ្ធផល យន្តការសំរាប់គ្រប់គ្រង និងត្រួតពិនិត្យផ្សេងៗដែលត្រូវមានជាមុនដើម្បីអោយសេដ្ឋកិច្ចទីផ្សារ ដំនើរការបានសក្តិសិទ្ធិ គឺឃើញមានតិចតួចណាស់ ។ អវត្តមាននៃយន្តការទាំងនេះ គឺជាឧបសគ្គចំបងមួយចំពោះវិស័យឯកជន និងប្រជាជនជាទូទៅ ហើយវាអាចក្លាយជាប្រភពមួយនៃការវឹកវរក្នុងសង្គមដែលប្រជាជនភាគច្រើន មិនចង់ជួបប្រទះម្តងទៀតទេ ។ ដូច្នេះតំរូវការដាក់ឱ្យដីធ្លីស្ថិតនៅក្រោមការគ្រប់គ្រងនៃក្របខ័ណ្ឌរដ្ឋបាល និងច្បាប់ដ៏គ្រប់ជ្រុងជ្រោយមួយ គឺមានអាទិភាពខ្ពស់ខ្លាំងណាស់ ។

ក្នុងពេលបច្ចុប្បន្ន គេឃើញមានប្រព័ន្ធគ្រប់គ្រងដីធ្លីជាច្រើនប្រភេទដែលកំពុងមានដំណើរការទន្ទឹមគ្នា និងមានប្រជាជនជាច្រើនកំពុងស្វែងរកដីធ្លីនៅឡើយ បន្ទាប់ពីបានផ្លាស់ប្តូរកន្លែងរស់នៅកាលពីក្នុងទសវត្សរ៍មុនៗ ។ ម្យ៉ាងវិញទៀត មានគ្រួសារថ្មីៗបានផុសឡើង ជាពិសេសដោយសារមានកំណើនប្រជាជនយ៉ាងលឿននៅក្នុងទសវត្សរ៍១៩៨០ ។ នៅចំពោះមុខសភាពការណ៍នេះ អាជ្ញាធរនានាគប្បីផ្តល់អាទិភាពខ្ពស់បំផុតដល់ដំណើរការវាស់វែង ផ្តល់កម្មសិទ្ធិ និងចុះបញ្ជីដីធ្លី ឱ្យបានពេញលេញ ដោយទទួលយកអ្នកជាប់ពាក់ព័ន្ធនឹងដីធ្លីទាំងអស់ មកធ្វើជាដៃគូ ។ ដោយហេតុថា ការកំណត់មុខសញ្ញាបានត្រឹមត្រូវនៃសកម្មភាពផ្តល់កម្មសិទ្ធិ និងចុះបញ្ជីដីធ្លី, ការធានាបាននូវភាពយុត្តិធម៌សំរាប់ស្រទាប់នានានៃប្រជាជនងាយរងគ្រោះ, លក្ខណៈសមស្របខាងសង្គមកិច្ច និងវប្បធម៌, លក្ខណៈអាចធ្វើបានយោងតាមសមត្ថភាពស្ថាប័ន, ការគិតគូរបានល្អអំពីបញ្ហាតួនាទីបុរស-ស្ត្រី, គឺសុទ្ធសឹងជាសមាសធាតុដ៏ចាំបាច់បំផុតរបស់គំរោង, ដូច្នេះហើយរដ្ឋាភិបាលបានយល់ឃើញថា ដំបូងគួរធ្វើការវាយតំលៃខាងសង្គមកិច្ចមួយ ដើម្បីប្រមូលទិន្នន័យមួយចំនួនដែលអាចជួយអោយសំរេចបាននូវគោលដៅទាំងនេះ ។ ឯកសារនេះគឺជាអត្ថបទរៀបចំថ្មីនៃរបាយការណ៍មួយដែល វបសអ បានកសាងជូនរដ្ឋាភិបាល ដើម្បីបង្ហាញពីលទ្ធផលនៃការវាយតំលៃនៅក្រោយពេលចុះពិនិត្យដល់

---

៥ មានការខ្វែងមតិគ្នាពីទំហំដីព្រៃសម្បទាន ។ តួលេខចុះក្នុងឯកសារនេះត្រូវបានស្រង់ចេញពីឯកសាររបស់ Williams (1999) ។ ការអធិប្បាយលំអិតថែមទៀតមានចុះក្នុងឯកសាររបស់ Chan *et al* (2001) ។

៦ ក្នុងប្រទេសភាគច្រើន កំលាំងទីផ្សារបានវិវត្តបន្តិចម្តងៗ ដែលអនុញ្ញាតអោយប្រជាជនអាចស្រូបយកទិដ្ឋភាពផ្សេងៗរបស់វាបានល្អ ។ ប៉ុន្តែនៅប្រទេសកម្ពុជាវិញ វាវិវត្តលឿនពេកសឹងតែបង្កជាវិបត្តិមួយទៅហើយ ។

មូលដ្ឋានដែលបានជ្រើសរើស និងក្រោយពេលបានធ្វើសំភាសន៍ជាមួយប្រជាជន អាជ្ញាធរមានសមត្ថកិច្ច និងទីភ្នាក់ងារផ្តល់ជំនួយនានាដែលមានជាប់ពាក់ព័ន្ធ ។

## ១.៣ គោលដៅ

ការវាយតំលៃសង្គមត្រូវបានធ្វើឡើងដោយមានគោលដៅជាក់លាក់ដូចតទៅ:

- ធ្វើចំណាត់ថ្នាក់ លើអ្នកជាប់ពាក់ព័ន្ធនឹងដីធ្លី និងគំរោង, លើកំរិតយល់ដឹង ចំណេះដឹង បទពិសោធន៍ ផលប្រយោជន៍ តំរូវការ បញ្ហាចោទ និងឧបសគ្គនានា ដែលពួកគេជួបប្រទះនៅក្នុងការទទួលបាន ឬការដាក់ពាក្យសុំកម្មសិទ្ធិ/សិទ្ធិកាន់កាប់ និងការចុះបញ្ជីជាបន្តបន្ទាប់នៃការទិញលក់ដីធ្លី ។
- កំណត់ពីកំរិតនៃអង្គការចាត់តាំងក្នុងសង្គម និងកំរិតសមត្ថភាពនៃថ្នាក់ភូមិ និងថ្នាក់ឃុំ ដើម្បីចូលរួមក្នុងការកាត់ក្តី និងក្នុងសកម្មភាពចុះបញ្ជីដីធ្លី ដែលមានលក្ខណៈជាប្រព័ន្ធ ។
- ស្វែងរកយន្តការដោះស្រាយទំនាស់ជាប្រពៃណី និងយន្តការដោះស្រាយទំនាស់នៅក្នុងពេលបច្ចុប្បន្ននៅកំរិតភូមិ ឃុំ ស្រុក និងខេត្ត ព្រមទាំងស្វែងយល់អំពីចំនាប់អារម្មណ៍របស់ប្រជាជនចំពោះប្រសិទ្ធិភាពនៃយន្តការដោះស្រាយទំនាស់ទាំងនេះ ។
- ទទួលស្គាល់ពីសមភាព និងវិសមភាពរវាងស្ត្រី និងបុរស នៅក្នុងបញ្ហាសិទ្ធិមានកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់អចលនទ្រព្យ ។
- ព្យាករណ៍អំពីផលប៉ះពាល់ជាអវិជ្ជមាននៃគំរោង ទៅលើបុគ្គល ឬក្រុមផ្សេងៗ និងអំពីវិធីសាស្ត្រសំរាប់កាត់បន្ថយផលប៉ះពាល់ទាំងនេះ ។
- លើកមតិអំពីការងារដែលត្រូវធ្វើដើម្បីជួយឱ្យភូមិ ឃុំ និងអាជ្ញាធរមូលដ្ឋាន អាចចូលរួមបានច្រើននៅក្នុងពេលកសាង និងអនុវត្តគំរោង ព្រមទាំងបញ្ជាក់ពីបែបបទនៃការចូលរួមរបស់អ្នកទាំងនេះ ។
- ដាស់តឿនពីហានិភ័យខាងសង្គមកិច្ចដែលអាចកើតមាន ហើយដែលអាចប៉ះពាល់ដល់ជោគជ័យនៃគំរោង ។

## ១.៤ វិធីសាស្ត្រ

ដូចមានបញ្ជាក់នៅក្នុងគោលដៅរួចហើយ ការវាយតំលៃខាងសង្គមសំដៅ: ១. កំណត់អត្តសញ្ញាណនៃអ្នកជាប់ពាក់ព័ន្ធសំខាន់ៗនៅក្នុងគំរោង និងក្នុងបញ្ហាដីធ្លី ២. វិនិច្ឆ័យពីសមត្ថភាពរដ្ឋបាលមូលដ្ឋានក្នុងការដោះស្រាយទិដ្ឋភាពផ្សេងៗដែលជាប់ទាក់ទងនឹងកម្មវិធីផ្តល់កម្មសិទ្ធិ និង ៣. ប៉ាន់ប្រមាណអំពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងលើកវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះ ។ បន្ទាប់ពីការអធិប្បាយសង្ខេបអំពីឯកសារពាក់ព័ន្ធនានា នឹងមានការធ្វើវិភាគពីអ្នកពាក់ព័ន្ធដោយផ្អែកលើពតិមាន និងការចុះសិក្សាដល់មូលដ្ឋាននៅក្នុង ៦ខេត្ត ។ អ្នកតំណាងស្ថាប័ននានាដែលពាក់ព័ន្ធនឹងការផ្តល់កម្មសិទ្ធិដីធ្លីត្រូវបានធ្វើសំភាសន៍ ហើយនៅក្នុងករណីខ្លះ ពួកគេត្រូវបានអញ្ជើញមកប្រជុំដើម្បីពិភាក្សាគ្នា ។ ក្នុងនេះមានមន្ត្រីរដ្ឋាភិបាលដែលមកពីក្រសួង MIMUPC, មន្ទីរ DLMUPCC, DLMUPCC, OLMUPCL, ការិយាល័យសុរិយោដីកណ្តាល, តំណាង LDSC, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ខេត្ត, ប្រធានតុលាការខេត្ត, មន្ត្រីមន្ទីរពន្ធដារ, អភិបាល និងអភិបាលរងស្រុក, និងប្រធានឃុំ ។ នៅក្នុងករណីខ្លះក្រុមសិក្សាស្រាវជ្រាវ បានជួបជាមួយអភិបាលខេត្តរងថែមទៀត ។ ដើម្បីស្វែងយល់ពីបញ្ហានានានៅក្នុងទីក្រុង តាមការយល់ឃើញដោយផ្ទាល់របស់អ្នកជាប់ពាក់ព័ន្ធនៅក្នុងគំរោង, សិក្ខាសាលាមួយត្រូវបានរៀបចំឡើងដោយមានអ្នកតំណាងមកពីសង្កាត់ ខ័ណ្ឌ សាលាក្រុង អាជ្ញាធរអភិវឌ្ឍន៍រាជធានី និង NGOs ។

ករណីសិក្សាចំនួនប្រាំ ធ្វើឡើងក្នុង ៥ភូមិនៅខេត្តកណ្តាល ព្រៃវែង កំពត កំពង់ស្ពឺ និងរតនគិរី (ដែលតំណាងឱ្យតំបន់កសិកម្ម និងអេកូឡូស៊ីខុសគ្នា ហើយដែលមានកំរិតភាគរយខុសគ្នានៃប្រជាជនមាតុភូមិនិវត្តន៍ ទាហានរំសាយ និងប្រជាជនដើម) និងករណីសិក្សាមួយទៀតធ្វើនៅទីក្រុង (ខ័ណ្ឌចំការមន ក្រុងភ្នំពេញ) គឺជាចំណុចស្នូលនៃការងារចុះសិក្សាដល់មូលដ្ឋាន ។ អ្នកឆ្លើយសំភាសន៍ មានជាអាទិ៍ ក្រុមកសិករ ក្រុមនារី ប្រជាជនមាតុភូមិនិវត្តន៍ ជនភៀសសឹក ទាហានរំសាយ និងជនចំណាកស្រុក (ពតិមានលំអិតស្តីពីគំរូតាងមានចុះក្នុងតារាង១.១) ។ វិធីសាស្រ្តមួយចំនួនដែលបានយកមកប្រើប្រាស់ក្នុងករណីសិក្សា គឺជាវិធីសិក្សាតាមបែបគុណភាព ដូចជា ការពិភាក្សាក្នុងក្រុមដែលប្រមូលផ្តុំតាមប្រធានបទ, ការពិភាក្សាជាក្រុមតូចៗ, ការពិភាក្សាផ្ទាល់មួយម្តងៗជាមួយកសិករ គ្រួសារ ក្រុមនារី មន្ត្រី អ្នកតំណាងភូមិ... និងការសិក្សាស៊ីជំរៅលើករណីមួយចំនួនដែលគួរយកចិត្តទុកដាក់ជាពិសេស ។

**តារាង១.១. តំបន់គំរូតាង**

| ខេត្តមុខសញ្ញា | លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសភូមិ/តំបន់ | ភូមិ/តំបន់ ឃុំ និងស្រុក ដែលបានជ្រើសរើស |
|---|---|---|
| កណ្តាល | សកម្មភាពពាណិជ្ជកម្មបន្ថែមលើការដាំដុះ - ប្រជាជនតាំងទីលំនៅសាជាថ្មី | ភូមិកំពង់ព្រីង ក្នុងឃុំសិត្បូ ស្រុកស្អាង |
| កំពត | ធ្វើស្រែ ធ្វើចំការ និងសកម្មភាពនេសាទ | ភូមិកំពង់ត្នោត ក្នុងឃុំកូនសត្វ ស្រុកកំពត |
| ព្រៃវែង | ធ្វើស្រែជាចំបង (ផលស្រូវលើសតំរូវការ) និងសកម្មភាពនេសាទ, ប្រជាជនមានលំនៅជាប់លាប់ | ភូមិបាបោង ក្នុងឃុំបាបោង ស្រុកពាមរក៍ |
| កំពង់ស្ពឺ | តំបន់តាំងទីលំនៅសាជាថ្មី, មានសកម្មភាពសម្បទានច្រើន | ភូមិ៤ ក្នុងឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច |
| រតនគិរី | ក្រុមប្រជាជនដើម | ភូមិផ្សាក់ ក្នុងឃុំតាអង ស្រុកកូនមុំ |
| ភ្នំពេញ | តំបន់តាំងទីលំនៅដែលមានប្រាក់ចំណូលទាប - ការកាន់កាប់ដីធ្លីដោយខុសច្បាប់ | ភូមិ ១៤ និង ១៥ ក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន |

ពតិមានដ៏មានប្រយោជន៍ស្តីពីកម្មវិធីចុះបញ្ជីដីធ្លីដែលជួយទ្រទ្រង់ដោយ GTZ និង FinnMap ក៏ត្រូវបានប្រមូល ដើម្បីរៀនសូត្រពីអ្វីដែល "ត្រូវធ្វើ" ឬ "មិនត្រូវធ្វើ" ហើយដែលជាប់ទាក់ទងដល់ការចូលរួមរបស់សហគមន៍នៅក្នុងកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីជាប្រព័ន្ធ ។

ដូចការសិក្សាផ្សេងទៀតដែរ ការសិក្សានេះមានចំណុចខ្សោយខ្លះ ។ ទីមួយ វាមានទ្រង់ទ្រាយតូច និងអនុវត្តលើគំរូតាងដែលត្រូវបានជ្រើសយកដោយមានគោលដៅជាក់លាក់ ដូច្នេះមិនអាចតំណាងឱ្យស្ថានភាពដីធ្លីក្នុងទូទាំងកម្ពុជាទេ ។ មួយចំណែកទៀត ស្ថានភាពទីប្រជុំជនក្នុងក្រុងតូចៗមិនត្រូវបានលើកយកមកសិក្សាទេ ហើយដោយសារវាជាការសិក្សាតាមបែបគុណភាពមានលក្ខណៈ "រហ័ស" ដូច្នេះវាអាចខ្វះខាតចំណុចខ្លះដែលការសិក្សាលំអិតតាមបែបមនុស្សសាស្រ្តអាចស្រាវជ្រាវរកឃើញ ។ នៅក្នុងន័យនេះ ការសិក្សាមិនអាចប្រមូលប៉ារ៉ាម៉ែត្រត្រឹមត្រូវពិតប្រាកដតាមបែបបរិមាណបានគ្រប់គ្រាន់ទេ ។

## ១.៥ ទំរង់របាយការណ៍

របាយការណ៍នេះមានចែកចេញជាប្រាំពីរជំពូក ។ បន្ទាប់ពីសេចក្តីផ្តើម ជំពូក២ នឹងលើកត្រួសៗពីបរិបទសេដ្ឋកិច្ច-សង្គមកិច្ច និងនយោបាយរបស់ប្រទេសកម្ពុជា ដែលអាចមានផលប៉ះពាល់ទៅលើស្ថានភាពដីធ្លី ។ ជំពូក៣ បកស្រាយលំអិតអំពីស្ថានភាពដីធ្លីនៅក្នុងប្រទេស ដោយផ្អែកលើការចុះសិក្សាតាមមូលដ្ឋានទាំងនៅជនបទ និងទីក្រុង, និងបទសំភាសន៍ជាមួយអ្នកពាក់ព័ន្ធ និងអាជ្ញាធរនានា ដោយមានឆ្លុះបញ្ចាំងជាពិសេសនូវភាពខុសគ្នារវាងតំបន់នីមួយៗ ។ ខ្លឹមសារសំខាន់នៃជំពូក៣ គឺកំនត់អត្តសញ្ញាណនៃអ្នកពាក់ព័ន្ធផ្សេងៗនឹងដីធ្លី ។ ជំពូក៤ ពិភាក្សាពីយន្តការរដ្ឋបាលដែលមានស្រាប់សំរាប់ការផ្តល់កម្មសិទ្ធិដីធ្លី និង

ការចុះបញ្ជី ព្រមទាំងចំណុចខ្លាំង និងចំណុចខ្សោយនៃយន្តការទាំងនេះ ។ ជំពូក៥ ពិនិត្យពីប្រភេទនៃទំនាស់ដីធ្លី, យន្តការផ្សេងៗសំរាប់ដោះស្រាយទំនាស់ (យន្តការរបស់រដ្ឋ និងសហគមន៏) ព្រមទាំងប្រសិទ្ធិភាពរបស់វា ។ ជំពូក៦ ផ្តល់អនុសាសន៏ខាងគោលនយោបាយ និងជួយមតិមួយចំនួន សំដៅជំរុញដំណើរការផ្តល់កម្មសិទ្ធិឱ្យមានលក្ខណៈរលូនល្អ និងហុចអត្ថប្រយោជន៏ច្រើនជាបន្តមកទៀត ។ ជំពូក៧ គឺជាការសន្និដ្ឋាននៃរបាយការណ៍ ។ សេចក្តីសង្ខេបខ្លីៗអំពីលក្ខណៈរបស់ភូមិ និងក្រុងនីមួយៗដែលបានសិក្សា, សេចក្តីសង្ខេបពីសិក្ខាសាលាសំរាប់អ្នកអនុវត្តគោលនយោបាយខាងទីក្រុង, មានចុះនៅក្នុងឧបសម្ព័ន្ធ ។ ឯកសារសំភាសន៏ និងមធ្យោបាយសំភាសន៏ ក៏មានបង្ហាញនៅក្នុងឧបសម្ព័ន្ធដែរ ។

# ជំពូក ២

# ស្ថានភាពដីធ្លីនៅប្រទេសកម្ពុជា [១]

## ២.១ ការកំណត់ស្ថានភាពដីធ្លីតាមទ្រឹស្តី

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ សិទ្ធិខាងកម្មសិទ្ធិ មានការប្រែប្រួលនៅក្នុងប្រទេសជាច្រើនលើពិភពលោក ជាពិសេសក្នុងតំបន់ខ្លះនៃទ្វីបអាស៊ី/អាហ្វ្រិក អតីតប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើត និងក្នុងប្រទេសនានាដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីរបរធ្វើកសិកម្ម មកធ្វើឧស្សាហកម្មវិញ ។ ការផ្លាស់ប្តូរនេះបានកើតមាននៅតាមកន្លែងនានាដែលមានការចូលរួមយ៉ាងច្រើនពីសំណាក់ប្រជាជនដើម ហើយក្នុងករណីជាច្រើនការផ្លាស់ប្តូរវាលឿនហួសពេក និងបានប៉ះពាល់ដល់មនុស្សយ៉ាងច្រើន ។ វិធីសាស្ត្រមួយដែលរដ្ឋាភិបាលនានាបានអនុម័តយក គឺការធ្វើឯកជនភាវូបនីយកម្មដីធ្លី ដោយគេសន្មតថា ទីផ្សារនឹងបែងចែកដីធ្លីបានសក្តិសិទ្ធិបំផុត ដើម្បីលើកកំពស់សុខុមាលភាពសង្គម ។ ប៉ុន្តែប្រការនេះមិនមែនសំរេចបានរាល់ៗលើកនោះទេ ជាពិសេសនៅពេលណាដែលទីផ្សារវាមិនសុក្រិត ឬមានការអភិវឌ្ឍន៍តិចតួច, នៅពេលណាមានធនធាន ឬឱកាសតិចតួចពេក ដើម្បីឱ្យកសិករជីវព្រឹត្តិ (subsistence farmers) អាចផ្លាស់ប្តូរទៅធ្វើសកម្មភាពផ្សេងទៀត, ឬនៅពេលណាដែលក្រុមអ្នកទទួលរងការប៉ះពាល់គេខ្វះខាតពត៌មានស្តីពីប្រព័ន្ធច្បាប់ និងរដ្ឋបាល ។ នៅក្នុងន័យនេះ ការគ្រប់គ្រងដំណើរការអន្តរកាលឱ្យបានល្អ ដោយឡែកកិច្ចការពារផលប្រយោជន៍របស់ក្រុមផ្សេងៗ (ជាពិសេសអ្នកទន់ខ្សោយ) មានសារៈសំខាន់ជាគន្លឹះដើម្បីញ៉ាំងឱ្យកំណែទំរង់ដីធ្លីសំរេចបានជោគជ័យ ។

កាលពីមុន ប្រព័ន្ធកសិកម្មនៅអាស៊ីអាចបែងចែកជាពីរប្រភេទធំៗគឺ ប្រព័ន្ធកសិកម្ម *អតិផល* និងប្រព័ន្ធកសិកម្ម *យថាផល* ។ ប្រព័ន្ធកសិកម្មអតិផលអនុវត្តក្នុងកន្លែងមានមនុស្សរស់នៅច្រើន ដោយធនធាននានាត្រូវបានកេណ្ឌប្រមូលឱ្យធ្វើការងារយ៉ាងសកម្មនៅលើផ្ទៃដីមិនសូវសំបូណ៌ ។ ប្រព័ន្ធគ្រប់គ្រងមានលក្ខណៈជាឋានានុក្រម និងមានរបៀបរបបជាក់លាក់ ។ សិទ្ធិលើកម្មសិទ្ធិត្រូវបានកំណត់ច្បាស់លាស់គួរសម ហើយមានគំនូរប្លង់ព្រំដីសំរាប់បញ្ជាក់ ។ មួយចំណែកទៀត មានកំរងច្បាប់អនុម័តស្តីពីសិទ្ធិប្រើប្រាស់ដីព្រៃ និងធនធានទ្រព្យរួមផ្សេងទៀត ។ ប្រព័ន្ធនេះឃើញអនុវត្តនៅក្នុងតំបន់ជាច្រើន ជាពិសេសអាស៊ីខាងត្បូង ។ ផ្ទុយទៅវិញ ក្នុងតំបន់ជាច្រើននៅអាស៊ីអគ្នេយ៍រួមទាំងកម្ពុជាផង គេអនុវត្តប្រព័ន្ធកសិកម្មយថាផល ពីព្រោះមានផ្ទៃដីធំទូលាយធៀបនឹងចំនួនប្រជាជន ។ ដីព្រៃអាចរានយកដីបន្ថែមមកធ្វើការដាំដុះ ដោយសឹងតែគ្មានផលប៉ះពាល់ខាងអេកូឡូស៊ីទេ ។ នៅក្នុងប្រព័ន្ធកសិកម្មបែបនេះ កសិករពុំមានមធ្យោបាយផលិតកម្មច្រើនទេ ហើយពួកគេវិនិយោគតិចតួចណាស់ទៅលើដីធ្លី ។ នៅពេលជីជាតិដីចាប់ផ្តើមធ្លាក់ចុះ ប្រជាជនអាចផ្លាស់ទីទៅកាន់ដីធ្លីថ្មី និងតំបន់ថ្មីទៀត ។ អាស្រ័យហេតុនេះ ការផ្លាស់ប្តូរការដាំដុះ គឺជាចំណែកមួយនៃប្រព័ន្ធកសិកម្មយថាផល ។ កាលពីមុនដីមិនមែនជាទំនិញដែលអាចជួញដូរបានទេ ប៉ុន្តែ

---

១ ជំពូកនេះផ្អែកជាសំខាន់លើឯកសារ និងទិន្នន័យដែលមានស្រាប់ ។

គេចាត់ទុកដីថាជាអំណោយពីធម្មជាតិ ។ ប្រព័ន្ធកសិកម្មយថាផលមានឋានានុក្រមសង្គមទន់ខ្សោយ និងមានប្រព័ន្ធកម្មសិទ្ធិដីធ្លីធូររលុង និងមិនបានចងក្រងជាច្បាប់ទេ (Boserup 1965)[២] ។ គោលគំនិតស្តីពីកម្មសិទ្ធិ ការកាន់កាប់ និងការប្រើប្រាស់ដីធ្លីក៏មានភាពមិនច្បាស់លាស់ដែរ ។ ឧទាហរណ៍ ការប្រើប្រាស់ដីធ្លីមានសារៈសំខាន់បំផុតនៅក្នុងន័យដែលអ្នកប្រើប្រាស់ដី កំណត់នូវការកាន់កាប់ និងកម្មសិទ្ធិរបស់ខ្លួន ។ នេះជាលក្ខណៈខុសគ្នាជាមូលដ្ឋាន រវាងការយល់ឃើញជាទូទៅនៅក្នុងរបបទ្រព្យសម្បត្តិឯកជនបច្ចុប្បន្ន ហើយនិងគំនិតយល់ឃើញនៅក្នុងប្រព័ន្ធកសិកម្មយថាផល (Hanks 1972) ។ អ្នកពាក់ព័ន្ធនឹងដីធ្លី គឺជាអ្នកស្រែចំការ (មិនអាចញែកបាន) ហើយតំរូវការដីធ្លីរបស់ពួកគេ ត្រូវបានដោះស្រាយដោយភាពសំបូណ៌បែបនៃធម្មជាតិ ។ នៅពេលទំនើបភាវូបនីយកម្មចូលមកដល់ ហើយចំនួនប្រជាជនក៏បានកើនឡើង ប្រព័ន្ធកសិកម្មយថាផលត្រូវរអាក់រអួលយ៉ាងខ្លាំង ហើយប្រជាជនដែលពឹងផ្អែកលើប្រព័ន្ធនេះ ត្រូវប្រឈមមុខនឹងការធ្លាក់ខ្លួនក្រីក្រ ។

ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រច្របូកច្របល់ខ្លាំងបំផុតនៅក្នុងរយៈពេល ១០០ឆ្នាំចុងក្រោយ ហើយយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតជាមូលដ្ឋានក៏គ្មានការប្រែប្រួលគួរឱ្យកត់សំគាល់សោះ ដើម្បីចេញពីការធ្វើកសិកម្មជីវព្រឹត្តិ ទៅកាន់របបរកចិញ្ចឹមជីវិតផ្សេងទៀត ។ ប្រជាកសិករនៅតែមិនចេះអក្សរ និងក្រីក្រ ហើយពួកគេគ្មានឱកាសធ្វើទំនើបភាវូបនីយកម្ម ឬកែលំអយុទ្ធសាស្ត្របន្តជីវិតរបស់ខ្លួនឡើយ ។ ជាការពិតហើយ ក្នុងតំបន់ជាច្រើន ទីផ្សារផលិតផលបានរីកលូតលាស់ ដោយសារកសិករចាប់ផ្តើមផលិតសំរាប់ទីផ្សារ និងរកប្រាក់ចំណេញ ជាពិសេសគឺដាំដំណាំ *ចំការ* (មិនមែនដំណាំស្រូវ ប៉ុន្តែជាកសិផលពាណិជ្ជកម្ម) ។ ប៉ុន្តែចំពោះ ទីផ្សារដីធ្លីវិញ វាមិនបានវិវត្តដូច្នេះទេ ។ ដូច្នេះប្រជាជនភាគច្រើនក៏បានបន្តរស់នៅក្រោមឥទ្ធិពលនៃប្រព័ន្ធដីធ្លីពីមុនដូចមានគូសបញ្ជាក់នៅខាងក្រោម ។

## ២.២ ប្រវត្តិសង្ខេបអំពីដីធ្លីនៅកម្ពុជា

នៅក្នុងសម័យមុនអាណានិគម ដីគឺជាសម្បត្តិរបស់ព្រះមហាក្សត្រ ប៉ុន្តែប្រជាជនអាចដាំដុះដោយសេរីលើដីធ្លី តាមទំហំដែលខ្លួនត្រូវការ ។ ប៉ុន្តែ ដោយសារខ្វះលទ្ធភាពខាងមធ្យោបាយផលិតកម្ម ដីធ្លីកាន់កាប់ជាឯនជនមានទំហំមិនលើសពី ១-៣ ហិកតាឡើយ ។ ម្យ៉ាងវិញទៀត នៅពេលនោះប្រជាជនមានចំនួនតិច ហើយគ្មានទីផ្សារដីធ្លីដូចសព្វថ្ងៃទេ ដូច្នេះប្រជាកសិករអាចចល័តពីកន្លែងមួយទៅកាន់កន្លែងមួយ និងអាចកាន់កាប់ដីធ្លីបានដោយសេរី ។ ម្ចាស់ដីមានសិទ្ធិផ្តាច់មុខក្នុងការកាន់កាប់ប្រើប្រាស់ ឬបន្តមរតកដីកសិកម្ម ដោយមិនចាំបាច់ត្រូវបំពេញសំណុំបែបបទអ្វីក្រៅពីការបង់ពន្ធជាសួយសារអាករតូចមួយទៅអោយសក្តិភូមិនោះទេ (Thion 1993) ។ ចាប់ពីក្នុងរង្វង់ឆ្នាំ១៨០០ ដល់១៩៣០ អាណានិគមបារាំងបានព្យាយាមដាក់បញ្ចូលនូវប្រព័ន្ធទ្រព្យសម្បត្តិឯកជន និងកម្មសិទ្ធិជាផ្លូវការ ប៉ុន្តែការងារនេះមិនបានជោគជ័យទាំងស្រុងទេ ។ ពួកបារាំងធ្វើបានសំរេចខ្លះៗនៅក្នុងតំបន់វាលទំនាបធ្វើស្រែ ប៉ុន្តែផ្ទៃដីដ៏ធំល្វឹងល្វើយក្រៅពីវាលទំនាប (ដូចជាដីព្រៃ និងដីចំការតំបន់ខ្ពង់រាប) ត្រូវបានរំលងចោល ។ នៅក្រោយសម័យអាណានិគម (១៩៥៣-១៩៧៥) ប្រទេសកម្ពុជាបានបន្តប្រើប្រាស់ប្រព័ន្ធដីធ្លីដែលបារាំងដាក់ឱ្យប្រើ ហើយដូចមុនដែរ ការចងក្រងច្បាប់ ការធ្វើឯកជនភាវូបនីយកម្ម និងការធ្វើពាណិជ្ជកម្មដីធ្លី មានជោគជ័យតែមួយក៏រិតប៉ុណ្ណោះ ។ របបខ្មែរក្រហម (១៩៧៥-៧៩) បានដកហូតយកដីទាំងអស់ដាក់ជាដីសមូហភាព ។ ឯកជនភាវូបនីយកម្មបានចាប់ផ្តើមជាថ្មីនៅពាក់កណ្តាលទសវត្សរ៍១៩៨០ និងបានចូលជាផ្លូវការនៅឆ្នាំ១៩៨៩ ។ ចាប់ពីពេលនោះមក ប្រជាជនទាំងកសិករ និងមិនមែនកសិករ គឺអាចមានដីឯកជន បើពួកគេប្រើប្រាស់ដីទាំងនេះ ។ ដីណាដែលមិនបានប្រើប្រាស់លើសពីបីឆ្នាំ គឺត្រូវក្លាយជាសម្បត្តិរដ្ឋវិញ ។

---

២ សូមអានឯកសាររបស់ Jose (1986) និង Bray (1986) ចំពោះពតិមានលំអិតបន្ថែមទៀតស្តីពីស្ថានភាពនៅអាស៊ីអគ្នេយ៍ ។ ចំពោះប្រទេសកម្ពុជា ពតិមានសំខាន់ៗមានកត់ត្រាផងដែរនៅក្នុងអត្ថបទនិពន្ធពីសម័យអាណានិគមបារាំង ដែលត្រូវបានសង្ខេបក្នុងសៀវភៅរបស់ Chandler (1993) and Meijers and also Thion (1993:20-41) ។

ដូចបានបញ្ជាក់ពីខាងដើមរួចហើយ នៅក្នុង ១០០ឆ្នាំចុងក្រោយនេះ ការលូតលាស់ទីផ្សារដីធ្លី និងការលក់ដូរដី មានការវិវត្តន៍យឺត ហើយមិនបានស្មើគ្នាល្អទេ ។ ឧទាហរណ៍ នៅក្នុងភាគខ្លះនៃប្រទេសកម្ពុជា (ដីស្រែធំៗនៅជុំវិញតំបន់ *ទន្លេសាប*) របបធ្វើកសិកម្មនៅជាប់លាប់មួយកន្លែងបានរីកចំរើនចាក់ឫសយ៉ាងមាំ ប៉ុន្តែរបៀបរបបតាមទំនៀមទំលាប់ប្រពៃណីក្នុងការកាន់កាប់ និងការប្រើប្រាស់ដីធ្លី ក៏នៅតែមានអនុវត្តច្រើននៅឡើយ ។ ដូចគ្នានេះដែរ នៅក្នុងតំបន់ថ្មីៗដែលទើបតែមានការដាំដុះក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទំលាប់ចាស់ក្នុងការចាប់ដីដោយការកាប់រំលំដើមឈើនៅតែមានធ្វើនៅឡើយ ។ ដំបូងគេចាប់យកដីសិនហើយក្រោយមកទើបដាក់ពាក្យសុំទៅអាជ្ញាធរដើម្បីអោយបានភាពស្របច្បាប់ ។ ប៉ុន្តែក្នុងករណីជាច្រើនទៀត គ្មានការដាក់ពាក្យសុំបែបនេះទេ ។ ទីបី ការដាំដុះដោយផ្លាស់កន្លែង (កាប់ព្រៃធ្វើចំការ) ដែលអនុវត្តភាគច្រើន (មិនមែនទាំងអស់ទេ) ដោយប្រជាជនដើម ឃើញមានច្រើននៅខាងភូមិភាគឦសាន ។ នៅទីនោះ គោលគំនិតក្នុងរឿងកម្មសិទ្ធិ គឺសំដៅដល់កម្មសិទ្ធិសហគមន៍ មិនមែនជាកម្មសិទ្ធិឯកជនទេ ។ រីឯព្រៃឈើដែលមានវិសាលភាពអាចគ្របដណ្តប់បានជាងពាក់កណ្តាលនៃផ្ទៃដីប្រទេសនៅឡើយ ឥឡូវនេះស្ថិតនៅក្រោមកម្មសិទ្ធិរដ្ឋ ទោះបីជាមានព្រៃសម្បទានធំៗជាច្រើន ត្រូវបានផ្តល់អោយក្រុមហ៊ុនឯកជនក៏ដោយ ។ នៅក្នុងដែនព្រៃឈើ មានភូមិជាច្រើនដែលមានប្រជាជនបន្តធ្វើកសិកម្មផ្លាស់ទី (កាប់ចំការ) ឬការដាំដុះទំរង់ផ្សេងទៀត ឬក៏កាប់ឧស និងប្រមូលអនុផលព្រៃឈើ[៣] ។

ដោយហេតុថា ដីត្រូវបានធ្វើឯកជនភាវូបនីយកម្មកាន់តែខ្លាំង (ទាំងការក្តាប់កម្មសិទ្ធិ ក៏ដូចជាការត្រួតត្រា) គេឃើញមានរបៀបរបបកាន់កាប់ដីធ្លីជាច្រើនប្រភេទបានផុសឡើង ។ ទី១ គឺរបៀបរបបជាលក្ខណៈជីវព្រឹត្តិ ដែលប្រជាជនភាគច្រើនបានអនុវត្ត ។ ទី២ ការកាន់កាប់ដីធ្លីជាលក្ខណៈសហគមន៍ ដែលគេនិយមអនុវត្តក្នុងតំបន់កាប់ព្រៃធ្វើចំការ ។ ទី៣ គឺរបៀបរបបទីផ្សារដែលបានគ្របដណ្តប់តំបន់ទីក្រុងទាំងអស់ និងបានរាលដាលដល់តំបន់ជនបទ ដោយសារអ្នកទិញលក់ដីកេញ្ចយកចំណេញកសិករដាំដំណាំពាណិជ្ជកម្ម អ្នកសុំសម្បទានដីព្រៃ និងអ្នកត្រូវការដីធ្លីផ្សេងទៀត ។ គេបានពិនិត្យឃើញថា ជាញឹកញយទំនាស់បានផុសឡើងរវាងប្រជាជនដែលអនុវត្តរបៀបរបបខុសៗគ្នានៃកាន់កាប់ដី ហើយក្នុងនេះផលប្រយោជន៍ខាងទីផ្សារតែងទទួលផលចំណេញជានិច្ច ពីព្រោះពួកគេមានរដ្ឋ ច្បាប់ និងពត៌មានគ្រប់គ្រាន់សំរាប់ជួយពួកគេ គឺផ្ទុយពីកសិករដែលច្រើនតែមិនចេះអក្សរ និងមានមធ្យោបាយតិចតួច ។ ប្រការនេះបណ្តាលឱ្យប្រជាជនជាច្រើនបាត់បង់ដីធ្លី និងធ្លាក់ក្នុងស្ថានភាពទាល់ច្រកហើយសភាពការណ៍នេះអាចប៉ះពាល់ដល់ស្ថិរភាពនយោបាយ បើសិននៅតែបន្តទៅមុខទៀត ។ ដូច្នេះហើយ ចំពោះអន្តរកាលដែលបានបញ្ជាក់ពីខាងដើម គេចាំបាច់ត្រូវតែគ្រប់គ្រងវាឱ្យបានហ្មត់ចត់ គឺធ្វើយ៉ាងណាបញ្ឈប់ឱ្យបាននូវនិន្នាការបាត់បង់ដី និងការធ្វើឱ្យខូចខាតដល់សមត្ថភាពរបស់ប្រជាជនក្នុងការរកចំណូលដើម្បីធានាជីវភាពរស់នៅរបស់ខ្លួន ។

## ២.៣ ក្តីកង្វល់ធំៗមួយចំនួនចំពោះស្ថានភាពដីបច្ចុប្បន្ន

នៅពេលដីធ្លីត្រូវបានធ្វើឯកជនភាវូបនីយកម្មនៅក្នុងឆ្នាំ១៩៨៩ គេមានជំនឿជាទូទៅថា ការបែងចែកដីមានសមធម៌គួរសម ហើយប្រជាជនស្ទើរតែគ្រប់រូបដែលមានសិទ្ធិទទួលដី គឺត្រូវបានទទួលដីដោយជាក់ស្តែង ។ សិទ្ធិកម្មសិទ្ធិត្រូវបានផ្តល់ចំពោះដីស្នាក់នៅ និងដីលំនៅដ្ឋានដែលមានទំហំមិនលើសពី ២.០០០ម៉ែត្រការ៉េ, សិទ្ធិកាន់កាប់ត្រូវបានផ្តល់ចំពោះដីដាំដុះកសិកម្ម ដែលមានទំហំមិនលើសពី ៥ហិកតា, ហើយសិទ្ធិផ្នែកសម្បទាន ត្រូវបានផ្តល់ចំពោះដីចំការដែលមានទំហំដីលើសពី ៥ហិកតា ។ ក្រៅពីនេះ សិទ្ធិកម្មសិទ្ធិត្រូវបានផ្តល់អោយប្រជាជនដែលកាន់កាប់ផ្ទះសំបែង និងរស់នៅក្នុងទីក្រុងភ្នំពេញ(Williams 1999) ។ ប៉ុន្តែប្រហែលមួយទសវត្សរ៍ក្រោយមក គេសង្កេតឃើញមានការមិនពេញចិត្តជាទូទៅនៅតាមមូលដ្ឋានពីភាពគ្មានដី និង វិសមភាព ។ ពត៌មានលំអិតអំពីរឿងនេះមានចុះផ្សាយយ៉ាងច្រើននៅក្នុងទំព័រសារពត៌មានមួយចំនួន ក៏ដូចជាមានលើកបង្ហាញ នៅក្នុងសារណាសិស្សនិស្សិត (Kato 1999) ។

[៣] ប៉ុន្តែឥឡូវនេះ អ្នកភូមិកាន់តែបាត់លទ្ធភាពចេញចូលទាញយកផលពីព្រៃឈើតាមប្រពៃណីរបស់ខ្លួនហើយ ដោយអ្នកកាន់កាប់ព្រៃសម្បទានហាមឃាត់ ។

ផលប៉ះពាល់ដោយផ្ទាល់នៃការបែងចែកដីធ្លីនៅក្នុងចន្លោះឆ្នាំ១៩៨៩-៩៨ ចំពោះ ការកាត់បន្ថយភាពក្រីក្រ គឺពិបាកនឹងអាចវិនិច្ឆ័យបាន ប៉ុន្តែគេឃើញមានការទទួលស្គាល់ជាទូទៅថា ចាំបាច់ត្រូវមានការកែទំរង់ ដីធ្លីយ៉ាងហ្មត់ចត់[៤] ។

មានបញ្ហា ៥ យ៉ាងតិចដែលបានបង្កការព្រួយបារម្ភជាទូទៅ: ១. កំណើនវិសមភាពដីធ្លី ២. ភាពគ្មានដីធ្លី ៣. កង្វះសុវត្ថិភាពក្នុងការកាន់កាប់ដី ៤. កំណើនទំនាស់ទាក់ទិននឹងដីធ្លី និង ៥. កំណើននៃការតាំងទីលំនៅខុសច្បាប់ក្នុងទីប្រជុំជនជាពិសេសនៅក្រុងភ្នំពេញ ។ ការពិភាក្សាវែកញែកពីបញ្ហាទាំងនេះមានដូចតទៅ ។

## *២.៣.១ វិសមភាពដីធ្លី*

សព្វថ្ងៃ ទិន្នន័យមានលក្ខណៈជាប្រព័ន្ធស្តីពីវិសមភាពដីធ្លី មិនទាន់មានគ្រប់គ្រាន់នៅឡើយទេ ប៉ុន្តែប្រភពទិន្នន័យដែលមានស្រាប់បានបង្ហាញថា វិសមភាពដីធ្លីបានកើនឡើងគួរឱ្យកត់សំគាល់ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ អង្កេត SES ឆ្នាំ១៩៩៧ ដែលតំណាងអោយប្រទេសកម្ពុជាទាំងមូល (លើកលែងតែតំបន់តូចៗមួយចំនួនចេញដែលត្រូវរំលងចោល ដោយសារការប្រយុទ្ធគ្នានៅពេលនោះ) បានបង្ហាញថា មេគុណជីនីនៃវិសមភាព (Gini coefficient of inequality) មានកំរិតស្មើនឹង ០,៦៦ នៅតំបន់ជនបទ[៥] ។ តួលេខនេះ បើគិតតាមតំលៃដាច់ខាត (absolute terms) ឃើញថាមានកំរិតខ្ពស់ ។ អង្កេត MRC ឆ្នាំ១៩៩៥-៩៦ ដែលអនុវត្តក្នុង ៨ខេត្ត បានគ្របដណ្តប់លើសហគមន៍នេសាទជាច្រើន ។ ប៉ុន្តែគំរូតាងមានទំហំធំ គឺមានជាង ៥.០០០គ្រួសារ ដូច្នេះអង្កេតតំណាងប្រជាជនដែលបានធ្វើអង្កេតបានល្អ ។ អង្កេតបានបង្ហាញតួលេខមេគុណជីនីស្មើនឹង ០,៦១ ។ អង្កេតឯទៀតដែលបង្ហាញនូវរបាយដីធ្លីមានវិសមភាព មានជាអាទិ៍ អង្កេតរួមគ្នារវាង WFP និង UNICEF (អង្កេត Baseline ឆ្នាំ១៩៩៨) ហើយអង្កេតមួយទៀតរបស់ WFP (អង្កេត PET-98) ។ ទោះបីជាអង្កេតទាំងនេះមានខ្នាតតូច និងផ្តោតទៅលើស្រទាប់ក្រីក្រក្នុងសង្គម ដូចជា ជនភៀសសឹក និងក្រុមប្រជាជនស្រដៀងគ្នា, ប៉ុន្តែវានៅតែបង្ហាញ មេគុណជីនីកំរិត ០,៥០ និង ០,៤៧ ។

វាអាចមានមូលហេតុច្រើនយ៉ាង ចំពោះវិសមភាពក្នុងការកាន់កាប់ដីធ្លី ។ ទីមួយគឺ *សម្ពាធប្រជាសាស្ត្រ* ។ ក្នុងទសវត្សរ៍ ១៩៨០ ប្រជាជនបានកើនយ៉ាងលឿន ហើយគេប៉ាន់ស្មានថា ពីឆ្នាំ១៩៩០-៩៨ កំណើនមានទំហំប្រហែល ៣០% (Williams 1999; NIS 1999) ។ គេឃើញមានគ្រួសារថ្មីៗច្រើនណាស់បានផុសឡើង ហើយមួយចំនួនធំជាអ្នកគ្មានដីធ្លី (Biddulph 2000) ។ ប៉ុន្តែផ្ទៃដីដាំដុះកើនឡើងក្នុងល្បឿនយឺតជាង ហើយសព្វថ្ងៃនេះមិនទាន់មានទំហំស្មើនឹងផ្ទៃដីដាំដុះកាលពីក្នុងទសវត្សរ៍១៩៦០ នៅឡើយ (តាមទិន្នន័យនៅចុងទសវត្សរ៍១៩៩០) ។ ដោយសារមានពហុកម្មមុខរបរតែមួយកំរិតតូច ឯចំនួនប្រជាជនរស់នៅពឹងផ្អែកលើកសិកម្មបានកើនឡើងគួរឱ្យកត់សំគាល់ ដូច្នេះគឺមានប្រជាជនកាន់តែច្រើនថែមទៀត ដែលត្រូវរស់នៅពឹងផ្អែកលើផ្ទៃដីកសិកម្មទំហំដដែល ។ ដោយហេតុថា រចនាសម្ព័ន្ធគ្រួសារ គុណភាពដី លំនាំនៃការឈឺថ្កាត់ និងចំណាយជាប់ទាក់ទិនមានលក្ខណៈខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយ និងពីតំបន់មួយទៅតំបន់មួយ ដូច្នេះឌីណាមិកខាងសេដ្ឋកិច្ច-សង្គមកិច្ច និងខាងនយោបាយនៃការគ្រប់គ្រងដីធ្លីក៏ប្រែប្រួលដែរ (Kato 1999; Biddulph 2000) ។ ជាលទ្ធផល គ្រួសារមួយចំនួនត្រូវពុះបំបែកដីឡូត៍ចែកគ្នា ឯអ្នកខ្លះទៀតត្រូវលក់ដីមួយចំណែក ឬលក់ទាំងអស់តែម្តង ។ អាស្រ័យហេតុនេះ វិសមភាពក៏កើតមានឡើង ។ មូលហេតុទី២ ទាក់ទងនឹង *ប្រជាជនយ៉ាងច្រើនដែលមិនទាន់បានតាំងទីលំនៅជាប់លាប់នៅឡើយ* ហើយបានផុសឡើងក្នុងទសវត្សរ៍១៩៩០ ។ ឧទាហរណ៍ ជនមាតុភូមិនិវត្តន៍ជាច្រើនដែលមកពីព្រំដែនថៃក្នុងឆ្នាំ១៩៩២-៩៣ មិនបានទទួលដីធ្លីទេ ដោយសារដីនៅតំបន់ដែលពួកគេចង់តាំងទីលំនៅមានម្ចាស់កាន់កាប់ទៅហើយ មានមីន ឬមានភាគីផ្សេងៗតវ៉ាជំទាស់ ។ ប្រជាជនជាច្រើនក្នុងក្រុមនេះមិនបានទទួលផលពីការបែងចែកដីក្នុងគំរោងបែងចែកឆ្នាំ១៩៨៩ ទេ ហើយត្រូវទៅរស់នៅលើដីធ្លីរបស់សាច់ញាតិ (ដែលធ្វើអោយមានការពុះចែកដីក្នុងគ្រួសារ និងមានកំណើនវិសមភាពដីធ្លី) ។ ទី៣ *ទីផ្សារផលិតផលទានផ្លូវការនៅទន់ខ្សោយ* ជាពិសេសក្នុងតំបន់

---

៤ ចំពោះនិន្នាការភាពក្រីក្រក្នុងទសវត្សរ៍១៩៩០ សូមអានឯកសារ RGC (1999) ។

៥ មេគុណជីនីអំពីវិសមភាពប្រែប្រួលពីកំរិតសូន្យ (សមភាពទាំងស្រុង) ទៅដល់ មួយ (វិសមភាពទាំងស្រុង) ។

ជនបទ ។ ដូច្នេះ កសិករត្រូវពឹងផ្អែកលើឥណទានដែលមានការប្រាក់ខ្ពស់សំរាប់ទិញ/ជួលមធ្យោបាយផលិតកម្ម ដូចជា ជី សត្វ អូសទាញ និងកំលាំងពលកម្ម ។ នៅពេលផលដំណាំត្រូវខូចខាត (ដោយសារទឹកជំនន់ រាំងស្ងួត ឬសត្វចង្រៃ) កសិករមួយចំនួនដែលមានធនធានតិចតួច ត្រូវបង្ខំចិត្តលក់ដីធ្លីមួយចំណែក ឬទាំងអស់ទៅអោយអ្នកមានធនធាន ដើម្បីសងបំណុល ។ ដូច្នេះហើយអ្នកខ្លះកាន់តែមានដីកាន់កាប់ច្រើនឡើង ឯអ្នកខ្លះទៀតកាន់តែមានតិចទៅៗ ។ មួយចំណែកទៀតគេសង្កេតឃើញថា ប្រព័ន្ធសុខាភិបាល សាធារណៈនៅទន់ខ្សោយដែលបង្ខំអោយប្រជាជនត្រូវប្រើប្រាស់សេវាសុខាភិបាលឯកជននៅពេលមានជំងឺ ។ សេវាទាំងនេះមានតំលៃខ្ពស់ ហើយប្រជាជនជាច្រើនត្រូវលក់ដី ឬធនធានផ្សេងទៀត ដើម្បីសងថ្លៃព្យាបាល (Biddulph 2000) ។

ចំនុចចុងក្រោយគឺ *ការទិញ-លក់ដើម្បីកេងយកចំណេញ* នូវដីធ្លីជាច្រើនដោយមនុស្សមួយចំនួនតូចដែលធ្វើឱ្យមានកំនើន វិសមភាព ។ សព្វថ្ងៃមានការទទួលស្គាល់ជាទូទៅថា អត្ថប្រយោជន៍នៃការអភិវឌ្ឍន៍នៅក្នុងទសវត្សរ៍ចុងក្រោយ ភាគច្រើន បំផុត គឺបានទៅដល់អ្នករស់នៅក្រុងភ្នំពេញ ឬទីប្រជុំជនផ្សេងទៀត[៦] ។ ប៉ុន្តែខុសពីប្រទេសឯទៀត (ឧទាហរណ៍ នៅថៃ ចិន ដែលមានជំរើសច្រើនសំរាប់ការធ្វើវិនិយោគ ដូចជាក្នុងឧស្សាហកម្ម ភាគហ៊ុន សញ្ញាប័ណ្ណ ឬសេវាកម្ម) នៅកម្ពុជាមានច្រកតិច តូចណាស់សំរាប់ធ្វើវិនិយោគ ។ បន្ទាប់ពីអស់លទ្ធភាពវិនិយោគលើផ្នែកសណ្ឋាគារ/ភោជនីយដ្ឋាន ប្រជាជនបែរមកវិនិយោគលើ ដីធ្លី ពីព្រោះគ្មានជំរើសណាផ្សេង ។ ដូច្នេះការផ្ទេរដីធ្លីពីប្រជាជន (ភាគច្រើនក្រីក្រ) នៅជនបទ ទៅអោយពួកអ្នកមានរស់នៅ ក្នុងទីក្រុង បានក្លាយជាដំណើរការមួយដែលមិនអាចចៀសវាងបាន ។

## ២.៣.២ ភាពគ្មានដីធ្លី

កង្វល់ចំបងមួយគឺ កសិករត្រូវបាត់បង់ដីធ្លីដោយបង្ខំ និងក្លាយជាអ្នកគ្មានដីធ្លី ។ ការប៉ាន់ស្មានផ្អែកលើទិន្នន័យ SES 1997 បង្ហាញថា ១២% នៃគ្រួសារនៅជនបទគ្មានដីធ្លីទេ ។ អង្កេត MRC បង្ហាញថា ក្នុងសហគមន៍នេសាទ អត្រាគ្រួសារគ្មានដីមានទំហំដល់ ២៤% ។ អង្កេត Baseline បង្ហាញថា អត្រាអ្នកគ្មានដីមានកំរិត ១១% ហើយការសិក្សា PET បង្ហាញថា អត្រាអ្នកគ្មានដីមានកំរិត ១៧% ។ គេសង្កេតឃើញថា គ្រួសារមានស្ត្រីជាមេគ្រួ មានអត្រាគ្មានដីធ្លី ខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួ ។ តំបន់ទីប្រជុំជន និងតំបន់ពាណិជ្ជកម្ម (កណ្តាល កំពង់ចាម) និងខេត្តមួយចំនួននៅភាគខាងលិច (បាត់ដំបង កោះកុង) មានអត្រាអ្នកគ្មានដីខ្ពស់ជាងខេត្តដទៃ ។ មូលហេតុដែលធ្វើអោយគ្មានដី គឺវាប្រហាក់ប្រហែលនឹងមូលហេតុនៃវិសមភាពក្នុងការបែងចែកដីធ្លីៈ សម្ពាធប្រជាសាស្ត្រខ្ពស់ ពហុកម្មមុខរបរកំរិតទាប ប្រជាជនមិនបានទទួលដំណោះស្រាយលើការតាំងទីលំនៅ (មានទាំងជនមាតុភូមិនិវត្តន៍) ការប្រាក់ខ្ពស់ សេវាខាងសង្គមកិច្ច និងសុខាភិបាលគុណភាពអន់ដែលបង្ខំប្រជាជនប្រើប្រាស់សេវា ឯកជនមានតំលៃខ្ពស់ និងការទិញ-លក់ដីកេញយកចំណេញដោយមនុស្សមួយចំនួនតូច ។ មូលហេតុខ្លះទៀតនៃបាត់បង់ដីធ្លី គឺ មានកង្វះខាតកំលាំងពលកម្ម (ជាពិសេសគ្រួសារមានស្ត្រីជាមេគ្រួ) ការប្រយុទ្ធគ្នាជាបន្តបន្ទាប់ក្នុងតំបន់មួយចំនួន និងការដោះ មីនយឺត ។ អង្កេត Baseline ក៏បង្ហាញដែរថា ប្រជាជនមួយចំនួនតូចត្រូវលក់ដីលំនៅដ្ឋានរបស់ខ្លួនដើម្បីយកប្រាក់ទិញស្បៀង ក្នុងនេះ គ្រួសារមានស្រីជាមេគ្រួមានច្រើនជាងគ្រួសារមានបុរសជាមេគ្រួ ។ ដោយសារដីច្រើនមានទំហំតូច (ដីកាន់កាប់តាម គ្រួសារមានទំហំពី ១-២ហិកតា) ដូច្នេះការលក់ដីក្នុងករណីភាគច្រើនធ្វើឱ្យគ្រួសារអស់ដីរលីង ។ ការសង្កេតតាមដានបានបង្ហាញ ថា អ្នកមានដីតិចតួចគឺជាអ្នកងាយបាត់បង់ដីធ្លី[៧] ។

## ២.៣.៣ កង្វះសុវត្ថិភាពក្នុងការកាន់កាប់ដី

៦ ការលំអៀងទៅរកទីក្រុង គឺជាហេតុការណ៍មួយដែលគេទទួលស្គាល់ជាទូទៅ ។ សូមអានឯកសារ Curtis (1998: 80-84) ។

៧ ចំពោះស្ថិតិលំអិតស្តីពីវិសមភាពដីធ្លី និងភាពគ្មានដី សូមអានឯកសាររបស់លោក Sik (2000) ។

បន្ទាប់ពីឯកជនភាវូបនីយកម្មដីធ្លីនៅឆ្នាំ១៩៨៩ កសិករ និងអ្នកទីក្រុងជាច្រើននាក់ បានទទួលបង្កាន់ដៃសំរាប់ជាសំអាងចំពោះការកាន់កាប់របស់ខ្លួន ។ ប៉ុន្តែនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ បានអោយដឹងថា ក្នុងចំណោមអ្នកដាក់ពាក្យសុំ ៤ ទៅ ៥លាននាក់ គឺមានប្រហែលតែ ១៣-១៤%ប៉ុណ្ណោះដែលបានទទួលប័ណ្ណប្លង់ដីជាផ្លូវការ ។ម្យ៉ាងវិញទៀត នៅក្រោយការចេញបង្កាន់ដៃជាសំអាង ចំពោះពាក្យសុំកម្មសិទ្ធិពីដំបូង ដីធ្លីត្រូវបានផ្ទេរ និង/ឬពុះជ្រៀកជាច្រើនលើក ហើយប្រតិបត្តិការទាំងនេះមិនសុទ្ធតែបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចរាល់ៗលើកនោះទេ ។ ការផ្ទេរដោយមិនបានរាយការណ៍បែបនេះ វាបានកើតមានចំពោះដីកសិកម្មនៅជនបទ ច្រើនជាងចំពោះដីលំនៅដ្ឋាន ឬដីនៅតំបន់ទីក្រុង ។ អង្កេត SES 1997 បានបង្ហាញដែរថា មានការយល់ច្រឡំមួយចំនួនក្នុងចំណោមអ្នកឆ្លើយសំភាសន៍ ពីព្រោះភាគច្រើនប្រហែលមិនបានដឹងថាអ្វីទៅជាឯកសារដីធ្លីត្រឹមត្រូវនោះទេ ។

ដូចបានលើកឡើងហើយ ជាលក្ខណៈប្រវត្តិសាស្ត្រ ប្រព័ន្ធកាន់កាប់ដីធ្លីនៅកម្ពុជាគឺជាប្រភេទ "យថាផល" ដែលក្នុងនេះគ្មានការផ្តល់សិទ្ធិដ៏ច្បាស់លាស់លើដីធ្លីទៅអោយប្រជាជនទេ ។ ក្នុងពេលថ្មីៗ ជាមួយនឹងការមកដល់នៃប្រព័ន្ធទីផ្សារ មរតកនេះបានបង្កអសុវត្ថិភាពក្នុងការកាន់កាប់ដី ។ នៅពេលមានការទិញលក់កាន់តែច្រើន អ្នកដែលមិនបានធ្វើសមាហរណកម្មល្អទៅក្នុងទីផ្សារ គឺកាន់តែមានអារម្មណ៏ថា មានអសុវត្ថិភាពខ្លាំងឡើងៗ ។ អង្កេត PET បង្ហាញថា មានគ្រួសាររហូតដល់ ៣% ដែលបានរាយការណ៏ថា បានបាត់បង់ដីដោយសារមានអ្នកដទៃរំលោភយក ។

បទពិសោធន៏ជាក់ស្តែងបានបង្ហាញថា សុវត្ថិភាពក្នុងការកាន់កាប់ដីមានសារៈសំខាន់ណាស់ ដើម្បីលើកទឹកចិត្តឱ្យកសិករធ្វើវិនិយោគក្នុងមធ្យោបាយធ្វើកសិកម្មមានចីរភាព ។ កសិករនៅកម្ពុជាគ្មានប័ណ្ណស្របច្បាប់អ្វីទេ សំរាប់ដីធ្លីដែលខ្លួនធ្វើការដាំដុះនោះទេ ។ ប្រការនេះធ្វើឱ្យមានទំនាស់ដីធ្លី និងបង្កើតនូវបរិស្ថានអស្ថិរភាពមួយដែលរារាំងការកែលំអដីធ្លី (RGC 1998) ។ នេះជាពត៌មានដែលស្រង់ចេញពីឯកសារផ្ទាល់របស់រដ្ឋាភិបាល ហើយដែលបានទទួលស្គាល់ពីផលវិបាកនៃអសុវត្ថិភាពក្នុងការកាន់កាប់ដី ។ សភាពការណ៏កាន់តែអាក្រក់ឡើងទៀត នៅពេលដែលមន្ត្រីរាជការត្រូវបានអូសទាញឱ្យបំរើផលប្រយោជន៏របស់ពួកអ្នកមានលទ្ធភាពបង់ប្រាក់សំរាប់ការងារធ្វើលិខិតស្នាម (Williams 1999) ។

ការខាតបង់ពុំមែនកើតមានតែចំពោះម្ចាស់ដី និងចំពោះកសិករប៉ុណ្ណោះទេ ប៉ុន្តែរដ្ឋក៏ត្រូវខាតបង់ដែរ ពីព្រោះមិនអាចប្រមូលពន្ធលើការទិញលក់ដីភាគច្រើនបាន ។ ទន្ទឹមនឹងនេះ គឺភាពស្របច្បាប់នៃប្រព័ន្ធនៅពេលដែលវាមានលក្ខណៈអសកម្ម ។

## *២.៣.៤ ទំនាស់ដីធ្លី*

គ្មានស្ថិតិជាប្រព័ន្ធស្តីពីស្ថានភាពទំនាស់ទេ ប៉ុន្តែគេមានជំនឿថា ទំនាស់ដីធ្លីកំពុងកើនឡើង ដូចមានបញ្ជាក់ក្នុងកំណត់ត្រារបស់គណៈកម្មការដោះស្រាយទំនាស់ដីធ្លីថ្នាក់ខេត្ត និងប្រព័ន្ធតុលាការជាដើម ។ ទំនាស់ក៏អាចមើលឃើញតាមរបាយការណ៏របស់ប្រព័ន្ធផ្សព្វផ្សាយស្តីពីកសិករមកធ្វើការតវ៉ានៅរដ្ឋសភា អំពីការបាត់បង់ដី ។ អង្កេតធំៗដែលលើកពីខាងដើម ក៏បង្ហាញដែរថា កសិករមួយចំនួនត្រូវបានបណ្តេញចេញពីដីរបស់ខ្លួន ។ ក្នុងស្ថានភាពបែបនេះ លទ្ធភាពកើតមានទំនាស់មានកំរិតខ្ពស់ណាស់ ។

គំរោងខាងដីធ្លីរបស់ Oxfam បានរាយការណ៏ពីករណីទំនាស់ដីធ្លីមិនទាន់ដោះស្រាយបានរវាងកសិករ និងអាជ្ញាធរនៅក្នុងខេត្ត ៥ នៅភាគខាងលិចនៃប្រទេសកម្ពុជាដែលគេបានសិក្សា (Williams 2000) ។ គឺមានទំនាស់ពីព្រំដីដែលមិនបានដោះស្រាយ ហើយក៏មានករណីដីកាន់កាប់មានការជំទាស់តវ៉ាក្នុងតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជាផងដែរ ។ ទំនាស់ដីធ្លីមិនមែនកើតឡើងតែនៅកម្ពុជានោះទេ ប៉ុន្តែឃើញមាននៅគ្រប់ទីកន្លែងក្នុងពិភពលោក ។ បញ្ហាវាផុសឡើងនៅពេលដែល ១. មូលដ្ឋានសំរាប់ធ្វើការដោះស្រាយនៅទន់ខ្សោយ (ដូចជា គ្មានការកសាងឯកសារ) ២. ប្រព័ន្ធច្បាប់មិនច្បាស់លាស់អាចបកស្រាយបានច្រើនយ៉ាង (មានទាំងនីតិវិធីស្មុគស្មាញ និងត្រូវចាយវាយប្រាក់កាសច្រើន) និង/ឬ ៣. កង្វះយន្តការដោះស្រាយទំនាស់ដែលមិនលំអៀង និងសក្តិសិទ្ធិ ។ នេះគឺជាករណីដែលកើតមានជាក់ស្តែងនៅកម្ពុជា ។

នៅក្នុងប្រទេសមួយចំនួន មានការកំណត់គោលនយោបាយច្បាស់លាស់ ស្តីពីការរុះរើផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជន ហើយក្នុងករណីដែលគេត្រូវការដីសំរាប់ប្រើប្រាស់ជាសាធារណៈ (ដូចជាសំរាប់គោលដៅខាងសន្តិសុខ) ភាគីដែលទទួលការប៉ះពាល់ត្រូវធ្វើការផ្លាស់ប្តូរលំនៅស្របតាមបទប្បញ្ញត្តិក្នុងគោលនយោបាយនេះ ។ នយោបាយផ្លាស់ប្តូរលំនៅរបស់កម្ពុជាមិនបានលើកបញ្ហានេះមកដោះស្រាយទេ ។

### *២.៣.៥ ការតាំងទីលំនៅរខេករខាក្នុងទីក្រុង*

តាំងពីទសវត្សរ៍១៩៨០ មកម្លេះ ក្រុងភ្នំពេញគឺជាគោលដៅនៃប្រជាជនចំណាកស្រុកដែលស្វែងរកកន្លែងចិញ្ចឹមជីវិត ។ ពួកគេមិនត្រឹមតែមកពីតាមខេត្តប៉ុណ្ណោះទេ ប៉ុន្តែក៏មានមកពីប្រទេសជិតខាងផងដែរ ។ ប្រជាជនជាច្រើននាក់ បានកាន់កាប់ដីដោយខុសច្បាប់ ហើយប្រមូលផ្តុំជាទីប្រជុំខ្ទមរកេតរកូតនៅលើដីសាធារណៈក្នុងទីក្រុង ។ ប្រការនេះបានកើតមាននៅតាមបណ្តោយដងទន្លេ នៅក្នុងតំបន់មួយចំនួននៅភាគខាងត្បូង និងនៅកន្លែងខ្លះនៃខ័ណ្ឌទួលគោក ។ អាជ្ញាធរបានដឹកប្រជាជនមួយចំនួនចេញពីកន្លែងទាំងនេះ ប៉ុន្តែដោយសារបញ្ហាជីវភាពពួកគេក៏វិលត្រលប់មកវិញ ។ គេប៉ាន់ស្មានថា មានប្រជាជនជាង ១៧៥.០០០នាក់ ដែលរស់នៅក្នុងតំបន់តាំងទីលំនៅខុសច្បាប់ និងតំបន់មានប្រាក់ចំណូលទាបចំនួន ២០កន្លែង ។ ការប្រទាំងប្រទើស រវាងការងាររៀបចំកតំបន់/ការធ្វើឱ្យទីក្រុងមានសោភណភាព និងកិច្ចប្រឹងប្រែងអ្នកតាំងទីលំនៅខុសច្បាប់ ក្នុងការរកចិញ្ចឹមជីវិត គឺជាបញ្ហាមួយគួរឱ្យបារម្ភ ។

ក្របខ័ណ្ឌនៃគោលនយោបាយដីធ្លីថ្មី (ក្នុងនេះកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិគឺជាចំណែកដ៏សំខាន់មួយ) រំពឹងថានឹងជួយផ្តល់ដំណោះស្រាយចំពោះបញ្ហានានាដែលបានលើកឡើង ព្រមទាំងបញ្ហាផ្សេងៗទៀត ។ ប៉ុន្តែ បើសំរេចគោលដៅនេះមិនបានទេ ក្របខ័ណ្ឌថ្មី អាចនៅតែគ្មានប្រសិទ្ធិភាពដូចច្បាប់ភូមិបាលចាស់ដូច្នោះដែរ ។ ការវាយតំលៃខាងសង្គមកិច្ច ព្យាយាមជួយបំភ្លឺចំពោះបញ្ហានីមួយៗ ព្រមទាំងគូសបញ្ជាក់ពីផលប៉ះពាល់ចំពោះកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ ។

## **២.៤. សេចក្តីសង្ខេប**

ទំនាក់ទំនងទីផ្សារ បានប៉ះពាល់កាន់តែខ្លាំងឡើងដល់វិស័យកសិកម្មជីវព្រឹត្តិ ដែលមានឫសគល់ប្រវត្តិសាស្ត្រនៅក្នុងប្រព័ន្ធកសិកម្មយថាផល ។ ប៉ុន្តែកម្ពុជានៅតែជាប្រទេសមានកំរិតពហុកម្មមុខរបរនៅទាបនៅឡើយ ។ ម្យ៉ាងវិញទៀត កម្ពុជាមានប្រជាជនភៀសសឹកដ៏ច្រើនដែលកំពុងស្វែងរកកន្លែងស្នាក់នៅៗឡើយ ។ ប្រការទាំងនេះបានធ្វើអោយមានកំណើនតំរូវការដីធ្លី ។ ជាមួយនឹងការរីកដុះដាលសកម្មភាពទិញលក់ដី ភាពតានតឹងហាក់ដូចបានផុសឡើងរវាងរបៀបរបបខុសៗគ្នានៃការប្រើប្រាស់ដីធ្លី ។ ដូច្នេះកម្មវិធីផ្តល់ប័ណ្ណប្លង់ដី ពិតជាអាចជួយកាត់បន្ថយ និងជួយដោះស្រាយនូវភាពតានតឹងនេះបាន ។

# ជំពូក ៣

# ស្ថានភាពដីធ្លី [១]

## ៣.១ លំនាំនៃការប្រើប្រាស់ដីធ្លី

ក្នុងទសវត្សរ៍១៩៨០ គ្រួសារនីមួយៗប្រើប្រាស់ដីធ្លីជាសំខាន់ដើម្បីធ្វើកសិកម្មសំរាប់ដោះស្រាយការហូបចុករបស់ខ្លួនឯងផ្ទាល់ និងសំរាប់ដោះដូរបន្តិចបន្តួច គឺពុំមែនសំរាប់ទីផ្សារធំទូលាយនោះទេ ។ គេបានប៉ាន់ថា ទំហំដីជាមធ្យមមិនលើសពី ១-១,៥ ហិកតាឡើយ ហើយទិន្នផលមានក៏រិតពី ១,២-១,៥តោនក្នុងមួយហិកតា ។ ទាំងទំហំដីកាន់កាប់តាមគ្រួសារ ទាំងផលិតភាពច្រើនតែមិនអាចបំពេញតំរូវការស្បៀងប្រចាំឆ្នាំក្នុងគ្រួសារបានទេ ។ ម្យ៉ាងវិញទៀត ដីអាចដាំដុះបានជាច្រើន មិនត្រូវបានគេប្រើប្រាស់ទេ ដោយសារមានការវឹកវរក្នុងសង្គម ។ ក្នុងទសវត្សរ៍១៩៨០ កម្ពុជាគឺជាប្រទេសនាំចូលស្បៀងអាហារ ។ ក្នុងតំបន់ជាច្រើន ជាពិសេសកន្លែងជិតប្រភពទឹក និង/ឬជិតតំបន់ព្រៃ, ប្រជាជនបំពេញកង្វះផលស្រូវតាមរដូវរបស់ខ្លួន ដោយការដាំដំណាំក្នុងដីលំនៅដ្ឋាន ការបេះប្រមូលផលិតផលផ្សេងៗពីព្រៃ និងការនេសាទ[២] ។ ជាទូទៅ ដីមានតំលៃទាប នៅពេលដែលមិនទាន់មានតំរូវការដីធ្លីក្រៅពីវិស័យជីវព្រឹត្តិ ដោយសារប្រជាជនមិនសូវមានចលនាផ្លាស់ប្តូរកន្លែង និងមិនសូវមានប្រាក់កាសសំរាប់ទិញដីធ្លី ។ ឧបសគ្គដទៃទៀតចំពោះការអភិវឌ្ឍន៍នៃទីផ្សារដីធ្លីគឺ ក៏រិតដ៏ទាបនៃសេវាអភិវឌ្ឍន៍ជនបទ, កង្វះហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្សេងទៀត, ក៏រិតដ៏ទាបនៃការកសាងធនធានមនុស្ស, និងភាពឯកោយ៉ាងខ្លាំងខាងសេដ្ឋកិច្ច ។ នៅក្នុងបរិយាកាសបែបនេះ កម្មសិទ្ធិដីធ្លី និងការគ្រប់គ្រងដីធ្លី ហាក់មានន័យស្រដៀងគ្នា និងផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់ដីសំរាប់ធ្វើផលិតកម្ម ហើយត្រូវបានទទួលស្គាល់តាមរបៀបរបបជាទំនៀមទំលាប់ពីសំណាក់អ្នករស់នៅជិតខាង និងពីអាជ្ញាធរមូលដ្ឋាន ។ ជាក់ស្តែងការធ្វើឯកជនភាវូបនីយកម្មដីធ្លីនៅឆ្នាំ១៩៨៩ បានឆ្លុះបញ្ចាំងនូវទំនាក់ទំនងជាមូលដ្ឋាន រវាងសិទ្ធិប្រើប្រាស់ និងសិទ្ធិគ្រប់គ្រង/កម្មសិទ្ធិ ពីព្រោះគ្រួសារនីមួយៗ បានទទួលកម្មសិទ្ធិដីធ្លីជាផ្លូវការ ដោយផ្អែកតាមចំនួនសមាជិកគ្រួសារ និងការប្រើប្រាស់ផ្ទៃដីណាមួយ សំរាប់ធ្វើផលិតកម្ម (រហូតដល់ ៥ហិកតា) ។

ចាប់ពីចុងទសវត្សរ៍១៩៨០ នៅពេលមានការបន្ធូរច្បាប់គ្រប់គ្រងលើចលនាផ្លាស់ទីរបស់ប្រជាជន និងការបើកចំហថែមទៀត ចំពោះសេដ្ឋកិច្ចទីផ្សារ និងការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិ លំនាំនៃការប្រើប្រាស់ដីមានការប្រែប្រួលយ៉ាងខ្លាំងនៅតំបន់នានានៅតាមដងផ្លូវសំខាន់ៗ និងនៅក្បែរទីផ្សារក្នុងទីប្រជុំជន ។ ឧទាហរណ៍ នៅស្រុកស្អាង (កណ្តាល) និងស្រុកភ្នំស្រួច (ខេត្តកំពង់ស្ពឺ) ប្រជាកសិករនៅមូលដ្ឋាន កំពុងបោះបង់ចោលការធ្វើស្រែដើម្បីចិញ្ចឹមក្រពះ ដើម្បីចូលបំរើក្នុងទីផ្សារពលកម្មនៅទីក្រុង ឬក៏ធ្វើ *ចំការ* សំរាប់លក់មកឱ្យទីផ្សារនៅភ្នំពេញ ។ នៅពេលធ្វើអង្កេត មានផលដំណាំ និងផលិតផលសត្វចិញ្ចឹម

---

១ ជំពូកនេះផ្អែកទាំងស្រុងទៅលើការចុះសិក្សាដល់ទីកន្លែង នៅក្នុងតំបន់តាំងទីលំនៅទាំង ៦កន្លែង ។

២ តួលេខស្ថិតិបង្ហាញថា នៅកម្ពុជា សាច់ត្រីតំណាងឱ្យរហូតដល់ ៧៥% នៃប្រូតេអ៊ីនដែលប្រជាជនបានទទួលតាមការហូបចុក (Murshid 1997) ។

(សាច់ជ្រូក សាច់មាន់) ច្រើនខ្លាំងណាស់នៅតាមទីផ្សារ ព្រមទាំងគ្រឿងផ្គត់ផ្គង់ទំនើបៗខាងកសិកម្មផង ។ នៅស្រុកពាមរក៍ (ខេត្តព្រៃវែង) កសិករបានបង្កើនផលិតកម្មស្រូវវស្សាសំរាប់លក់មកទីក្រុង តាមរយៈការប្រើប្រាស់ធាតុចូល ដូចជា ជីគីមីជាដើម ។ ប៉ុន្តែក្នុងតំបន់ជាច្រើននៃស្រុកកំពត (ខេត្តកំពត) និងខេត្តរតនគិរី ដែលប្រជាជនដើមមានប្រពៃណីធ្វើកសិកម្មផ្លាស់ទី ពួកគេនៅតែរក្សាលំនាំប្រើប្រាស់ដីធ្លីតាមបែបប្រពៃណីរបស់ខ្លួនប្រហាក់ប្រហែលមុនដដែល ។ គេជឿជាក់ថា ផលិតកម្មសំរាប់លក់ទៅទីផ្សារដែលមានកំរិតលូតលាស់មិនស្មើគ្នានេះ វាក៏កើតមាននៅក្នុងតំបន់ផ្សេងៗទៀតនៃប្រទេសកម្ពុជាដែរ ពីព្រោះមានតែកន្លែងមួយចំនួនប៉ុណ្ណោះដែលធ្លាប់បានពាក់ព័ន្ធនឹងការរីកចំរើននៅខាងក្រៅ ចំណែកឯភាគច្រើនមិនទាន់មានការពាក់ព័ន្ធទេ ។

ការប្រែប្រួលក្នុងការប្រើប្រាស់ដីធ្លីដោយប្រជាជនបានកើតឡើងព្រមគ្នានឹង (ហើយជាក់ស្តែងគឺបណ្តាលមកពី) កំណើនតំរូវការធនធានដីធ្លីពីប្រភពខាងក្រៅសហគមន៍ មានជាអាទិ៍ បុគ្គល ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ ។ ឧទាហរណ៍ នៅស្រុកស្អាង និងភ្នំស្រួច កសិករមូលដ្ឋានជាច្រើននាក់បានលក់ដីលំនៅដ្ឋាន និងដីកសិកម្ម ទៅឱ្យអ្នកមកពីភ្នំពេញដែលមានផលប្រយោជន៍ខាងពាណិជ្ជកម្ម ឬអ្នកទិញផ្សេងទៀតមកទីក្រុងដែរ ដែលគេហៅថា "អ្នកភ្នំពេញ" ។ នៅភ្នំស្រួច កសិករនៅមូលដ្ឋានបានលក់ដីទៅឱ្យកសិករធ្វើពាណិជ្ជកម្មធំៗ ពួកឈ្មួញដី ឬក្រុមហ៊ុនឯកជន ។ នៅរតនគិរី ប្រជាជនមូលដ្ឋានលក់ដីទៅឱ្យជនចំណាកស្រុកមកពីខេត្តដទៃ ហើយអ្នកទាំងនេះ បានចាប់ផ្តើមប្រើប្រាស់ដីធ្លីក្នុងលក្ខណៈអតិផលខុសពីការដាំដុះដោយផ្លាស់ទី ។ នៅភ្នំស្រួច ក្រុមហ៊ុនឯកជនបានទទួលដីកសិកម្មពីយោធាតាមរយៈការផ្តល់សម្បទាន ។ ដូច្នេះ ប្រភពមួយទៀតនៃតំរូវការដី គឺសម្បទានផ្តល់ចំពោះការធ្វើចំការ ការកាប់ឈើ ឬផលិតកម្មកសិកម្មសំរាប់បំរើពាណិជកម្ម ។ ស្ទើរតែគ្រប់ករណី (ក្រៅពីព្រៃសម្បទានចេញ) ការផ្គត់ផ្គង់ដីផុសចេញមកពីវិស័យជីវព្រឹត្តិ ។

នៅភ្នំពេញ លំនាំនៃការប្រើប្រាស់ដីក៏ប្រែប្រួលយ៉ាងច្បាស់ដែរ ។ កាលពីមុនគេចាត់ទុកភ្នំពេញជាក្រុងមួយដែលមានសោភណភាពល្អបំផុតនៅអាស៊ីអគ្នេយ៍ ប៉ុន្តែសព្វថ្ងៃមានប្រជាជនរស់នៅច្រើនជាងពីរដងនៃកំរិតបានគ្រោងទុកក្នុងប្លង់ចាស់ ។ មួយភាគធំនៃប្រជាជនកើនថ្មីបានទៅរស់នៅតាមដងទន្លេ មាត់បឹង ដីសាធារណៈ ចិញ្ចើមថ្នល់ និងនៅតាមតំបន់ជុំវិញទីក្រុង ។ តំរូវការដីក្នុងក្រុងភាគច្រើនមានដំណោះស្រាយជាការចាប់យកដី ការលក់-ទិញដោយខុសច្បាប់ និងការផ្ទេរការប្រើប្រាស់ដីធ្លីពីដីកសិកម្មទៅជាដីលំនៅដ្ឋាន ។

ការផ្លាស់ប្តូរនិន្នាការប្រើប្រាស់ដីធ្លី ធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនពីរឿងសិទ្ធិខាងដីធ្លី ។ ជាទូទៅ នៅក្នុងលក្ខខណ្ឌនៃការដាំដុះជីវព្រឹត្តិ (ដែលដីមានតំលៃថោក) ការគ្រប់គ្រងដីធ្លីផ្អែកជាសំខាន់លើការប្រើប្រាស់ដីជាក់ស្តែងបំរើផលិតកម្ម ហើយការទទួលស្គាល់ និងការអនុវត្តន៍សិទ្ធិនេះ គេធ្វើស្របតាមប្រពៃណី-ទំនៀមទំលាប់នៅមូលដ្ឋាន ។ ប៉ុន្តែនៅពេលដីឡើងថ្លៃ និងក្លាយជាកម្មវត្ថុនៃការលក់ដូរ សិទ្ធិគ្រប់គ្រងកាន់តែផ្អែកច្រើនឡើងទៅលើមធ្យោបាយខាងផ្លូវច្បាប់ដែលរដ្ឋបានទទួលស្គាល់ និងដាក់អនុវត្ត ។ ប្រព័ន្ធពីរផ្សេងគ្នានៃការគ្រប់គ្រង និងកម្មសិទ្ធិដី បានផុសឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់ដែលមានដីធ្លីទិញយកដោយប្រជាជន និងស្ថាប័នមកពីក្រៅសហគមន៍ សំរាប់បំរើគោលដៅក្រៅពីកសិកម្មជីវព្រឹត្តិ ។ *សិទ្ធិនៃការប្រើប្រាស់ដីធ្លី* ត្រូវបានទទួលស្គាល់នៅមូលដ្ឋានដោយប្រជាជនក្នុងសហគមន៍ រីឯ *សិទ្ធិស្របច្បាប់ជាផ្លូវការ* វិញត្រូវបានទទួលស្គាល់ដោយប្រជាជនមកពីក្រៅសហគមន៍ ។ ប៉ុន្តែតាមការពិត ប្រព័ន្ធមិនអាចបែងចែកជាពីរប្រភេទយ៉ាងច្បាស់បានទេ ។ អ្នកដែលទទួលស្គាល់សារៈសំខាន់នៃការមានឯកសារខ្លះ សំរាប់បញ្ជាក់សិទ្ធិលើដីធ្លី ប៉ុន្តែមិនអាច "ទិញ" ក្រដាសស្នាមត្រឹមត្រូវបាន, ក៏បានខិតខំកសាងលិខិតភស្តុតាងផ្សេងៗ ដែលមាំទាំជាងអ្វីដែលគេធ្លាប់អនុវត្តតាមបែបប្រពៃណី ប៉ុន្តែនៅតែមិនទាន់ត្រឹមត្រូវតាមច្បាប់នៅឡើយ ។ អាស្រ័យហេតុនេះ មានកិច្ចសន្យាជាច្រើនប្រភេទ ដែលមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ និងត្រូវបានចុះហត្ថលេខា និងរក្សាទុកដោយអ្នកកាន់កាប់ដីធ្លី ។

## ៣.២ ការផ្ទេរដី និងលទ្ធកម្មដី

សំរាប់ ៤តំបន់ ក្នុងចំណោម ៥តំបន់ជនបទដែលបានសិក្សា មធ្យោបាយជាមូលដ្ឋានក្នុងការទទួលបានដី (ក្រៅពីការបន្តមរតក) គឺការលក់ដី និង "ការចាប់យកដី" ។ មានតែនៅខេត្តកំពតប៉ុណ្ណោះ (តំបន់ទី៥) ដែលមិនសូវមានការលក់ដី ឬផ្ទេរដី គឺឃើញមានតែរបាយការណ៍ពីការទទួលមរតកប៉ុណ្ណោះ ។ ប៉ុន្តែក្រុមស្រាវជ្រាវបានទទួលពត៌មានថា មានការរំលោភយកដីនៅក្នុងស្រុកនានានៅជិតស្រុកកំពត ។

### *៣.២.១ ការលក់ដី*

នៅស្វាង និងនៅភ្នំស្រួច ការលក់ដីពាក់ព័ន្ធជាចំបងទៅនឹងកសិករតូចតាចដែលលក់ដីទៅឱ្យអ្នកភ្នំពេញដែលមករកទិញដីលំនៅដ្ឋាន និង/ឬដីកសិកម្ម សំរាប់ធ្វើ *ចំការ* ឬសំរាប់វិនិយោគទុនកេងយកចំណេញ ។ ក្នុងករណីដីមិនមែនកសិកម្មគោលដៅគឺសំរាប់សាងសង់រោងចក្រ ធ្វើអាជីវកម្ម ឬសង់លំនៅដ្ឋាន ។ នៅរតនគិរី អ្នកមូលដ្ឋានបានលក់ដីទៅឱ្យអ្នកមកពីក្រុងបានលុង ឬអ្នកមកពីតំបន់ទីផ្សារផ្សេងទៀត (ដូចជា អ្នកជំនួញ មន្ត្រីរដ្ឋាភិបាល និងមន្ត្រីយោធា) ។ គេបានលក់ដីទៅអោយជនចំណាកស្រុកមកពីតំបន់នានាដូចជាកំពង់ចាម និងតាកែវផងដែរ ។ នៅក្នុងករណីភាគច្រើន កត្តាជំរុញឱ្យមានការលក់ដីគឺ តំរូវការសាច់ប្រាក់ក្នុងរយៈពេលខ្លីដែលសកម្មភាពកសិកម្មជីវភាពមិនអាចដោះស្រាយបាន ។ ចំពោះការលក់ដីដោយសារមានវិបត្តិ ប្រជាជនបានរាយការណ៍ពីតំរូវការសាច់ប្រាក់សំរាប់ទូទាត់ថ្លៃព្យាបាលជំងឺ (កំពត) និង/ឬសងបំណុលដែលមានការប្រាក់ខ្ពស់ (៣មករក៏) ។ ក្នុងករណីផ្សេងទៀត គេលក់ដីដើម្បីយកប្រាក់ទិញទំនិញប្រើប្រាស់ និង/ឬជួសជុលផ្ទះសម្បែង ។ ប្រជាជនខ្លះគេលក់ដីដើម្បីទៅទិញដីនៅកន្លែងដទៃ និង/ឬវិនិយោគក្នុងមុខរបរមានផលិតភាពខ្ពស់ជាង ដូចជាទិញម៉ូតូសំរាប់ប្រើប្រាស់ក្នុងការងារលក់ដូរ (នៅស្វាង និងកំពត) ។

នៅរតនគិរី មានករណីប្លែកមួយ គឺប្រជាជនបានលក់ដីក្រោយពេលមានការគំរាមកំហែងពីអ្នកទិញមកពីក្រៅ ឬពីភ្នាក់ងាររបស់អ្នកទិញទាំងនោះ ។ ក្នុងករណីនេះ អ្នកស្រុកនិយាយថា ពួកខ្លួនបានសុខចិត្តលក់ដី តាមបណ្តោយផ្លូវក្រោយពេលមានគេមកប្រាប់ថា បើមិនលក់ទេ រដ្ឋនឹងដកហូតយកដីទាំងនោះ ។ ដូច្នេះអ្នកស្រុកក៏គិតថា គួរលក់ដីយកប្រាក់ខ្លះ ពីព្រោះដីទាំងនេះគង់តែរដ្ឋដកហូតយកដដែល ។

### *៣.២.២ ការរំលោភយកដី*

នៅភ្នំស្រួច និងរតនគិរី មានរបាយការណ៍អំពីករណីរំលោភយកដី ។ ទោះបីមានគ្រួសារខ្លះបានទទួលរងគ្រោះក៏ដោយក៏ចំនួនដីរំលោភយកមិនច្រើនដល់ថ្នាក់ប៉ះពាល់ដល់ភូមិទាំងមូលទេ ។ ជាទូទៅ ករណីទាំងនេះជាប់ពាក់ព័ន្ធនឹងបុគ្គល ឬក្រុមហ៊ុនមកពីក្រៅសហគមន៍ ឬខាងយោធាដែលមានធនធាន និងអំណាច ។ ក្នុងតំបន់ទាំងពីរ ការរំលោភយកដីបានកើតឡើងតាមពីររូបភាព ។ ទី១ ការរំលោភយកដីកើតមាននៅក្នុងតំបន់ធ្វើកសិកម្មផ្លាស់ទី ។ ដីប្រភេទនេះគេទុកចោលទំនេរ ប៉ុន្តែនៅមូលដ្ឋានគេទទួលស្គាល់ថា វាជាសម្បត្តិរបស់កសិករជីវភាព និងសហគមន៍ពួកគេ ។ ប៉ុន្តែចំពោះអ្នកមកពីខាងក្រៅដីទុកចោលទំនេរគ្មានការផលិតបែបនេះ គេគិតថាអាចចាប់យកបាន ។ ទី២ ការរំលោភយកដីដែលអ្នកស្រុកកំពុងប្រើប្រាស់ជាក់ស្តែង ប៉ុន្តែគ្មានប័ណ្ណប្លង់ដីសំរាប់បញ្ជាក់ ។ ឧទាហរណ៍យ៉ាងច្បាស់មួយនៃករណីរំលោភយកដីបែបនេះ គឺក្រុមហ៊ុនកូរ៉េមួយបានទទួលដីក្នុងស្រុកភ្នំស្រួចពីយោធា ។ ក្រុមហ៊ុនបានពង្រីកតំបន់គ្រប់គ្រងរបស់ខ្លួន ដោយយកដីកំពុងដាំដុះរបស់ ១០៨គ្រួសារ ដែលមានទាំងដីរបស់ប្រធានភូមិផង ។

ករណីពិសេសមួយនៃការរំលោភយកដីបានកើតឡើងនៅស្វាង ក្នុងនេះយ៉ាងហោចណាស់មានបុគ្គលម្នាក់ដែលគ្រប់គ្រងដីមួយកន្លែងរួចហើយ បានធ្វើវិលងវិធីធម្មតាដែលត្រូវឆ្លងកាត់ប្រធានភូមិ-ឃុំ ដើម្បីសុំលិខិតកាន់កាប់ដី ។ គេបានប្រាប់ថាបុគ្គលនោះមានលទ្ធភាព "បញ្ចុកបន្ស៊ី" ពួកមន្ត្រីនៅថ្នាក់លើអោយចេញប្រកាសថា ដីរបស់ខ្លួនធំជាង ទំហំជាក់ស្តែងរបស់វា

ដើម្បី អោយខ្លួនអាចរំលោភយកដីរបស់អ្នកជិតខាងម្នាក់ ។ ដីធំជាងមុននេះ ត្រូវបានចុះបញ្ជីជាដីមួយប្លង់ គឺបានន័យថាមានការដក ហូតដីមួយផ្នែក ឬដីទាំងអស់របស់អ្នកជិតខាងដែលមិនបានដឹងខ្លួន ។

### *៣.២.៣ ការចាប់យកដី*

ជួនកាល គេបានដីដោយសារការចាប់យកដី ។ ប្រការនេះតាមធម្មតាពាក់ព័ន្ធនឹងកសិករតូចតាច/អ្នកគ្មានដីដែលចាប់យកដីរដ្ឋ ឬដីរបស់ក្រុមហ៊ុនពាណិជ្ជកម្មធំៗ ។ រដ្ឋ បុគ្គលឯកជន និងក្រុមហ៊ុនផ្សេងៗ បានរាយការណ៍ពីករណីជាច្រើននៃការចាប់យកដីដែលអ្នកចូលមកកាន់កាប់បានអះអាងថាជាដីរបស់ខ្លួន ។ នៅស្វាង ជនមាតុភូមិនិវត្តន៍ឆ្នាំ១៩៩២-៩៣ មួយក្រុមកាន់កាប់ដីធ្លីនៅតាមបណ្តោយព្រែកជីកដែលជាដីរបស់រដ្ឋ តែក្រោយមកត្រូវនគរបាលមូលដ្ឋានបណ្តេញចេញពីទីនោះវិញ ។ នៅភ្នំស្រួច ជនចំណាកស្រុកបានកាន់កាប់ដីទំនេរដែលអ្នកភ្នំពេញបានទិញពីអ្នកភូមិ ។ ករណីផ្សេងទៀតនៃការចាប់យកដី គឺមានករណីអ្នកមកបង្កើតជីកសិកម្មនៅក្នុងតំបន់ព្រៃដែលរដ្ឋគ្រប់គ្រង និងករណីជនមាតុភូមិនិវត្តន៍ចាប់យកដីរបស់ក្រុមហ៊ុននៅខេត្តកំពត ។ ប៉ុន្តែករណីចាប់យកដីដែលល្បីសុះសាយខ្លាំងជាងគេ បានកើតឡើងក្នុងក្រុងភ្នំពេញ ដោយសារជនចំណាកស្រុកមកពីតំបន់ជនបទទទួលបាន (ក្រោយការចាប់យកជាក់ស្តែង) នូវសិទ្ធិប្រើប្រាស់ដីសាធារណៈ ដោយបានបង្កើតក្រុមខ្មែរកេតរកូត និងកន្លែងរកស៊ីជាទ្រង់ទ្រាយធំឡើង ។ ការចាប់យកដីនេះ ត្រូវបានសន្មតថា មានលក្ខណៈពាក់កណ្តាលអចិន្ត្រៃយ៍ដោយដីធ្លី និងផ្ទះសម្បែងមានគេទិញលក់ជាប្រចាំ ។

## ៣.៣ ការផ្តល់ប័ណ្ណប្លង់ដី និងប័ណ្ណប្លង់ដី

ពាក្យសុំប័ណ្ណប្លង់ដី មានសរុបជាង ៤លានច្បាប់ ។ ប៉ុន្តែប័ណ្ណប្លង់ដីដែលបានចេញឱ្យជាក់ស្តែងចាប់ពីឆ្នាំ១៩៨៩ មក មានប្រមាណ ៥៤០.០០០ច្បាប់ប៉ុណ្ណោះ ហើយតួលេខនេះក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងតំបន់សិក្សាផងដែរ ។

មន្ត្រីរដ្ឋាភិបាលនៅ DLMUPCC និង OLMUPCL តែងបញ្ជាក់ប្រាប់ថា ប័ណ្ណដែលបានចេញអោយមានចំនួនតិច ពីព្រោះប្រជាជនមិនអោយតំលៃដល់ប័ណ្ណប្លង់ដី និង/ឬមិនដឹងពីនីតិវិធីដើម្បីបានទទួលប័ណ្ណនេះ ។ ផ្ទុយទៅវិញ ប្រជាជនក្នុងតំបន់សិក្សាតែងលើកពីមូលហេតុ ៥ ដែលធ្វើអោយគេមិនបានប័ណ្ណប្លង់ដី ប៉ុន្តែក្នុងនេះប្រជាជនជាច្រើននាក់ក៏មិនបានប្រឹងប្រែងខ្លាំងដែរ ។ ទី១ ប្រជាជនសង្កេតឃើញថា ប័ណ្ណប្លង់ដីជួយសំរួលការលក់ដី (កណ្តាល) ។ ទី២ ពួកគេរៀបរាប់ថា ប័ណ្ណប្លង់ដីមានប្រយោជន៍ក្នុងការសុំឥណទាន (ពាមរក៍) ។ ទី៣ ប័ណ្ណប្លង់ដីជួយសំរួលការកំណត់ព្រំដី និងជួយកាត់បន្ថយទំនាស់ដីធ្លី (ភ្នំស្រួច) ។ ទី៤ ប័ណ្ណប្លង់ដីជួយការពារសិទ្ធិលើដីធ្លីនៅក្នុងតំបន់ខ្លះ (ភ្នំស្រួច) ។ ទី៥ ប័ណ្ណប្លង់ដីជួយសំរួលដល់ក្រុមគ្រួសារក្នុងការផ្ទេរដីធ្លីទៅអោយកូនចៅនៅពេលអនាគត (គ្រប់កន្លែង) ។ ប៉ុន្តែអ្នកភូមិបានប្រាប់ថា តំរូវការចំណាយប្រាក់ និងពេលវេលាច្រើន (ប្រើពេល យូរ និងត្រូវសូកប៉ាន់ច្រើន) គឺជាមូលហេតុចំបងដែលធ្វើអោយពួកខ្លួនមិនបានទទួលប័ណ្ណប្លង់ដី ។ តាមពិតអំនះអំណាងទាំងរបស់ មន្ត្រីរដ្ឋាភិបាល និងរបស់អ្នកកាន់កាប់ដីធ្លី សុទ្ធតែត្រឹមត្រូវមួយចំនែកដូចគ្នា ទោះបីជាពួកគេមានហេតុផលផ្សេងគ្នាក៏ដោយ ។ ការ ពន្យល់បំភ្លឺពីបញ្ហានេះ មានលក្ខណៈស្មុគស្មាញជាងអ្វីដែលមន្ត្រីរដ្ឋាភិបាល ឬប្រជាជនបានបកស្រាយ ។

នៅក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនៃទសវត្សរ៍១៩៨០ មានប្រជាជនជាច្រើនបានដាក់ពាក្យសុំប័ណ្ណប្លង់ដី គឺនៅពេលដែលដីត្រូវបានប្រើប្រាស់ជាចំបងសំរាប់ផលិតកម្មកសិកម្មជីវព្រឹត្តិ ឬសំរាប់លំនៅដ្ឋានក្នុងភូមិ ។ កាលនោះ តំលៃដីនៅថោក ហើយមិនទាន់មានទីផ្សារដីធ្លីអ្វីធំដុំគួរអោយកត់សំគាល់ទេ ។ នៅក្នុងស្ថានភាពបែបនេះ សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី ត្រូវបានគេទទួលស្គាល់ និងដាក់អោយអនុវត្ត ដោយយោងទៅតាមប្រពៃណី និងទំនៀមទំលាប់នៅតាមមូលដ្ឋាន ។ ការអះអាងកម្មសិទ្ធិលើដីធ្លីពឹងផ្អែកលើការព្រមព្រៀងក្រៅផ្លូវការរបស់អ្នកជិតខាង និងអាជ្ញាធរមូលដ្ឋាន ជាជាងការទទួលស្គាល់ជាផ្លូវការពីរដ្ឋ ។

ក្នុងពេលដែលគ្មានទីផ្សារដីធ្លី ហើយដីក៏មានតំលៃតិចតួច ឬគ្មានតំលៃជាទំនិញសំរាប់លក់ដូរប័ណ្ណប្លង់ដីហាក់ដូចមិនសូវតំលៃទេ ។ ស្ថានភាពបែបនេះឃើញមានជាបន្តទៀតនៅក្នុងតំបន់ឆ្ងាយៗជាច្រើននៃប្រទេសកម្ពុជា ដូច្នេះហើយបានជាប្រជាជនជាច្រើននាក់មិនបានប្រឹងប្រែងសុំប័ណ្ណប្លង់ដី ។ ក្នុងន័យនេះ មន្ត្រីរដ្ឋាភិបាលនិយាយត្រូវមួយជ្រុងដែរដែលថាប្រជាជនមិនអោយតំលៃចំពោះប័ណ្ណប្លង់ដី ។ ប៉ុន្តែវាត្រឹមត្រូវជាង បើសិនជា និយាយថា ប្រជាជនមិនឱ្យតំលៃប័ណ្ណប្លង់ដីនៅក្នុងលក្ខខណ្ឌដ៏ជាក់លាក់ ពោលគឺនៅកន្លែងដែលកសិកម្មជីវព្រឹត្តិនៅបន្តអនុវត្តនៅកន្លែងដែលមានសម្ពាធប្រជាសាស្ត្រតិចតួច ឬគ្មានសោះ និងកន្លែងមានសម្ពាធតំរូវការទិញដីតិចតួច ។

លើសពីនេះទៀត សមត្ថភាពរបស់មន្ត្រី DLMUPCC និង OLMUPCL ក្នុងការធ្វើអង្កេតដីធ្លី និងចេញវិញ្ញាបនប័ត្រក៏មានការខ្វះខាតខ្លាំង ដោយសារកង្វះខាតធនធានខាងបច្ចេកទេស បុគ្គលិក និងហិរញ្ញវត្ថុ ។ ដើម្បីប៉ះប៉ូវកង្វះខាតធនធានបេក្ខជនដាក់ពាក្យសុំ ត្រូវបានស្នើឱ្យបង់ "ប្រាក់កំរៃក្រៅផ្លូវការ" ។ ដោយសារយូរទៅកាន់តែអស់សោហ៊ុយច្រើនឡើង ប្រជាជនក៏បានសំរេចចិត្តថា មិនបន្តដំណើរការសុំប័ណ្ណប្លង់ដីទៀតទេ ទោះបីខ្លួនត្រូវបានប័ណ្ណនេះនៅចុងបញ្ចប់ក៏ដោយ[៣] ។ កាលៈទេសៈបែបនេះបានធ្វើឱ្យកសិករតូចតាចភាគច្រើននៅក្នុងតំបន់ដែលមានទីផ្សារដីធ្លីផុសឡើងថ្មីៗ គេពុំមានប័ណ្ណប្លង់ដីទេ ទោះបីបានដាក់ ពាក្យសុំតាំងពីដំបូងក៏ដោយ ។

ប៉ុន្តែគួរកត់សំគាល់ចំណុចសំខាន់មួយថា ក្នុងតំបន់សិក្សាទាំងបួននៅជនបទដែលមានទីផ្សារដីធ្លីផុសឡើង គឺមានកំណើនតំរូវការ ឯកសារទទួលស្គាល់ជាផ្លូវការនូវការអះអាងកម្មសិទ្ធិលើដីធ្លី ដើម្បីសំរួលដល់ការទិញលក់ដីធ្លីផ្សេងៗ ។ នៅក្រុងភ្នំពេញ តំរូវការដីធ្លីបានកើនឡើងយ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំចុងក្រោយ ប៉ុន្តែតំរូវការឯកសារផ្លូវការមិនបានស្ទុះឡើងទេ ពីព្រោះដីធ្លីក្នុងក្រុងមានប័ណ្ណផ្លូវការ សំរាប់បញ្ជាក់ជាយូរមកហើយ ។ ចំពោះការកាន់កាប់ដីមិនស្របច្បាប់ តំរូវការឯកសារទទួលស្គាល់បានផុសឡើង ដោយសារប្រជាជនរស់នៅក្នុងសង្កាត់ក្រីក្របានកសាងសំណង់ជាប់លាប់ ហើយសភាពការណ៍នេះបានធ្វើអោយការបណ្តេញចេញជួបការលំបាកខ្លាំង ។

នៅតំបន់ជនបទ ៤ ដែលបានសិក្សា និងដែលមានកំលាំងទីផ្សារជ្រៀតចូលមួយកំរិត ទំនាក់ទំនងរវាងកំណើនតំរូវការដីធ្លី និងការធ្វើពហុកម្មនៃការប្រើប្រាស់ដី បានធ្វើឱ្យប្រែប្រួលដល់ទស្សនៈរបស់ប្រជាជនស្តីពីសិទ្ធិខាងដីធ្លី ។ ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេដែលគេបានសង្កេតឃើញថា នៅពេលតំលៃដីកើនឡើង ប្រជាជនត្រូវការស្ថាប័នដែលផ្លូវការខ្លាំងជាងមុន សំរាប់បញ្ជាក់ទទួលស្គាល់ និងដាក់អនុវត្តន៍សិទ្ធិខាងដីធ្លីរបស់ខ្លួន ។ ដូច្នេះនៅពេលលំនាំនៃការប្រើប្រាស់ដីធ្លីមានការប្រែប្រួល និងកាន់តែមានលក្ខណៈសំបូណ៌បែបមធ្យោបាយគ្រប់គ្រងដីតាមបែបប្រពៃណី ត្រូវបានជំនួសដោយតំរូវការស្ថាប័នផ្លូវការសំរាប់គ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លីកាន់តែច្រើនឡើង ។ ឧទាហរណ៍ នៅស្អាង និងភ្នំស្រួច ការលក់ដីធ្លីពាក់ព័ន្ធនឹងអ្នកមានដីតិចតួចដែលលក់ដីទៅអោយអ្នកមកពីក្រៅ ហើយតំរូវការប័ណ្ណប្លង់ដីវាផុសចេញពីតំរូវការកាត់បន្ថយចំនោយជាប់ទាក់ទិននឹងការលក់ ។ អ្នកទិញរមែងចង់បានឯកសារអ្វីមួយដែលបង្កើត និងធានាកម្មសិទ្ធិលើដីធ្លី ។ អ្នកទិញត្រូវការប័ណ្ណប្លង់ដីដែលបញ្ជាក់ព្រំដីច្បាស់លាស់ផងដែរ សំរាប់បង្ការទំនាស់ក្នុងពេលអនាគត ។ ប៉ុន្តែនៅកំពត តំរូវការប័ណ្ណប្លង់ដី មានគោលដៅចំបងសំរួលដល់ការបែងចែកដីនៅពេលបន្តមរតក ។ នៅភ្នំពេញ អាជ្ញាធរបានខិតខំគ្រប់គ្រងការរំលោភយកដី តាមរយៈការធ្វើកិច្ចព្រមព្រៀងជាបណ្តោះអាសន្នស្តីពី "សិទ្ធិប្រើប្រាស់" ជាមួយនឹងអ្នកស្នាក់នៅ ។

នៅរតនគិរី និងកំពង់ស្ពឺ ដែលគេដឹងឮច្រើនពីបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការរំលោភយកដី, ប្រជាជនចង់បានប័ណ្ណប្លង់ដីសំរាប់ការពារសិទ្ធិរបស់ខ្លួននៅលើដីធ្លី ។ ប្រជាជនយល់ថា នៅក្នុងបរិបទនៃការកកើតទីផ្សារដីធ្លី និងកំនើនតំលៃដី, ប្រពៃណី

---

៣ គួរកត់សំគាល់ថា តំរូវការប័ណ្ណប្លង់ដីបានផុសឡើងតាំងពីមុនម្លេះ និងកើនខ្ពស់បំផុតក្នុងឆ្នាំ១៩៩៥ ។ ចំណាយច្រើនហួសហេតុ គឺជាមូលហេតុនៃការថយចុះតំរូវការនាពេលបន្ទាប់ ។ មានមូលហេតុផ្សេងខ្លះដែរ ប៉ុន្តែពុំមានបកស្រាយក្នុងឯកសារនេះទេ ។

និងទំនៀមទំលាប់នៅមូលដ្ឋានមិនទាន់គ្រប់គ្រាន់សំរាប់ការពារកម្មសិទ្ធិលើដីធ្លីទេ ។ ប្រជាជនបង្ហាញទឹកចិត្តចង់បានប័ណ្ណប្លង់ដីសំរាប់ប្រើជាមធ្យោបាយសំរួលដល់ការលក់ដី ហើយបាននិយាយថា ដីដែលមានប័ណ្ណបញ្ជាក់រួចហើយ មានតំលៃខ្ពស់ជាងដីដែលមិនទាន់មានប័ណ្ណ ។

យន្តការស្ថាប័នផ្លូវការសំរាប់ផ្តល់ប័ណ្ណប្លង់ដី ដើរមិនទាន់តំរូវការទេ ។ ដូច្នេះហើយ យន្តការស្របគ្នាមួយត្រូវបានប្រើប្រាស់ ដើម្បីឆ្លើយតបនឹងតំរូវការ ។ ឧទាហរណ៍ ការលក់ដីក្នុងពេលបច្ចុប្បន្នត្រូវបានសំរួលតាមរយៈយន្តការពីរ ។ ទី១ នៅក្នុងតំបន់ ដូចជា ស្អាង និងភ្នំស្រួចជាដើម ការទិញលក់ដី ជាទូទៅច្រើនត្រូវបានសំរួលតាមរយៈការផ្ទេរបង្កាន់ដៃទទួលពាក្យសុំប័ណ្ណប្លង់ដី ។ ទី២ នៅរតនគីរី ការលក់ដីត្រូវបានសំរួលតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងអ្នកទិញ និងអ្នកលក់ ។ ក្នុងករណីទាំងពីរនេះ ប្រធានភូមិ (និងមេឃុំផងក្នុងករណីខ្លះ) បញ្ជាក់ទទួលស្គាល់លើកិច្ចសន្យា (ដោយអ្នកទិញត្រូវបង់ប្រាក់កំរៃមួយចំនួនឱ្យ) ដែលធ្វើអោយការទិញ-លក់មានសុពលភាព ។ ក្នុងករណីទាំងពីរនេះ តុលាការ និងគណៈកម្មការដោះស្រាយទំនាស់ដីធ្លី ក៏ទទួលស្គាល់ការទិញ-លក់ថាមានតំលៃស្របច្បាប់សំរាប់បញ្ជាក់សិទ្ធិលើដីធ្លី ទោះបីជាពន្ធលើការលក់ដីមិនទាន់បានទូទាត់នៅឡើយក៏ដោយ ។ នីតិវិធីបែបនេះ មានលក្ខណៈខុសគ្នាខ្លាំងពីសេចក្តីចែងនៅក្នុងច្បាប់ ។ អ្នកទិញមកពីក្រៅសហគមន៍ ក៏អាចកសាងភស្តុតាងបន្ថែមសំរាប់បញ្ជាក់សិទ្ធិលើដីណាមួយដោយធ្វើរបងព័ទ្ធជុំវិញ (ដូចជានៅស្អាង ពាមរក៍ ភ្នំស្រួច) និង/ឬដាំដើមឈើ (នៅខេត្តរតនគីរី) ។ ទោះបីជានៅទីក្រុងភ្នំពេញក្តី ការទិញលក់ដែលផ្អែកលើលិខិតមានសាក្សីបញ្ជាក់ មិនមែនជារឿងចំលែកទេ ។ មានករណីតិចតួចណាស់ដែលអ្នកទិញដាក់ពាក្យសុំកម្មសិទ្ធិជាផ្លូវការស្របតាមនីតិវិធីជាធរមាន ។ ចំនួនប័ណ្ណប្លង់ដីតិចតួចដែលបានផ្តល់ ធៀបនឹងចំនួនទិញលក់ជាក់ស្តែងអាចធ្វើឱ្យគេយល់បានថា សោហ៊ុយចំនាយខ្ពស់ដើម្បីបានប័ណ្ណប្លង់ដី វាជាកត្តារារាំងចំពោះអ្នកទិញជាច្រើន ទោះបីក្នុងករណីនៃការលក់ដោយបង្ខិតបង្ខំ ដូចនៅរតនគីរីក៏ដោយ ។

នៅខេត្តកំពត ដែលលំនាំនៃការប្រើប្រាស់ដីសំរាប់បំរើកសិកម្មជីវព្រឹត្តិគ្មានការប្រែប្រួល ប្រជាជនភាគច្រើនបន្តពឹងផ្អែកលើស្ថាប័នជាប្រពៃណីនៅតាមភូមិ ដើម្បីបញ្ជាក់កម្មសិទ្ធិផ្អែកលើការប្រើប្រាស់ ។ ជាការពិតណាស់ គ្រួសារជាច្រើន ឬទាំងអស់បានទទួលបង្កាន់ដៃទទួលពាក្យសុំប័ណ្ណប្លង់ដី សំរាប់ដីលំនៅដ្ឋាននៅដើមទសវត្សរ៍១៩៩០ ។ ប៉ុន្តែបង្កាន់ដៃត្រូវបាត់បង់ដោយសារអគ្គីភ័យ ហើយក្រោយមកប្រជាជនក៏មិនបានសាកសួរ ឬទាមទារប័ណ្ណប្លង់ដីអ្វីទៀតដែរ ។ ប្រជាជនបញ្ជាក់ថា ខ្លួនចង់បានប័ណ្ណប្លង់ដី ប៉ុន្តែមិនចង់ចំណាយលើសពី ២.០០០-៣.០០០រៀលទេ ។ ប្រការនេះបង្ហាញថា កាលណាដីមានតំលៃទាប គឺគ្មានទីផ្សារដីធ្លីសកម្មទេ ។ ក្នុងស្ថានភាពបែបនេះ ទំនាស់ដីធ្លីមានតិចតួច ឬគ្មានសោះ ដូច្នេះមិនសូវមានតំរូវការប័ណ្ណប្លង់ដីទេ ។

## ៣.៤ ទិដ្ឋភាពនៃតួនាទីបុរស-ស្ត្រី ក្នុងការប្រើប្រាស់ដី និងកម្មសិទ្ធិដីធ្លី

ស្ថានភាពតួនាទីបុរស-ស្ត្រី ពុំមានលក្ខណៈល្អទេ ក្នុងសេណារីយ៉ូនៃដីធ្លីនៅកម្ពុជា ។ វិសមភាពរវាងបុរស និងស្ត្រី នៅក្នុងលទ្ធភាពមានដី និងមានកម្មសិទ្ធិដីធ្លី កំពុងកើនឡើងនៅក្នុងភូមិសិក្សា ។ ក្នុងការសិក្សានេះ គេអាចឃើញយ៉ាងច្បាស់នូវគំលាតរវាងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។ គ្រួសារស្ត្រីមេគ្រួគ្រប់គ្រងដីកសិកម្ម តូចជាងគ្រួសារបុរសមេគ្រួ ទោះបីជាកាលពីដំបូង គ្រួសារទាំងពីរប្រភេទបានទទួលដីពីរដ្ឋក្នុងទំហំដូចគ្នាក្តី ។ ក្រោយពេលបែងចែកដីធ្លីនៅចុងទសវត្សរ៍១៩៨០ គ្រួសារស្ត្រីមេគ្រួ មិនអាចពង្រីកដីកសិកម្មរបស់ខ្លួន ដូចគ្រួសារបុរសមេគ្រួទេ ដោយសារខ្វះកំលាំងពលកម្ម និងសត្វអូសទាញ ។ ជាទូទៅគ្រួសារស្ត្រីមេគ្រួច្រើនងាយរងគ្រោះក្លាយជាអ្នកគ្មានដីធ្លី ជាជាងគ្រួសារបុរសមេគ្រួ ។

ទាក់ទងនឹងកម្មសិទ្ធិដីធ្លី ស្ត្រីមានចំណេះដឹងតិចជាងបុរស អំពីសារៈសំខាន់នៃបង្កាន់ដៃ ប័ណ្ណប្លង់ដី និងឯកសារនានា ។ ស្ត្រីជាភរិយាភាគច្រើន លើកលែងតែស្ត្រីមេគ្រួចេញ មិនដឹងអំពីទំហំដីរបស់គ្រួសារខ្លួនទេ ។ ការរៀនសូត្របានតិចតួចមានចំណែកយ៉ាងធំក្នុងរឿងនេះ ។ ការសិក្សាបានបង្ហាញថា ទោះបីដីកេរ្តិ៍ភាគច្រើនស្ថិតក្នុងឈ្មោះឪពុកម្តាយនៅឡើយក្តី ប៉ុន្តែក្នុង

ចំណោមអ្នកទទួលមរតក គឺកូនប្រុសជាអ្នករក្សាទុកបង្កាន់ដៃ ឬប័ណ្ណប្លង់ដី (ពាមរក៏ ស្អាង កំពត និងភ្នំស្រួច) ។ ដោយឡែក ស្ត្រីតែងមានសិទ្ធិអំណាចខ្សោយ ក្នុងកិច្ចការពារកម្មសិទ្ធិលើដីមរតក ឬដីដែលស្ថិតក្នុងកម្មសិទ្ធិរួមគ្នា ។ ជាញឹកញយណាស់ ស្ត្រីជាភរិយាត្រូវបានបង្ខំឱ្យលះបង់ដីមរតក ដើម្បីដោះបំណុលប្តី (ពាមរក៏) ។

អង្កេតបានរកឃើញថា ប្រព័ន្ធតុលាការទាមទារការចំនាយប្រាក់ច្រើន ហើយគ្រួសារដែលស្ត្រីជាមេគ្រួពុំមានលទ្ធភាពបង់ប្រាក់អោយតុលាការ និងបង់សោហ៊ុយឯទៀតបានទេ ។ ហេតុនេះគ្រួសារស្ត្រីមេគ្រួនានា មិនអាចបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធដោះស្រាយទំនាស់ផ្លូវការទេ ។ លើសពីនេះទៀតដោយសារស្ត្រីច្រើនតែរៀនសូត្របានតិចជាងបុរស ដូច្នេះស្ត្រីតែងត្រូវពឹងផ្អែកលើសាច់ញាតិ និងមិត្តភក្តិ ជាបុរសនៅពេលធ្វើការចរចាជាមួយអាជ្ញាធរ ។ ប្រការនេះធ្វើអោយស្ត្រីត្រូវចំណាយប្រាក់បន្ថែមដែលមិនមែនសុទ្ធតែអាចរកបានរាល់លើកនោះទេ[៤] ។ ដូច្នេះស្ត្រី បញ្ឈប់ការតស៊ូតាមផ្លូវច្បាប់ ហើយបែរមកពឹងផ្អែកលើសច្ចភាព និង ជំនឿជាប្រពៃណីវិញ ដើម្បីលួងចិត្តពីការខាតបង់ ។ ដោយសារឥណទាន និងទីផ្សារផ្សេងៗ នៅទន់ខ្សោយជាញឹកញយណាស់ គ្រួសារអ្នកស្រែត្រូវប្រឈមមុខនឹងស្ថានភាពអស់សង្ឃឹម ដែលបណ្តាលមកពីបំណុលមានការប្រាក់ខ្ពស់ គ្រោះធម្មជាតិ និងការ ឡើងចុះថ្លៃស្រូវអង្ករមិនអាចស្មានត្រូវ ។ ស្ថានភាពបែបនេះបង្ខំអោយមានការលក់ដីដោយទាល់ច្រក ។ គ្រួសារស្ត្រីមេគ្រួ ច្រើន ងាយរងគ្រោះរហូតអស់ដីធ្លី ពីព្រោះការប្រាក់មានកំរិតខ្ពស់ពេក ។ ពួកគេច្រើនខ្វះកំលាំងពលកម្ម សត្វអូសទាញ និងប្រាក់ទិញជី ដូច្នេះអ្វីៗទាំងអស់ត្រូវតែទិញជឿ ។

## ៣.៥ អំពីតុល្យភាពរវាងប្រជាជន និងធនធាន

គេមានជំនឿជាទូទៅថា កម្ពុជាមានដីគ្រប់គ្រាន់ ដូច្នេះយុទ្ធសាស្ត្រចិញ្ចឹមជីវិត ត្រូវតែកំណត់ផ្សេងពីប្រទេសជាច្រើនទៀត ។ ទស្សនកិច្ចតាមភូមិបានបង្ហាញថា ដីកសិកម្មក្នុងមួយគ្រួសារ គឺតូចទេ (០,៥០-១,០ហិកតានៅកំពត, ០,៧៥-១,២៥ហិកតានៅស្អាង, ១,៥០-២,០ហិកតានៅពាមរក៏...) ប៉ុន្តែកសិករនៅតែមិនអាចប្រើប្រាស់ដីអោយបានពេញលេញ ដោយសារខ្វះធាតុចូល ដូចជា សត្វអូសទាញ និងឥណទានសំរាប់ទិញធាតុចូលផ្សេងទៀត ។ សន្តិសុខសេដ្ឋកិច្ចក្នុងគ្រួសារត្រូវប៉ះពាល់ថែមទៀត ដោយសារការថយចុះនៃធនធានទ្រព្យរួម ដូចជា ព្រៃ និងផលនេសាទ ។ លទ្ធភាពទាំងនេះនឹងមានកំហិតបន្ថែមទៀត នៅពេលព្រំប្រទល់ដីព្រៃត្រូវបានកំណត់ជាក់លាក់ជាផ្លូវការ ។

កិច្ចប្រឹងប្រែងរបស់ប្រជាជនមួយចំនួនក្នុងការលក់ដី ដើម្បីទិញម៉ូតូ ឬទូកសំរាប់ការងារជួញដូរ ឬដើម្បីធ្វើដំណើរទៅកាន់ តំបន់ទីក្រុង គឺជាកិច្ចប្រឹងប្រែងយ៉ាងអាសន្នសំដៅគេចឱ្យផុតពី "អន្ទាក់ដីធ្លី" ។ ក្នុងន័យនេះ កម្មវិធីផ្តល់ប័ណ្ណប្លង់ដីតែមួយមុខ មិនអាចជួយកែលំអជីវភាពប្រជាជននៅជនបទបានសក្តិសិទ្ធិទេ បើសិនក្នុងការធ្វើប្រពលវប្បកម្មកសិកម្ម គេពុំបានបង្កើតបណ្តាញ ផ្គត់ផ្គង់ធាតុចូលទៅតាមថ្លៃប្រកួតប្រជែង និងទីផ្សារមានស្ថិរភាពល្អសំរាប់បញ្ចេញលក់ផលិតផលទេ ។ ដូច្នេះហើយ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទដែលជួយសំរួលដល់វិនិយោគឯកជនក្នុងការបង្កើនផលិតភាពដីធ្លី និងការធ្វើឱ្យសំបូណ៌បែបនូវចំនួនមុខរបរ គឺជាការសំខាន់ ។

## ៣.៦ សេចក្តីសង្ខេប

៤ ក្នុងករណីក្រុមហ៊ុនកូរ៉េរំលោភយកដីពី ១០៨គ្រួសារនៅភ្នំស្រួច ពួកស្ត្រីមេគ្រួដែលឆ្លើយសំភាសន៍បានសារភាពថា ចង់ឈប់តវ៉ាហើយនៅពេលបណ្តឹងឡើងទៅដល់ស្រុក បើសិនជាធ្វើដូច្នេះវាមិនចោទបញ្ហាដល់សហគមន៍ទាំងមូលទេ ។ នៅខេត្តកណ្តាល ស្ត្រីមេគ្រួសារម្នាក់ដែលដីចំការគាត់ត្រូវអ្នកជិតខាងជាមន្ត្រីថ្នាក់ខេត្តម្នាក់រំលោភយកបានឈប់ប្តឹងតវ៉ាពីព្រោះគ្មានប្រាក់សំរាប់ប្តឹងបន្តទៅថ្នាក់ខ្ពស់ទៀត ។

ទីផ្សារដីធ្លីមានសកម្មភាពខ្លាំងបំផុតនៅក្នុងតំបន់នានាតាមដងផ្លូវ ជិតទីប្រជុំជន និងទីផ្សារ ។ ក្នុងតំបន់ទាំងនេះ ឯកសារផ្លូវការបញ្ជាក់កម្មសិទ្ធិដីធ្លីមានតំរូវការខ្ពស់បំផុតដើម្បីសំរួលដល់ការផ្ទេរដីធ្លី ការបញ្ជាក់ព្រំដី និងការបង្ការទំនាស់ជាមួយអ្នកទាមទារសិទ្ធិជាយថាហេតុ ។ ប៉ុន្តែ ដោយសារប័ណ្ណប្លង់ដីមានតំលៃខ្ពស់ ការទិញលក់ដីជាច្រើនត្រូវបានសំរួលនៅរដ្ឋបាលថ្នាក់ក្រោម តាមរយៈការផ្ទេរបង្កាន់ដៃពាក្យសុំ ឬកិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងអ្នកទិញ និងអ្នកលក់ ។ ដូច្នេះហើយមានតែអ្នកមានធនធានហិរញ្ញវត្ថុ និងមានទំនាក់ទំនងគ្រប់គ្រាន់ទេ ដែលមានលទ្ធភាព និងចង់បានប័ណ្ណប្លង់ដី ។ នៅកន្លែងគ្មានទីផ្សារដីធ្លី ជាពិសេសនៅតំបន់មានប្រព័ន្ធកសិកម្មជីវព្រឹត្តិ តំបន់ឆ្ងាយពីផ្លូវថ្នល់ ទីក្រុង ឬទីផ្សារ ប្រជាជនពឹងផ្អែកលើបង្កាន់ដៃ ឬលើស្ថាប័នសង្គមនៅមូលដ្ឋាន ដើម្បីបញ្ជាក់ពីសិទ្ធិប្រើប្រាស់ដី ។

ការវិភាគខាងលើ បានបង្ហាញពីពួកអ្នកពាក់ព័ន្ធនឹងដីធ្លីដែលមានសកម្មភាពរស់រវើក និងមានរូបភាពខុសៗគ្នាទៅតាមតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ។ ក្នុងប្រវត្តិសាស្ត្រ អ្នកពាក់ព័ន្ធដំបូងគេគឺ កសិករដែលអនុវត្តតាមប្រពៃណីផ្ទាល់របស់ខ្លួន រហូតដល់ពេលត្រូវបង្ខំអោយមានការផ្លាស់ប្តូរ ។ អ្នកពាក់ព័ន្ធថ្មីបានផុសឡើងជាបន្តបន្ទាប់ ហើយតទៅមុខទៀត ប្រភេទនិងចំនួនពួកនេះ ក៏មិននៅដដែលដូចសព្វថ្ងៃដែរ ។ ក្នុងន័យទូលាយ ផលប្រយោជន៏ខាងពាណិជ្ជកម្ម និងឧស្សាហកម្មដែលតំណាងដោយអ្នកជំនួញ គឺជាក្រុមមួយ ។ ក្រុមទី២ គឺពួកមន្ត្រីយោធា និងអាជ្ញាធរស៊ីវិលដែលមានអំណោចខាងហិរញ្ញវត្ថុ និងនយោបាយ ហើយដែលយកចិត្តទុកដាក់ក្នុងការបង្កើនទ្រព្យធន តាមរយៈការទិញលក់កេញយកចំណេញ ក៏ដូចជាការប្រើប្រាស់ដីធ្លី ក្នុងលក្ខណៈពាណិជ្ជកម្ម ។ ក្រុមទី៣ រួមមាន ជនចំណាកស្រុក ជនមាតុភូមិនិវត្តន៏ និងប្រជាជនដាច់ឫសគល់ដែលផ្លាស់ទីចុះឡើងក្នុងប្រទេសដើម្បីស្វែងរកកន្លែងជ្រកកោន និងចិញ្ចឹមជីវិត ។ ក្រុមនេះមានកំលាំងខាងហិរញ្ញវត្ថុ និងនយោបាយតិចតួច ប៉ុន្តែវត្តមានរបស់ពួកគេ ក៏មានទំងន់គួរកត់សំគាល់ដែរ[៥] ។

---

៥ ឯកសារនេះមិនបានវែកញែកពិភាក្សាពីតំបន់មានមីនទេ ដោយសារភូមិសិក្សាជាតំបន់គ្មានមីន ។ ប៉ុន្តែមីនជាបញ្ហាចំបងមួយនៅកម្ពុជា ។ យោងតាម CMAC ប្រមាណជា ១,៧% នៃផ្ទៃប្រទេសមានគ្រាប់មីន ហើយភាគច្រើនគឺជាដីមានផលិតភាព ។ សកម្មភាពដោះមីនកំពុងធ្វើបន្ត ។ នៅពេលដោះមីនរួចដីទាំងនេះមានតំរូវការច្រើនណាស់ ពីព្រោះវាមានផលិតភាពខ្ពស់ ហើយវាបានទាក់ទាញអ្នកពាក់ព័ន្ធជាច្រើន ។ ការបែងចែកដីធ្លីដោះមីនរួចមានបញ្ហាចោទជាច្រើន ។ របាយការណ៏របស់ Halo Trust និង Mines Awareness Group (NGOs ធ្វើសកម្មភាពសំអាតគ្រាប់មីន) បានបញ្ជាក់ពីរឿងនេះ ។

# ជំពូក ៤

# រចនាសម្ព័ន្ធអភិបាលកិច្ចដីធ្លី [១]

## ៤.១ សេចក្តីផ្តើម

មុននឹងពិភាក្សាលំអិតអំពីការគ្រប់គ្រងដីធ្លី និងប្រព័ន្ធផ្តល់កម្មសិទ្ធិ មានចំណុចមួយស្តីពីការបែងចែកដីនៅឆ្នាំ១៩៨៩ ដែលត្រូវលើកមកបញ្ជាក់ ។ ការបែងចែកដីនៅចុងទសវត្សរ៍១៩៨០ មួយចំណែកគឺជាការទទួលស្គាល់ស្ថានភាពជាក់ស្តែងនៃដីធ្លី ដែលប្រជាជនបានគ្រប់គ្រងរួចទៅហើយនៅក្នុងប្រព័ន្ធក្រុមសាមគ្គី ទោះបីនៅពេលនោះមានការបែងចែកដីថ្មីខ្លះដែរក៏ដោយ ។ កម្ពុជាទើបងើបចេញផុតពីរយៈពេលមួយទសវត្សរ៍កន្លះនៃរបបផ្សេងៗខាងកសិកម្មសមូហភាព និងកសិកម្មសហករណ៍ ហើយប្រជាជន ក៏ដូចជារដ្ឋអំណាច មិនបានទទួលស្គាល់ ឬអនុវត្តគោលការណ៍ស្តីពីកម្មសិទ្ធិឯកជនឯកភាពគ្នាទេ ។ ដូច្នេះនៅពេលបែងចែកដីរួច (កម្មសិទ្ធិដីឯកជនក៏ត្រូវបានទទួលស្គាល់) គឺពុំទាន់មានការកំណត់ព្រំដីមួយប្លង់ៗអោយបានច្បាស់នៅឡើយទេ ។ អាជ្ញាធរពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើការងារនេះទេ[២] ហើយប្រជាជនធម្មតាក៏មិនបានដឹងពីតំរូវការព្រំដីជាក់លាក់ ដោយសារពួកគេមិនចេះអក្សរ ហើយក៏មិនធ្លាប់ជួបបញ្ហាខាងផ្លូវច្បាប់ ។ ដូចមានអធិប្បាយក្នុងជំពូក៥ ព្រំដីមិនច្បាស់លាស់នេះ អាចក្លាយជាប្រភពនៃវិវាទ ។

## ៤.២ ប្រព័ន្ធផ្តល់កម្មសិទ្ធិ

នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធចុះបញ្ជីដីធ្លី និងផ្តល់ប័ណ្ណប្លង់ដី មានលក្ខណៈខុសប្លែកពីប្រព័ន្ធក្នុងប្រទេសផ្សេងៗទៀតជាច្រើន ។ ឧទាហរណ៍ អាជ្ញាធរតែមួយទទួលបន្ទុកចុះបញ្ជីទាំងដីកសិកម្មផង និងដីលំនៅដ្ឋានផង, ទាំងដីនៅតាមជនបទ និងដីនៅទីក្រុង ។ ចាប់ពីឆ្នាំ១៩៨៩-៩៤ នាយកដ្ឋានសុរិយោដី មានទីតាំងនៅក្នុងក្រសួងកសិកម្ម ។ មន្ទីរសុរិយោដីខេត្ត និងការិយាល័យសុរិយោដីស្រុក គឺជាអ្នកអនុវត្តកិច្ចការនេះ ហើយអភិបាលខេត្តមានសមត្ថកិច្ចសំរេចអារកាត់លើការចេញប័ណ្ណកម្មសិទ្ធិសំរាប់ដីកសិកម្ម និងដីលំនៅដ្ឋានចុងក្រោយគេ ។ ចាប់ពីឆ្នាំ១៩៩៥-៩៨ នាយកដ្ឋាសុរិយោដី បានប្តូរទៅនៅក្រោមក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយសមត្ថកិច្ចចុងក្រោយក៏ត្រូវបានផ្ទេរពីអភិបាលខេត្ត ទៅប្រធាននាយកដ្ឋានសុរិយោដី ។ នៅក្នុងឆ្នាំ១៩៩៨ នាយកដ្ឋានសុរិយោដី (ឥឡូវហៅថា អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ត្រូវបានផ្ទេរម្តងទៀតទៅនៅក្រោមក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម និងសំណង់ ។ ភារកិច្ចចំបងមួយរបស់ក្រសួងនេះ គឺការធ្វើអង្កេតគ្រប់ជ្រុងជ្រោយ គូសផែនទី និងចុះបញ្ជីដីធ្លីទាំងអស់នៅក្នុងប្រទេស ។

---

១ ជំពូកនេះផ្អែកលើបទសំភាសន៍ជាមួយក្រុមនានានៅតាមភូមិ មន្ត្រីភូមិ-ឃុំ មន្ត្រីទទួលបន្ទុកផ្តល់កម្មសិទ្ធិនៅថ្នាក់ខុសៗគ្នា និងអាជ្ញាធរខេត្ត ។

២ ការិយាល័យសុរិយោដីកណ្តាល បានបញ្ជាក់យ៉ាងដូច្នេះ ។

នៅក្នុងគោលនយោបាយបច្ចុប្បន្ន យន្តការផ្លូវការនៃការផ្តល់ប័ណ្ណប្លង់ដី និងការចុះបញ្ជីដីធ្លី មានដូចតទៅ:

## ប្រអប់ ៤.១. ដំណើរការផ្តល់ប័ណ្ណប្លង់ដីដោយចោះៗនៅកម្ពុជា[៣]

១. អ្នកស្នើសុំធ្វើពាក្យសុំតាមគំរូស្តង់ដាមួយ ដាក់ជូនទៅប្រធានឃុំរបស់ខ្លួន ។ ពាក្យសុំដែលបានបំពេញសព្វគ្រប់ ត្រូវបានចុះបញ្ជាក់ដោយប្រធានឃុំ និងបញ្ជូនទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល (OLMUPCL) នៅថ្នាក់ស្រុក ។ ម្ចាស់ដីបានទទួលបង្កាន់ដៃមួយ ចំពោះការដាក់ពាក្យសុំរបស់ខ្លួន ។

២. អនុគណៈកម្មការមួយត្រូវបានបង្កើតឡើង ដោយមានមេឃុំជាប្រធាន, ប្រធានភូមិ (នៃភូមិអ្នកដាក់ពាក្យសុំ) មន្ត្រីមួយនាក់ ឬពីរនាក់នៃ OLMUPCL (ថ្នាក់ស្រុក) និងចាស់ព្រឹទ្ធាចារ្យម្នាក់ដែលមកពីសហគមន៍ ហើយមានចំណេះដឹង និងមានគេគោរពរាប់អាននៅក្នុងភូមិជាប់ពាក់ព័ន្ធ ។

៣. ដោយមានការពិគ្រោះជាមួយអ្នកដាក់ពាក្យសុំ អនុគណៈកម្មការកំណត់កាលបរិច្ឆេទសំរាប់ធ្វើអធិការកិច្ច ។ ម្ចាស់ដីដែលនៅជិតខាងអ្នកដាក់ពាក្យសុំក៏ត្រូវបានអញ្ជើញមកបញ្ជាក់ និងឯកភាពទៅវិញទៅមកអំពីព្រំដីនៅក្នុងដំណើរការវាស់វែង ។

៤. មុនពេលចុះទៅពិនិត្យ មានសេចក្តីប្រកាសមួយ (ធ្វើឡើងដោយអភិបាលស្រុក) អំពីគោលបំណងរបស់បេក្ខជនអ្នកដាក់ពាក្យសុំដើម្បីសុំប័ណ្ណប្លង់ដីលើដីធ្លីរបស់ខ្លួន ។ សេចក្តីប្រកាសទុករយៈពេល ១០-១៥ថ្ងៃ សំរាប់ឱ្យភាគីមានជាប់ទាក់ទិនណាមួយ ដើម្បីធ្វើការជំទាស់នឹងពាក្យសុំ ។ សេចក្តីប្រកាសនេះត្រូវបានបិតផ្សាយនៅទីតាំងដី ឬនៅជិតទីនោះ (ឧទាហរណ៍ នៅក្នុងភូមិ ឬនៅការិយាល័យឃុំ ឬនៅការិយាល័យស្រុកដែលពាក់ព័ន្ធ) ។

៥. នៅក្នុងអំលុងពេលចុះពិនិត្យ បេក្ខជនត្រូវដោតបង្គោលនៅត្រង់កន្លែងសមស្រប ដើម្បីកំណត់ព្រំដី និងទ្រង់ទ្រាយដីរបស់ខ្លួនផងដែរ ។ ក្នុងដំណាក់កាលនេះ អ្នកជិតខាងអាចលើកការជំទាស់បាន ប្រសិនបើមាន ។ អង្កេតដីធ្លី ត្រូវបានបញ្ចប់ នៅពេលដែលមានការពេញចិត្តលើការដៅព្រំដីរួច ។ មានគំរូពាក្យមួយដែលត្រូវបំពេញ ហើយត្រូវបញ្ជាក់ដោយអ្នកជិតខាង និងសមាសភាពនៅក្នុងអនុគណៈកម្មការ ។ មានការកត់ត្រានូវសាវតារបស់បេក្ខជន ពតិមានលំអិតអំពីគ្រួសារ និងវិធីនៃការបានទទួលដីមកកាន់កាប់ (ឧទាហរណ៍ បន្តមរតក ទិញ) ។ មានការកត់ត្រាដំណាំ ឬសំណង់លើដីនោះផងដែរ ។ ក្នុងករណីមានអ្នកជិតខាងមួយ ឬច្រើនជាស្ថាប័នរដ្ឋ គឺត្រូវអញ្ជើញអ្នកតំណាងនៃស្ថាប័ននោះ មកចូលរួមធ្វើអធិការកិច្ចព្រំដី ។

៦. ក្នុងករណីមានទំនាស់ជាប់ទាក់ទងនឹងពាក្យសុំរបស់បេក្ខជន កិច្ចការខាងលើត្រូវផ្អាកសិន រហូតទាល់តែមានដំណោះស្រាយរួចរាល់ ។ បើគ្មានទំនាស់ទេ គំរូពាក្យនោះ ត្រូវបានចុះហត្ថលេខាដោយមេឃុំក្នុងសមត្ថកិច្ចខ្លួនជាប្រធាន ហើយបញ្ជូនទៅកាន់ OLMUPCL ថ្នាក់ស្រុកដោយមានចំណារសុំឱ្យចេញប័ណ្ណប្លង់ដី ។ បន្ទាប់មក ឯកសារពាក់ព័ន្ធត្រូវបានបញ្ជូនទៅអភិបាលស្រុក ។

៧. ក្នុងករណីនៃដីកសិកម្ម អភិបាលស្រុកអាចផ្តល់ការឯកភាពឱ្យចេញប័ណ្ណប្លង់ដី បើសិនខ្លួនពេញចិត្តហើយ ។ អភិបាលស្រុកអាចកោះហៅឱ្យមានការបញ្ជាក់ពីអ្នកពាក់ព័ន្ធ បើសិនមានការចាំបាច់ ។ នៅក្នុងករណីដីលំនៅដ្ឋាន ប្រធានការិយាល័យសុរិយោដីថ្នាក់ស្រុកលើកអនុសាសន៍ជូនអភិបាលស្រុក សំរាប់ការពិនិត្យផ្ទៀងផ្ទាត់ ហើយអភិបាលស្រុកបញ្ជូនករណីនោះ ទៅកាន់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី (DLMUPCC) ថ្នាក់ខេត្ត ។ មន្ទីរនេះដាក់ឯកសារបញ្ជូនទៅអភិបាលខេត្ត ដើម្បីសុំការឯកភាពជាចុងក្រោយ រួចហើយចេញប័ណ្ណប្លង់ដី ។

៨. ដំណើរការមិនមែនចប់នៅត្រឹមនេះទេ ។ នៅក្នុងករណីដីកសិកម្ម OLMUPCL ថ្នាក់ស្រុក បញ្ជូនសំណុំរឿងទៅកាន់ DMLUPCC ថ្នាក់ខេត្តដែលបញ្ជូនបន្តទៅអាជ្ញាធរថ្នាក់មជ្ឈិម (ការិយាល័យសុរិយោដីនៃ MLMUPC) ដើម្បីពិនិត្យពីភាពស្របច្បាប់ និងពិនិត្យមើលថាតើនីតិវិធីទាំងឡាយត្រូវបានប្រតិបត្តិតាមត្រឹមត្រូវដែរឬទេ ។ ក្នុងករណីដីលំនៅដ្ឋាន អាជ្ញាធរខេត្តបញ្ជូនសំណុំបែបបទមកកាន់អាជ្ញាធរមជ្ឈិម (ការិយាល័យសុរិយោដីនៃ MLMUPC) ដើម្បីត្រួតពិនិត្យពីនីតិវិធី និងភាពស្របច្បាប់ដូចគ្នា ។ នៅក្នុងករណីទាំងពីរនេះ ប័ណ្ណប្លង់ដីត្រូវបានចេញឱ្យនៅក្រោយពេលដែលការិយាល័យសុរិយោដីកណ្តាលបានផ្ទៀងផ្ទាត់នីតិវិធី និងលក្ខណៈស្របច្បាប់ រួចចុះពតិមានលំអិតនៃករណីនោះនៅក្នុងបញ្ជីកម្មសិទ្ធិអចលនទ្រព្យ ។ សំណុំឯកសារមួយ ត្រូវបានបង្កើតនៅការិយាល័យសុរិយោដីកណ្តាល សំរាប់ដីនីមួយៗដែលមានចេញប័ណ្ណប្លង់ដី ។

*ប្រភព: សំភាសន៍ជាមួយមន្ត្រី និងជាមួយ van Acker (1999) ។*

៣ ខុសពីការចុះបញ្ជីដោយចោះៗ ការចុះបញ្ជីជាប្រព័ន្ធអនុវត្តតាមជំហានខុសគ្នា (ពតិមានលំអិតក្នុង RGC 2000) ។

ប្រអប់៤.១ បង្ហាញថា ដំណើរការផ្តល់ប័ណ្ណប្លង់ដីចោះៗ ទោះបីអាចបានសព្វគ្រប់ក៏ដោយ ក៏ត្រូវការពេលច្រើនណាស់ ។ ដំណើរការក៏ជាប់ពាក់ពន្ធ័ដល់មន្ត្រីនៅមូលដ្ឋាន និងនៅថ្នាក់ជាតិដែរ[៤] ។ ក្នុងការផ្ទេរកម្មសិទ្ធិ មានការចូលរួមពីនាយកដ្ឋានពន្ធដារក្រៅពីនេះ ដំណើរការនៅដូចគ្នាដដែល ។ មានមនុស្សជាច្រើននៅមូលដ្ឋាននិយាយថា ការផ្តល់ប័ណ្ណប្លង់ដីធ្លី និងដំណើរការចុះបញ្ជី ទាមទាររយៈពេលវែងហួសពេក ហើយងាយរងគ្រោះដោយសារអំពើពុករលួយរបស់មន្ត្រីនៅគ្រប់ថ្នាក់ ពីព្រោះមន្ត្រីរដ្ឋាភិបាល មានប្រាក់ខែទាបងាយធ្លាក់ខ្លួនទទួលយកជំនួយឧបត្ថម្ភផ្សេងៗ ជាថ្នូរនឹងការជួយជ្រោមជ្រែងតបវិញ ។ ពួកមន្ត្រីរឹតតែងាយធ្វើ ដូច្នេះបាន ដោយសារនីតិវិធីមានច្រើនដំណាក់ និងស្មុគស្មាញ ។ ការកកើតឈ្មួញកណ្តាលជួយរត់ការដើម្បីជាថ្នូរនឹងប្រាក់កំរៃ ក៏ពុំមែនជារឿងប្លែកដែរ ។ បញ្ហានេះហើយគឺជាចំណុចដែលមានការត្អូញត្អែរជាទូទៅនៅស្អាង និងពាមរក៍ ។

ដំណើរការចុះបញ្ជីមួយចប់ គួរមានតំលៃជាផ្លូវការពី ១៥.០០០ ទៅ ២០.០០០រៀល (ប្រហែលពី ៤ ទៅ ៥ដុល្លារ) ។ ប៉ុន្តែ ក្រុមស្រាវជ្រាវបានទទួលដំណឹងថា ប័ណ្ណប្លង់ដីនីមួយៗអាចត្រូវចំណាយជាក់ស្តែងរហូតដល់ ៣០០-៤០០ដុល្លារ ដែលភាគច្រើនត្រូវទូទាត់ក្នុងទំរង់ជាសោហ៊ុយ និងជំនូនក្រៅផ្លូវការ ។ នៅក្រុងភ្នំពេញ ចំណាយកាន់តែខ្ពស់ថែមទៀត ។ មូលហេតុមួយគឺរដ្ឋមិនបានជួយទ្រទ្រង់ខាងហិរញ្ញវត្ថុសំរាប់ចំណាយប្រតិបត្តិការទេ ។ ជាលទ្ធផល ចំណាយធ្វើដំណើរទៅផ្ទៀងផ្ទាត់ និងចំណាយដទៃទៀត ត្រូវរ៉ាប់រងដោយភាគីពាក់ព័ន្ធ ។ ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលការផ្តល់ប័ណ្ណប្លង់ដីបានត្រឹមប្រហែល ១៣-១៤% នៃដីធ្លីជាកម្មវត្ថុនៃការដាក់ពាក្យសុំប្រហែល ៤ ទៅ ៥លានច្បាប់របស់ប្រជាជននៅដើមទសវត្សរ៍១៩៩០ ។

ការត្អូញត្អែរធំមួយទៀតដែលក្រុមស្រាវជ្រាវក្តាប់បាន គឺជាប់ទាក់ទងនឹងការប្រែប្រួលនីតិវិធី ។ គ្រប់ៗគ្នាដឹងថា ដីនៅកម្ពុជាគ្មានគូសផែនទីទេ ដូច្នេះវាពិបាកពិតមែនក្នុងការចុះបញ្ជីឱ្យបានត្រឹមត្រូវដោយគ្មានផែនទីប្រើប្រាស់ ។ ប៉ុន្តែអ្វីដែលរំខានគ្រប់គ្នានោះ (ប្រជាជន តំណាងស្ថាប័នសាធារណៈ និងមន្ត្រីថ្នាក់ក្រោម) គឺការកែប្រែនីតិវិធីម្តងហើយម្តងទៀត (ស្អាង កំពត ពាមរក៍ ភ្នំពេញ) ។ រហូតមកដល់ឆ្នាំ១៩៩២ នីតិវិធីចុះបញ្ជីត្រូវបញ្ចប់នៅត្រឹមថ្នាក់ខេត្ត ។ នៅក្នុងករណីដីកសិកម្ម អាជ្ញាធរដែលពាក់ព័ន្ធ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ហើយក្នុងករណីដីលំនៅដ្ឋាន គឺអាជ្ញាធរស្រុក និងខុទ្ទកាល័យអភិបាលខេត្ត ។ បន្ទាប់មកការគ្រប់គ្រងត្រូវបានផ្ទេរទៅឱ្យទីស្តីការគណៈរដ្ឋមន្ត្រី គឺរហូតដល់ពេលក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ (MLMUPC) បានកើតឡើងនៅចុងទសវត្សរ៍១៩៩០ ។ ប័ណ្ណប្លង់ដីដែលបានចេញអោយកាលពីមុន មានទំរង់ខុសគ្នា និងមានបញ្ជាក់ខុសពីប័ណ្ណប្លង់ដីបច្ចុប្បន្ន ។ កម្មវិធីផ្តល់ប័ណ្ណប្លង់ដីជាប្រព័ន្ធដែលបានស្នើឡើង គឺជាការកែប្រែលើកទី៣ ហើយប្រជាជនភាគច្រើន ក៏ដូចជាមន្ត្រីរាជការ (ក្រៅពី MLMUPC) មិនទាន់ដឹងច្បាស់ទេថាតើប័ណ្ណប្លង់ដីដែលមានស្រាប់ នឹងត្រូវធ្វើថ្មីជំនួស ឬក៏មានសុពលភាពបន្តទៀត ។ នីតិវិធី គឺជារឿងមួយទៀតដែលមិនច្បាស់លាស់ៈ ឧទាហរណ៍ តើអ្នកមានប័ណ្ណប្លង់ដីរួចហើយត្រូវដាក់ពាក្យសុំសាថ្មីឬយ៉ាងណា? បើសិនជាត្រូវដាក់ពាក្យសាថ្មីតើត្រូវធ្វើដូចម្តេច និងនៅទីណា? តើត្រូវបង់ប្រាក់ថែមទៀតឬទេ?

## ៤.៣ អ្វីទៅជាប័ណ្ណប្លង់ដី?

ដូចបានបញ្ជាក់ច្រើនលើកហើយ ប្រជាជនមានជំនឿ និងការយល់ដឹងជាទូទៅថា បើអ្នកណាមួយគ្រប់គ្រងដីរបស់ខ្លួនហើយអ្នកភូមិ និងអ្នកជិតខាងស្គាល់ដីគ្នាទៅវិញទៅមក ស្ថានភាពនេះគឺជាភស្តុតាងគ្រប់គ្រាន់សំរាប់បញ្ជាក់កម្មសិទ្ធិ និងការគ្រប់គ្រង ។ សិទ្ធិប្រើប្រាស់ដែលបានលើកពីខាងដើម នៅតែមានតំលៃដដែលរហូតមកដល់ពេលនេះ ជាពិសេសនៅតំបន់ជនបទ

[៤] ប្រអប់៤.១ សំដៅជាពិសេសដល់ដំណើរការផ្តល់កម្មសិទ្ធិដីធ្លីនៅក្នុងក្របខ័ណ្ឌ MLMUPC ។ គួរកត់សំគាល់ថា នាយកដ្ឋានរុក្ខាប្រមាញ់ និងនេសាទ ក៏មានពាក់ព័ន្ធនឹងការផ្តល់កម្មសិទ្ធិដីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនដែរ ។ មួយចំណែកទៀត បែបបទចុះបញ្ជីដីធ្លីក្នុងពេលបច្ចុប្បន្ន ត្រូវបានធ្វើវិមជ្ឈការនៅខេត្តកណ្តាល និងនៅក្រុងភ្នំពេញ ដោយសមត្ថកិច្ចចុងក្រោយ សំរាប់ផ្តល់ការយល់ព្រម និងចេញប័ណ្ណប្លង់ដី ត្រូវបានផ្តល់ទៅឱ្យថ្នាក់ខេត្ត-ក្រុង មិនមែនក្រសួងនៅភ្នំពេញទេ ។

និងចំពោះដីកសិកម្ម និងសំខាន់បំផុតចំពោះប្រជាជនដែលរស់ឆ្ងាយពីទីផ្សារ ឆ្ងាយពីផ្លូវជាតិ ឬតំបន់នានាដែលមានសកម្មភាពពាណិជ្ជកម្មច្រើន ។ ប៉ុន្តែ របៀបរបបអនុវត្តបែបនេះ កាន់តែទទួលរងការគំរាមកំហែងហើយ នៅពេលដែលផលប្រយោជន៍ពាណិជ្ជកម្មបានជ្រៀតចូលមកក្នុងតំបន់ (ឧទាហរណ៍ ភូមិនៅតាមផ្លូវជាតិលេខ៤) ។

បន្ទាប់មក មានបង្កាន់ដៃពាក្យសុំដែលគ្រួសារនានាបានទទួលសំរាប់ការដាក់ពាក្យសុំកាលពីមុនចំពោះដីធ្លីរបស់ខ្លួន ។ ដូច បានបញ្ជាក់ហើយ បង្កាន់ដៃមានច្រើនណាស់ (ប្រហែលពី ៤ ទៅ ៥លានក្នុងទូទាំងប្រទេស) ប៉ុន្តែគេមិនដឹងទេថា វាតំណាងអោយប៉ុន្មានភាគរយនៃចំនួនប្លង់ដីសរុប[៥] ។ ការធ្វើសំភាសន៏តាមភូមិបានអោយដឹងថា បង្កាន់ដៃសំរាប់ដីលំនៅដ្ឋានមានចំនួនច្រើនជាងបង្កាន់ដៃសំរាប់ដីកសិកម្ម ។ មូលហេតុដ៏សាមញ្ញដែលគេបានប្រាប់ក្រុមស្រាវជ្រាវគឺថា នៅតាមមូលដ្ឋានជាច្រើនមន្ត្រីថ្នាក់ស្រុកបានចុះមកផ្តល់ "លិខិតស្នាមមួយចំនួន" ចំពោះដីធ្លីរបស់ប្រជាជន (កំពត ភ្នំស្រួច ពាមរក៏) ។ មន្ត្រីទាំងនោះមិនបានធ្វើដំណើរទៅកាន់វាលស្រែទេ ពីព្រោះកន្លែងខ្លះគ្មានសន្តិសុខគ្រប់គ្រាន់ (ដើមទសវត្សរ៍១៩៩០) និងក្នុងករណីខ្លះទៀតមន្ត្រីស្រុកមិនចង់ធ្វើដំណើរឆ្ងាយ ។ មកដល់ពេលនេះ អ្នកខ្លះបានបាត់បង់បង្កាន់ដៃរបស់ខ្លួនហើយ ។ បង្កាន់ដៃជាច្រើនត្រូវវង្វេងដៃ ឬផ្ញើទុកនឹងភាគីណាមួយក្នុងពេលផ្ទេរ ឬបែងចែកដី ។ ក្នុងករណីមានការបែងចែកដីធ្លី បង្កាន់ដៃក្លាយជាមិនសំខាន់ ពីព្រោះវាជាប់ទាក់ទងនឹងប្លង់ដីមិនទាន់បែងចែក ។ ប៉ុន្តែទោះយ៉ាងនេះក្តី ប្រជាជននៅតែរក្សាបង្កាន់ដៃ (កំពត ស្ត្រីមេគ្រួសារនៅភ្នំស្រួច ពាមរក៏) ។ ម្យ៉ាងវិញទៀត រឿងប្រជាជនមិនសូវខ្វាយខ្វល់ចង់បានប័ណ្ណប្លង់ដី វាបញ្ជាក់គាំទ្រចំពោះមតិដែលអះអាងថា សំរាប់ប្រជាជនជាច្រើន នៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជា សិទ្ធិលើដីធ្លីតាមការប្រើប្រាស់នៅតែអនុវត្តជាបន្តទៀត ។

ប្រជាជនមួយចំនួនធំចាត់ទុកបង្កាន់ដៃថាជាប័ណ្ណសំគាល់កម្មសិទ្ធិ ។ អ្នកខ្លះដែលរស់នៅតំបន់ដាច់ស្រយាល និងមិនសូវមានការលួតលាស់ (ដូចជានៅកំពត និងរតនគិរី) បាននិយាយថា ខ្លួនមិនបានដឹង ហើយក៏ត្រូវការអ្វីទៀតលើសពីលិខិតស្នាមដែលមានសព្វថ្ងៃទេ ប៉ុន្តែក្នុងនេះប្រជាជនច្រើនគ្នាបានយកចិត្តទុកដាក់ចំពោះលិខិតដែលខ្លួនមាន ។ ផ្ទុយទៅវិញនៅក្នុងតំបន់មានទាក់ទងច្រើននឹងសកម្មភាពទីផ្សារ ប្រជាជននិយាយថា បង្កាន់ដៃមិនគ្រាន់តែជួយធានាទប់ទល់នឹងការរំលោភយកដីប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានប្រយោជន៏នៅពេលត្រូវលក់ដី ឬបន្តមរតក ។ ចំលើយខាងក្រោយនេះ ស្រង់បានពីភូមិនានាដែលកំពុងពើបប្រទះនឹងសកម្មភាពអភិវឌ្ឍន៏ឆក់ឱកាស/អភិវឌ្ឍន៏ទីផ្សារ ហើយដីធ្លីនៅទីនោះ កាន់តែក្លាយជាចំនុចដៅរបស់បណ្តាទីភ្នាក់ងារមកពីក្រៅភូមិ (តំបន់នានានៅស្អាង កែប[៦] និងភ្នំស្រួច) ។ នៅពេលមានការទិញលក់ដីធ្លី បង្កាន់ដៃត្រូវបានគេផ្ទេរចុះផ្ទេរឡើងដោយសេរី ។ ដោយបានទទួលប្រាក់កំរៃក្រៅផ្លូវការមួយចំនួន ប្រធានភូមិ ឬមេឃុំ ជួយប្តូរឈ្មោះលើបង្កាន់ដៃនៅពេលមានការផ្លាស់ប្តូរម្ចាស់ដី ។ ទោះបីនៅចំពោះមុខច្បាប់ឯកសារបែបនេះមិនអាចទទួលយកបានក៏ដោយ ក៏ក្នុងការទិញលក់ដីធ្លីសំរាប់ធ្វើកសិកម្មជីវព្រឹត្តិ អ្នកភូមិបានទទួលស្គាល់វាជាទូទៅ ។ ក្នុងបរិបទនៃការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុង *គំរោង* រឿងនេះអាចជាការប្រទាំងប្រទើសខ្លាំងណាស់ ពីព្រោះអ្នកការពារច្បាប់បានជំរុញឱ្យមានការអនុវត្តន៏បែបនេះ ។

ប័ណ្ណប្លង់ដីដែលបានចេញអោយហើយ មានតិចជាងបង្កាន់ដៃ ហើយការិយាល័យសុរិយោដីបញ្ជាក់ថា មានទាំងអស់ ៥១៨.២៥៨ (ចំនួនបែងចែកតាមខេត្តមានចុះក្នុងតារាង៤.១) ។ ក្នុងករណីជាច្រើន ប័ណ្ណប្លង់ដីត្រូវបានផ្តល់ដោយឆន្ទៈរបស់អាជ្ញាធរ មិនមែនដោយសារការទទូចរបស់ម្ចាស់ដីទេ ។ គ្រួសារស្ត្រីមេគ្រួនៅភ្នំស្រួច បានផ្តល់ពត៌មានឱ្យក្រុមស្រាវជ្រាវថា នៅដើមទសវត្សរ៍១៩៩០ មន្ត្រីថ្នាក់ស្រុកបានមកដល់ភូមិ ដើម្បីរៀបចំបញ្ចប់សំណុំបែបបទ និងផ្តល់លិខិតស្នាម ។ នៅភូមិកំពង់ត្នោតក្នុងខេត្តកំពត ច្បាប់ចំលងប័ណ្ណប្លង់ដីលំនៅដ្ឋានត្រូវបានចេញឱ្យនៅពេលពាក្យសុំ និងកំណត់ត្រាផ្សេងៗត្រូវបំផ្លាញអស់ដោយ

---

៥ វាសំខាន់ខ្លាំងណាស់ដែលគេត្រូវដឹងពីចំនួនប្លង់ដីសរុបក្នុងប្រទេស (តាមប្រភេទនៃការប្រើប្រាស់: សំរាប់កសិកម្ម លំនៅដ្ឋាន កន្លែងសាធារណៈ...) ប៉ុន្តែស្ថិតិដែលមានស្រាប់បែបនេះ គ្មានភាពត្រឹមត្រូវល្អទេ ។

៦ ទោះបី កែប ពុំមែនជាតំបន់ត្រូវសិក្សាក៏ដោយ ប៉ុន្តែក្រុមស្រាវជ្រាវបានចុះពិនិត្យមួយរយៈពេលខ្លីដែរ តាមសំណើរបស់មន្ត្រីនៅខេត្តកំពត ។

អគ្គីភ័យនៅការិយាល័យឃុំ និងស្រុក ។ ប៉ុន្តែមកទល់សព្វថ្ងៃ ប័ណ្ណទាំងនេះបានស្ថិតនៅជាមួយប្រធានភូមិអស់ច្រើនឆ្នាំហើយៗ វាមានសភាពចាស់ និងត្រូវខ្ចូតស៊ី ដែលបង្ហាញឱ្យដឹងអំពីអាយុរបស់វា ។ ប្រជាជនមិនបានមកយកវាទេ ពីព្រោះមិនចង់បង់ប្រាក់ត្រឹម ៥.000-៦.000រៀលសំរាប់ប័ណ្ណនីមួយៗ (ប្រធានភូមិអះអាងថា គាត់បានចំនាយប្រាក់នេះក្នុងការចេញប័ណ្ណសាជាថ្មី) ។ អ្នកដែលមានប័ណ្ណ និង/ឬទទួចចង់បានវា គឺជាអ្នកដែលបានទិញដីសំរាប់ធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម ពីព្រោះប័ណ្ណត្រូវមានជាចាំបាច់សំរាប់ការលក់បន្ត ឬសំរាប់ទទួលបានឥណទានជាផ្លូវការ ឬសំរាប់សាងសង់ ឬសំរាប់ប្រើប្រាស់ដីធ្លីតាមបែបបទណាមួយដែលតំរូវឱ្យម្ចាស់ដីជួបពាក់ព័ន្ធជាមួយរដ្ឋអំណាច ។

**តារាង៤.១ លទ្ធផលនៃការចុះបញ្ជីដីធ្លី (ចាប់ពីឆ្នាំ១៩៨៩ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២000)**

| ខេត្ត-ក្រុង | ក. ប័ណ្ណកាន់កាប់ (១៩៨៩-១៩៩៥) | ខ. ប័ណ្ណកាន់កាប់ (១៩៩៥-ធ្នូ២000) | សរុប ក និង ខ |
|---|---|---|---|
| កណ្តាល | 109 .749 | 9 .675 | 119 .424 |
| ក្រុងព្រះសីហនុ | 11 .659 | 5 .779 | 17 .438 |
| សៀមរាប | 28 .098 | 5 .041 | 33 .139 |
| កំពង់ចាម | 16 .618 | 6 .505 | 23 .123 |
| ក្រចេះ | 3 .064 | 1 .261 | 4 .325 |
| ពោធិសាត់ | 10 .857 | 4 .140 | 14 .997 |
| កោះកុង | 6 .490 | 2 .756 | 9 .246 |
| ព្រៃវែង | 36 .884 | 2 .061 | 38 .945 |
| ស្វាយរៀង | 38 .530 | 1 .808 | 40 .338 |
| កំពង់ឆ្នាំង | 25 .981 | 3 .291 | 29 .272 |
| បាត់ដំបង | 19 .432 | 6 .683 | 26 .115 |
| បន្ទាយមានជ័យ | 13 .641 | 3 .745 | 17 .386 |
| កំពង់ស្ពឺ | 22 .469 | 4 .204 | 26 .673 |
| តាកែវ | 43 .336 | 2 .770 | 46 .106 |
| កំពត | 54 .462 | 1 .668 | 56 .130 |
| កំពង់ធំ | 4 .973 | 2 .152 | 7 .125 |
| កែប | 570 | 783 | 1 .353 |
| រតនគិរី | 00 | 1 .056 | 1 .492 |
| មណ្ឌលគិរី | 00 | 00 | 00 |
| ស្ទឹងត្រែង | 00 | 128 | 128 |
| ព្រះវិហារ | 00 | 104 | 101 |
| ប៉ៃលិន | 00 | 31 | 31 |
| ឧត្តរមានជ័យ | 00 | 95 | 95 |
| ភ្នំពេញ | 1 .028 | 4 .621 | 5 .649 |
| **សរុប** | **448 .277** | **70 .357** | **518 .258** |

*ប្រភព: MLMUPC ។*

ដូចបានលើករួចហើយ គេឃើញមានករណីជាច្រើនដែលប្រជាជនបានលក់ដីធ្លី និងផ្ទះសំបែង ដោយលុបឈ្មោះចាស់ដាក់ឈ្មោះថ្មីនៅលើប័ណ្ណ ព្រមទាំងមានការបញ្ជាក់ពីប្រធានភូមិ-ឃុំផង (ដើម្បីបានកំរៃក្រៅផ្លូវការ) ។ ការអនុវត្តនីបែបនេះជួយកាត់បន្ថយទាំងចំនាយជាផ្លូវការ និងចំនាយមិនផ្លូវការ ព្រមទាំងកាត់បន្ថយការស្មុគស្មាញ ឈឺចាប់ និងការខាតពេលច្រើនជាមួយនឹងពួកមន្ត្រីដែលបង្កការរំខាន ។ ដំណោះស្រាយបែបនេះ (ដែលប្រជាជនទទួលស្គាល់ជាទូទៅ) បង្ហាញថា ការគ្រប់គ្រង និងសិទ្ធិអំណាចរបស់អាជ្ញាធរ ព្រមទាំងវិធាន និងបទប្បញ្ញត្តិជាផ្លូវការផ្សេងៗ មិនសូវមានតំលៃទេនៅតាមមូលដ្ឋាន ។ ប៉ុន្តែ

វិបត្តិអាចកើតមាននៅពេលត្រូវជួបពាក់ព័ន្ធនឹងទីភ្នាក់ងារមកពីក្រៅ ដោយសារច្បាប់មិនលាយលក្ខណ៍អក្សរ ត្រូវរំលាយចោលអស់ដោយច្បាប់ជាលាយលក្ខណ៍អក្សរ ទោះបីវាមិនសូវល្អឬមិនយុត្តិធម៌ក្តី ។ ប្រការនេះបានបន្តធ្វើឱ្យកសិករចាញ់ប្រៀបយ៉ាងខ្លាំង ។

តើអ្វីទៅជាប័ណ្ណប្លង់ដី តើគេផ្ទេរប័ណ្ណរបៀបណា ហើយស្ថាប័នណាដែលមានការពាក់ព័ន្ធ? នៅតំបន់ទីក្រុង ម្ចាស់ដីស្របច្បាប់ ភាគច្រើនមានប័ណ្ណត្រឹមត្រូវ ហើយជនចាប់យកដីមិនអាចយកអ្វីបានក្រៅពីលិខិតជូលបណ្តោះអាសន្ននោះឡើយ ។ ចំពោះប្រជាជនទូទៅវិញ មានវិធីសាស្រ្តផ្សេងៗជាច្រើនដែលគេប្រើក្នុងគោលដៅនៃប័ណ្ណប្លង់ដី ។ គឺមានតាំងពីពាក្យសន្យាផ្ទាល់មាត់ បង្កាន់ដៃ កិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ និងប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ។ ការផ្ទេរកម្មសិទ្ធិក៏មានភាពមិនច្បាស់លាស់ដែរ ។ អាជ្ញាធរថ្នាក់ខុសៗគ្នា បោះត្រាបញ្ជាក់ជាចុងក្រោយលើលិខិតផ្ទេរកម្មសិទ្ធិ យោងតាមប្រភេទអតិថិជន និងយោងតាមការដែលសង្គមទទួលស្គាល់អាជ្ញាធរថ្នាក់នោះ ។ ដូចនេះ ទីភ្នាក់ងារពាក់ព័ន្ធក៏អាចខុសៗគ្នាដែរ គឺមានចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់មជ្ឈិមនៅភ្នំពេញ ។ អ្នកខ្លះមានសមត្ថកិច្ចត្រឹមត្រូវ ឯអ្នកខ្លះទៀតគឺជាសមត្ថកិច្ចចាត់តាំងដោយខ្លួនឯង ។

## ៤.៤ បញ្ហានានាដែលអាជ្ញាធរត្រូវប្រឈមមុខ ក្នុងការផ្តល់ប័ណ្ណប្លង់ដី និងការចុះបញ្ជី

យន្តការផ្លូវការក៏មានការលំបាកផ្ទាល់ខ្លួនឯងដែរ ។ នៅកំរិតម៉ាក្រូ មានបញ្ហាចោទជាមូលដ្ឋានអំពីនិយមន័យនៃការប្រើប្រាស់ដី និងដែនសមត្ថកិច្ចនៃអាជ្ញាធរនីមួយៗ ។ ដីធ្លីមួយភាគធំ (ប្រមាណ ៨០%) ជារបស់រដ្ឋ គឺមានដីព្រៃ ដីសាធារណៈ ផ្លូវទឹក ដីទំនេរ ដីព្រៃគម្ពោត... ។ មានក្រសួង និងស្ថាប័នជាច្រើនដែលគ្រប់គ្រងដីធ្លី (ដូចជា ក្រសួងកសិកម្មគ្រប់គ្រងព្រៃ និងផ្ទៃទឹក យោធាគ្រប់គ្រងដីដែលខ្លួនបានទទួលសំរាប់គោលដៅខាងយុទ្ធសាស្រ្ត) ។ ប៉ុន្តែគេមិនច្បាស់លាស់ទេថា ព្រំដែនស្ថាប័នណាត្រូវចប់ត្រឹមណា ។ ម្យ៉ាងវិញទៀត ២៥% នៃបណ្តាឃុំសព្វថ្ងៃ មិនទាន់មានកំណត់ព្រំប្រទល់ជាក់លាក់ទេ[៧] ។ ដូចគ្នាដែរមិនទាន់មាននិយមន័យច្បាស់លាស់ទេ សំរាប់តំបន់ទីក្រុង រីឯនិយមន័យនៅក្នុងជំរឿនពុំមែនជានិយមន័យផ្លូវការទេ ។ កង្វះការពិភាក្សាគ្នារវាងក្រសួងមន្ទីររដ្ឋ ឬរវាងឃុំ និងស្រុក កាន់តែធ្វើឱ្យបញ្ហាចោទខ្លាំងថែមទៀត ។ កន្លងមកធ្លាប់មានរួចហើយនូវករណីក្រសួងមន្ទីររដ្ឋដណ្តើមគ្នាគ្រប់គ្រងលើដីតែមួយ ។ កង្វះស្ថាប័នចំបងគេមួយសំរាប់វិនិច្ឆ័យបញ្ហាវិវាទរវាងក្រសួងនានាបានផ្តល់លទ្ធភាពអោយក្រសួងមន្ទីរធំៗ អាចគ្រប់គ្រងដីធ្លីរបស់ខ្លួនទៅតាមបែបបទមួយដែលសឹងតែឯករាជ្យ និងគ្មានអភិបាលកិច្ចជាលក្ខណៈប្រមូលផ្តុំអ្វីសោះ ។ នៅក្នុងកាលៈទេសៈបែបនេះ មន្ត្រីនៃមន្ទីរ-ស្ថាប័នខ្សែបណ្តោយ ជាពិសេសនៅថ្នាក់ក្រោមមានការច្របូកច្របល់ខ្លាំងណាស់[៨] ។

បញ្ហារឹតតែធ្ងន់ធ្ងរថែម នៅពេលមានប្រជាជនកាន់តែច្រើនមកចូលរួមពាក់ព័ន្ធ ។ ក្នុងនេះគួរលើកយកករណីស្តីពីតំបន់ព្រៃនៅក្នុងភូមិមួយនៅកំពត ។ ប្រទេសកម្ពុជាមានតំបន់ព្រៃធំទូលាយ ប៉ុន្តែនៅក្នុងព្រៃមានប្រជាជនរស់នៅប្រមូលផ្តុំជាភូមិតូចៗ ។ អ្នកភូមិដាំស្រូវដោយកាប់ចំការតូចៗនៅក្នុងព្រៃ និងបេះប្រមូលអនុផលព្រៃឈើ ។ នៅពេលរដ្ឋាភិបាលធ្វើ "ឯកជនភាវូបនីយកម្ម" ព្រៃឈើ ដោយផ្តល់ជាសម្បទានមួយចំនួន, ទាំងការផលិតស្រូវ និងការប្រមូលអនុផលព្រៃឈើរបស់កសិករមានការប៉ះពាល់ក្នុងកំរិតខុសៗគ្នា ។ មន្ត្រីទទួលបន្ទុកមិនដឹងថា តើត្រូវអនុវត្តតាមគោលនយោបាយណាមួយទេ ពីព្រោះគ្មានច្បាប់ចែងច្បាស់លាស់ពីសិទ្ធិរបស់ប្រជាជនទាំងនេះ និងគ្មានគោលនយោបាយអនុវត្តជាក់ស្តែងណាមួយស្តីពីការស្តារលទ្ធភាព និងការរុះរើផ្លាស់កន្លែងតាំងទីលំនៅរបស់អ្នកភូមិ ។ កាន់តែស្មុគស្មាញជាងនេះទៀត គឺគេមិនដឹងច្បាស់ពីចំនួនប្រជាជនត្រូវប៉ះពាល់ និងមធ្យោបាយរកចិញ្ចឹមជីវិតរបស់ពួកគេទេ ។ ជំរឿនឆ្នាំ១៩៩៨ បានផ្តល់ពត៌មានខ្លះដែរ ប៉ុន្តែមិនទាន់គ្រប់គ្រាន់សំរាប់ចំណាត់

---

៧ ទិន្នន័យត្រូវបានផ្តល់នៅក្នុងការិយាល័យដែលធ្វើការចុះបញ្ជីក្នុងលក្ខណៈជាប្រព័ន្ធ ។

៨ ការជួបពិភាក្សាជាមួយមន្ត្រី MLMUPC និងការិយាល័យសុរិយោដីកណ្តាល គឺជាមូលដ្ឋាននៃការសន្និដ្ឋានទាំងនេះ ។

ការទេ ។

នៅពេលខ្លះវិធីដែលស្ថាប័នរដ្ឋមួយចំនួនបានប្រើប្រាស់ក្នុងការកាន់កាប់ដីធ្លី បានក្លាយជាប្រភពវិវាទរវាងពួកអ្នកពាក់ព័ន្ធនឹងដីធ្លី និងវាធ្វើឱ្យមន្ត្រីតាមមន្ទីរក្រសួងមានការច្របូកច្របល់ ។ ឧទាហរណ៍ដែលគេលើកយកមកនិយាយជាញឹកញាប់ គឺការកាន់កាន់ដីដោយយោធាក្នុងរង្វង់ឆ្នាំ១៩៩០-៩៥ នៅភ្នំស្រួច និងស្រុកដទៃទៀតនៅកំពង់ស្ពឺ ។ គ្មានអ្នកណាជំទាស់ពីរឿងហេតុផលខាងសន្តិសុខនៃដីធ្លីដែលយោធាកាន់កាប់នោះទេ ប៉ុន្តែមានចំណុចពីរដែលត្រូវធ្វើការកត់សំគាល់ ។ ទី១ យោធាមិនបានទូទាត់តំលៃដីដែលខ្លួនបានយកទេ ហើយកសិករភៀសសឹក និងពួកអ្នកភូមិដែលតាំងទីលំនៅក្នុងកន្លែងផ្សេងទៀតក៏មិនបានទូទាត់ដូចគ្នា ។ ក្នុងករណីដូច្នេះ នៅពេលគ្រោះអាសន្នចប់អស់ទៅ ដីទាំងនោះគួរប្រគល់អោយម្ចាស់ដើមវិញ ។ ប៉ុន្តែកន្លងមកគេមិនបានធ្វើដូច្នេះទេ ។ ផ្ទុយទៅវិញ យោធាបានអភិវឌ្ឍដី ឬមួយសំរាប់ដោះស្រាយកន្លែងរស់នៅឱ្យទាហានចូលនិវត្តន៍ ឬមួយសំរាប់ជួលឱ្យក្រុមហ៊ុនឯកជន ។ ទី២ នៅពេលប្រតិបត្តិការទាក់ទងនឹងសន្តិសុខបានចប់សព្វគ្រប់ តើការចាត់ចែងដីធ្លីវាជាកិច្ចការរបស់យោធាឬយ៉ាងណា? តើ MLMUPC ក្រសួងកសិកម្ម ឬក្រសួងដទៃ ឬអាជ្ញាធរវិមជ្ឈការ (ដូចជាក្រុមប្រឹក្សាឃុំជាដើម) ត្រូវចូលរួមឬទេក្នុងការសំរេចថា ស្ថាប័នណាត្រូវទទួលគ្រប់គ្រងដីទាំងនេះ, ឬក៏ដីត្រូវទុកធ្វើអ្វីជាចុងក្រោយ? ក្នុងពេលសព្វថ្ងៃដែលមានសន្តិភាពឡើងវិញហើយ តើត្រូវមានច្បាប់សំរាប់គ្រប់គ្រងរឿងនេះដែរឬទេ?

ផ្ទៃទឹកគឺជាករណីមួយទៀតនៃភាពមិនច្បាស់លាស់ ។ នៅប្រទេសកម្ពុជា ទឹកឡើងខ្ពស់នៅរដូវវស្សាហើយជន់លិចផ្ទៃដីយ៉ាងធំដែលក្លាយទៅជាជំរកដ៏ល្អសំរាប់ត្រីបន្តពូជ ហើយអ្នកម៉ៅការនេសាទ ក៏ជួលកន្លែងទាំងនេះ តាមតំលៃមួយពីនាយកដ្ឋានជលផល ។ នៅពេលទឹកស្រកផុត គេប្រើប្រាស់ដីសំរាប់ដាំដំណាំ ។ មានមតិមួយលើកថា បើដីទាំងនេះត្រូវបានផ្តល់ជាកម្មសិទ្ធិទៅអោយម្ចាស់ដី តាមលក្ខណៈបច្ចេកទេស សិទ្ធិនេសាទក៏គប្បីផ្តល់ទៅអោយម្ចាស់ដីដូចគ្នា ។ ប៉ុន្តែមតិនេះ មិនបានទទួលការគាំទ្រពីទាំងអស់គ្នាទេ ពីព្រោះវាជាករណីខាងធនធានដែលក្នុងរដូវមួយវាជាសម្បត្តិសាធារណៈ និងនៅក្នុងរដូវមួយទៀតវាជាទ្រព្យឯកជន ។ ហេតុនេះចំពោះការនេសាទ ត្រូវអនុវត្តច្បាប់ស្តីពីធនធានទ្រព្យរួម ប៉ុន្តែទោះធ្វើដូច្នេះក៏ដោយ ក៏នៅតែមិនទាន់ដោះស្រាយបានថា តើអ្នកណាត្រូវបានប្រាក់សួយលើការនេសាទ ។ បញ្ហាទាំងនេះត្រូវបានពិភាក្សាក្នុងសិក្ខាសាលាមួយចំនួនដោយបានទទួលមតិខុសៗគ្នាជាច្រើនស្តីពីដំណោះស្រាយ ។ ចំពោះមន្ត្រីអ្នកអនុវត្តផ្ទាល់ គេមិនទាន់ឃើញមានសេចក្តីណែនាំពីរឿងនេះទេ ។

កម្ពុជាមានដីនៅចោលទំនេរធំៗជាច្រើនកន្លែង ។ ក្រុមស្រាវជ្រាវបានឮថ្នាក់ស្រុក-ឃុំ ត្អូញត្អែរជាញឹកញាប់ពីជនមួយចំនួនដែលមានដីប្រភេទនេះតែគេចវេសមិនព្រមបង់ពន្ធដោយសារមានឥទ្ធិពលនយោបាយ ហើយរឿងនេះធ្វើឱ្យប្រទេសជាតិទទួលខាតបង់មួយមុខថែមទៀតពីព្រោះដីធ្លីត្រូវទុកចោលមិនប្រើប្រាស់ ។ ប៉ុន្តែគេក៏ឃើញមានដីរដ្ឋដែលទុកចោលមិនប្រើប្រាស់ដែរ ហើយវាមានទំហំធំៗទៀតផង ។ គ្មានក្រសួងមន្ទីរណាបានបង់ពន្ធចំពោះការទុកចោលដីធ្លីឱ្យនៅទំនេរទេ ។ ស្ថានភាពនេះមិនគ្រាន់តែបង្កើតឱ្យមានស្តង់ដាខុសគ្នារវាងវិស័យសាធារណៈ និងវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែវារួមចំនែកធ្វើឱ្យប្រទេសជាតិខាតបង់ដូចក្នុងករណីមុនដែរ ។

ក្នុងច្បាប់ នៅមានភាពមិនច្បាស់លាស់ផ្សេងៗទៀតដែលធ្វើអោយភារកិច្ចរបស់មន្ត្រីជួបការលំបាក ។ ឧទាហរណ៍មួយគឺសំណង់នៅតាមផ្លូវជាតិ និងតាមដងទន្លេ ។ តាមអនុក្រឹត្យលេខ០៦ (សេចក្តីប្រកាសស្តីពីការបំបាត់ និងការដោះស្រាយការចាប់យកដីអនាធិបតេយ្យ ខែកក្កដា ឆ្នាំ១៩៩៧) មិនត្រូវឱ្យមានសំណង់ទេ នៅត្រឹមចំងាយណាមួយពីផ្លូវជាតិ ។ ជាក់ស្តែងកម្ពុជាមានប្រជាជនរស់នៅប្រមូលផ្តុំជាភូមិធំៗ នៅតាមដងផ្លូវ និងដងទន្លេ មួយផ្នែកគឺដោយសារហេតុផលខាងសន្តិសុខ ។ ប្រជាជនប្រហែលអាចចាកចេញពីទីនោះ បើសិនជាមានបង្កើតហេដ្ឋារចនាសម្ព័ន្ធខ្លះនៅឆ្ងាយពីដងផ្លូវសំរាប់ពួកគេ ។ ប៉ុន្តែដោយគ្មានហេដ្ឋារចនាសម្ព័ន្ធបែបនេះ គេមិនអាចអនុវត្តតាមច្បាប់បានទេ ពីព្រោះគ្មានមធ្យោបាយ សំភារៈ ដើម្បីរុះរើប្រជាជនដ៏ច្រើនយ៉ាង

នេះចេញពីចិញ្ចើមថ្នល់ និងតាមដងទន្លេ ។

**តារាង៤.២ តួលេខប៉ាន់ស្មានពីចំនួនបុគ្គលិកធ្វើការនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ខេត្ត-ក្រុង និងមជ្ឈិម)**

| | | បុគ្គលិកវិជ្ជាជីវៈ* | អ្នកបច្ចេកទេស** | កម្មករជំនាញ | ទូទៅ | សរុប |
|---|---|---|---|---|---|---|
| | **ខេត្ត-ក្រុង** | | | | | |
| 1 | ប៉ៃលិន | 2 | 7 | | 23 | 32 |
| 2 | បន្ទាយមានជ័យ | 6 | 14 | | 30 | 50 |
| 3 | បាត់ដំបង | 4 | 24 | 1 | 66 | 95 |
| 4 | សៀមរាប | 5 | 15 | | 79 | 99 |
| 5 | កំពង់ធំ | 5 | 14 | 0 | 28 | 47 |
| 6 | ពោធិសាត់ | 2 | 9 | 2 | 32 | 45 |
| 7 | កំពង់ឆ្នាំង | 3 | 24 | | 56 | 83 |
| 8 | ស្ទឹងត្រែង | 1 | 4 | 0 | 9 | 14 |
| 9 | ក្រចេះ | 3 | 9 | | 17 | 29 |
| 10 | កំពង់ចាម | 5 | 47 | 4 | 59 | 115 |
| 11 | ព្រៃវែង | 2 | 24 | 3 | 71 | 100 |
| 12 | ស្វាយរៀង | 2 | 16 | 0 | 23 | 41 |
| 13 | តាកែវ | 2 | 35 | 6 | 52 | 95 |
| 14 | កែប | 1 | 13 | | 4 | 18 |
| 15 | កំពត | 2 | 27 | 3 | 52 | 84 |
| 16 | កំពង់ស្ពឺ | 4 | 23 | 2 | 39 | 68 |
| 17 | ក្រុងព្រះសីហនុ | 10 | 17 | 2 | 38 | 67 |
| 18 | កោះកុង | 2 | 25 | | 19 | 46 |
| 19 | ព្រះវិហារ | 1 | 5 | | | 6 |
| 20 | រតនគិរី | 2 | 6 | | 6 | 14 |
| 21 | កណ្តាល | 17 | 84 | 2 | 94 | 197 |
| 22 | ភ្នំពេញ | 141 | 98 | 5 | 243 | 486 |
| 23 | ឧត្តរមានជ័យ | 1 | 2 | | 6 | 9 |
| 24 | មណ្ឌលគិរី | 0 | 0 | | 4 | 4 |
| | សរុប ក | **223** | **542** | **30** | **1050** | **1 .844** |
| | **ក្រសួងរៀបចំដែនដី ភ្នំពេញ** | | | | | |
| | អគ្គនាយកដ្ឋានរដ្ឋបាល | 15 | 12 | 1 | 106 | 134 |
| | ទីប្រជុំជន | 89 | 18 | | 9 | 116 |
| | សំណង់ | 94 | 28 | | 3 | 125 |
| | សុរិយោដី | 19 | 90 | 4 | 123 | 236 |
| | សរុប ក + ខ | **440** | **690** | **35** | **1 .291** | **2 .455** |

** បុគ្គលិកវិជ្ជាជីវៈ រួមមាន បណ្ឌិត វិស្វករវ៉ៃ និងជលវិទ្យា និងស្ថាបត្យករ ។ ** អ្នកបច្ចេកទេសរួមមានបុគ្គលិកសំណង់ និងសុរិយោដី ។*

ចំណុចចុងក្រោយគឺបញ្ហាចំនាយ ។ បុគ្គលិករដ្ឋគ្មានរបបចំណាយផ្លូវការគ្រប់គ្រាន់សំរាប់កិច្ចការពេញច្បាប់របស់ខ្លួនទេ ។ ការធ្វើដំណើរ ចំណាយហូបចុក ហើយចំណាយផ្សេងទៀត តាមធម្មតាត្រូវចេញពីហោប៉ៅផ្ទាល់ខ្លួន ព្រោះថាការទូទាត់សង (បើសិនជាមានសង) ក៏មិនគ្រប់គ្រាន់ដែរ ។ ជាការពិតហើយ បន្ទុកខាងលើមិនអាចរ៉ាប់រងបានទេ ដូច្នេះគេតែងរកសោហ៊ុយពីពួកអតិថិជន ។ វិធីនេះមិនអាចមានចីរភាពទេ ព្រោះថាមិនគ្រាន់តែតួនាទីមិនប្រកាន់បក្សពួករបស់មន្ត្រីត្រូវជួបបញ្ហាប៉ុណ្ណោះទេ

ប៉ុន្តែប្រសិទ្ធិភាពការងារក៏ត្រូវពឹងផ្អែកលើចំនួនទឹកប្រាក់ដែលអតិថិជនផ្តល់ឱ្យដែរ ។ គួរបញ្ជាក់ថែមទៀតថា មន្ត្រីជាច្រើននៅថ្នាក់ក្រោម អ្នកតំណាងស្ថាប័នសាធារណៈ និងអ្នកធ្វើការនៅការិយាល័យទទួលប្រាក់ខែស្តួចស្តើងមិនអាចដោះស្រាយជីវភាពបានទេ ។ មន្ត្រីម្នាក់និយាយថា បើច្បាប់ស្តីពីបៀវត្សរ៍អប្បបរមា ៤៥ដុល្លារក្នុងមួយខែសំរាប់កម្មកររោងចក្រកាត់ដេរ ត្រូវបានដាក់អនុវត្តលើគ្រប់វិស័យ រដ្ឋាភិបាលនឹងក្លាយទៅជាអ្នកជំពាក់បំណុលដ៏ធំជាងគេបំផុត ។

## ៤.៥ អំពីសមត្ថភាព

បុគ្គលិកនៅ DLMUPCC (ថ្នាក់ខេត្ត) និង OLMUPCL (ថ្នាក់ស្រុក) ក៏ជួបបញ្ហានៅក្នុងការងារ ដោយសារតែកង្វះសមត្ថភាពដែរ ។ នៅក្នុងខេត្តទាំងប្រាំដែលបានចុះពិនិត្យ សមត្ថភាពបុគ្គលិកនៅមូលដ្ឋានមានកំរិតខុសៗគ្នា ប៉ុន្តែមិនឃើញមានចំណងទាក់ទងអ្វីទេរវាងចំនួនបុគ្គលិក តំបន់ពួកគេគ្រប់គ្រង ឬប្រជាជនដែលគេបំរើ ។ ចំនួនបុគ្គលិកមានពី ១៤-១០០នាក់ក្នុងមួយខេត្តៗ (តារាង៤.២) ។ នៅខេត្តកណ្តាលគេអះអាងថា បុគ្គលិកមានជំនាញគ្រប់គ្រាន់ គឺខ្វះតែសំភារៈ, ប៉ុន្តែនៅកន្លែងឯទៀតគេត្អូញត្អែរពីតំរូវការនូវការបណ្តុះបណ្តាល ។ ក្នុងរឿងនេះការបណ្តុះបណ្តាលផ្តល់ដោយអង្គការ GTZ បានទទួលការវាយតំលៃយ៉ាងខ្ពស់ ។ ស្តីពីសំភារៈវិញ មន្ទីរ DLMUPCC និងការិយាល័យ OLMUPCL មានសំភារៈបរិក្ខារតិចជាងថ្នាក់ស្មើគ្នានៅខាងកសិកម្ម ឬផែនការ ។ គេមិនឃើញមានកុំព្យូទ័រ ផែនទី ឬមធ្យោបាយដឹកជញ្ជូនទេ ហើយក្នុងករណីមួយ គឺគ្មានទាំងកៅអីគ្រប់គ្រាន់សំរាប់មនុស្ស ១០-១២នាក់ជួបប្រជុំគ្នាផង ។ ក្នុងករណីខ្លះ មានបញ្ហាចោទខាងដែនសមត្ថកិច្ច ។ ដូចជានៅឃុំត្រែងត្រយឹង (ស្រុកភ្នំស្រួច) ជាដើម អតីតខ្មែរក្រហមបានមកតាំងទីលំនៅ ហើយបានប្រកាសជាឯកតោភាគីថា តំបន់របស់ពួកខ្លួនជាឃុំមួយដែលឯករាជ្យ ។ មកទល់សព្វថ្ងៃ រដ្ឋាភិបាលមិនយល់ព្រមចំពោះការបែងចែកបែបនេះទេ ។ មេឃុំត្រែងត្រយឹងនិយាយថា គាត់មានការពិបាកក្នុងការចូលទៅធ្វើកិច្ចការជាផ្លូវការនៅក្នុងតំបន់គ្រប់គ្រងរបស់គាត់ណាស់ ពីព្រោះគេមិនបានទទួលស្គាល់គាត់ជាប្រធានទេ ។

## ៤.៦ សេចក្តីសង្ខេប

នៅក្នុងបរិបទនៃបញ្ហានានាដែលបានផុសឡើងពីគោលដៅដូចមានបញ្ជាក់នៅក្នុងជំពូក១ អ្នកពាក់ព័ន្ធនៅក្នុង *គំរោង* អាចត្រូវបានពង្រីកទៅដល់មន្ត្រីផ្សេងៗ និងអ្នកតំនាងនៅថ្នាក់ភូមិ ស្រុក ខេត្ត និងមជ្ឈិម ។ ប៉ុន្តែបញ្ហាវាស្មុគស្មាញជាងបញ្ជីឈ្មោះឆ្ងាយណាស់ ។ ទី១ កសិករក្រីក្រដឹង/ជឿតិចតួចទេ ចំពោះអ្វីដែលមិននៅជុំវិញខ្លួនគេ ។ ចំពោះអ្នកទាំងនោះ ប្រធានភូមិ និងមេឃុំ ទោះល្អឬអាក្រក់ គឺជាអាជ្ញាធរពិតប្រាកដ ។ ពិតណាស់ អ្នកតំណាងទាំងនេះបានកំណត់ច្បាប់សំរាប់អនុវត្តខ្លួនឯង ។ ឧទាហរណ៍ ពួកគេបញ្ជាក់លើការផ្ទេរដីធ្លីនៅត្រឹមកំរិតរបស់ខ្លួន ។ នៅថ្នាក់ខ្ពស់ជាងនេះ ប្រតិបត្តិការមានលក្ខណៈឯកភាពគ្នាជាងមុនបន្តិច ប៉ុន្តែនៅរតនគិរីមានភស្តុតាងបង្ហាញថា នីតិវិធីមួយបែបទៀតដែលខុសពីវិធានផ្លូវការ ក៏មានអនុវត្តយ៉ាងច្រើននៅថ្នាក់លើដែរ ។

គេត្រូវបង្ខំចិត្តធ្វើការសន្និដ្ឋានថា ស្ថានភាពទីតាំងកំណត់ដោយផ្ទាល់នូវប្រភេទអ្នកពាក់ព័ន្ធនៅក្នុងគំរោង ចំណែកឯអ្នកពាក់ព័ន្ធជាទូទៅ គឺដូចមានលើកឡើងក្នុងជំពូក៣ រួចហើយ ។ គួរបញ្ជាក់ដែរថា អ្នកពាក់ព័ន្ធផ្សេងៗ ប្រហែលមានការលំបាកក្នុងការសំរបសកម្មភាពកាលពីមុនរបស់ខ្លួនវិញ ពីព្រោះម្នាក់ៗបានរំលោភច្បាប់ក្នុងអតីតកាល ហើយឥឡូវនេះត្រូវតែសន្យាអនុវត្តតាមច្បាប់នៅក្នុងកម្មវិធីផ្តល់ប័ណ្ណប្លង់ដី ។ បញ្ហាមួយទៀត គឺមួយចំនួននៃអ្នកពាក់ព័ន្ធនឹង *ដីធ្លី* ក៏ជាអ្នកពាក់ព័ន្ធនៅក្នុង *គំរោង* ផងដែរ ។ ជួនកាលមុខងារទាំងពីរ ពិបាកនឹងបន្សុីគ្នាណាស់ ។ ឧទាហរណ៍ ប្រសិនបើប្រធានភូមិ នៅភូមិ៤ ស្រុកភ្នំស្រួច បានបាត់បង់ដី គេមិនអាចរំពឹងទេថា គាត់នឹងមានជំហរមិនប្រកាន់បក្សពួកឥតខ្ចោះ ក្នុងការអនុវត្តនីភារកិច្ចជាប្រធានភូមិនៅក្នុងកម្មវិធីផ្តល់ប័ណ្ណប្លង់ដី ។ ក្នុងស្ថានភាពបែបនេះ សហគមន៍ខ្លះនៅតាមភូមិ បានស្នើអោយមានការចូលរួមពី NGOs ដែលគេមាន

ជំនឿថាមានជំហរមិនប្រកាន់បក្សពួក ( កំពត កំពង់ស្ពឺ) ។

ភាពស្របច្បាប់ និងសមត្ថភាពនៃអាជ្ញាធរនានា ជួនកាលមានបញ្ហាចោទដែរ ។ ប្រជាជននៅមូលដ្ឋានជឿទុកចិត្តបរិស្ថាននៅជុំវិញខ្លួនគាត់ ឯអ្នកមានផលប្រយោជន៍ពាណិជ្ជកម្មធំៗ ជួយទ្រទ្រង់ និងជឿជាក់លើរបបការិយាធិបតេយ្យនៅថ្នាក់ខ្ពស់ៗ ។ របៀបរបបបែបនេះដំណើរការបានល្អ ដរាបណាមិនទាន់មានការពើបប្រទះគ្នារវាងផលប្រយោជន៍ខុសៗគ្នា ប៉ុន្តែគេប្រមើលដឹងថានឹងមានការរកាំរកូស បើសិនជាមានការប៉ះទង្គិចផលប្រយោជន៍គ្នា ។ ចំពោះរឿងសមត្ថភាពវិញ ផ្នែកស្តីពី "សមត្ថ ភាព" នៅខាងលើបានធ្វើការបូកសរុបរួចហើយ ។ ក្នុងនេះគ្រាន់តែបញ្ជាក់បន្ថែមថា មានមនុស្សជាច្រើនចង់ឱ្យមានបុគ្គលិក NGO ចូលរួមជួយសំរបសំរួលផង ពីព្រោះជាទូទៅគេយល់ថាអ្នកទាំងនេះមានប្រវត្តិមិនប្រកាន់បក្សពួកនៅគង់វង្សល្អណាស់ ។

# ជំពូក ៥

# ទំនាស់ និងយន្តការដោះស្រាយទំនាស់ [១]

## ៥.១ សេចក្តីផ្តើម

ចំនួន និងប្រភេទទំនាស់ដីធ្លីបានផ្លាស់ប្តូរ ខណៈដែលការប្រើប្រាស់ដី បានឈានពីការផលិតគ្រាន់តែគ្រប់ហូប មកជាការផលិតបែបពាណិជ្ជកម្ម ។ នៅពេលប្រជាជនផលិតសំរាប់តែគ្រប់ហូប សិទ្ធិប្រើប្រាស់ដីត្រូវបានត្រួតត្រាជាចំបងដោយស្ថាប័ននៅថ្នាក់មូលដ្ឋាន ដោយគោរពតាមប្រពៃណី និងទំនៀមទំលាប់នៃមូលដ្ឋាននោះ ។ ខណៈពេលដែលតំរូវការដីកើនឡើង ស្ថាប័នផ្លូវការរបស់រដ្ឋជាច្រើនថែមទៀតដែលជាភាគីទី៣ សំរាប់អនុវត្តន៍ច្បាប់ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងលើសិទ្ធិកាន់កាប់ដីធ្លី ។ ការឈានពីស្ថាប័នក្រៅផ្លូវការមកជាស្ថាប័នផ្លូវការសំរាប់គ្រប់គ្រងដីធ្លីបានជួបបញ្ហា ដោយសារមូលហេតុផ្សេងៗជាច្រើន ។ ទី១ យន្តការអភិបាលកិច្ចផ្លូវការ ខ្វះទាំងហិរញ្ញវត្ថុ និងបុគ្គលិក ។ ទី២ គ្រប់ភាគីទាំងអស់ដែលពាក់ព័ន្ធនឹងដីធ្លីមានការយល់ដឹងខុសច្រើនណាស់អំពីច្បាប់ និងនីតិវិធី ។ ទី៣ ស្ថាប័នផ្លូវការបានបាត់បង់ទំនុកចិត្តរបស់ប្រជាជន ដោយសារបញ្ហាពុករលួយ ។ ជំពូកនេះ គូសបញ្ជាក់អំពីប្រភេទទំនាស់ដីដែលបានពិនិត្យឃើញនៅក្នុងតំបន់សិក្សា និងពិភាក្សាអំពីមធ្យោបាយដោះស្រាយទំនាស់ ។

## ៥.២ ទំនាស់ដីធ្លី

ទំនាស់អំពីដីធ្លីបានកើតមាននៅគ្រប់តំបន់សិក្សាទាំងអស់ ប៉ុន្តែចរិតនៃទំនាស់ និងភាគីមានទំនាស់វាខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ។ ទំនាស់មានរាយការណ៍ញឹកញាប់ជាងគេ គឺទំនាស់ព្រំដីរវាងអ្នកជិតខាងគ្នា ។ ទំនាស់ប្រភេទនេះបានកើតឡើងយ៉ាងច្រើននៅដើមទសវត្សរ៍១៩៩០ ដោយសារតែគ្មានការវាស់វែងត្រឹមត្រូវនៅពេលដីធ្លី ត្រូវបានបែងចែកឡើងវិញនៅឆ្នាំ១៩៨៩ ។ ជាការពិតហើយ ដំណើរការផ្តល់ប័ណ្ណប្លង់ដីមិនអាចទៅមុខបានទេ ដរាបណាទំនាស់ពុំទាន់ដោះស្រាយរួច ។

ក្នុងដំណាក់កាលដំបូងនៃការផ្តល់ប័ណ្ណប្លង់ដី គឺពេលដែលដីមានតំលៃថោកនៅឡើយ និងមិនសូវមានតំរូវការខ្លាំង ទំនាស់ភាគច្រើនត្រូវបានដោះស្រាយទៅតាមទំនៀមទំលាប់ និងប្រពៃណីដែលគ្រប់គ្រងសិទ្ធិប្រើប្រាស់ដីនៅតាមមូលដ្ឋាន ។ ប៉ុន្តែនៅពាក់កណ្តាលទសវត្សរ៍១៩៩០ ចរិតនៃទំនាស់ និងភាគីពាក់ព័ន្ធ មានការផ្លាស់ប្តូរដោយសារថ្លៃដីចេះតែកើនឡើង ។ ចំណុចចំបងមួយនៃការប្រែប្រួលនេះ គឺដោយសារមានកំណើនករណីរំលោភយកដី ការផ្តល់សម្បទានដីកសិកម្ម ឬទំនាស់ដែលទាក់ទងនឹងការយកដីទៅបញ្ចាំ ប្រជាជននៅមូលដ្ឋានចាប់ផ្តើមបាត់បង់ដីធ្លីដែលត្រូវបានទៅលើប្រជាជន ឬស្ថាប័នមកពីក្រៅសហគមន៍ ។ បច្ចុប្បន្ន ទំនាស់ដីធ្លីបានក្លាយជាបញ្ហាសង្គមដែលចោទកាន់តែធ្ងន់ធ្ងរឡើង ហើយដែលបានធ្វើឱ្យខូចខាតដល់ជំនឿរបស់ប្រជាជនលើប្រព័ន្ធគ្រប់គ្រង និងធ្វើឱ្យខូចខាតលទ្ធភាពរបស់ពួកគាត់ក្នុងកសាងជីវភាពឱ្យមានចីរភាព ។

១ ជំពូកនេះផ្អែកលើការធ្វើសម្ភាសន៍នៅថ្នាក់មូលដ្ឋាន និងការពិភាក្សាជាមួយមន្ត្រីមួយចំនួន ។

### ៥.២.១ ទំនាស់រវាងអ្នកជិតខាង

ជាប្រពៃណីគេតែងប្រើរបង ឬបង្គោលព្រំច្បោល១ សំរាប់បញ្ជាក់កម្មសិទ្ធិដីធ្លី ហើយគេអនុវត្តសិទ្ធិលើដីធ្លី ។ ទៅតាមទំលាប់ក្នុងមូលដ្ឋានដែលប្រជាជននៅក្នុងសហគមន៍បានទទួលស្គាល់ ។ ក្នុងករណីខ្លះទៀត ព្រំប្រទល់រឹតតែមើលមិនសូវឃើញ ប៉ុន្តែអ្នកជិតខាង គេបានដឹងឮ ។ ដូច្នេះគេអាចនិយាយថា សិទ្ធិប្រើប្រាស់ដីក្នុងកន្លែងណាមួយ មិនបានកំណត់ជាក់លាក់ល្អទេ ប៉ុន្តែអ្នកផងបានដឹង-ស្គាល់យ៉ាងច្បាស់ ។ ទំនាស់លើការប្រើប្រាស់ ឬកាន់កាប់ដី ជាទូទៅត្រូវបានដោះស្រាយតាមរយៈការចរចាររវាងអ្នកជិតខាង ដោយផ្អែកទៅតាមគោលការណ៍ និងទំនៀមទំលាប់ក្នុងសហគមន៍ ដែលមានជាការអនុគ្រោះគ្នាទៅវិញទៅមក និង/ឬការប៉ះប៉ូវខ្លះៗតាមការឯកភាពរវាងភាគីពាក់ព័ន្ធ ។ ក្នុងករណីខ្លះ ប្រធានភូមិអាចជួយសំរុះសំរួលអោយមានការព្រមព្រៀងគ្នាបាននៅពេលណាភាគីទាំងសងខាងមិនឯកភាពគ្នា ។ ជាលក្ខណៈប្រពៃណី នៅខេត្តរតនគិរី ចាស់ទុំក្នុងស្រុកបានដើរតួនាទីចំបងក្នុងការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងទំនាស់ដែលពាក់ព័ន្ធ ។ ក្នុងករណីទំនាស់លើដីកសិកម្មដែលពាក់ព័ន្ធដល់ប្រជាជននៅក្នុងភូមិផ្សេងៗគ្នា ភាគីមានទំនាស់អាចប្តឹងតវ៉ាទៅប្រធានភូមិរៀងៗខ្លួន ឬទៅអ្នកចាស់ទុំក្នុងភូមិដែលអាចជួយសំរួលការចរចាបាន ។

ទំនាស់ព្រំដីរវាងអ្នកជិតខាង បានប្រែប្រួលចរិតរបស់វា នៅពេលដីឡើងថ្លៃ និងមានការលក់ដូរច្រើនជាងមុន ។ មានចំណុចជាច្រើនដែលបង្កអោយមានទំនាស់ទាំងនេះ ។ ទី១ នៅពេលដីឡើងថ្លៃ ប្រជាជនមួយចំនួន ព្យាយាមទាមទារយកដីអោយបានច្រើនជាងមុន ។វិធីមួយដែលប្រជាជនបានប្រើដើម្បីទាមទារយកដីអោយបានច្រើនជាងមុន គឺការបង្ខិតបង្គោលរបងចូលទៅក្នុងដីអ្នកជិតខាង ។ ទី២ មានករណីជាច្រើនដែលប្រជាជនដាក់ពាក្យសុំប្លង់កាន់កាប់ដីធ្លីជាន់គ្នា ។ ការអះអាងកម្មសិទ្ធិជាន់គ្នានេះ គឺជាបញ្ហាធំមួយនៅក្នុងបរិបទនៃការលក់ដី ។ ចំណុចទី៣ ដែលប្រហែលជាចំណុចសំខាន់ជាងគេក្នុងការប្រែប្រួលចរិតនៃទំនាស់ គឺកំណើនការលក់ដីទៅឱ្យអ្នកនៅក្រៅសហគមន៍ ។ កាលពីមុនអ្នកជិតខាងគ្នាក្នុងភូមិតែមួយពឹងផ្អែកលើរបៀបរបបជាប្រពៃណី ដើម្បីដោះស្រាយទំនាស់ ប៉ុន្តែឥឡូវនេះជាញឹកញយការដោះស្រាយទំនាស់មានការចូលរួមពីប្រជាជនមូលដ្ឋានផង និងប្រជាជនពីក្រៅសហគមន៍ផង ។ ទំនាស់ជាច្រើនបានកើតឡើង នៅពេលដែលអ្នកមកពីក្រៅសហគមន៍ទិញដី ហើយធ្វើរបងដើម្បីពង្រឹង កម្មសិទ្ធិលើដីណាមួយ ។ ទំនាស់អាចជាប់ទាក់ទងនឹងព្រំដីជាក់ស្តែង និង/ឬការបិទផ្លូវដើរសាធារណៈ ។ ឧទាហរណ៍ នៅស្អាង អ្នកភូមិម្នាក់រាយការណ៍ថា អ្នកមកពីក្រៅភូមិម្នាក់បានសង់របងបិទផ្លូវដែលអ្នកភូមិដឹកសត្វពាហនៈចេញចូល ។ ទំនាស់បានកើតឡើងនៅពេលដែលអ្នកភូមិរុះរបងមួយចំណែកចេញ ។ នៅក្នុងករណីនេះ យុទ្ធសាស្រ្តបោះរបងដើម្បីបង្កើត ឬបញ្ជាក់សិទ្ធិលើដីណាមួយ វាអាចជាមូលហេតុនៃទំនាស់ផង និងជាមធ្យោបាយសំរាប់ដោះស្រាយ ឬចៀសវាងទំនាស់ក្នុងពេលអនាគតផង ។

### ៥.២.២ ទំនាស់នៅក្នុងគ្រួសារ

រូបភាពទូទៅមួយទៀតនៃទំនាស់ដីធ្លី ទាក់ទងនឹងដីមរតកដែលបងប្អូនបង្កើត ឬសមាជិកផ្សេងៗក្នុងគ្រួសារដណ្តើមគ្នា ។ ទំនាស់មួយទៀតដែលកើតមានច្រើនដែរ គឺដីស្ថិតនៅក្រោមការកាន់កាប់របស់អ្នកណាម្នាក់ ប៉ុន្តែប្រើប្រាស់ដោយសាច់ញាតិផ្សេងទៀត ។ ឧទាហរណ៍ នៅស្អាង មន្ត្រីមូលដ្ឋានបានរាយការណ៍ថា សមាជិកគ្រួសារដែលមកពីក្រៅភូមិ បានសុំប្រើប្រាស់ដីរបស់សាច់ញាតិ ។ ក្រោយពីដាំដុះលើដីបានប៉ុន្មានឆ្នាំមក សមាជិកគ្រួសាររូបនេះ បានរៀបចំសំណុំបែបបទសុំកាន់កាប់ដីដោយផ្អែកលើការដាំដុះរបស់ខ្លួនលើដីនោះ ។ ស្ត្រីអាចងាយរងគ្រោះដោយសារទំនាស់ដីធ្លីក្នុងរង្វង់គ្រួសារ ជាពិសេសនៅពេលដែលពួកគេមិនត្រូវបានបញ្ចូលជាផ្លូវការនៅក្នុងពាក្យសុំប្លង់ដី ឬនៅក្នុងប័ណ្ណប្លង់ដី ។ ស្ត្រីងាយរងគ្រោះនៅក្នុងទំនាស់ទាំងនេះ ពីព្រោះពួកគេច្រើនខ្វះខាតធនធានឯទៀតៗដែលធ្វើឱ្យពួកគេអាចរក្សាសិទ្ធិប្រើប្រាស់បាន និង/ឬមានលទ្ធភាពធ្វើសេចក្តីសំរេចផ្សេងៗ ។

### ៥.២.៣ ទំនាស់ជាមួយម្ចាស់បំណុល

នៅពាមរក៍ (ភូមិបាបោង) គេបានរាយការណ៍ពីទំនាស់ដីធ្លី ៣ករណី ដែលបានកើតឡើងនៅពេលម្ចាស់ដីយកដីទៅ

បញ្ចាំ ដើម្បីខ្ចីប្រាក់យកមកប្រើប្រាស់ក្នុងការដាំដុះ ។ នៅពេលកូនបំណុលមិនអាចសងវិញបានដោយសារបានផលតិច និង/ឬ លក់បានថោកនោះ ម្ចាស់បំណុលទាមទារការផ្ទេរកម្មសិទ្ធិដីទាំងមូល ឬមួយចំណែកមកឱ្យខ្លួន ។ ក្នុងទំនាស់បែបនេះ ស្ត្រីមេគ្រួ មានស្ថានភាពងាយរងគ្រោះខ្លាំងណាស់ ពីព្រោះពួកគេមានការពឹងផ្អែកច្រើនជាងអ្នកឯទៀត ទៅលើឥណទានសំរាប់ទិញធាតុចូលនានា ។ ករណីពីរក្នុង ចំណោមករណីទាំងបី ត្រូវបានអាជ្ញាធរមូលដ្ឋានធ្វើអន្តរគមន៍ជួយដោះស្រាយ ។

### ៥.២.៤ ទំនាស់រវាងអ្នកភូមិ និងរដ្ឋអំណាចមូលដ្ឋាន

ទំនាស់ដីធ្លីទាក់ទងនឹងអ្នកភូមិ និងរដ្ឋអំណាចមូលដ្ឋាន មានច្រើនរូបភាព ។ ទី១ គេបានរាយការណ៍ពីទំនាស់នៅកន្លែងខ្លះនៅពេលដែលប្រធានភូមិ និង/ឬប្រធានឃុំ បានលក់ដីភូមិទៅឱ្យក្រុមហ៊ុន ឬបុគ្គលនៅក្រៅភូមិ ។ ឧទាហរណ៍ នៅកំពតមានគេរាយការណ៍ពីករណីប្រធានឃុំ និងប្រធានភូមិ បានលក់ដីភូមិដោយគ្មានការពិគ្រោះយោបល់ជាមួយអ្នកភូមិ ឬការផ្ដល់សំណងប៉ះប៉ូវអ្វីឡើយ ។ នៅក្នុងករណីនេះ រដ្ឋអំណាចមូលដ្ឋានទទួលផលចំណេញផ្ទាល់ពីការលក់ ចំណែកឯអ្នកភូមិត្រូវបាត់បង់លទ្ធភាពប្រើប្រាស់ដីភូមិ ។ ក្នុងករណីខ្លះទៀត ទំនាស់បានកើតឡើងនៅពេលប្រជាជនចាប់យកដីសាធារណៈដែលរដ្ឋអំណាចមូលដ្ឋាន ឬអាជ្ញាធរស្រុកបានអះអាងកម្មសិទ្ធិ ។ ឧទាហរណ៍ ទំនាស់មួយនៅស្រុកស្អាង ទាក់ទងនឹងជនមាតុភូមិនិវត្តន៍មួយក្រុមកាលពីឆ្នាំ១៩៩២-៩៣ ដែលបានទៅតាំងទីលំនៅតាមមាត់ព្រែកដែលត្រូវបានចាត់ទុកជាដីសាធារណៈដោយរដ្ឋអំណាចមូលដ្ឋាន ។ នៅក្នុងករណីនេះ មន្ត្រីស្រុកបានហៅប៉ូលីសមូលដ្ឋានមកដេញជនមាតុភូមិនិវត្តន៍ចេញ ព្រោះគេបានចាត់ទុកថា បានតាំងទីលំនៅដោយខុសច្បាប់នៅលើដីជាប់ទាក់ទិន ។ បញ្ហាបែបនេះកាន់ស្មុគស្មាញនៅពេលដែលព្រំប្រទល់រវាងភូមិ និងការគ្រប់គ្រងដីសាធារណៈនៅក្នុងសហគមន៍ មិនត្រូវបានកំណត់ច្បាស់លាស់ទេនោះ ។

### ៥.២.៥ ទំនាស់រវាងដែនសមត្ថកិច្ចនៅមូលដ្ឋាន

នៅភ្នំស្រួច មានករណីប្រធានភូមិនៃភូមិមួយ បានកសាងសំណុំបែបបទសុំប្លង់ដីចំពោះដីក្នុងភូមិមួយទៀត ។ នៅស្រុកភ្នំស្រួចដដែល ទាហានខ្មែរក្រហមដែលចូលសារភាព បានបង្កើតជាឃុំដោយឡែកមួយដែលអាជ្ញាធរស៊ីវិលមិនទទួលស្គាល់ជាផ្លូវការទេ ។ នៅក្នុងឃុំនេះ អ្នកដឹកនាំអតីតទាហានខ្មែរក្រហម បានផ្ដល់សិទ្ធិលើការសុំកាន់កាប់ដីដែល DLMUPC មិនបានអនុញ្ញាតទេ ។ ប៉ុន្តែមេឃុំបានប្រាប់ថា ទោះបីជាគាត់មិនបានពាក់ព័ន្ធដោយផ្ទាល់នឹងសកម្មភាពផ្ដល់ប័ណ្ណកាន់កាប់ដីនៅក្នុងតំបន់នោះក៏ដោយ ក៏គាត់ត្រូវបានគេហៅម្ដងម្កាលអោយជួយដោះស្រាយទំនាស់ទាក់ទងនឹងការទាមទារសិទ្ធិលើដីធ្លីទាំងនេះ ។ នៅខេត្តរតនគីរី ប្រជាជនក្នុងភូមិតាអង១ បានទាមទារយកដី កំពុងប្រើប្រាស់ដោយអ្នកភូមិក្នុងភូមិរបង១ (ដែលនៅក្នុងស្រុកមួយផ្សេងទៀត) ។ អ្នកភូមិតាអងបានសំអាងថា ពួកខ្លួនបានប្រើប្រាស់ដីនេះនៅក្នុងរបបប៉ុលពត ។ អ្នកភូមិតាអងបានដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរស្រុក ឯអ្នកភូមិរបងធ្វើការតវ៉ាទៅអាជ្ញាធរខេត្ត ។ ករណីនេះបង្ហាញអោយឃើញថា ភាពមិនច្បាស់លាស់នៅក្នុងការកំណត់ដែនសមត្ថកិច្ច (យុត្តាធិការ) ខាងរដ្ឋបាល គឺជាប្រភពនៃទំនាស់ក្នុងការកាត់ក្ដីលើពាក្យបណ្ដឹង ព្រមទាំងបង្កើតឧបសគ្គដល់ការដោះស្រាយទំនាស់ទាំងនេះ ។

### ៥.២.៦ ទំនាស់ពាក់ព័ន្ធនឹងស្ថាប័នរដ្ឋ

រឿងមួយដែលលេចធ្លោជាងគេបំផុត គឺករណីយោធាកាន់កាប់ដីមួយចំនួននៅក្នុងពេលមានសង្គ្រាមជាមួយខ្មែរក្រហម ។ ក្រោយពេលខ្មែរក្រហមបានផ្ដាច់ខ្លួននៅឆ្នាំ១៩៩៧ ហើយសន្តិភាព និងសន្តិសុខ ក៏បានប្រសើរឡើង ខាងយោធានៅតែបន្តការគ្រប់គ្រងលើតំបន់នោះទៀត ។ ករណីទំនាស់ដីធ្លី រវាងប្រជាជនមូលដ្ឋាន និងយោធា ត្រូវបានគេរាយការណ៍នៅខេត្តកំពតនៅពេលប្រជាជនចាប់ផ្ដើមដាំដុះលើដីដែលទុកចោលទំនេរ ។ ករណីមួយពាក់ព័ន្ធនឹងដីប្រហែល ១០ហិកតាដែលប្រជាជន ៤០ គ្រួសារអះអាងថាជារបស់ខ្លួន ។ ដីនេះត្រូវយោធាទុកចោលទំនេរចាប់តាំងពីឆ្នាំ១៩៩៥ មក ។ ក្នុងភូមិ៤ នៅខេត្តកំពង់ស្ពឺ អ្នកភូមិបានទាមទារយកដីដែលយោធាកំពុងប្រើប្រាស់សំរាប់ការហ្វឹកហ្វឺនបាញ់កាំភ្លើងធំ ។ ក្នុងករណីនេះ គណៈកម្មការដោះស្រាយបាតុភាពដីធ្លីខេត្ត (LDSC) បានសំរេចប្រគល់ដីអោយទៅយោធា ។ ទំនាស់មួយប្រភេទទៀត គឺទាហានជាបុគ្គលទាមទារយកដី

ដែលគ្រប់គ្រងដោយអង្គភាពយោធា ។ ក្នុងករណីនេះ អង្គភាពយោធាបានប្រាប់ទាហានទាំងនោះថា ពួកគេរួមទាំងក្រុមគ្រួសារត្រូវប្រគល់ដីដែលខ្លួនបានតាំងទីលំនៅមកវិញក្នុងពេលអនាគត ។ ទាហានជាបុគ្គលបានបញ្ជាក់ថា នឹងប្តឹងទៅអាជ្ញាធរស៊ីវិលនៅមូលដ្ឋាន ប៉ុន្តែអាជ្ញាធរស៊ីវិលនៅថ្នាក់ខេត្តបញ្ជាក់ថា ខ្លួនគ្មានសមត្ថកិច្ចលើដីធ្លីដែលត្រួតត្រាដោយយោធាទេ ។

### *៥.២.៧ ទំនាស់រវាងអ្នកភូមិ និងក្រុមហ៊ុន ឬបុគ្គលជាឯកជន*

ករណីទាំងនេះ ពាក់ព័ន្ធទៅនឹងការរំលោភយកដី និងការផ្តល់ដីសម្បទាន ។ ឧទាហរណ៍ក្នុងស្រុកភ្នំស្រួច ប្រជាជនមួយក្រុមមាន ១០៨គ្រួសារបានរាយការណ៍ថា ខ្លួនបានបាត់បង់ដីដែលខាងយោធាបានលក់ទៅអោយក្រុមហ៊ុនកូរ៉េមួយសំរាប់ការដាំដំណាំកសិកម្ម ។ ក្រុមនេះរួមទាំងប្រធានភូមិផង បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរស្រុកយោធីថ្នាក់ស្រុកដែលបានបញ្ជូនករណីបន្តទៅ LDSC ថ្នាក់ខេត្ត បន្ទាប់មកទៀតដល់ LDSC ថ្នាក់ជាតិ ។ ប្រជាជនក្នុងភូមិ៤ បញ្ជាក់ថា ខ្លួនមិនទាន់បានឮអ្វីសោះពីដំណោះស្រាយចំពោះករណីនេះ ហើយខ្លួនចង់ប្តឹងទៅដល់អាជ្ញាធរថ្នាក់ខ្ពស់បំផុត ។ ប្រជាជនមានមតិថា ខ្លួនអាចទទួលយកសំណងជាដីនៅក្នុងតំបន់ដដែល ប៉ុន្តែមិនទទួលយកដីនៅក្រៅតំបន់នោះឡើយ ។ នៅខេត្តរតនគិរី ប្រជាជនក្នុង ៣ភូមិនៃស្រុកបរកែវបានដាក់ពាក្យប្តឹងទៅ LDSC ដោយចោទថាមានអ្នករត់ការម្នាក់ធ្វើការឱ្យបុគ្គលម្នាក់ទៀត បានយកដីរបស់ពួកគាត់តាមមធ្យោបាយក្លែងបន្លំ ។ ទោះបីតុលាការឱ្យអ្នករត់ការ និងបុគ្គល នៅពីក្រោយឈ្នះក៏ដោយ ក៏តុលាការបានកាត់ឱ្យមានសំណងប៉ះប៉ូវខ្លះទៅអោយភាគីចាញ់ក្តី ។ មានសេចក្តីរាយការណ៍ថា រឿងក្តីនឹងត្រូវបញ្ជូនឡើងដល់តុលាការកំពូល ។ នៅក្នុងខេត្តរតនគិរីដដែល ប្រជាជននៅភូមិតាអង១ បានរាយការណ៍ពីការរំលោភយកដីដោយមន្ត្រីរដ្ឋាភិបាលមកពីបានលុង ។ ករណីបែបនេះ ភាគច្រើនកើតមានចំពោះដីនៅតាមដងផ្លូវដែលប្រជាជនមូលដ្ឋានបានអនុញ្ញាតអោយមន្ត្រីទាំងនេះប្រើប្រាស់តាមសំណូមពរ ។ នៅក្នុងករណីខ្លះ ប្រជាជនមូលដ្ឋានព្រមទទួលយកសំណងប៉ះប៉ូវដើម្បីដោះស្រាយទំនាស់ ឯក្នុងករណីផ្សេងទៀត ប្រជាជនត្រូវបាត់បង់ដីដោយគ្មានបានសំណងអ្វីឡើយ ។

## ៥.៣ ការដោះស្រាយទំនាស់ដីធ្លី

ជាទូទៅមានយន្តការស្ថាប័ន ២ប្រភេទ ដែលត្រូវបានប្រើប្រាស់សំរាប់គ្រប់គ្រងការប្រើប្រាស់ដី និងការដោះស្រាយទំនាស់ដីធ្លី គឺមាន *យន្តការនៅសហគមន៍មូលដ្ឋាន*[២] និង *យន្តការផ្លូវការ* ។ យន្តការនៅសហគមន៍ ត្រូវបានប្រើប្រាស់នៅកំរិតមូលដ្ឋាន ដើម្បីដោះស្រាយទំនាស់រឿងប្រើប្រាស់ដីធ្លី និងទំនាស់ផ្សេងៗដែលជាប់ពាក់ព័ន្ធ និងដែលកើតមានឡើងរវាងអ្នកជិតខាង និង/ឬសាច់ញាតិ ។ យន្តការទាំងនេះបានពិភាក្សានៅខាងលើរួចហើយ ។ យន្តការផ្លូវការទាក់ទងនឹងអន្តរាគមន៍ដោយស្ថាប័នរដ្ឋ ។ យន្តការផ្លូវការសំរាប់ដោះស្រាយទំនាស់មាន ៣ប្រភេទជាចំបង ។ ជារឿយៗ ដំណើរដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា មានជាប់ទាក់ទងនឹងយន្តការទាំងជាផ្លូវការ និងក្រៅផ្លូវការក្នុងពេលជាមួយគ្នា ។

### *៥.៣.១ អាជ្ញាធរមូលដ្ឋាន*

ក្នុងរូបភាពខ្លះ ប្រធានភូមិ និងប្រធានឃុំ ដើរតួជាស្ពានចំលង រវាងយន្តការក្រៅផ្លូវការក្នុងសង្គម និងរចនាសម្ព័ន្ធផ្លូវការរបស់រដ្ឋ ។ អ្នកដឹកនាំទាំងនេះ ជាទូទៅប្រើប្រាស់ប្រពៃណី និងទំនៀមទំលាប់របស់មូលដ្ឋាន ដើម្បីដោះស្រាយទំនាស់រវាងអ្នកជិតខាង ឬនៅក្នុងគ្រួសារ ហើយក្នុងពេលជាមួយគ្នា ក៏តំណាងឱ្យអាជ្ញាធរស្របច្បាប់របស់រដ្ឋាភិបាលដែរ ។ គឺនៅថ្នាក់មូលដ្ឋាននេះហើយដែលការសំរេចចិត្ត និងសកម្មភាពរបស់អ្នកដឹកនាំនៅមូលដ្ឋានក្នុងសមត្ថកិច្ចជាអាជ្ញាធររដ្ឋាភិបាល ទទួលបាននូវកំលាំងស្របច្បាប់ និងពេញសិទ្ធិ ទោះបីនីតិវិធីដែលពួកគាត់ប្រើប្រាស់ មិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសខាងច្បាប់ក៏ដោយ ។ ចំណុចនេះគឺជាប្រភពមួយនៃការច្រឡំបល់អំពីច្បាប់គ្រប់គ្រងសិទ្ធិដីធ្លី និងជាចំណុចដែលការមិនទុកចិត្តទៅលើប្រព័ន្ធបានចាប់

២ ពាក្យនេះ ជួនកាលហៅថា យន្តការក្រៅផ្លូវការនៅក្នុងអត្ថបទនេះ ។

កកើតឡើង ។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកភូមិជារឿយៗបង្ហាញពីការមិនទុកចិត្តទៅលើមន្ត្រីនៅថ្នាក់ខេត្តដែលពួកគាត់យល់ថា មិនយល់ស្ថានការណ៍នៅមូលដ្ឋាន ។ ប្រជាជននៅមូលដ្ឋានក៏បានបង្ហាញពីការបារម្ភចំពោះអ្នកមកពីខាងក្រៅសហគមន៍ដែលប្រើប្រាស់នីតិវិធីច្បាប់ និងមានលទ្ធភាពប្រើប្រាស់នីតិវិធីនេះ ច្រើនជាងប្រជាជននៅមូលដ្ឋាន ។

### *៥.៣.២ តុលាការខេត្ត*

តាំងពីដើមទសវត្សរ៍១៩៩០ និងបន្ទាប់ពីមានកំណើនទំនាស់ដីធ្លីនៅក្រោយពីការចែកដីនៅឆ្នាំ១៩៨៩ មក តុលាការខេត្តត្រូវបានប្រើប្រាស់យ៉ាងច្រើនដោយអ្នកមានទំនាស់ ដើម្បីដោះស្រាយទំនាស់ដីធ្លី ។ ទំនាស់ភាគច្រើនជាប់ទាក់ទិននឹងព្រំដី, ការអះអាងកម្មសិទ្ធិជាន់គ្នាលើដីតែមួយ និងការបន្តមរតក ។ ករណីដែលមិនអាចដោះស្រាយបានរវាងអ្នកជិតខាង ទោះជាមានឬគ្មានអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានក៏ដោយ គឺត្រូវឡើងដល់តុលាការខេត្ត ។ ឧទាហរណ៍ មន្ត្រីតុលាការរាយការណ៍ថា មានករណីជាច្រើនពាក់ព័ន្ធនឹងទំនាស់រវាងបុគ្គល និងបុគ្គល ។ តុលាការត្រូវចេញសេចក្តីសំរេចលើករណីទាំងឡាយ ដោយផ្អែកលើច្បាប់ជាប់ទាក់ទិន ។ ក្នុងន័យនេះ តុលាការនឹងវិនិច្ឆ័យថា អ្នកណាត្រូវ និងអ្នកណាខុស ។

តុលាការខេត្តប្រឈមមុខនឹងកង្វះខាតទាំងខាងបុគ្គលិក និងហិរញ្ញវត្ថុ បើធៀបនឹងចំនួនករណីបណ្តឹងដែលត្រូវកាត់ក្តី ។ នៅគ្រប់ខេត្តទាំងអស់ តុលាការបានរាយការណ៍ថា មិនអាចកាត់ក្តីលើរាល់ករណីទំនាស់ដីធ្លីដែលបានទទួលបណ្តឹងទេ ។ ជាញឹកញាយករណីទំនាស់ដីធ្លី ត្រូវប្រជែងជាមួយករណីស៊ីវិលផ្សេងទៀត (ដូចជាការលែងលះ) និងករណីព្រហ្មទ័ណ្ឌ ដើម្បីទទួលការកាត់ក្តីពីតុលាការខេត្ត ។ ជាលទ្ធផល ទំនាស់ដីធ្លីជាច្រើនត្រូវពន្យាពេលកាត់ក្តី ពីមួយឆ្នាំទៅមួយឆ្នាំ (ដូចជា កំពត កណ្តាល កំពង់ស្ពឺ) ។ បញ្ហាមួយទៀតពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និងការត្រួតពិនិត្យចៅក្រម ។ មិនមែនចៅក្រមទាំងអស់សុទ្ធតែចេះច្បាប់ភូមិបាលនោះទេ ដូច្នេះអាចកាត់ក្តីខុសនឹងបទប្បញ្ញត្តិច្បាប់ ។ លើសពីនេះទៀត គេបានរាយការណ៍នៅក្នុងខេត្តមួយថា ប្រធានចៅក្រមខ្វះសិទ្ធិអំណាចក្នុងការគ្រប់គ្រងត្រួតពិនិត្យលើចៅក្រមថ្នាក់ក្រោមៗ ។ តារាង៥.១ ផ្តល់ទិន្នន័យសង្ខេបអំពីស្ថានភាពតុលាការខេត្ត ។

**តារាង៥.១. សង្ខេបករណីទំនាស់ដីធ្លី នៅតាមតុលាការខេត្ត**

| ទីកន្លែង | ចំនួនករណីសរុប (ឆ្នាំ២០០០) | ទំនាស់ដីធ្លី | ចំនួនករណីបាន ដោះស្រាយ | ចំនួនករណីមិន ទាន់ដោះស្រាយ | ករណីទំនាស់ដីធ្លី បំរែបំរួល |
|---|---|---|---|---|---|
| កណ្តាល | ១.១៥២ | ៦០០ | ៤០០ | ៦០០ | កើនឡើង |
| កំពត | មិនដឹង | ៧៦ | គ្មានតួលេខ | គ្មានតួលេខ | កើនឡើង |
| ព្រៃវែង | គ្មានតួលេខ | គ្មានតួលេខ | គ្មានតួលេខ | គ្មានតួលេខ | កើន២៥-៣០% ធៀបឆ្នាំ១៩៩០ |
| កំពង់ស្ពឺ | ប្រហែល ៥០០ | ប្រហែល ២០០ | ប្រហែល ២០០ | ប្រហែល ៣០០ | កើនឡើង |
| រតនគីរី | ១០០ | ដោះស្រាយបាន ៣/៤ | គ្មានតួលេខ | គ្មានតួលេខ | រំពឹងថានឹងកើន |

### *៥.៣.៣ គណៈកម្មការដោះស្រាយបាតុភាពដីធ្លី (LDSC)*

គណៈកម្មការទាំងនេះ ត្រូវបានរដ្ឋាភិបាលបង្កើតឡើងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ តាំងពីឆ្នាំ១៩៩៨ មក ក្នុងគោលដៅដោះស្រាយទំនាស់ដីធ្លីតាមរយៈការចរចា ដោយសារតុលាការទទួលករណីបណ្តឹងច្រើនលើសលុបពេក ។ LDSC ស្ថិតនៅក្រោមឱវាទរបស់ក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី និងមានក្រុមការងារនៅថ្នាក់ស្រុកផងដែរ ។ ជាទូទៅ អភិបាលរងខេត្តម្នាក់ធ្វើជាប្រធាន LDSC ថ្នាក់ខេត្ត ។ សមាជិកផ្សេងទៀត គឺជាមន្ត្រីមកពីមន្ទីររៀបចំដែនដីខេត្ត ការិយាល័យរៀបចំដែនដីស្រុក យោធា នគរបាល ក៏ដូចជាអភិបាលស្រុក មេឃុំ ប្រធានភូមិ មកពីតំបន់ដែលមានទំនាស់ ។

LDSC ថ្នាក់ខេត្ត ទទួលករណីដែលពាក់ព័ន្ធនឹងទំនាស់រវាងបុគ្គលនឹងស្ថាប័នរដ្ឋ ព្រមទាំងទំនាស់រវាងបុគ្គល និងបុគ្គល ។

LDCS ខិតខំសំរុះសំរួលឱ្យមានការព្រមព្រៀងរវាងភាគីទំនាស់តាមរយៈការសំរបសំរួលការចរចា ។ LDSC គ្មានអំនាចជាផ្លូវការ ដើម្បីធ្វើសេចក្តីសំរេចដោយផ្អែកលើច្បាប់ទេ ប៉ុន្តែគឺតំណាងអោយនីតិវិធីរដ្ឋបាល ដើម្បីសំរេចបាននូវកិច្ចព្រមព្រៀងគ្នា ។ វិធីសាស្រ្តជាមូលដ្ឋាន សំរាប់ដោះស្រាយករណីទំនាស់ទាំងនេះ គឺផ្អែកទៅលើយន្តការជាប្រពៃណីនៃការចរចាក្រៅផ្លូវការ និងការព្រមព្រៀងដែលអាចមានការសំរបសំរួលគ្នា, ការពុសបំបែកចំណុចមានទំនាស់ និង/ឬការប៉ះប៉ូវសងខ្លះៗ (ជាប្រាក់ជារបស់) ។ ឧទាហរណ៍ សមាជិកម្នាក់នៃក្រុមការងារនៅស្រុកកូនមុំ (នៅក្នុងខេត្តរតនគីរី) បានប្រាប់ថា វិធីសាស្រ្តដែលអនុវត្តបានល្អជាងគេក្នុងការដោះស្រាយករណីទំនាស់ គឺការប្រើប្រាស់ទំលាប់ប្រពៃណីនៅក្នុងមូលដ្ឋាន ដើម្បីសំរបសំរួលអោយមានកិច្ចព្រមព្រៀងរវាងភាគីទំនាស់គ្នា ។

នៅពេលយន្តការក្នុងមូលដ្ឋាន/សហគមន៍ មិនអាចធ្វើឱ្យមានកិច្ចព្រមព្រៀងគ្នាបាន គូភាគីមានទំនាស់ ឬមេឃុំ ជាអ្នកនាំយកករណីទៅដាក់ជូនយន្តការដោះស្រាយទំនាស់ថ្នាក់ស្រុកពិនិត្យ ។ បើសិនជាគណៈកម្មការថ្នាក់ស្រុកមិនអាចដោះស្រាយបាន ករណីអាចបញ្ជូនទៅ LDSC ថ្នាក់ខេត្ត ។ ករណីស្មុគស្មាញជាងនេះដែលពាក់ព័ន្ធដល់ស្ថាប័នរដ្ឋ ឬបុគ្គលមានអំណាច ជួនកាលត្រូវបញ្ជូនរហូតដល់ LDSC នៅថ្នាក់ជាតិ ។ ប៉ុន្តែ ករណីខ្លះអាចបញ្ជូនត្រឡប់មកតុលាការខេត្តវិញ ដើម្បីកាត់ក្តីជាចុងក្រោយ ។ ឧទាហរណ៍ ករណីនៅស្រុកបរកែវ ដែលបានលើកឡើងខាងលើ ត្រូវបានថ្នាក់ជាតិ បញ្ជូនមកតុលាការខេត្តរតនគីរីវិញ ។ ដូចបានបញ្ជាក់រួចមកហើយ ករណីនេះប្រហែលត្រូវបញ្ជូនទៅដល់តុលាការកំពូល ។ ឧទាហរណ៍មួយទៀតពាក់ព័ន្ធនឹងករណីបានលើកឡើងរួចហើយដែរ ក្នុងស្រុកភ្នំស្រួចដែលមាន ១០៨គ្រួសារបានបាត់បង់ដី ដោយសារការផ្តល់សម្បទានកសិកម្មទៅអោយក្រុមហ៊ុនកូរ៉េមួយ ។

LDSC រាយការណ៍ថា កន្លងមកអាចដោះស្រាយករណីបានមួយចំនួនដែរក្នុងចំណោមករណីនានាដែលបញ្ជូនមកដល់ខ្លួន (តារាង៥.២ និង ៥.៣) ។ ប៉ុន្តែ ការដោះស្រាយករណីទាំងនេះ ទាមទារពេលវេលា និងការចំណាយច្រើនណាស់ពីសំនាក់សមាជិក LDSC ក៏ដូចជាភាគីមានទំនាស់ ។ ឧទាហរណ៍ សមាជិក LDSC ក្នុងជំហានដំបូង ត្រូវធ្វើការស៊ើបអង្កេតករណីទំនាស់នៅទីកន្លែងជាក់ស្តែង ហើយជាញឹកញយ ការសំរបសំរួលកិច្ចចរចាររវាងភាគីទំនាស់គ្នា ក៏ត្រូវបានធ្វើឡើងនៅនឹងកន្លែងជាក់ស្តែងដែរ ។ LDSC ខ្លះបានប្រាប់ថា សំរាប់ករណីនិមួយៗអាចព្យាយាមដោះស្រាយរហូតដល់បីដង មុននឹងបញ្ជូនទៅថ្នាក់លើបន្ទាប់ ។ ទោះបីជាបានជោគជ័យក្នុងការដោះស្រាយករណីមួយចំនួនក៏ដោយ ក៏ LDSC ថ្នាក់ស្រុក និងថ្នាក់ខេត្ត បានរាយការណ៍ថា មិនអាចបម្រើយការងារចំពោះគ្រប់ករណីដែលបានបញ្ជូនមកដល់នោះទេ ហើយតែងមានករណីខ្លះត្រូវបានបន្សល់ទុកទៅឆ្នាំក្រោយជានិច្ច គ្រាន់តែតិច ឬច្រើន ។ ជាលទ្ធផល ក្នុងតំបន់ជាច្រើនករណីបណ្តឹងមិនទាន់ដោះស្រាយកើនឡើងជាប់រហូតក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ។

**តារាង៥.២ គណៈកម្មការដោះស្រាយបាតុភាពដីធ្លី (LDSC) ការសង្ខេបថ្នាក់ខេត្ត**

| ទីកន្លែង | សរុបចំនួនករណី | ឆ្នាំ១៩៩៩ | ឆ្នាំ២០០០ | ចំនួនករណីដោះស្រាយ/ មិនទាន់ដោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| កំពង់ស្ពឺ | ៤៨ | ២២ | ២៦ | ១៥/៣៤មិនទាន់ដោះស្រាយ | ១៩ មិនទាន់ស៊ើបអង្កេត |
| កណ្តាល | មិនដឹង | | ៣២ | ១៦/១០ | ៦ បញ្ជូនទៅកន្លែងផ្សេង |
| កំពត | ១២ | | | | |
| ព្រៃវែង | គ្មានតួលេខ | | | ៩៥% ប្តឹងទៅតុលាការ | |
| រតនគីរី | ប្រហែល ២០ | គ្មានតួលេខ | ២០ | ៤/៤ | ៦ ប្តឹងទៅកន្លែងផ្សេង ឯករណីផ្សេងទៀតមិនដឹង |

**តារាង៥.៣ សង្ខេបថ្នាក់ស្រុក**

| ទីកន្លែង | សរុបចំនួនករណី | ឆ្នាំ១៩៩៩ | ឆ្នាំ២០០០ | ចំនួនករណីដោះស្រាយហើយ/ មិនទាន់ដោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| ភ្នំស្រួច | គ្មានតួលេខ | | | | |
| ស្អាង | ២២ | | | ៩/៧ | ៦ បញ្ជូនទៅកន្លែងផ្សេង |
| កំពត | គ្មានតួលេខ | | | | |
| ពាមរក៏ | គ្មានតួលេខ | | | | |
| កួនមុំ | ៥ | គ្មានតួលេខ | ៥ | ៤/០ | ១ មិនត្រូវបានដោះស្រាយ |

LDSC ត្រូវជួបនឹងឧបសគ្គជាច្រើន ដូចជា កង្វះបុគ្គលិក ការបណ្តុះបណ្តាល និងថវិកា ទាំងនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ។ ទី១ LDSC គ្មានបុគ្គលិកអចិន្ត្រៃយ៍ទេ ព្រោះសមាជិកទាំងអស់សុទ្ធតែយកមកពីមន្ទីរ ឬស្ថាប័នផ្សេងៗ ។ ក្នុងករណីភាគច្រើន សមាជិក LDSC ពុំបានទទួលការបណ្តុះបណ្តាលជាផ្លូវការពីការដោះស្រាយទំនាស់ និងការចរចាទេ ព្រមទាំងមិនបានទទួលការបង្រៀនពីច្បាប់ដីធ្លីដែលជាប់ទាក់ទិនផង ។ ទី២ LDSC គ្មានថវិកាប្រតិបត្តិការសំរាប់ធ្វើការស៊ើបអង្កេត និងសំរបសំរួលការចរចាទេ ។ សមាជិកគណៈកម្មការត្រូវផ្តល់ថវិកាដោយខ្លួនឯងសំរាប់សកម្មភាពរបស់ខ្លួន និង/ឬទទួលវិភាគទានក្រៅផ្លូវការពីភាគីទំនាស់ សំរាប់ចំណាយធ្វើដំណើរហូបចុក សំភារៈ និងសោហ៊ុយផ្សេងៗទៀត ។ ដោយសារឧបសគ្គទាំងនេះពេលវេលា និងធនធានសំរាប់ធ្វើការងារដោះស្រាយករណីទំនាស់ដីធ្លីមានតិចតួចណាស់ ។ ជាការពិតហើយ របៀបរបបទទួលហិរញ្ញប្បទានក្រៅផ្លូវការអាចធ្វើអោយខូចខាតដល់អព្យាក្រិត្យភាពនៃ LDSC (បើសិនភាគីទំនាស់ណាមួយ ផ្តល់ថវិកាឱ្យធ្វើសកម្មភាព) ។

## ៥.៤ ការកត់សំគាល់

ទាំងតុលាការ ទាំង LDSC បានរាយការណ៍ថា បញ្ហាចំបងមួយដែលជួបប្រទះ គឺមនុស្សជាច្រើនដែលពាក់ព័ន្ធនឹងការងារដោះស្រាយទំនាស់មិនយល់ពីច្បាប់ និង/ឬនីតិវិធីជាប់ពាក់ព័ន្ធទេ ។ មូលហេតុមួយគឺអាចមកពីប្រជាជននៅមូលដ្ឋានដែលធ្លាប់តែពឹងផ្អែកទៅលើទំនៀមទំលាប់សហគមន៍សំរាប់ដោះស្រាយទំនាស់ គេរំពឹងថា នឹងមានការអនុវត្តស្រដៀងគ្នាដែរនៅក្នុងប្រព័ន្ធច្បាប់ជាផ្លូវការ ។ នៅពេលមានការសំរេចអោយពួកគាត់ចាញ់ក្តី ដោយយកច្បាប់មកសំអាង គាត់អាចមានអារម្មណ៍ថាគេបោកប្រាសពួកគាត់ ។ នៅក្នុងន័យនេះ ទំនាស់ដីធ្លីជាច្រើនដែលពាក់ព័ន្ធដល់ប្រជាជនមូលដ្ឋាន និងបុគ្គល ឬស្ថាប័ននៅក្រៅសហគមន៍ បានបង្ហាញឱ្យឃើញពីភាពខ្វាស់គ្នារវាងស្ថាប័នផ្លូវការ និងស្ថាប័ននៅមូលដ្ឋានដែលគ្រប់គ្រងកម្មសិទ្ធិដីធ្លី ។

បញ្ហាមួយចំនួនទៀតបានកើតមាននៅក្នុងការអនុវត្តន៍សេចក្តីសំរេច ។ ឧទាហរណ៍ តុលាការខេត្តកំពង់ស្ពឺ បានបញ្ជាក់ថា តុលាការមិនអាចផាកពិន័យ ឬធ្វើការចាប់ខ្លួនបានទេ ក្នុងករណីមានភាគីមួយមិនមកបង្ហាញខ្លួននៅតុលាការ ឬមិនគោរពសាលក្រមតុលាការ ។ តុលាការក៏បានអោយដឹងដែរថា ការអនុវត្តន៍ច្បាប់មានការលំបាក ជាពិសេសនៅពេលមានការពាក់ព័ន្ធនឹងបុគ្គល និង/ឬស្ថាប័នដែលមានអំណាច ។ ក្នុងការដាក់បង្ខំឱ្យអនុវត្តន៍ តុលាការច្រើនធ្វើការងារតាមរយៈបណ្តាញសង្គមដែលក្នុងនេះសមាជិកគ្រួសារ ឬនិយោជក ត្រូវបានអំពាវនាវឱ្យជួយជ្រោមជ្រែង ។ នេះគឺជាឧទាហរណ៍មួយទៀតនៃករណីប្រព័ន្ធផ្លូវការសំរាប់ដោះស្រាយទំនាស់ ត្រូវពឹងផ្អែកលើយន្តការក្រៅផ្លូវការ ដើម្បីគ្រប់គ្រងបញ្ហាកម្មសិទ្ធិដីធ្លី ។

ចំណុចមួយទៀតគឺ តុលាការខេត្តមានបន្ទុកករណីច្រើនជាង LDSC ថ្នាក់ខេត្ត និងថ្នាក់ស្រុក ។ មូលហេតុមួយគឺមកពី LDSC ទើបត្រូវបានបង្កើតឡើង ហើយមនុស្សជាច្រើននៅមិនទាន់ដឹងពីមុខងាររបស់ស្ថាប័ននេះនៅឡើយ ។ មូលហេតុទី២ គឺតុលាការមានកាតព្វកិច្ចទទួលគ្រប់ករណីបណ្តឹងទាំងអស់ ចំនែក LDSC មានសិទ្ធិសំរេចក្នុងការទទួលយកករណីទំនាស់ ឬក៏

បញ្ជូនវាទៅកន្លែងផ្សេង ។ ចំណុចទី៣ ដែលប្រហែលជាចំណុចសំខាន់ជាងគេ ជាប់ពាក់ព័ន្ធនឹងសមាសភាពនៃ LDSC ដោយសារស្ថាប័ននេះមានសមាជិកជាបុគ្គលមកពីស្ថាប័នមានអំណាច (ដូចជាយោធា និងប៉ូលីស) ។ ចំពោះមនុស្សជាច្រើន ជាពិសេសប្រជាជននៅមូលដ្ឋាន ការមានឋានៈសង្គមខុសគ្នាអាចធ្វើអោយពួកគាត់ភ័យខ្លាច ។ លើសពីនេះទៀត ប្រជាជនអាចជឿថានៅក្នុងករណីដែលពាក់ព័ន្ធនឹងស្ថាប័នរដ្ឋ ពួកគាត់មិនអាចទទួលបានការវិនិច្ឆ័យដោយយុត្តិធម៌ឡើយ ពីព្រោះករណីបណ្តឹងត្រូវបានសំរបសំរួលដោយបុគ្គលដែលតំណាងឱ្យស្ថាប័នពាក់ព័ន្ធក្នុងទំនាស់ ។ ក្នុងន័យនេះ ទំនាស់រវាងផលប្រយោជន៍ដែលអាចកើតមាននៅក្នុង LDSC អាចក្លាយជាឧបសគ្គខាងរចនាសម្ព័ន្ធដែលរាំងរាដល់ការដោះស្រាយទំនាស់ឱ្យបានសក្តិសិទ្ធិ ។ ជាលទ្ធផល អ្នកស្វែងរកអន្តរាគមន៍ពីភាគីទី៣ អាចនឹងសំរេចថា តុលាការគឺជាជំរើសល្អជាង LDSC ក្នុងការដោះស្រាយទំនាស់ ។ ប៉ុន្តែយ៉ាងនេះក៏មិនមែនមានន័យថា ប្រជាជនមានជំនឿច្រើនជាងទៅលើភាពសត្យានុម័តរបស់តុលាការនោះដែរ ។ ជាក់ស្តែងរឿងមួយដែលតែងផុសឡើងនៅក្នុងពេលឆ្លើយសម្ភាសន៍ គឺប្រជាជនខ្វះជំនឿលើភាពសត្យានុម័ត និងអព្យាក្រិតភាពរបស់ស្ថាប័នផ្លូវការ ហើយជាទូទៅពួកគេមានទំនុកចិត្តលើស្ថាប័ននៅនឹងមូលដ្ឋានច្រើនជាង ។

ទី៤ ចំនួនប្រៀបធៀបនៃករណីដែលតុលាការ និង LDSC ទទួលបាន គិតតាមប្រភេទទំនាស់ ពុំមានលក្ខណៈទៀងទាត់ទេ ពីព្រោះស្ថាប័នទាំងពីរនេះ មានទទួលករណីដូចគ្នាមួយចំនួនធំ ។ ស្ថានភាពនេះសបញ្ជាក់អោយឃើញថា គ្មានការបែងចែកច្បាស់លាស់រវាងដែនសមត្ថកិច្ចពាក់ព័ន្ធនឹងប្រភេទករណីដែលស្ថាប័ននីមួយៗទទួលយកឡើយ ។ ជាលទ្ធផល ស្ថាប័នទាំងពីរបានរាយការណ៍ថា បានពិនិត្យករណីដែលទាក់ទិនទៅនឹងទំនាស់ក្នុងគ្រួសារ, ទំនាស់រវាងគ្រួសារ ជាមួយនឹងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាទំនាស់រវាងគ្រួសារប្រជាជន និងស្ថាប័នរដ្ឋផងដែរ ។ ប៉ុន្តែ នៅមានចំណុចខុសគ្នាមួយគឺ LDSC ហាក់ដូចជាបានពិនិត្យករណីទំនាស់រវាងប្រជាជន និងអាជ្ញាធរមូលដ្ឋាន ឬក្រុមហ៊ុនផ្សេងៗច្រើនជាង ចំណែកឯតុលាការ បានពិនិត្យករណីទំនាស់រវាងបុគ្គលច្រើនជាង ។ ដូច្នេះហើយ ស្ថាប័នទាំងពីរ ជួនកាលហាក់ដូចជាធ្វើការងារប្រកួតប្រជែងគ្នាមិនមែនបំពេញអោយគ្នាទៅវិញទៅមកទេ ។

ទី៥ គឺចំណុចចាប់ផ្តើមនៃការប្តឹងផ្តល់មានលក្ខណៈផ្សេងៗគ្នាខ្លាំង ពីព្រោះជាញឹកញាប់ករណីដែលស្រដៀងៗគ្នាបានចាប់ផ្តើមឡើងនៅចំណុចខុសៗគ្នា និងនៅកំរិតខុសៗគ្នា នៅក្នុងប្រព័ន្ធដោះស្រាយទំនាស់ ។ ឧទាហរណ៍ ភាគីមួយចំនួនបានដាក់បណ្តឹងទៅ LDSC ថ្នាក់ស្រុក ឬថ្នាក់ខេត្តតែម្តង ដោយរំលងដំណើរការដោះស្រាយទំនាស់នៅមូលដ្ឋាន (ដូចជារំលងប្រធានភូមិ ឬមេឃុំ) ។ ក្នុងចំណុចនេះ គេឃើញថា ប្រជាជន ឬស្ថាប័ននៅក្រៅសហគមន៍ ច្រើនតែរំលងស្ថាប័នមូលដ្ឋាននៃការដោះស្រាយទំនាស់ ហើយប្តឹងទៅអាជ្ញាធរថ្នាក់លើផ្ទាល់តែម្តង ។ ការធ្វើដូច្នេះ អាចជាការកាត់បន្ថយអំណាចដល់ប្រជាជននៅមូលដ្ឋាន ។ ទន្ទឹមនេះដែរ មានភស្តុតាងខ្លះៗ (នៅពាមរក៍) ដែលបង្ហាញថា ប្រជាជនមូលដ្ឋានដែលមានចំណងទាក់ទងជាមួយថ្នាក់លើ អាចបញ្ជូនករណីរបស់ខ្លួនទៅឱ្យសាច់ញាតិ ឬមិត្តភក្តិ ដែលមានតួនាទីខ្ពស់នៅភ្នំពេញ ឬនៅខេត្ត។ អ្នកមានតួនាទីខ្ពស់នេះ បញ្ជូនករណីត្រឡប់ទៅតុលាការ ឬ LDSC វិញ តាមរយៈបណ្តាញក្រៅផ្លូវការ ។ ជារួមកត្តាទាំងអស់នេះបញ្ជាក់ថា ចំណុចចាប់ផ្តើមនៃពាក្យបណ្តឹងជួនកាលផ្អែកទៅលើការវាយតំលៃជាយុទ្ធសាស្ត្ររបស់អ្នកដែលមានខ្សែទំនាក់ទំនងដ៏មានអំណាច ដោយស្វះស្វែងរកច្រកណាដែលអំណោយផលដល់ខ្លួនគេបំផុត ។ ដំណើរការរបៀបនេះ ជាពិសេសគួបផ្សំជាមួយសមាសភាព LDSC ដូចបានរៀបរាប់ខាងលើនោះ អាចធ្វើអោយប្រជាជនបាត់ជំនឿលើអព្យាក្រិត្យភាពនៃប្រព័ន្ធ ហើយអាចជាមូលហេតុមួយដែលធ្វើអោយប្រជាជនជ្រើសយកវិធីក្រៅប្រព័ន្ធ ។

ចំណុចទី៦ គឺដំណើរការដោះស្រាយទំនាស់ ត្រូវចំណាយពេលវេលា និងធនធានហិរញ្ញវត្ថុច្រើនណាស់ ។ ការអស់សោហ៊ុយច្រើន មួយចំណែកគឺដោយសារ LDSC និងតុលាការសុទ្ធតែខ្វះធនធានសំរាប់ធ្វើការងាររបស់ខ្លួន ។ ចំណុចមួយទៀតដែលធ្វើអោយអស់សោហ៊ុយច្រើនជាពិសេសក្នុងករណីប្តឹងទៅតុលាការ គឺចំងាយផ្លូវពីភូមិទៅទីរួមខេត្ត ។ ប្រជាជនដែលខ្វះថវិកា និង/ឬពេលវេលា ដើម្បីធ្វើដំណើរទៅតុលាការនឹងជ្រើសរើសវិធីផ្សេងពីតុលាការ ជាពិសេសបើសិនគេយល់ឃើញជាមុនថា

ការកាត់ក្តីទំនងជានឹងលំអៀងទៅរកអ្នកដទៃហើយនោះ ។ ក្នុងន័យនេះ កង្វះខាតធនធានគឺជាឧបសគ្គខាងរចនាសម្ព័ន្ធមួយដែលរារាំងអ្នកចាញ់ប្រៀបគេនៅក្នុងសង្គម (ដូចជាកសិករក្រីក្រជាដើម) មិនអោយបានប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ។ ការផាត់ចេញបែបនេះកើតមានច្រើនណាស់ ចំពោះស្ត្រី ជាពិសេសស្ត្រីជាមេគ្រួដែលមិនសូវមានពេល និងថវិកាដូចជាបុរស ។

ចំណុចទី៧ គឺទាំងតុលាការ និង LDSC សុទ្ធតែមានការងារច្រើនលើសចំណុះ ក្នុងការដោះស្រាយករណីទំនាស់ដីធ្លី ។ ភស្តុតាងដ៏ជាក់លាក់បំផុត (បន្ថែមទៅលើសេចក្តីថ្លែងរបស់ចៅក្រម និងសមាជិក LDSC) គឺតួលេខនៅក្នុងតារាងខាងលើ ។ នៅសឹងតែគ្រប់កន្លែង សុទ្ធតែមានករណីដែលត្រូវបន្សល់ទុកទៅឆ្នាំក្រោយ ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលករណីបន្សល់ទុក (ពិសេសចំពោះតុលាការ) មានចំនួនច្រើនបំផុតនៅក្នុងខេត្តមានដង់ស៊ីតេប្រជាជនខ្ពស់ (ឧទាហរណ៍នៅខេត្តកណ្តាល) ហើយក្នុងនេះករណីទំនាស់ដីធ្លីនៅតំបន់ទីក្រុង និងជនបទ ត្រូវប្រជែងគ្នាជាមួយនឹងករណីទំនាស់ស៊ីវិល និងបទព្រហ្មទណ្ឌផ្សេងទៀត ។ សូម្បីករណីទំនាស់ក្នុងតំបន់ឆ្ងាយៗ (ដែល LDSC ទទួលយកតិចតួច) ក៏ឃើញមានមួយចំនួនត្រូវបន្សល់ទុកទៅឆ្នាំក្រោយ ឬក៏ត្រូវបញ្ជូនទៅកន្លែងផ្សេង ។ នៅក្នុងបទសំភាសន៏ស្ទើរតែទាំងអស់ សមាជិក LDSC និងគណៈកម្មការថ្នាក់ស្រុកបានប្រាប់ថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ន (ឧទាហរណ៏ ដែលមានកង្វះថវិកា និងបុគ្គលិក) ពួកខ្លួនត្រូវធ្វើការអស់ពីសមត្ថភាពហើយៗមិនអាចទទួលករណីបន្ថែមទៀតបានទេ ។ មូលហេតុមួយទៀតដែលធ្វើអោយ បន្ទុកការងារក្នុងប្រព័ន្ធ LDSC មានច្រើនលើសចំណុះ គឺមកពីវិធីសាស្ត្រដែលបានអនុវត្ត ។ ដូចមានបញ្ជាក់រួចហើយ LDSC មិនធ្វើការកាត់ក្តីដោយផ្អែកលើច្បាប់ឡើយ ប៉ុន្តែគ្រាន់តែសំរុះសំរួលឱ្យមានកិច្ចព្រមព្រៀង តាមរយៈការចរចារវាងភាគីទំនាស់ ។ ដំណើរការបែបនេះអាចចំណាយពេលច្រើនណាស់ ជាពិសេស នៅពេលដែលគូភាគីមិនឯកភាពគ្នា ហើយជាលទ្ធផលករណីនិមួយៗអាចចំណាយពេល និងការប្រឹងប្រែងអស់យ៉ាងច្រើន មុននឹងត្រូវបញ្ជូនទៅកន្លែងផ្សេងអោយដោះស្រាយ ។

ដើម្បីពិនិត្យពីលទ្ធភាពរបស់ស្ថាប័នផ្លូវការក្នុងការដោះស្រាយករណីទំនាស់ វិធីមួយគឺចាត់ទុកការដោះស្រាយទំនាស់ថាជាធនធានមួយដែលមានកំរិត និងដែលត្រូវបែងចែកទៅតាមប្រភពផ្សេងៗនៃតំរូវការដែលកំពុងប្រជែងគ្នា ។ ក្នុងនេះ ត្រូវមានការសំរេចចិត្តពីរបៀបបែងចែកពេលវេលា និងធនធាន ដើម្បីដោះស្រាយទំនាស់ ។ ឧទាហរណ៏ នៅពេលចោទសួរថា តើត្រូវផ្តល់អាទិភាពលើករណីទំនាស់បែបណា តុលាការខេត្តកណ្តាលបានប្រាប់ថា អាទិភាពត្រូវផ្តល់ចំពោះករណីព្រហ្មទ័ណ្ឌ ។ សមាជិកម្នាក់នៃ LDSC ខេត្តកំពង់ស្ពឺបានប្រាប់ថា អាទិភាពត្រូវផ្តល់ ចំពោះករណីដែលអាចជាប់ទាក់ទងដល់បញ្ហានយោបាយ ។ នៅកំពង់ ស្ពឺនេះដែរ ក៏មានការលើកឡើងថា ករណីដែលត្រូវដោះស្រាយ គឺអាស្រ័យទៅលើលទ្ធភាពរបស់ភាគីទំនាស់ក្នុងការផ្តល់ថវិកា សំរាប់ធ្វើការស៊ើបអង្កេត ។ កត្តាទាំងនេះ ដោយគួបផ្សំនឹងការស្វែងរកជំនួយទ្រទ្រង់ជាយុទ្ធសាស្ត្រពីបុគ្គល និងស្ថាប័នដូចបាន រៀបរាប់ខាងលើ អាចជាចំណុចខ្សោយដ៏ធំមួយដែលផុសចេញពីកង្វះថវិកា ក៏ដូចជាកង្វះបុគ្គលិក និងការបណ្តុះបណ្តាលសំរាប់ បុគ្គលិក ។

ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលប្រជាជននៅមូលដ្ឋានតែងមានទំនុកចិត្តលើស្ថាប័នប្រពៃណីនៅមូលដ្ឋាន សំរាប់ដោះស្រាយទំនាស់ច្រើនជាងស្ថាប័នផ្លូវការដែលនៅឆ្ងាយពីពួកគេ ។ បញ្ហាមួយចំណែកគឺ ប្រជាជនមូលដ្ឋានយល់ឃើញថា មន្ត្រីនៅថ្នាក់លើប្រហែលមិនខ្វល់ខ្វាយខិតខំស្វែងយល់ពីស្ថានការណ៏នៅមូលដ្ឋានទេ ។ នៅកំរិតមួយទៀត បញ្ហាវាជាប់ពាក់ព័ន្ធនឹងជំនឿដែលថា យុត្តិធម៌គឺសំរាប់តែអ្នកមានធនធាន និងមានអំណាចប៉ុណ្ណោះ ។ ដូច្នេះ គឺមានវិបត្តិអភិបាលកិច្ចទូទៅមួយ ពីព្រោះស្ថាប័នផ្លូវការសំរាប់ការដោះស្រាយទំនាស់ មិនត្រូវបានគេគិតថា មានយុត្តិធម៌ និងអព្យាក្រិត្យឡើយ ។

ជាការពិតហើយ អ្នកភូមិជាច្រើន ជាពិសេសអ្នកធ្លាប់មានទំនាស់ជាមួយបុគ្គល ឬស្ថាប័ននៅក្រៅសហគមន៏បានត្អូញត្អែរថា ពួកគេគ្មានលទ្ធភាពរ៉ាប់រងចំណាយដ៏ច្រើនសំរាប់ដោះស្រាយវិវាទទេ ។ អ្នកភូមិម្នាក់នៅស្អាងបានពន្យល់ពីបញ្ហាទាក់ទិននឹង LDSC ដូចតទៅៈ អ្នកមានធនធានច្រើន និង/ឬមានអំណាចអាចអូសវាឆ្លងកាត់ប្រព័ន្ធ រហូតទាល់តែបានលទ្ធផលដូចបំណង

របស់គេ ។ ដូច្នេះហើយ ករណីទំនាស់មួយចំនួនប្រហែលមិនបានដោះស្រាយទេ ពីព្រោះប្រជាជនដែលមានធនធានតិចតួច (ដូចជា ប្រាក់កាស ពេលវេលា) មិនជ្រើសយកប្រព័ន្ធដោះស្រាយជាផ្លូវការឡើយ ។ ហើយនេះគឺជាបញ្ហាដ៏ធំមួយចំពោះស្ត្រីជាមេគ្រួសារដែលច្រើនតែខ្វះខាតពេលវេលា និងធនធានជាងភាគីទំនាស់ជាបុរស ។

## ៥.៥ សេចក្តីសង្ខេប

ចំនួន និងចរិតនៃទំនាស់ដីធ្លី កំពុងកើនឡើង ដោយសារមានការប្រជែងយកដីដើម្បីផលប្រយោជន៍ផ្សេងៗគ្នា ។ បច្ចុប្បន្នទំនាស់ដីធ្លីកាន់តែកើតមានច្រើនឡើង រវាងប្រជាជនក្នុងភូមិ និងអ្នកមកពីក្រៅភូមិដែលមានទាំងក្រុមហ៊ុន និងអង្គភាពផ្សេងៗផង ។ ក្នុងការដោះស្រាយទំនាស់ភាគីវិវាទគ្នាកាន់តែពឹងពាក់ច្រើនទៅលើស្ថាប័នផ្លូវការដែលនៅឆ្ងាយជាបន្ថែមទៅលើអាជ្ញាធរនៅមូលដ្ឋាន ។ ការនេះបង្ហាញថា តំរូវការដោះស្រាយទំនាស់ដែលមានប្រើប្រាស់ទាំងយន្តការផ្លូវការ និងក្រៅផ្លូវការប្រហែលនឹងកើនឡើងយ៉ាងលឿន ។ កំណើននេះអាចធំលើសលប់ពេកសំរាប់ប្រព័ន្ធមួយដែលកំពុងមានរឿងក្តីនៅសល់ស្រាប់ទៅហើយ ។ កំហិតដ៏ធំជាងគេចំពោះសមត្ថភាពនៃប្រព័ន្ធផ្លូវការដើម្បីរ៉ាប់រងកំណើនករណីដ៏ស្មុគស្មាញនានាគឺ កង្វះខាត ថវិកា និងធនធានមនុស្ស ដោយរួមទាំងការបណ្តុះបណ្តាលអំពីច្បាប់ និងនីតិវិធីផងដែរ ។ ប្រព័ន្ធក្រៅផ្លូវការដែលជាគ្រឿងដំណោលពីរបបចាស់ បច្ចុប្បន្ននេះកំពុងចាប់ផ្តើមខ្វះខាតភាពស្របច្បាប់ តម្លាភាព និងសមកាលកម្ម (synchronisation) ជាមួយនឹងប្រព័ន្ធផ្លូវការ និងច្បាប់ ។

ទោះបីមានយន្តការផ្លូវការសំរាប់ដោះស្រាយទំនាស់ក៏ដោយ ក៏ប្រជាជនជាច្រើនយល់ឃើញថា វាគ្មានភាពយុត្តិធម៌ ដោយសារវាលំអៀងទៅខាងអ្នកដែលមានធនធានច្រើនជាង និងមានអំណាច ហើយវារារាំងដល់ការចូលរួមយ៉ាងពេញលេញ និងស្មើភាពពីសំណាក់ប្រជាជនដែលចាញ់ប្រៀបគេ (ឧទាហរណ៍ ជនក្រីក្រ ស្ត្រី ប្រជាជនដើម) ។ ដូច្នេះហើយ ដំណើរការដោះស្រាយវិវាទនៅក្នុងរចនាសម្ព័ន្ធ និងតាមបែបបទដូចកំពុងអនុវត្តសព្វថ្ងៃ ហាក់ដូចកំពុងជួបវិបត្តិនៃកង្វះខាតទំនុកចិត្ត ។

បញ្ហាមួយចំណែកដែលធ្វើអោយប្រជាជនគ្មានជំនឿលើប្រព័ន្ធ អាចជាប់ទាក់ទងផងដែរទៅនឹងកង្វះខាត ការយល់ដឹងពីច្បាប់ និងនីតិវិធីស្តីពីកម្មសិទ្ធិ ។ មូលហេតុម៉្យាង គឺមកពីកង្វះខាតការអប់រំ ។ មូលហេតុម៉្យាងទៀត គឺមកពីកង្វះខាតពត៌មានអំពីច្បាប់ និងនីតិវិធី ។ រឿងនេះកាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារកង្វះតម្លាភាព និងការអនុវត្តន៍ខ្ជាប់ខ្ជួនតាមនីតិវិធីពីសំណាក់គ្រប់ភាគីជាប់ពាក់ព័ន្ធ ។ ដោយសារប្រព័ន្ធក្រៅផ្លូវការមិនត្រូវបានពង្រឹងឡើងវិញ ហើយប្រព័ន្ធថ្មីត្រូវបានគេយល់ឃើញដូចមានបញ្ជាក់នៅខាងលើ វិបត្តិទំនុកចិត្តពិតជាមិនអាចចៀសផុតទេ ។ ដូចក្នុងប្រទេសមួយចំនួនដែលជួបបញ្ហាស្រដៀងៗគ្នា ករណីប្រជាជនប្រើប្រាស់យុទ្ធសាស្ត្រក្រៅច្បាប់ ដើម្បីឱ្យមានការកាត់ក្តីលំអៀងមកខាងខ្លួន ប្រហែលមិនអាចចៀសផុតទេ ហើយវាជាបញ្ហាមួយខាងអភិបាលកិច្ចល្អ ។

មាន "កត្តាបានជោគជ័យ" មួយចំនួនដែលគួរយកចិត្តទុកដាក់ ។ កត្តាចំបងៗដែលជំរុញឱ្យមានដំណោះស្រាយទំនាស់ប្រកបដោយជោគជ័យនោះគឺៈ (ក) ច្បាប់ដែលមានការយល់ដឹងជាទូទៅ (ខ) ជំនឿលើភាពអព្យាក្រឹត្យ និងយុត្តិធម៌នៃនីតិវិធី និង (គ) ការដាក់អនុវត្តន៍សេចក្តីសំរេចយ៉ាងសក្តិសិទ្ធិ ។ ឧទាហរណ៍ មូលហេតុមួយដែលធ្វើអោយទំនាស់ព្រំដី រវាងកសិករអាចដោះស្រាយបានជារឿយៗនៅថ្នាក់មូលដ្ឋាន គឺមកពីប្រជាជនមានការយល់ដឹងដូចគ្នាជាទូទៅ អំពីប្រពៃណី និងរបៀបរបបសំរាប់ដោះស្រាយទំនាស់បែបនេះ ។

# ជំពូក ៦

# គោលនយោបាយ និងអនុសាសន៍

## ៦.១ សេចក្តីផ្តើម

ការវាយតំលៃសង្គមនេះ សំដៅបង្កើនការយល់ដឹងសភាពការណ៍ពិតនៅមូលដ្ឋាន ដូច្នេះគេរំពឹងថា វាអាចជួយដល់ការងាររដ្ឋាភិបាលក្នុងការកសាងគោលនយោបាយសំរាប់ផ្តល់កម្មសិទ្ធិដីធ្លី ។ ឯកសារនេះបង្ហាញនូវករណី និងភស្តុតាងជាច្រើនដែលជាប់ពាក់ព័ន្ធដល់គោលនយោបាយ ។ ជំពូក៦ ប្រមូលផ្តុំចំណុចពាក់ព័ន្ធទាំងអស់នេះ ដើម្បីគេអាចជ្រើសរើសយកមួយចំនួន ឬទាំងអស់បញ្ចូលទៅក្នុងកញ្ចប់គោលនយោបាយ ។ គោលបំណងជាមូលដ្ឋាននៃជំពូកនេះ គឺតំរូវការពង្រឹងសន្តិភាព ផ្តល់យុត្តិធម៌ដល់ជនគ្រប់រូបជាពិសេស ប្រជាជនអ្នកទន់ខ្សោយ និងជួយជំរះបញ្ហានៅសេសសល់ទាំងឡាយខាងដីធ្លី ។ គេមិនរំពឹងថា គោលដៅអភិវឌ្ឍន៍ធំៗ នឹងត្រូវសំរេចបានដោយសារការផ្តល់ប័ណ្ណប្លង់ដីតែមួយមុខនេះទេ ពីព្រោះកម្មវិធីផ្តល់កម្មសិទ្ធិដីមិនមែនជាផែនការអភិវឌ្ឍន៍ទេ ។ ប៉ុន្តែ កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីមួយដែលមានជោគជ័យ នឹងជួយត្រួសត្រាយផ្លូវសំរាប់ការអនុវត្តន៏ផែនការអភិវឌ្ឍន៍ឱ្យបានកាន់តែសក្តិសិទ្ធិឡើង ។

## ៦.២ ការផ្តល់កម្មសិទ្ធិដីទៅតាមច្បាប់ និងការកំណត់លំដាប់សកម្មភាព

ដំណើរការផ្តល់កម្មសិទ្ធិដីធ្លី មិនគួរក្លាយជាការផ្តល់ប័ណ្ណជាស្វ័យប្រវត្តិដល់អ្នកកាន់កាប់ដីនៅពេលបច្ចុប្បន្ន ឬនៅកាលបរិច្ឆេទជាក់លាក់ណាមួយនោះទេ ។ ដោយសារគ្មានផែនទីបង្ហាញព្រំប្រទល់រវាងដីដែលកាន់កាប់ដោយអ្នកពាក់ព័ន្ធផ្សេងៗរួមទាំងមន្ទីរក្រសួងរដ្ឋផង និងដោយសារមានទំនាស់ដូចបានរៀបរាប់ខាងលើ ការផ្តល់ប័ណ្ណប្លង់ដី ដោយផ្អែកលើ "ការកាន់កាប់បច្ចុប្បន្ន" ទំនងជានឹងបង្កឱ្យមានបញ្ហាអនាធិបតេយ្យច្រើនដែលធ្វើអោយខូចខាតដល់ភាពស្របច្បាប់នៃការងារនេះ ។ ក្នុងបរិបទនេះ ការបកស្រាយ និងការអនុវត្តប្រកបដោយសុភវិនិច្ឆ័យនូវច្បាប់ដីធ្លី (ថ្មី) នៅក្នុងដំណើរការផ្តល់ប័ណ្ណប្លង់ដី គឺជាគន្លឹះនៃជោគជ័យចំពោះកម្មវិធីផ្តល់ប័ណ្ណប្លង់ដី ។ ដូច្នេះ ចាំបាច់ត្រូវតែបញ្ជាក់ខ្លះៗពីច្បាប់ថ្មី ។ ឯកសារនេះបានបង្ហាញយ៉ាងច្បាស់ហើយថា ទាំងអតិថិជន ទាំងមន្ត្រីរាជការ សុទ្ធតែមានការភាន់ច្រឡំអំពីច្បាប់ដែលមានស្រាប់ ។ នីតិវិធី និងការតំរូវផ្សេងៗបានធ្វើឱ្យអតិថិជនរាថយ ចំណែកខាងពួកមន្ត្រីមានការយល់ច្រឡំនៅក្នុងការបកស្រាយច្បាប់ និងចំនុចដែលគ្មានចែងក្នុងច្បាប់ ។ ដូច្នេះហើយ ភាពច្បាស់លាស់ ភាពសាមញ្ញ និងការផ្សព្វផ្សាយទូលាយនូវច្បាប់ដែលជាមូលដ្ឋាននៃដំណើរការផ្តល់កម្មសិទ្ធិ (ក្នុងករណីនេះ គឺច្បាប់ភូមិបាលថ្មីដែលនឹងត្រូវដាក់ជូនសភាអនុម័តក្នុងពេលឆាប់ៗ) គឺជាកត្តាគន្លឹះដែលនាំឱ្យមានជោគជ័យ ។

សំនួរមួយចំនួនដែលបានជួបប្រទះនៅក្នុងអង្កេត បានបង្ហាញពីតំរូវការកសាងច្បាប់ឱ្យមានន័យច្បាស់មិនអាចបកស្រាយបានច្រើនយ៉ាង ។ ច្បាប់ភូមិបាលកម្ពុជាដែលមានស្រាប់ បានកំណត់ពីទំហំអតិបរមានៃដីកាន់កាប់ ប៉ុន្តែដាក់ស្តែងប្រជាជនជា

ច្រើននាក់បានកាន់កាប់ដីលើសពីកំរិតកំណត់នេះ ។ តើច្បាប់គួរមានដាក់កំណត់ឬទេនូវទំហំដីអតិបរមាដែលបុគ្គលអាចកាន់កាប់បាន? តើគួរបំពេញឱ្យបានជាមុនឬយ៉ាងណានូវកំរិតកំណត់ក្នុងច្បាប់ស្តីពីទំហំដីធ្លី មុននឹងចាប់អនុវត្តកម្មវិធីផ្តល់ប័ណ្ណប្លង់ដី? ហើយគួរមានករណីលើកលែងដែរឬទេ? សំនួរទាំងនេះគួរតែយកចិត្តទុកដាក់ ពីព្រោះតួអង្គផ្សេងគ្នាបកស្រាយច្បាប់បច្ចុប្បន្នខុសៗគ្នា ។ ឧទាហរណ៍ មានការបកស្រាយមួយថា កំរិតកំណត់គឺអនុវត្តចំពោះតែការបែងចែកដីលើកដំបូងប៉ុណ្ណោះ មិនមែនកំណត់លើការទទួលបានដីលើកក្រោយៗទៀតនោះទេ[១] ។ បន្ទាប់មក មានបញ្ហាការកាន់កាប់ការចាប់យកដីដោយខុសច្បាប់ ទោះបីលើដីឯកជន ឬដីសាធារណៈក៏ដោយ ។ តើការកាន់កាប់ដីដោយខុសច្បាប់ដែលពុំមានអ្នកណាជំទាស់អស់រយៈពេលច្រើនឆ្នាំមកហើយបញ្ជាក់ អ្នកកាន់កាប់មានសិទ្ធិជាក់ស្តែងលើដីនោះបុ យ៉ាងណា? តើច្បាប់មានជំហរយ៉ាងដូចម្តេចក្នុងរឿងនេះ? តើចាំបាច់ត្រូវបញ្ជាក់ដែនសមត្ថកិច្ចរបស់ក្រសួងនីមួយៗក្នុងការប្រើប្រាស់ លក់ ឬជួលដីតាមដែលក្រសួងយល់ឃើញថាសមស្របនោះ អោយបានច្បាស់ឬទេ?[២] នៅមានបញ្ហាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ ហើយបើសិនជាគ្មានការបកស្រាយវិធាន និងនីតិវិធី ច្បាស់លាស់ទេនោះ បញ្ហាថ្មីៗទៀតនឹងបន្តផុសឡើង ។ សង្ខេបមក ច្បាប់ភូមិបាលថ្មី គួរមាន *ការបកស្រាយយ៉ាងច្បាស់គ្មានភាព ស្រពិចស្រពិល* និងក្លាយជាគោលការណ៍ណែនាំសំរាប់ការផ្តល់ប័ណ្ណប្លង់ដី ។

ការកំណត់លំដាប់ការងារនៅក្នុងការផ្តល់ប័ណ្ណប្លង់ដី អាចមានសារៈសំខាន់ខ្លាំង ។ ឧទាហរណ៍ អាចមានការខ្វាត់ខ្វាយប្រជាជនដែលរស់នៅតាមភូមិក្នុងព្រៃយ៉ាងធ្ងន់ធ្ងរ បើសិនព្រៃទាំងអស់ត្រូវបានចុះបញ្ជីជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយគ្មានគិតគូរដល់វត្តមាននៃប្រជាជនទាំងនេះ ។ ទំនាស់អាចកើតមានឡើងដែរនៅតាមតំបន់ជាយព្រៃ ដោយសារមានកសិករមួយចំនួន ទាមទារកម្មសិទ្ធិដីនៅត្រង់នោះ ។ ការដោះស្រាយទំនាស់នឹងត្រូវពិបាកខ្លាំង បើសិនគេចេញប័ណ្ណប្លង់ដីដោយមិនបានគិតគូរពីបញ្ហាអស់នេះ ពីព្រោះភាគីដែលបានប្លង់ដី នឹងនៅក្រាញតស៊ូយូរអង្វែងដើម្បីរក្សាកម្មសិទ្ធិរបស់គេ ។ នីតិវិធីក៏កាន់តែស្មុគស្មាញឡើងដែរ ពីព្រោះរឿងរ៉ាវត្រូវធ្លាក់ដល់អាជ្ញាធរមួយផ្សេងទៀត ។ បន្ទាប់មកគឺ បញ្ហាផ្លាស់ប្តូរការប្រើប្រាស់ដី (ក្នុងករណីនេះគឺផ្លាស់ពីដីព្រៃ មកជាដីកសិកម្ម) ។ ចំណុចចុងក្រោយ គឺប័ណ្ណប្លង់ដីទើបចេញថ្មី នឹងមានការកែតំរូវ ហើយវានឹងចោទបញ្ហាដល់ភាពស្របច្បាប់នៃដំណើរការទាំងមូល[៣] ។ នៅសឹងគ្រប់ខេត្ត អ្នកភូមិ អ្នកតំណាងសហគមន៍មូលដ្ឋាន ក៏ដូចជាមន្ត្រីរដ្ឋាភិបាល បានលើកមតិថា ការងារផ្តល់ប័ណ្ណប្លង់ដីគួរតែការពារដល់ជីវភាពជាមូលដ្ឋានរបស់ប្រជាជនទាំងអស់ ។ ក្នុងន័យនេះ កម្មវិធីផ្តល់ប្លង់ថ្មី គួរមានលំដាប់លំដោយដូចតទៅៈ ផ្តល់ប័ណ្ណសំរាប់ដីលំនៅស្ថានជាមុន បន្ទាប់មក ដីស្រែ ដីចំការ ហើយក្រោយមកទៀត ដីសាធារណៈដែលមានដូចជា ឆ្នេរសមុទ្រ ព្រៃឈើ ផ្លូវលំ និងផ្លូវថ្នល់[៤] ។ ព្រៃឈើ និងព្រៃលិចទឹក

១ ប្រភពៈ ការវិនិច្ឆ័យរបស់តុលាការនៅខេត្តរតនគិរី ។

២ ឯកសារនេះព្យាយាមឆ្លើយសំនួរខាងលើ ដោយផ្អែកលើស្ថានការជាក់ស្តែងនៅតាមមូលដ្ឋាន ។ ចម្លើយនឹងក្លាយជាមូលដ្ឋានសំរាប់បញ្ចូលបញ្ហានានាដែលគ្មានចែងក្នុងច្បាប់បច្ចុប្បន្នទៅក្នុងច្បាប់ថ្មី ។ ការកំនត់ចំនួនដីអតិបរមាដែលបុគ្គលអាចកាន់កាប់បាន មានសារៈសំខាន់ដោយធ្វើឱ្យដីធ្លីបានដល់ប្រជាជនច្រើននាក់បំផុត ។ ប្រជាជន ទាំងអស់ត្រូវការទីលំនៅ ហើយភាគច្រើនត្រូវការដីកសិកម្ម ពីព្រោះពហុវប្បកម្មការងារនៅមានកំរិតទាបនៅឡើយ ។ លើសពីនេះ មានមូលហេតុច្រើនដែលបង្ហាញ ថា កសិដ្ឋានតូចៗមានប្រសិទ្ធិភាពជាងនៅក្នុងបរិបទកម្ពុជាដែលខ្វះខាតធនធាន ដូចជា មូលធនកំលាំងអូសទាញ. ។ ទីផ្សារលក់ទិញធាតុចូល-ធាតុចេញ ក៏ដូចជា ហេដ្ឋារចនាសម្ព័ន្ធនៅទន់ខ្សោយនៅឡើយ ហើយមិនទាន់អនុញ្ញាតឱ្យយកចំណេញតាមសេដ្ឋកិច្ចវិមាត្របានទេ ។ ការសង្កេតនៅតាមមូលដ្ឋានបានបង្ហាញថា ដីធំៗជា ច្រើនត្រូវគេទិញទុកលក់យកចំនេញដោយមិនបានធ្វើផលិតកម្មអ្វីទេ ។ អាចមានករណីលើកលែងខ្លះចំពោះគំរោងធ្វើចំការខ្នាតធំ សំរាប់ផ្គត់ផ្គង់ទីផ្សារធំៗ ។ មុននឹង ផ្តល់ប័ណ្ណប្លង់ដី អាជ្ញាធរគួរផ្ទៀងផ្ទាត់ឱ្យហើយពីលក្ខណៈសមស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីទំហំដីអតិបរមា ពីព្រោះបើផ្តល់ប្លង់ហើយវាពិបាកសើរើណាស់ ។ ចំពោះ ការចាប់យកដីបើមានទំនាស់គួរមានការដោះស្រាយដោយអាជ្ញាធរពាក់ព័ន្ធសិន ។ ការកាន់កាប់ដោយគ្មានទំនាស់ បើសិនបានដំណើរការយូរមកហើយ (ឧទាហរណ៍ ៥ឆ្នាំ) គួរផ្តល់ភាពស្របច្បាប់ឱ្យអ្នកកាន់កាប់បច្ចុប្បន្នទៅ ។ ចំនុចចុងក្រោយគឺ ច្បាប់ភូមិបាលគួរបញ្ជាក់អោយបានច្បាស់ពីដែនសមត្ថកិច្ចរបស់ក្រសួងមន្ទីរនីមួយៗ ។

៣ អាចមានលទ្ធភាពផ្ទុយ កសិករទាមទារ និងរំលោភយកដីដែលមិនមែនជារបស់ខ្លួន ប៉ុន្តែស្ថានភាពកម្ពុជា យុត្តិធម៌ចំពោះកសិករតូចតាច សំខាន់ជាងបញ្ហាទាំងនេះ ។

៤ ការដាក់លំដាប់បែបនេះ គឺជាយោបល់របស់មនុស្សមួយចំនួនដែលមិនបានដឹងថាកម្មវិធីផ្តល់ប្លង់ដីថ្មី នឹងត្រូវអនុវត្តតាមរូបភាពជាប្រព័ន្ធ (systematic) ឬក៏ដោយ

ត្រូវមានដំណោះស្រាយមួយផ្សេង ដោយក្នុងនេះគួរមានការធានាសិទ្ធិប្រើប្រាស់ ផលិតផលព្រៃឈើ និងការអនុញ្ញាតឡើងវិញនូវសិទ្ធិនេសាទតាមប្រពៃណីរបស់សហគមន៍[៥] ។ គួរបញ្ជាក់ដែរថា គោលគំនិតស្តីពីការគ្រប់គ្រងព្រៃសហគមន៍ ឬការគ្រប់គ្រងព្រៃឈើរួមគ្នាដោយរដ្ឋាភិបាល និងសហគមន៍ គឺជាគំនិតមួយថ្មីនៅឡើយចំពោះប្រជាជននៅក្នុងតំបន់ដែលយើងបានធ្វើការសិក្សា ។ ប៉ុន្តែសំរាប់ប្រទេសកម្ពុជាវាមិនមែនជារឿងថ្មីទេ ហើយគេអាចដាក់បញ្ចូលវាជាបណ្តើរៗតែជាស្ថាពរបាន[៦] ។

## ៦.៣ ការពង្រឹង និងការធ្វើវិមជ្ឈការអាជ្ញាធរអភិបាលកិច្ចដីធ្លី

មានបញ្ហាមួយចំនួនដែលត្រូវលើកឡើងនៅក្នុងបរិបទនៃការគ្រប់គ្រងការផ្តល់ប័ណ្ណប្លង់ដី ។ បញ្ហាមួយចំនួនដែលបានផុសឡើងក្នុងពេលធ្វើការសិក្សា មានពិភាក្សាវែកញែកដូចតទៅនេះ ។

- មានការយល់ច្រឡំ និងការមិនសប្បាយចិត្តជាច្រើន ទាំងក្នុងមជ្ឈដ្ឋានអតិថិជន និងអាជ្ញាធរ ចំពោះការអនុវត្តន៍នីតិវិធី និងការធ្វើមជ្ឈការខ្លាំងពេកក្នុងការផ្តល់ប័ណ្ណប្លង់ដី ។ ប្រជាជនដែលមិនសូវមានទ្រព្យសម្បត្តិ ត្រូវចំណាយពេល និងថវិកាយ៉ាងច្រើន ហើយមានការខកលចិត្តទៀតផង ។ ដូចបានលើកឡើងរួចហើយ មូលហេតុមួយចំនួនដែលធ្វើឱ្យប្រជាជនមិនសុំប្លង់ដី គឺសោហ៊ុយខ្ពស់ និងការចំណាយកំលាំងច្រើន ។ ប្រជាជនមួយចំនួនដែលបាននិយាយពីរឿងនេះ គេមិនចូលចិត្តចំពោះការប្រមូលផ្តុំសិទ្ធិអំនាចនៅភ្នំពេញទេ ។ តាមបទសំភាសន៍នានានៅកំរិតភូមិអាចទាញការសន្និដ្ឋានបានថា អាជ្ញាធរចុងក្រោយ មិនគួរនៅជិតពេក និងមានលក្ខណៈជាបុគ្គលពេកទេ (ដើម្បីអោយមានភាពពេញច្បាប់) ប៉ុន្តែក៏មិនត្រូវនៅឆ្ងាយពេកដែរ ។ គេយល់ថា ស្រុកគឺជាកំរិតមួយដ៏ល្អសំរាប់បញ្ចប់ប្រតិបត្តិការផ្តល់ប័ណ្ណប្លង់ដី ។ អាជ្ញាធរថ្នាក់លើ (ថ្នាក់ខេត្ត និងថ្នាក់ជាតិ) គួរទទួលត្រឹមតែទិន្នន័យបូកសរុបជាតារាងសំរាប់ធ្វើជាឯកសារតំកល់ទុក ចំណែកឯកសារច្បាប់ដើមគួររក្សាទុកនៅថ្នាក់ស្រុក ។ ប៉ុន្តែការធ្វើវិមជ្ឈការនេះ អាចទាមទារការកសាងសមត្ថភាពច្រើននៅថ្នាក់ស្រុក គឺបានន័យថាត្រូវចំណាយថវិកាថែមទៀត ។ ដូច្នេះជាអនុសាសន៍មួយ គឺគោលការណ៍វិមជ្ឈការ គឺជាទិសដៅមួយដែលត្រូវប្រកាន់យក ប៉ុន្តែចំពោះបញ្ហាថាតើប្រតិបត្តិការនានាត្រូវចាប់ផ្តើមនៅកំរិតណាខ្លះ វាអាស្រ័យទៅលើលទ្ធភាពខាងរដ្ឋបាល ។
- សិទ្ធិអំនាចនៃស្ថាប័នថ្នាក់មូលដ្ឋាន (ភូមិ និងឃុំ) មិនគួរមានអ្នកណាម្នាក់បំពានទេ ។ គួរកំនត់ជាកាតព្វកិច្ចថារាល់លទ្ធកម្មដីធ្លី (លក់ ឬផ្ទេរ) ត្រូវឆ្លងកាត់តាមច្រកដែលបានកំនត់ហើយ គឺខុសពីពេលបច្ចុប្បន្នដែលអ្នកមានអំណាចមួយចំនួនចាប់ផ្តើមពីថ្នាក់លើមកមុន ហើយនៅចុងបញ្ចប់គ្រាន់តែប្រាប់អោយអាជ្ញាធរមូលដ្ឋានបានដឹងប៉ុណ្ណោះ[៧] ។ ការដែលគ្រប់ៗគ្នាអនុវត្តតាមនីតិវិធីមានសារៈសំខាន់ ទាំងដើម្បីរក្សាប្រសិទ្ធិភាពនៃច្បាប់ និងនីតិវិធីផង និងដើម្បីកសាងទំនុកចិត្តចំពោះប្រព័ន្ធផង ។
- តម្លាភាពក្នុងការងាររដ្ឋបាល គឺជាចំណុចស្នូលដើម្បីសំរេចបាននូវអភិបាលកិច្ចល្អ ។ តំរូវការចំណាយក្រៅផ្លូវការយ៉ាងច្រើនក្នុងពេលសព្វថ្ងៃ មិនត្រឹមតែបង្អាក់ចិត្តប្រជាជនមិនឱ្យធ្វើប័ណ្ណប្លង់ដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ភាពស្របច្បាប់នៃប្រព័ន្ធទៀតផង ។ មនុស្សជាច្រើនបានផ្តល់មតិថា គណៈកម្មការដែលស្រដៀងគ្នានឹងគណៈកម្មការអភិវឌ្ឍន៍ភូមិនៅក្នុងតំបន់សីលា គួរតែបង្កើតឡើងសំរាប់ការពិគ្រោះយោបល់ និងការតាមដានដំណើរការ

---

ចោះៗ (sporadic) នោះទេ ។ នៅក្នុងដំណើរការចុះបញ្ជីជាប្រព័ន្ធ លំដាប់ការងារត្រូវកំណត់តាមលក្ខណៈភូមិសាស្ត្រ មិនមែនតាមលំនាំនៃប្រើប្រាស់ដីទេ ។ ប៉ុន្តែទោះជាយ៉ាងដូច្នេះក្តី ក៏ការពិចារណាពីការព្រួយបារម្ភដែលគេបានលើកឡើងនៅតាមមូលដ្ឋាន គឺជាចំណុចមួយដ៏សំខាន់ ។

៥ រដ្ឋាភិបាលបានផ្តល់សិទ្ធិនេសាទដល់សហគមន៍ហើយ ។ អ្នកដែលបានដឹងរឿង បានស្វាគមន៍វិធានការណ៍នេះ ។

៦ NGOs មួយចំនួនបានអនុវត្តគោលគំនិតនេះក្នុងទ្រង់ទ្រាយតូចរួចមកហើយ នៅក្នុងប្រទេសកម្ពុជា ។

៧ សមាជិកនៃអាជ្ញាធរថ្នាក់ខេត្ត ក្នុងពីរខេត្តយ៉ាងតិច បាននិយាយដូច្នេះ ។

។ ក្រៅពីប្រធានភូមិ គណៈកម្មការអាចមានសមាជិក ជាចាស់ទុំក្នុងភូមិ ទាហានរំសាយ គ្រូបង្រៀនក្នុងភូមិ តំណាងស្រ្តី. ។ ខ្លះទៀតបានឱ្យយោបល់ថា គួរបង្កើតគណៈកម្មការឃុំវិញ ពីព្រោះឃុំប្រហែលនឹងក្លាយជាមែកធាងសំខាន់នៅក្នុងប្រព័ន្ធវិមជ្ឈការថ្មី ក្រោយពេលបោះឆ្នោតឃុំ ដែលគ្រោងធ្វើនៅដើមឆ្នាំ២០០២ ។ សរុបមក វត្តមានគណៈកម្មការតំណាងមួយសំរាប់តាមដានប្រតិបត្តិផ្សេងៗនៅថ្នាក់មូលដ្ឋាន នឹងមានប្រយោជន៏ច្រើន ។

- កន្លងមកមានកិច្ចព្រមព្រៀង និងការទិញដូរ តាមរយៈការផ្ទេរបង្កាន់ដៃ ប័ណ្ណប្លង់ដី ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៏អក្សរ ដោយមានអាជ្ញាធរច្រើននាក់បញ្ជាក់ថាត្រឹមត្រូវ ប៉ុន្តែការអនុវត្តន៏បែបនេះមិនមែនសុទ្ធតែត្រឹមត្រូវទៅតាមច្បាប់ទាំងអស់ទេ ។ ម្យ៉ាងវិញទៀត គេមិនអាចសើរើ និងកែតំរូវឯកសារចាស់ទាំងអស់បានទេ ។ ជាអនុសាសន៏សំរាប់បញ្ហានេះ គឺរាល់ករណីដែលគ្មានទំនាស់រវាងភាគីពាក់ព័ន្ធ គួរមានការទទួលស្គាល់ឱ្យទៅជាស្របច្បាប់ ។ ចំពោះករណីដីមានទំនាស់ត្រូវបញ្ជូនទៅឱ្យអាជ្ញាធរដោះស្រាយទំនាស់ពិនិត្យដោះស្រាយសិន មុននឹងចេញប័ណ្ណប្លង់ដីអោយ ។ នេះគឺជាគោលការណ៏ដែលគេបានអនុវត្តនៅក្នុងកម្មវិធីចុះបញ្ជីដីជាប្រព័ន្ធ ។
- បញ្ហាចៀសមិនផុតនៃកង្វះបុគ្គលិកនៅថ្នាក់មូលដ្ឋាន និងបុគ្គលិកច្រើនពេកនៅថ្នាក់លើ ត្រូវតែប្រឈមមុខដោះស្រាយតាមការអនុវត្តន៏គោលនយោបាយបុគ្គលិកមួយដែលមានលក្ខណៈប្រាកដនិយម ។

## ៦.៤ ការដោះស្រាយវិវាទ

### *៦.៤.១ ប្រព័ន្ធបែបប្រពៃណី*

សំរាប់ការដោះស្រាយវិវាទ ដោយសារមានប្រជាជនជាច្រើន ពិសេសនៅតាមតំបន់ជនបទ គេទុកចិត្តលើស្ថាប័នក្រៅផ្លូវការនៅក្នុងសហគមន៏ជាងស្ថាប័នផ្លូវការនានា ដូច្នេះវាជាការសំខាន់ដែលត្រូវពង្រឹងសមត្ថភាពនៃស្ថាប័នទាំងនេះ ដោយធ្វើឱ្យស៊ីសង្វាក់គ្នានឹងច្បាប់ភូមិបាលផង ។ វិធីសាស្រ្តល្អជាងគេ គឺការផ្តល់សិទ្ធិអំណាចអោយស្ថាប័ននៅកំរិតឃុំ ពីព្រោះក្នុងពេលដ៏ខ្លីខាងមុខ ថ្នាក់ឃុំនឹងមានអ្នកតំណាងដែលប្រជាជនបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ ។ ក្នុងនេះក្រុមប្រឹក្សាឃុំ-សង្កាត់គួរធ្វើការផ្សព្វផ្សាយច្បាប់ភូមិបាលតាមមធ្យោបាយផ្លូវការ និងក្រៅផ្លូវការដែលសក្តិសិទ្ធិបំផុត ឱ្យបានដល់ប្រជាជនយ៉ាងច្រើនបំផុត ។

គួរមានការប្រឹងប្រែងជាកំរិតអតិបរមាក្នុងការដោះស្រាយទំនាស់នៅថ្នាក់មូលដ្ឋានផ្ទាល់ ទោះបីចំពោះករណីដែលមានជាប់ពាក់ព័ន្ធនឹងស្ថាប័នរដ្ឋ ឬក្រុមហ៊ុនក៏ដោយ ។ ក្នុងគោលដៅនេះ ត្រូវពង្រឹងស្ថាប័នមូលដ្ឋាន ទាំងចំពោះដែនសមត្ថកិច្ច និងការអនុវត្តន៏ ។ ទាល់តែករណីដីធ្លីណាមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋាន ទើបគួរបញ្ជូនទៅអាជ្ញាធរថ្នាក់លើ ។

ចំពោះករណីមានស្រាប់ដែលមិនទាន់បានដោះស្រាយ គួរដោះស្រាយមួយម្តងៗតាមរយៈការប្រជុំជាបន្ថែមរបស់ក្រុមប្រឹក្សាឃុំ ឬអាជ្ញាធរស្រដៀងគ្នា (បើសិនមានការចាំបាច់) មុននឹងធ្វើការផ្តល់ប័ណ្ណប្លង់ដី ។ ផលចំណេញដ៏ធំមួយពីការអនុវត្តន៏ដូច្នេះ គឺក្រោយពីការផ្តល់ប័ណ្ណប្លង់ដី គ្មានបន្ទុកការងារបន្សល់ទុកពីអតីតកាលសំរាប់យកទៅដោះស្រាយក្នុងអនាគតឡើយ ។

### *៦.៤.២ ប្រព័ន្ធផ្លូវការ*

ក្នុងពេលបច្ចុប្បន ប្រព័ន្ធផ្លូវការសំរាប់ដោះស្រាយទំនាស់ដីធ្លី ខ្វះធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីដោះស្រាយបន្ទុកករណីដ៏ច្រើនឱ្យបានយុត្តិធម៌ដូចៗគ្នាសំរាប់ប្រជាជនទាំងអស់ ។ កំណើនក្នុងកំរិតណាមួយនៃករណីទំនាស់ នឹងបង្កើនបន្ទុកចំពោះយន្តការបច្ចុប្បន្ន ហើយធ្វើអោយប្រជាជនកាន់តែបាត់ទំនុកចិត្ត ។ ដើម្បីពង្រឹងប្រព័ន្ធផ្លូវការ នីតិវិធីសំរាប់ដាក់បណ្តឹង និងផ្លូវសំរាប់ប្តឹងឧទ្ធរណ៏ គួរតែបញ្ជាក់អោយបានច្បាស់ និងរៀបចំឱ្យសាមញ្ញ ។ គួរយកចិត្តទុកដាក់ខ្លាំងចំពោះការពង្រឹងសមត្ថភាពស្ថាប័ននៃ LDSCs ទាំងនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ។ ក្នុងនេះ LDSC ត្រូវមានថវិកាផ្ទាល់ និងមានកម្មវិធីបណ្តុះបណ្តាលសំរាប់បុគ្គលិកខ្លួន ។

*ការបញ្ជាក់នីតិវិធីអោយបានច្បាស់:* ករណីទាំងអស់គួរត្រូវបានដោះស្រាយទៅតាមស្មារតី និងខ្លឹមសារនៃច្បាប់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មសិទ្ធិដីធ្លី ។ ដំណើរការដោះស្រាយទំនាស់ ត្រូវធ្វើវិមជ្ឈការតាមលក្ខណៈមួយដែលស្របគ្នានឹងដំណើរការផ្តល់ប័ណ្ណប្លង់ដី ។ ជាគោលការណ៍សំរាប់គ្រប់ករណីទំនាស់ដីធ្លី ត្រូវដាក់បណ្តឹងទៅថ្នាក់មូលដ្ឋានមុន ។ ដូច្នេះនៅជំហានទី១ ត្រូវផ្តល់អាទិភាពទៅលើការដោះស្រាយទំនាស់នៅថ្នាក់មូលដ្ឋាន មុននឹងបញ្ជូនទៅអោយប្រព័ន្ធផ្លូវការ ។ ជាវិធីសាស្ត្រល្អគួរសិក្សាពីនីតិវិធីដែលគេប្រើនៅក្នុងគំរោងផ្តល់ប្លង់ដីជាប្រព័ន្ធ (របស់ GTZ និង FinnMap) ដែលមានជាអាទិ៍ ការប្រជុំជាសាធារណៈនៅថ្នាក់ឃុំ ដើម្បីបញ្ជាក់បំភ្លឺពីរឿងព្រំដី ។ ចំពោះករណីមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋានគួរបញ្ជូនតាមផ្លូវឧទ្ធរណ៍ដ៏ច្បាស់លាស់មួយពីសមត្ថកិច្ចមួយទៅសមត្ថកិច្ចមួយទៀត (ឧទាហរណ៍ គួរបញ្ជូនទៅថ្នាក់ស្រុកជាមុន បន្ទាប់មកទៅ LDSC...) ។ ទាំងតុលាការថ្នាក់ខេត្ត និងថ្នាក់ជាតិគួរមានសិទ្ធិអំណាចក្នុងការបដិសេធមិនទទួលយកករណីមួយចំនួន ។ ក្នុងន័យនេះ តុលាការ គួរមានភារកិច្ចសំរេចលើករណីដែលពាក់ព័ន្ធនឹងធម្មនុញ្ញនៃច្បាប់ ក៏ដូចជាករណីទំនាស់រវាងដែនសមត្ថកិច្ចផ្សេងៗ ។ ក្នុងតុលាការនីមួយៗ គួរមានការបង្កើតអង្គភាពពិសេសសំរាប់ដោះស្រាយទំនាស់ដីធ្លី នៅក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានចៅក្រម (Chief Justice) ដែលជាអ្នកទទួលខុសត្រូវធានាឱ្យរាល់ការវិនិច្ឆ័យទាំងអស់ ត្រូវបានធ្វើឡើងដោយត្រឹមត្រូវបំផុតទៅតាមច្បាប់ ស្តីពីកម្មសិទ្ធិដីធ្លី ។ ចៅក្រមដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងអង្គភាពដោះស្រាយទំនាស់ដីធ្លីគួរមានកំរិត ជំនាញខាងច្បាប់ក្នុងវិស័យច្បាប់ភូមិបាល ។

*ការកសាងសមត្ថភាពស្ថាប័ន:* ដើម្បីពង្រឹងសមត្ថភាពស្ថាប័ននៃប្រព័ន្ធវិមជ្ឈការដោះស្រាយទំនាស់ គួរមានការផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុបន្ថែមទៀតសំរាប់ថ្នាក់មូលដ្ឋាន (ដូចជា ប្រធានភូមិ មេឃុំ សមាជិកក្រុមប្រឹក្សាឃុំ) ។ ពាក់ព័ន្ធនឹងបញ្ហានេះ មានចំណុចបីដូចតទៅ:

- *ការបណ្តុះបណ្តាល:* មន្ត្រីថ្នាក់មូលដ្ឋាន សមាជិក LDSC និងចៅក្រមខេត្ត ជាញឹកញាយពុំមានការយល់ដឹងពីច្បាប់ និងនីតិវិធីដែលពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី និងការដោះស្រាយទំនាស់ច្បាស់លាស់ទេ ។ គួរផ្តល់ការបណ្តុះបណ្តាលសំរាប់មន្ត្រីពាក់ព័ន្ធនៅបីកំរិតខុសគ្នា: ១. អាជ្ញាធរមូលដ្ឋាន (ដូចជាប្រធានភូមិ មេឃុំសង្កាត់ បុគ្គលិកក្រុមប្រឹក្សាឃុំ) ២.សមាជិកនៃអាជ្ញាធរដីធ្លីថ្នាក់ស្រុក និងថ្នាក់ខេត្ត (រួមទាំងសមាជិក LDSC) និង ៣.តុលាការខេត្ត និងតុលាការជាតិ (ប្រធានចៅក្រម និងចៅក្រមឯទៀតដែលកាត់ក្តីករណីទំនាស់ដីធ្លី) ។ ការបណ្តុះបណ្តាលគួរផ្តោតលើច្បាប់ផ្សេងៗដែលពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី ព្រមទាំងបច្ចេកទេសក្នុងការចរចា និងដោះស្រាយទំនាស់ ។
- *សមាជិក LDSC:* បច្ចុប្បន្នសមាជិកនៃ LDSC បានមកពីមន្ទីរផ្សេងៗនៅថ្នាក់ខេត្ត ឬថ្នាក់ស្រុក ក្នុងនេះមួយចំនួនអាចតំណាងឱ្យផលប្រយោជន៍ផ្ទុយគ្នា ។ យោបល់នៅទីនេះគឺ សមាជិកនៃ LDSC គួរតែមិនចូលបក្សខាងណា និងជាមន្ត្រីស៊ីវិលទាំងអស់ ។ LDSC គួរមានបុគ្គលិកអចិន្ត្រៃយ៍ដែលទទួលបន្ទុក តែការងារខាងទំនាស់ដីធ្លី និងករណីដីធ្លីផ្សេងទៀតរួមទាំងការស៊ើបអង្កេត និងការផ្តល់អនុសាសន៍ ។
- *ហិរញ្ញប្បទាន:* អាជ្ញាធរដោះស្រាយទំនាស់ទាំងអស់ សុទ្ធតែគ្មានថវិកាសំរាប់ធ្វើការស៊ើបអង្កេត និងការចរចាករណីទំនាស់ដីធ្លីទេ ។ គួរផ្តល់ថវិកាអោយបានគ្រប់គ្រាន់ដល់ LDSC ដើម្បីធ្វើការស៊ើបអង្កេត និងសំរុះសំរួលករណី ។ ថវិកានេះគួរមានទាំងសំរាប់ការធ្វើដំណើរការហូបចុក សម្ភារៈផ្គត់ផ្គង់ និងចំណាយផ្សេងៗទៀត ។ ថវិកាផ្លូវការគួរត្រូវបានបំពេញបន្ថែមដោយប្រាក់កំរៃមួយចំនួនតូចដែលភាគីមានទំនាស់ត្រូវបង់ស្មើគ្នា ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

## ៦.៥ ការកំណត់គោលនយោបាយថ្មីស្តីពីទីជំរក និងការផ្លាស់ទីលំនៅ

កម្ពុជាមានគោលនយោបាយជួយផ្តល់ទីលំនៅដល់ប្រជាជនភៀសខ្លួនក្នុងរយៈពេលមានសង្គ្រាមស៊ីវិល ។ គោលនយោបាយនេះត្រូវពង្រីកថែមទៀត ដើម្បីជួយដល់ប្រជាជនដែលបានផ្លាស់ទីដោយបង្ខំចិត្តចេញពីដីលំនៅដ្ឋាន និងដីកសិកម្មរបស់ខ្លួននៅក្នុងជនបទ ព្រមទាំងប្រជាជនដែលត្រូវប៉ះពាល់ដោយការរុះរើសំណង់អនាធិបតេយ្យនៅក្នុងទីក្រុង[៨] ។ បញ្ហាពីរ គឺការផ្លាស់ទីលំនៅដោយបង្ខំចិត្ត និងចំណាកស្រុកពីជនបទមកទីក្រុង មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។ បាតុភាពនៃប្រជាជនផ្លាស់ទីពីជនបទមកកាន់កាប់ដីក្នុងតំបន់ទីក្រុង ក៏កើតមានដែរក្នុងប្រទេសឯទៀតៗ ប៉ុន្តែនៅកម្ពុជាវាធ្ងន់ធ្ងរជាពិសេសដោយសារមានទីក្រុងធំតែមួយគត់ ។ នៅក្នុងស្ថានភាពមួយដែលការអភិវឌ្ឍន៍ភាគច្រើនបំផុតប្រមូលផ្តុំតែនៅក្នុងទីក្រុងភ្នំពេញ តើគេអាចធ្វើអ្វីបានខ្លះ ដើម្បីបញ្ឈប់ការហូរចូលនៃប្រជាជនជនបទ? ដំណោះស្រា យមួយ គឺត្រូវលើកកំពស់គំរូអភិវឌ្ឍន៍មានតំបន់ស្នូលអោយបានច្រើន និងការបង្កើតការងារឱ្យបានច្រើនមុខ ។ ប៉ុន្តែក្នុងរយៈពេលខ្លី គេត្រូវគ្រប់គ្រងប្រព័ន្ធសព្វថ្ងៃឱ្យបានល្អ ដើម្បីបានទទួលផលប្រយោជន៍ទាំងអស់គ្នា ។

មានបញ្ហាបន្ទាន់មួយគឺការផ្លាស់ទីលំនៅប្រជាជនប្រហែល ៥000គ្រួសារ (១៥000នាក់) ដែលរស់នៅក្នុងតំបន់ខុសច្បាប់ និងដែលតំណាងឱ្យប្រហែល ១៥%នៃប្រជាជនសរុបក្នុងក្រុងភ្នំពេញ[៩] ។ គេមិនដឹងច្បាស់ទេថា ប្រជាជនទាំងនេះដែលរស់នៅក្នុងប្រហែល ២០កន្លែងផ្សេងគ្នា សុទ្ធតែកាន់កាប់ដីដោយខុសច្បាប់ទាំងអស់គ្នា, ប៉ុន្តែច្បាស់ជាមានមួយចំនួនខុសច្បាប់មែន ជាពិសេសអ្នកដែលរស់នៅតាមច្រាំងទន្លេ ដូចបញ្ជាក់ក្នុងករណីសិក្សាទី៦នៃឯកសារនេះ ។ ការសិក្សាបានបង្ហាញដែរថា មនុស្សមួយចំនួនដែលត្រូវបានផ្លាស់ទីលំនៅរួចហើយ ក៏ត្រលប់មកវិញទៀត ពីព្រោះជីវភាពនៅក្នុងកន្លែងថ្មីមិនធានាបាន ។

លទ្ធភាពមួយដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវអនុវត្តគោលនយោបាយសព្វជ្រុងជ្រោយមួយស្តីពីទីជំរក និងការផ្លាស់លំនៅដូចដែលគេបានធ្វើកន្លងមកនៅទីក្រុងជាច្រើននៅអាស៊ី និងអាមេរិកឡាទីន ។ មានគំរូប្លែកៗគ្នាជាច្រើន អាស្រ័យទៅតាមលទ្ធភាពហិរញ្ញវត្ថុ ភូមិសាស្ត្រទីក្រុង និងស្ថានភាពខាងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រជាជន ។ ជ័យជំនះនៃគោលនយោបាយវាអាស្រ័យផងដែរទៅតាមគោលនយោបាយអភិវឌ្ឍន៍គួបផ្សំផ្សេងៗ ដូចជាគោលនយោបាយបង្កើតការងារ និងបង្កើនចំណូលរបស់ប្រជាជនដែលមានការងារធ្វើ[១០] ។ ត្រូវមានការប្រុងប្រយ័ត្នមួយដែរគឺ សំណងប៉ះប៉ូវប្រាក់មានប្រយោជន៍តិចតួចណាស់ ពីព្រោះវាមានចំនួនតិចពេក ត្រូវចាយអស់យ៉ាងរហ័ស ហើយជាញឹកញយគឺចាយមិនត្រូវតាមគោលដៅដែលគេចង់បានផង ។

អ្នកកសាងនយោបាយ និងភ្នាក់ងារអភិវឌ្ឍន៍ភាគច្រើនយល់ថាទីក្រុងភ្នំពេញត្រូវមានការចែកតំបន់ត្រឹមត្រូវ ហើយការផ្លាស់លំនៅប្រជាជនត្រូវអនុវត្តតាមផែនការជាក់លាក់មួយ ។ ពួកគេជឿថា ក្រុងភ្នំពេញនឹងរីកធំជាងមុន ហើយប្រជាជនច្រើនទៀតនឹងចូលមករស់នៅក្នុងពេលអនាគត ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ផែនការតាំងទីលំនៅផ្អែកលើតំរូវការ និងការចូលរួមថវិកាមួយចំណែកពីប្រជាជន នោះដំណើរការនេះប្រហែលជាបានល្អជាងវិធីសាស្ត្រផ្សេងៗទៀត ។ ការពង្រីកក្រុងទៅភាគខាងលិចងាយអនុវត្តជាង ពីព្រោះភាគខាងកើតងាយរងគ្រោះដោយទឹកជំនន់ ។

ប៉ុន្តែការរើរុះផ្លាស់កន្លែងតាំងលំនៅអនាធិបតេយ្យក្នុងទីក្រុង មិនមែនជាការងាយស្រួលទេដោយសារមូលហេតុច្រើនយ៉ាងជាអាទិ៍ ចំណាយខ្ពស់ ចំណុចរសើបខាងនយោបាយ ចំណែកឯដីធ្លីនិងការងារ ក៏មិនអាចរកបានភ្លាមនៅកន្លែងថ្មីដែរ[១១] ។

---

៨ ទោះបីកម្មវិធីផ្លាស់ទីលំនៅជាច្រើននៅក្នុងពិភពលោកមិនបានជោគជ័យក្តី ក៏មានករណីខ្លះៗបានជោគជ័យដែរ ដូចជានៅចិន និងម៉ាឡេស៊ី ។ បរាជ័យជាទូទៅនេះមិនគួររារាំងការកសាង ឬការពឹងផ្អែកលើយុទ្ធសាស្ត្រផ្លាស់ទីលំនៅនោះទេ ។

៩ សាលាក្រុងភ្នំពេញបានផ្តល់តួលេខទាំងនេះ ។

១០ ពត៌មានលំអិតមាននៅក្នុងឯកសារ ILO (1999) ។

១១ គួររំលឹកថា ជនចំណាកស្រុកតែងមកតាំងទីលំនៅនៅកន្លែងដែលមានការងារធ្វើនៅជិតៗនោះ ។ បើសិនទៅនៅកន្លែងឆ្ងាយពីការងារពេក ពួកគេគ្មានលទ្ធភាព រ៉ាប់រងចំណាយធ្វើដំណើរទេ ។

ដំណោះស្រាយដាច់ណាត់បំផុត គឺធ្វើអោយស្របច្បាប់នូវទីតាំងលំនៅដែលអាជ្ញាធរមិនបានទទួលស្គាល់ ចាត់បញ្ចូលទីតាំងទាំងនេះជាកន្លែងប្រក្រតីដែលមានចំណូលទាប និងដោះស្រាយគ្រឿងផ្គត់ផ្គង់ការងាយស្រួលផ្សេងៗដែលទីក្រុងតែងផ្តល់អោយប្រជាជនរបស់ខ្លួន ។ ប៉ុន្តែការងារនេះ មិនមែនចេះតែធ្វើបានតាមចិត្តចង់នោះទេ ពីព្រោះអាចមានតំលៃខ្ពស់ពេក ហើយតំរូវការប្រជែងគ្នានូវដីធ្លីក៏អាចមានកំរិតខ្ពស់ខ្លាំង ។ វាក៏អាចទាក់ទាញអោយប្រជាជនហូរចូលទីក្រុងកាន់តែច្រើនថែមដែរ ។ ដូច្នេះហើយគោលនយោបាយចោះៗអាចអនុវត្តបានស្រួលជាង ។ នៅក្នុងប្រទេសជាច្រើន ទីលំនៅមិនស្របច្បាប់ត្រូវបានរៀបចំអោយទៅជាស្របច្បាប់ និងធ្វើចំណាត់ថ្នាក់ឡើងវិញ ប៉ុន្តែអ្នកតាំងទីលំនៅ ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅបន្តទៀត លុះត្រាតែគ្រួសារនោះបានរស់នៅក្នុងក្រុង ឬបានកាន់កាប់ដីនោះគ្រប់ចំនួនឆ្នាំតាមការកំណត់ ។ លក្ខខ័ណ្ឌផ្សេងទៀត អាចមានដូចជា ការមានប័ណ្ណគ្រួសារ ឬក្រដាសស្នាមផ្សេងទៀត ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន និងភស្តុតាងបញ្ជាក់ពីការធ្វើអាជីវកម្ម ការបំរើជីវិតជាដំរិះ ឬការបំពេញសេវាអ្វីមួយដែលស្របច្បាប់[១២] ។ ក្នុងស្ថានភាពខ្លះអាចមានដំណោះស្រាយដាច់ណាត់ផ្សេងទៀត ដូចជាការបង្កើតភូមិថ្មីនៅជាយក្រុងសំរាប់ប្រជាជនទាំងនេះតាំងលំនៅជាដើម ។ បន្ទាប់មកត្រូវប្រឹងប្រែងបង្កើតការងារថ្មីឱ្យពួកគេផ្តល់មីក្រូឥណទាន បង្កលក្ខណៈងាយស្រួលខាងទីផ្សារបណ្តុះបណ្តាលជំនាញថ្មីអោយពួកគេ. ។ ប៉ុន្តែជំរើសទាំងនេះមិនមែនថោកទេ ។

គេប៉ាន់ស្មានថា នៅតាមជនបទ ដីមិនប្រើប្រាស់ដែលមិនមែនជាដីព្រៃ មានប្រហែល ១,៧លានហិកតា[១៣] ។ អាចថាដីប្រភេទនេះប្រហែលមិនសមស្របសំរាប់កសិកម្ម ឬការតាំងលំនៅទាំងអស់ទេ ប៉ុន្តែមួយចំនួនធំ ពិតជាអាចប្រើប្រាស់បាន ។ ការសិក្សាអំពីដីធ្លីរបស់ Oxfam បានប៉ាន់ស្មានថា ៣%នៃគ្រួសារនៅក្នុងប្រទេសទាំងមូល មានទំនាស់ពាក់ព័ន្ធនឹងដីធ្លី[១៤] ។ គិតជាតួលេខអ្នកពឹងផ្អែកលើកសិកម្មមានប្រហែល ១,៥លានគ្រួសារ ដូច្នេះ ៣%នៃចំនួននេះត្រូវជា ៥០០០០គ្រួសារ ។ បើសិនជាគ្រួសារទាំងអស់នេះត្រូវផ្លាស់ប្តូរទីលំនៅ (ប្រហែលគ្មានព្រឹត្តិការណ៍បែបនេះទេ) ដីកសិកម្មសរុបដែលត្រូវមានសំរាប់ពួកគេ គឺតិចជាង ១០០០០០ហិកតា ឬតិចជាង ៧%នៃដីទុកចោលទំនេរ ។ សរុបមក គោលនយោបាយផ្លាស់ទីលំនៅក្នុងតំបន់ជនបទ គឺមានលទ្ធភាពអាចធ្វើបាន ទោះបីអនុវត្តតាមគោលការណ៍ "ដីដូរដី"ក៏ដោយ ។

## ៦.៦ ការទទួលស្គាល់សិទ្ធិប្រជាជនដើម

នៅក្នុងតំបន់មួយចំនួនដូចជាខេត្តរតនគិរីជាដើម គេឃើញមានប្រជាជនដើមរស់នៅទីនោះតាំងពីយូរណាស់មកហើយ ។ ពួកគេមានលំនាំប្រើប្រាស់ដី និងរបៀបរស់នៅខុសប្លែកពីប្រជាជន ខ្មែរភាគច្រើន, ប៉ុន្តែសព្វថ្ងៃលទ្ធភាពប្រើប្រាស់ដីជាប្រពៃណីរបស់ពួកគេកាន់តែខើចទៅៗ ដោយសារការផ្ទេរដីទៅឱ្យបុគ្គល ឬស្ថាប័នមកពីក្រៅសហគមន៍ ។ ការលក់ដី ការរំលោភយកដី និងការផ្តល់សម្បទានដីដោយរដ្ឋ បានបង្កឱ្យមានការផ្ទេរនេះឡើង ។

ត្រូវថ្លឹងថ្លែងធ្វើយ៉ាងណាអោយមានតុល្យភាពដ៏សមរម្យ រវាងកិច្ចការពារលទ្ធភាពជាប្រពៃណីរបស់ប្រជាជនដើមក្នុងការទាញយកផលនិងគ្រប់គ្រងលើដីសហគមន៍ និងការសំរេចគោលដៅអភិវឌ្ឍន៍ធំៗរបស់រដ្ឋដែលសំដៅលើកកំពស់កំរិតជីវភាពប្រជាជនក្នុងតំបន់ ។ សំរាប់រយៈពេលវែងគោលដៅបង្កើនកំរិតជីវភាព និងធ្វើឱ្យប្រាក់ចំណូលមានស្ថិរភាពជាងមុន ទាមទារនូវការប្រើប្រាស់ដីឱ្យមានផលិតភាពខ្ពស់ថែមទៀត ។ ចំពោះប្រជាជនភាគច្រើន គឺត្រូវមានការទទួលយកបច្ចេកទេសកសិកម្មមានផលិតភាពខ្ពស់ និងកសាងប្រភពចំណូលផ្សេងទៀតក្រៅពីលទ្ធ ភាពជាប្រពៃណីខាងធនធានព្រៃឈើ ។ ចំពោះប្រជាជនផ្សេងទៀត គេនឹងមានឱកាសច្រើនថែមទៀត ដើម្បីទទួលបាននូវការងារដែលផ្តល់ផលចំណេញ និងមានសុវត្ថិភាព ។

---

១២ ចំណុចនេះមិនមែនមានន័យថា ជនអត់ការងារធ្វើនឹងគ្មានកន្លែងរស់នៅក្នុងសង្គមទេ ។ គោលបំណងនៃការកំណត់ដូច្នេះ គឺដើម្បីផាត់ចេញនូវជនណាដែលពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ ឬអសីលធម៌ ។

១៣ Williams (1999) បានគណនាតួលេខនេះដោយផ្អែកលើប្រភពទិន្នន័យជាច្រើន ។

១៤សូមអានឯកសារ Bilddulph (2000:7) ។

ប៉ុន្តែគោលដៅរយៈពេលវែងទាំងនេះ ត្រូវបានរាំងស្ទះដោយលំនាំសព្វថ្ងៃនៃការផ្ទេរដីទៅឱ្យបុគ្គល និងស្ថាប័នមកពីក្រៅសហគមន៍ប្រជាជនដើម ហើយវាជាគ្រោះថ្នាក់អាចធ្វើឱ្យប្រជាជនបាត់បង់លទ្ធភាពប្រើប្រាស់ដីធ្លីដែលជាប្រពៃណីតែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍កុលសម្ព័ន្ធ ។ សំរាប់រយៈពេលខ្លី នីតិវិធីដីធ្លីត្រូវតែតាក់តែងឡើងដោយអនុលោមទៅតាមច្បាប់ដែលការពារលំនាំប្រើប្រាស់ដីជាប្រពៃណីរបស់ប្រជាជនដើម គឺព្រមៗគ្នានឹងការដាក់អនុវត្តន៍គោលដៅរយៈពេលវែង ។

វិធីសាស្ត្រសំរាប់ការពារសិទ្ធិប្រើប្រាស់ដីរបស់ប្រជាជនដើម គឺការកំនត់គោលការណ៍ផ្តល់ប័ណ្ណប្លង់ដីដល់សហគមន៍ ដែលក្នុងនេះសហគមន៍ត្រូវបានផ្តល់កម្មសិទ្ធិលើដីធ្លីដែលខ្លួនកំពុងគ្រប់គ្រង ។ បច្ចុប្បន្ន គេឃើញមានមានគំរូជាច្រើនដែលបង្ហាញថា គោលគំនិតនៃសិទ្ធិដីធ្លីរបស់សហគមន៍អាចអនុវត្តទៅបាន ។ ប៉ុន្តែការប្រឹងប្រែងអនុវត្ត ដូច្នេះអាចមានតំលៃខ្ពស់ផង និងចំណាយពេលច្រើនផង ។ ឧទាហរណ៍ គេត្រូវធ្វើអង្កេត និងធ្វើប្លង់ដីជាមុន ដើម្បីកំណត់ព្រំប្រទល់បានច្បាស់លាស់រវាងសហគមន៍នានា ។ ម្យ៉ាងវិញទៀត បែបបទអនុវត្តន៍នីតិវិធីនេះត្រូវតែកំណត់ជាមុនដោយ DLMUPCC ថ្នាក់ខេត្ត ដើម្បីអាចយកវាទៅអនុវត្តបានយ៉ាងសក្តិសិទ្ធិ និងមានប្រសិទ្ធិភាពសំរាប់ការផ្តល់ប័ណ្ណប្លង់ដីឱ្យសហគមន៍ជាច្រើនទៀត ។

សហគមន៍ត្រូវគ្រប់គ្រងដីធ្លីរបស់ខ្លួន ដោយអនុលោមតាមច្បាប់ទំលាប់នៅមូលដ្ឋាន និងឱ្យបានស្របតាមច្បាប់រដ្ឋដែលពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី ។ មួយចំណែកទៀត គួរបង្កើតវិធាន និងវិធីសាស្ត្រ សំរាប់គ្រប់គ្រងការបែងចែកដី និងសំរាប់គ្រប់គ្រងទំនាស់រវាងបុគ្គលមកពីសហគមន៍ផ្សេងគ្នា ឬក៏ទំនាស់រវាងសហគមន៍ និងសហគមន៍ ។ គួរយកចិត្តទុកដាក់ជាពិសេសចំពោះយន្តការនានាដែលអាចយកមកអនុវត្ត ដើម្បីធានាថា ប្រធានភូមិធ្វើសកម្មភាពដោយអនុលោមទៅតាមបំណងចង់បានរបស់សមាជិកសហគមន៍ ។ លើសពីនេះទៀតក្នុងការអនុវត្តន៍ជាក់ស្តែង ការគ្រប់គ្រងដីរបស់សហគមន៍ត្រូវធ្វើតាមវិធីមួយដែលទទួលស្គាល់កម្មសិទ្ធិរបស់បុគ្គលនៅលើដីជាក់លាក់មួយចំនួន រួមទាំងសិទ្ធិលក់ និងផ្ទេរ កម្មសិទ្ធិទៅឱ្យភាគីផ្សេងទាំងនៅក្នុង និងនៅក្រៅសហគមន៍ ។ ចំណុចទាំងនេះ និងបញ្ហាស្មុគស្មាញផ្សេងទៀត ត្រូវដោះស្រាយយ៉ាងល្អិតល្អន់ មុននឹងចាប់ដំណើរការផ្តល់ប័ណ្ណប្លង់ដីឱ្យសហគមន៍ ។

ដើម្បីចាត់វិធានការទាំងឡាយដូចខាងលើ រាជរដ្ឋាភិបាលគួររួមសហការជាមួយនឹងអង្គការសង្គមស៊ីវិល (ប្រសើរជាងធ្វើតែម្នាក់ឯង) ។ ដូច្នេះហើយ ក្នុងដំណើរការផ្តល់ប័ណ្ណប្លង់ដីសហគមន៍ ត្រូវមានការសហការយ៉ាងសកម្មរវាងវិស័យសាធារណៈ និងវិស័យឯកជន (រួមទាំង NGOs ដែលមានបទពិសោធន៍ក្នុងបញ្ហានេះផង) ។ គួរយកចិត្តទុកដាក់ធ្វើការសិក្សាថែមទៀតពីបទពិសោធន៍ដែលបានអនុវត្តកន្លងមក ។

នៅក្នុងតំបន់ដែលប្រជាជនដើមរស់នៅ គួរប្រឹងប្រែងធ្វើការផ្សព្វផ្សាយពតិមានជាពិសេសដល់ភាគីជាប់ពាក់ព័ន្ធទាំងអស់អំពីច្បាប់ស្តីពីការប្រើប្រាស់ និងកម្មសិទ្ធិដីធ្លី និងនីតិវិធីនៃការដោះស្រាយទំនាស់ដីធ្លី ។ ការងារនេះមានសារៈសំខាន់ជាពិសេសចំពោះពួកប្រជាជនដើមដែលភាសាខ្មែរមិនមែនជាភាសាទី១ សំរាប់ពួកគេនិយាយ ឬអាន ។ យុទ្ធនាការលើកកំពស់ ការយល់ដឹងជាសាធារណៈនេះ ទាមទារកិច្ចសហការគ្នាយ៉ាងសកម្មរវាងវិស័យសាធារណៈ និងឯកជន ។

## ៦.៧ ការទទួលស្គាល់សិទ្ធិស្ត្រី

ស្ថានភាពរបស់ស្ត្រី និងគ្រួសារមានស្ត្រីជាមេគ្រួ ទាមទារអោយមានការពិចារណាជាពិសេស ។ ស្ត្រីជួបនឹងឧបសគ្គខាងសេដ្ឋកិច្ច និងសង្គមកិច្ចជាច្រើន ដែលធ្វើអោយខូចខាតដល់សមត្ថភាពរបស់ពួកគេ ដើម្បីបានចូលត្រួតត្រា និងរក្សាការត្រួតត្រាលើដីធ្លី ។ ឧទាហរណ៍ ស្ត្រីងាយរងគ្រោះជាពិសេសក្នុងករណីមានការបែងចែកដីរបស់គ្រួសារ នៅពេលមានការលែងលះ ឬបន្តមរតក ។ បញ្ហាមួយ គឺពួកគេច្រើនតែមិនបានចុះឈ្មោះនៅក្នុងឯកសារដីធ្លី ។ បញ្ហាមួយទៀតគឺស្ត្រីច្រើនតែខ្វះពតិមានអំពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងដីធ្លី ហើយជាលទ្ធផល ស្ត្រីមិនអាចការពារកម្មសិទ្ធិរបស់ខ្លួនបានទេនៅពេលមានទំនាស់កើតឡើង ។ ស្ត្រី

មេគ្រួសារច្រើនតែខ្វះធនធានសំរាប់វិនិយោគក្នុងផលិតកម្មគ្រួសារ (ដូចជា សត្វពាហនៈ) និងម្ហូបដើម្បីដោះស្រាយតំរូវការប្រចាំថ្ងៃក្នុងគ្រួសារ ។ ចំពោះអ្នកដែលមានដីធ្លីជារឿយៗ ពួកគេច្រើនយកវាទៅដាក់បញ្ចាំ ឬយកទៅលក់ ដើម្បីបានប្រាក់សំរាប់ដោះស្រាយស្បៀងអាហារ ធុរៈបន្ទាន់ក្នុងគ្រួសារ (ដូចជាព្យាបាលជំងឺ) ឬធាតុចូលកសិកម្ម (agricultural inputs) ។

នៅក្នុងបរិបទនៃការអនុវត្តច្បាប់ភូមិបាលថ្មី គួរប្រឹងប្រែងជាពិសេសពង្រឹងលទ្ធភាពរបស់ស្ត្រីក្នុងការកាន់កាប់ដីធ្លី និងការដោះស្រាយទំនាស់[១៥] ។ ត្រូវកសាងច្បាប់ដែលធានាអោយស្ត្រីមានសិទ្ធិទទួលបាននូវការបែងចែកដីស្មើភាពគ្នា ក្នុងករណីមានការលែងលះ និងបន្តមរតកជាបន្ទាន់ ។ ត្រូវមានច្បាប់ធានាសិទ្ធិរបស់ស្ត្រីក្នុងការទទួលបាននូវការដោះស្រាយទំនាស់ដ៏ត្រឹមត្រូវ និងមិនលំអៀង ។ ជំហានមួយដ៏សំខាន់នៅក្នុងរឿងនេះ គឺកិច្ចសហការយ៉ាងសកម្មរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីផ្តល់ពត៌មានឱ្យស្ត្រីអំពីសិទ្ធិរបស់គេនៅក្នុងច្បាប់ភូមិបាលថ្មី ក៏ដូចជាជួយគាំទ្រដល់ស្ត្រីដើម្បីឱ្យមានលទ្ធភាពការពារសិទ្ធិរបស់ខ្លួន ។ ក្នុងការលើកកំពស់លទ្ធភាពរបស់ស្ត្រី ដើម្បីទទួលបានប្លង់ដី គេគួរពិចារណាពីការបង់កំរៃតាមអត្រាអនុគ្រោះសំរាប់ការធ្វើប័ណ្ណប្លង់ដី ។ វិធីនេះអាចមានសារៈសំខាន់ជាពិសេសចំពោះករណីស្ត្រីជាមេគ្រួ ។ អាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដី និងការដោះស្រាយទំនាស់ដីធ្លីគួរបានទទួលការបណ្តុះបណ្តាល និងសេចក្តីណែនាំស្តីពីសិទ្ធិរបស់ស្ត្រីដែលជាប់ទាក់ទងទៅនឹងច្បាប់ភូមិបាលថ្មី ។

គេគួរកត់សំគាល់ដែរថា ជោគជ័យក្នុងរយៈពេលវែងនៃគោលនយោបាយទាំងនេះ ក៏ពឹងផ្អែកទៅលើគោលនយោបាយអភិវឌ្ឍន៍ផ្សេងៗទៀតដែលសំដៅដោះស្រាយតំរូវការរបស់ស្ត្រីនៅក្នុងសង្គមផងដែរ គឺមានទាំងតំរូវការជាក់ស្តែង (ដូចជា ការអប់រំ ការថែទាំសុខភាព ប្រាក់ចំណូល) និងតំរូវការជាយុទ្ធសាស្ត្រ (ការចូលរួមយ៉ាងសកម្មនៅក្នុងការសំរេចផ្សេងៗដែលមានផលប៉ះពាល់ដល់គ្រួសារ និងសហគមន៍) ។ ក្នុងពេលជាមួយគ្នានេះ ការប្រឹងប្រែងទាំងឡាយ ដើម្បីពង្រឹងសុវត្ថិភាពនៃសិទ្ធិលើដីធ្លី ក៏អាចជួយបានយ៉ាងច្រើនក្នុងការលើកកំពស់ស្ថានភាពជាទូទៅរបស់ស្ត្រី ក៏ដូចជារបស់សង្គមទាំងមូល ។

## ៦.៨ ការធ្វើតាមបទពិសោធន៍ល្អបំផុត

មានបទពិសោធន៍ផ្តល់ប្លង់ដីដែលមានជោគជ័យជាច្រើន ក្នុងប្រទេសមួយចំនួននៅលើពិភពលោក ក្នុងនេះបទពិសោធន៍នៅថៃ និងឥណ្ឌូណេស៊ី បង្ហាញនូវចំណុចល្អៗជាពិសេស ។ នៅក្នុងប្រទេសកម្ពុជា MLMUPC ដោយមានជំនួយបច្ចេកទេសពី GTZ និង FinnMap បាននិងកំពុងអនុវត្តការផ្តល់ប័ណ្ណប្លង់ដីជាប្រព័ន្ធនៅក្នុងតំបន់មួយចំនួននៅតាកែវ កំពង់ធំ កំពត និងកំពង់សោម, ក្នុងលក្ខណៈជាការសាកល្បងដកបទពិសោធន៍ ។ ពួកគេប្រើប្រាស់រូបថតពីអាកាសដែលមានស្រាប់នៅគណៈកម្មាធិការទន្លេមេគង្គ ដើម្បីសំគាល់ដីកសិកម្មនីមួយៗ ។ ដោយសាររូបថតទាំងនេះត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រ ហើយគូរផែនទីមានមាត្រដ្ឋានច្បាស់លាស់ ដូច្នេះមិនអាចមានកំហុសក្នុងព្រំប្រទល់បានទេ ។ តាមការជួបប្រជុំគ្នានៅក្នុងភូមិ គេទទួលបានការឯកភាពគ្នាពីព្រំប្រទល់ដី បន្ទាប់មកទើបមានការចេញប័ណ្ណកម្មសិទ្ធិអោយ ដោយនៅលើប័ណ្ណនោះមានគំនូរផែនទីនៃដីមួយប្លង់ៗ ព្រមទាំងបរិស្ថានដែលនៅជុំវិញដីនោះ ។ បទពិសោធន៍កន្លងមកបង្ហាញថា បុគ្គលិករបស់ក្រសួងរៀនសូត្របច្ចេកទេសបកស្រាយផែនទីបានយ៉ាងរស់រហ័ស ។ គេប្រាប់ថា សំរាប់ប័ណ្ណនីមួយៗត្រូវចំណាយអស់ ១៥-២០ដុល្លារ រីឯការធ្វើតាមរបៀបដោយចោះៗវិញគឺត្រូវចំណាយលើសនេះ ២ដង[១៦] ។ ចំណែកឯពេលវេលាក៏ខ្ជីជាងច្រើនដែរ ។

---

១៥ អគ្គនាយកដ្ឋានសុរិយោដី ទើបនឹងកសាងបានស្ថិតិមួយដែលផ្អែកលើកំរូតាងប្រហែល ៥000ប្លង់ដី ហើយដែលបង្ហាញថា ប័ណ្ណប្លង់ដីភាគច្រើនបំផុត គឺជាប័ ណ្ណកាន់កាប់រួមគ្នាដោយចុះឈ្មោះទាំងបុរស និងស្ត្រី ។ ប្លង់ដែលមានឈ្មោះតែបុរសមានតិចតួច ហើយតិចជាងប្លង់ដែលមានឈ្មោះតែស្ត្រី ។ តួលេខទាំងនេះបង្ហាញថា ការមានឈ្មោះលើប្លង់ដីតែមួយផ្នែកមិនអាចនាំអោយមានសមភាពតួនាទីបុរស-ស្ត្រីទេ គោលនយោបាយនឹងត្រូវដោះស្រាយចំពោះសង្គមតួនាទីបុរស-ស្ត្រីទាំងមូល ។

១៦ ក្នុងការគណនានេះ គេមិនច្បាស់ទេថាតើបានបូកសោហ៊ុយចំនាយលើជំនាញការបរទេសចូលដែរទេដែលបច្ចុប្បន្នត្រូវចេញដោយរដ្ឋាភិបាលអាល្លឺម៉ង់ និងហ្វាំងឡង់ ។

ការផ្តល់ប័ណ្ណប្លង់ដីជាប្រព័ន្ធមិនអាចជំនួសការ "ព្រមព្រៀងរវាងមនុស្ស" បានទេ [១៧] ។ សំរាប់ដីលំនៅដ្ឋាន គ្មានអ្វីអាចមកជំនួសការពិគ្រោះយោបល់នៅមូលដ្ឋាន និងការដោះស្រាយព្រំប្រទល់ឡើយ ដោយហេតុថាដីលំនៅដ្ឋាន មិនអាចថតជាប់បានច្បាស់ល្អទេ ពីព្រោះវាតូចហើយមានដើមឈើច្រើន ។ សំរាប់ដីកសិកម្ម ផែនទីតាមរូបថតពីអាកាស អាចជួយផ្តល់នូវមូលដ្ឋានសត្យានុម័តសំរាប់ការកំណត់ព្រំដី ប៉ុន្តែក៏នៅតែមិនអាចជំនួសបាននូវការចុះអនុវត្តជាក់ស្តែង ឬការដោះស្រាយទំនាស់ ។ មេរៀនមួយដែលទទួលបានពីការចុះបញ្ជីជាប្រព័ន្ធ គឺបច្ចេកវិទ្យាវាជួយសំរួលការងារ ប៉ុន្តែមិនអាចជំនួសការគ្រប់គ្រងដោយច្បាប់ និងអភិបាលកិច្ចល្អបានទេ ។

មាន NGOs មួយចំនួន (ដូចជា Non-Timber Forest Product ក្នុងខេត្តរតនគីរី) បានជួយបង្កើតបទពិសោធន៍សំរាប់ការផ្តល់ប័ណ្ណប្លង់ដីសហគមន៍ ការដោះស្រាយទំនាស់ដីធ្លី និងការគ្រប់គ្រងព្រៃរួមគ្នា ។ អន្តរាគមន៍របស់ព្រះសង្ឃនៅក្នុងការដោះស្រាយទំនាស់ ក៏ទទួលបានជោគជ័យដែរ ។ ឯកសារនេះមិនអាចនិយាយលំអិតច្រើនអំពីអ្វីដែលមិនបានសង្កេតឃើញនៅក្នុងការចុះសិក្សាដល់មូលដ្ឋានទេ ប៉ុន្តែការបញ្ជាក់ខ្លះៗពីស្ថាប័ន និងបទពិសោធន៍ផ្សេងៗដែលជាប់ទាក់ទងនឹងការគ្រប់គ្រងដីធ្លី និងការដោះស្រាយទំនាស់ពិតជាមានប្រយោជន៍ ។

## ៦.៩ ការធ្វើហិរញ្ញប្បទានដល់ដំណើរការធ្វើប័ណ្ណប្លង់ដី

MLMUPC, DLMUPCCs ខេត្ត និង OLMUPCLs ស្រុក សុទ្ធតែគ្មានថវិកាគ្រប់គ្រាន់សំរាប់ចំណាយលើការផ្តល់ប័ណ្ណប្លង់ដី ។ ចំណាយប្រតិបត្តិការជាប់ទាក់ទិននឹងការធ្វើប័ណ្ណប្លង់ដី មានជាអាទិ៍ សំភារៈបរិក្ខារសំរាប់ធ្វើអង្កេតសុរិយោដី, គ្រឿងបរិក្ខាររដ្ឋបាល (ដូចជាកំព្យូទ័រ) សំភារៈការិយាល័យ មធ្យោបាយធ្វើដំណើរ និងបុគ្គលិក (ដូចជា ការបណ្តុះបណ្តាល និងប្រាក់បៀវត្សរ៍) ។ បច្ចុប្បន្ននេះ ប្រជាជនបង់ប្រាក់កំរៃមួយចំនួនតូចទៅឱ្យអាជ្ញាធរមូលដ្ឋាន ដើម្បីដាក់ពាក្យសុំប័ណ្ណប្លង់ដី ។ ប្រជាជនក៏ត្រូវបង់ប្រាក់កំរៃក្រៅផ្លូវការទៅអោយបុគ្គលិករដ្ឋាភិបាលនៅថ្នាក់ស្រុក និងថ្នាក់ខេត្តផងដែរ ដើម្បីដោះស្រាយបន្ទុកចំណាយលើការវាស់វែងដី និងការចេញប័ណ្ណប្លង់ដី ។ កំរៃក្រៅផ្លូវការទាំងនេះមានកំរិតខ្ពស់ណាស់ចំពោះលទ្ធភាពបច្ចុប្បន្នរបស់ប្រជាជនភាគច្រើន ហើយជាលទ្ធផល ប្រជាជនភាគច្រើនបានសំរេចចិត្តមិនស្វែងរកប័ណ្ណប្លង់ដី ។ ជាទូទៅ ពួកគេពឹងផ្អែកលើបង្កាន់ដៃទទួលពាក្យសុំប័ណ្ណប្លង់ដី សំរាប់បញ្ជាក់ពីសិទ្ធិរបស់ខ្លួនចំពោះដីណាមួយ ។ នៅក្នុងដំនើរការនេះ រដ្ឋក៏ត្រូវបាត់បង់ចំនូលយ៉ាងច្រើនដែរ ។ *គោលការណ៍ជាមាតិរួមគឺការផ្តល់ប័ណ្ណប្លង់ដីគួរមានតំលៃសមរម្យដែលប្រជាជនទាំងអស់អាចរ៉ាប់រងបាន* ។

អនុសាសន៍ដូចតទៅនេះ គួរត្រូវបានដាក់អនុវត្តនៅក្នុងបរិបទនៃគោលដៅនានា នៅក្នុងកំណែទំរង់ហិរញ្ញវត្ថុសាធារណៈរដ្ឋាភិបាលដែលកំពុងពិចារណាក្នុងពេលសព្វថ្ងៃ ។ កំណែទំរង់ទាំងនេះ តំរង់ទិសទៅរកប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយដែលមានលក្ខណៈវិមជ្ឈការ ហើយក្នុងនេះសេវាសាធារណៈត្រូវបានផ្តល់ហិរញ្ញប្បទានដោយចំណូលពន្ធដាររបស់រដ្ឋ និងម្ចាស់ជំនួយបរទេសក៏ដូចជា ការយកកំរៃពីអ្នកប្រើប្រាស់សេវា ។ ចំពោះការយកកំរៃពីអ្នកប្រើប្រាស់សេវា គោលការណ៍ជាមូលដ្ឋានគឺធ្វើយ៉ាងណាឱ្យការប្រមូលកំរៃផាត់ចំណាយនេះ មានប្រសិទ្ធិភាព តំលាភាព និងគណនេយ្យភាព ប្រសើរជាងមុន គឺបានន័យថា ការផ្គត់ផ្គង់សេវាជាក់លាក់ណាមួយ ត្រូវអាចឆ្លើយតបទៅនឹងតំរូវការបានសមស្រប ។

ដូចបានលើកឡើងរួចមកហើយ ចំណុចសំខាន់បំផុតគឺ ថវិកាដំណើរការសំរាប់រដ្ឋបាលគ្រប់កំរិតដែលពាក់ព័ន្ធនឹងការធ្វើប័ណ្ណប្លង់ដី គួរពង្រឹងឡើងតាមរយៈការផ្ទេរថវិកាផ្ទៃក្នុងរដ្ឋាភិបាល ។ ថវិកានេះគួរបំពេញបន្ថែមដោយចំណូលប្រាក់កំរៃដែលប្រជាជនបានបង់សំរាប់ការសុំប័ណ្ណប្លង់ដី និងសំរាប់ដំណើរការផ្តល់ប័ណ្ណប្លង់ដី ។ ប្រាក់កំរៃដ៏តូចដែលបានប្រមូលយកក្នុងពេល

---

១៧អនុក្រិត្យស្តីពីនីតិវិធីនៃការបង្កើត ផែនទីសុរិយោដី និងការចុះបញ្ជីដីធ្លី (RGC 2000) បានចែងយ៉ាងច្បាស់ថា នីតិវិធីនៃការពិគ្រោះយោបល់ដោយមនុស្សមិនអាចរំលងចោលបានទេ ។

បច្ចុប្បន្នសំរាប់ការសុំប័ណ្ណប្លង់ដី គួរបន្តប្រមូលយក ហើយអាចបង្កើនបន្ថិចថែមទៀតសំរាប់ការផ្តល់ប័ណ្ណ និងគួរមានអត្រាកើនឡើងទៅតាមតំលៃដី គឺបើដីថ្លៃខ្ពស់ គួរបង់កំរៃខ្ពស់តាមនោះដែរ ។ ចំណូលពីការយកកំរៃនេះ គួររក្សាទុកនៅនឹងអាជ្ញាធរដែលចេញប័ណ្ណប្លង់ដី ។ ការបង់ថ្លៃផ្សេងៗទៀតទាំងអស់ដែលជាប់ទាក់ទងនឹងដំណើរការធ្វើប័ណ្ណប្លង់ដី គួរធ្វើអោយមានលក្ខណៈជាផ្លូវការ ។ លើសពីនេះទៀត ប្រាក់កំរៃគួរមានលក្ខណៈឯកភាពគ្នាសំរាប់ប្រជាជនទាំងអស់ ហើយគួរផ្សព្វផ្សាយអត្រាត្រូវបង់ដែលកំណត់ដោយ MLMUPC ផងដែរ ។ ចំណូលបានមកពីប្រាក់កំរៃដែលជាប់ពាក់ព័ន្ធនឹងការអង្កេតសុរិយោដី និងការចេញប័ណ្ណប្លង់ដី គួរបែងចែកទៅអោយថ្នាក់ស្រុក និងថ្នាក់ខេត្ត សំរាប់ទូទាត់ចំណាយផ្សេងៗដែលជាប់ទាក់ទងនឹងដំណើរការធ្វើប័ណ្ណប្លង់ដី ។ វិធីសាស្ត្របែបរិមជ្ឈការនៃការយកកំរៃដើម្បីផាត់ចំនាយមួយចំនែកបែបនេះ នឹងជួយលើកកំពស់ចីរភាពក្នុងរយៈពេលវែងនៃដំណើរការធ្វើប័ណ្ណប្លង់ដី ។

ពន្ធលើការលក់ និងការផ្ទេរដីធ្លី អាចជាប្រភពដ៏សំខាន់មួយនៃចំណូលរបស់រដ្ឋ ។ បែបបទអនុវត្តន៍សព្វថ្ងៃ គឺ ៤%នៃតំលៃដីដែលលក់បាន ត្រូវបង់ទៅអោយមន្ទីរពន្ធដារខេត្តមុននឹងចេញប័ណ្ណប្លង់ដីអោយ ។ ប៉ុន្តែក្នុងករណីជាច្រើន ប្រជាជនដាក់តំលៃដីទាបជាងថ្លៃលក់ពិត ។ ក្នុងករណីជាច្រើនទៀត គេធ្វើការផ្ទេរកម្មសិទ្ធិដីធ្លីនៅខាងក្រៅដំណើរការផ្លូវការ ដូច្នេះហើយគ្មានការបង់ពន្ធទេ ។ របៀបអនុវត្តន៍ទាំងពីរបែបនេះ ធ្វើឱ្យរដ្ឋបាត់បង់ចំណូលច្រើនសំបើមណាស់ ។ ចំណុចសំខាន់មួយទៀតគឺការអនុវត្តន៍បែបនេះនាំអោយមានការច្របូកច្របល់ និងការយល់ខុសច្រើនណាស់ក្នុងចំណោមភាគីនានា អំពីលក្ខណៈវិនិច្ឆ័យសំរាប់ការទាមទារសិទ្ធិដោយស្របច្បាប់លើដីធ្លី ។ ពន្ធលើការលក់ និងផ្ទេរកម្មសិទ្ធិដីធ្លី គួរត្រូវបង់ឱ្យបានស្រេចបាច់មុននឹងផ្តល់ការយល់ព្រមលើការលក់ដូរ ។LDSC និងតុលាការមិនគួរទទួលស្គាល់ការអះអាងកម្មសិទ្ធិណាមួយដែលគ្មានការបង់ពន្ធទៅតាមនីតិវិធីបានកំណត់ហើយនោះទេ ។ ដើម្បីបញ្ជាក់នូវការអះអាងកម្មសិទ្ធិរបស់បុគ្គល ឬស្ថាប័ន (ដូចជាក្រុមហ៊ុនឯកជន) ចំពោះដីកន្លែងណាមួយ តុលាការគួរទាមទារឯកសារភស្តុតាងថា បានពន្ធបង់ហើយ ។

ដើម្បីសំរេចបាននូវប្រព័ន្ធពន្ធដារមួយដែលមានលក្ខណៈជឿនលឿន និងស្មើភាព ក្រុមហ៊ុន ឬបុគ្គល ដែលមានដីលើសពី ៥ហិកតា គួរបង់ពន្ធតាមអត្រាមួយដែលខ្ពស់ជាងកំរិតធម្មតា ។ ដើម្បីទប់ស្កាត់ទំលាប់របស់ប្រជាជនក្នុងការរាយការណ៍បន្ទាបតំលៃលក់ដី អាជ្ញាធរមូលដ្ឋានដែលចុះហត្ថលេខាលើការលក់ដីគួរបញ្ជាក់ថា តំលៃលក់នោះសមតាមតំលៃទីផ្សារនៃដីប្រភេទនោះ ។ នីតិវិធីនេះ គួរបំពេញបន្ថែមដោយការប្រឹងប្រែងពង្រឹងប្រព័ន្ធវាយតំលៃដីធ្លីនៅគ្រប់កំរិតថ្នាក់ដែលសមស្រប ។ វិធីមួយដែលគេអនុវត្តក្នុងប្រទេសមួយចំនួន គឺការដាក់អត្រាស្តង់ដាតាមតំបន់ (តាមតំបន់ជនបទ ទីក្រុង និងតាមការប្រើប្រាស់ដី) និងដោយផ្អែកលើការវាយតំលៃដីក្នុងពេលបច្ចុប្បន្ន ។ អត្រាស្តង់ដានេះ ត្រូវសើរើពិនត្យឡើងវិញរៀងរាល់ពីរ-ប្ញីឆ្នាំម្តង ។

## ៦.១០ ការបង្កើតទិន្នន័យនិងពត៌មាន និងការពង្រីកការអប់រំអំពីបញ្ហាដីធ្លី

ក្នុងពេលសព្វថ្ងៃ មានទិន្នន័យតិចតួចពេកសំរាប់សឹងតែគ្រប់ផ្នែកនៃសេដ្ឋកិច្ច និងសង្គម ហើយពតិមានរិតតែមានក្រខ្សត់ថែមទៀតសំរាប់ថ្នាក់មូលដ្ឋាន ។ ម្យ៉ាងវិញទៀត ចំពោះទិន្នន័យដែលមាន (ដូចជាពតិមានអំពីការផ្ទេរដីនៅថ្នាក់ភូមិ និងឃុំ) គេមិនបានចងក្រងវា និងរៀបចំបង្ហាញអោយបានល្អឡើយ ។ យុទ្ធសាស្ត្របង្កើតមូលដ្ឋានទិន្នន័យនៅថ្នាក់វិមជ្ឈការ វាមានសារៈសំខាន់ ទាំងសំរាប់ការធ្វើប្លង់ដី និងសំរាប់គោលដៅខាងការអភិវឌ្ឍន៍ ។ វិធីមួយដែលមានប្រសិទ្ធិភាពតំលៃ (cost effective) គឺមជ្ឈមណ្ឌលអង្កេតនៅថ្នាក់ភូមិ និងឃុំ ដែលទទួលបន្ទុកកត់ត្រាពតិមានស្តីពីអញ្ញាតជ្រើសរើស និងការប្រែប្រួលជាគន្លឹះមួយចំនួននៅក្នុងកំរិតរបស់ខ្លួនដែលគេអាចយកមកចងក្រងចូលគ្នានៅថ្នាក់ស្រុក និងថ្នាក់ខាងលើទៀត ។ មន្ត្រីដែលមានស្រាប់អាចធ្វើការងារនេះបាន ដូច្នេះមិនចាំបាច់ជ្រើសរើសបុគ្គលិកថែមទៀតឡើយ ។ មូលដ្ឋានទិន្នន័យទាំងនេះ គួរធ្វើចរន្តការ (updated) អោយបានទៀងទាត់ និងគួរផ្សព្វផ្សាយឱ្យបានទូលាយក្នុងចំណោមអ្នកប្រើប្រាស់ ហើយគួរកាត់បន្ថយការយឺតយ៉ាវទាំងក្នុងការចងក្រង និងការផ្សព្វផ្សាយនេះ ។ ប៉ុន្តែទិន្នន័យទាំងនេះមិនអាចជំនួសអង្កេតធំៗដែលគួរធ្វើយូរៗម្តងបានទេ ។

មកទល់សព្វថ្ងៃ មន្ទីរក្រសួងនានាបានរក្សាទុកមូលដ្ឋានទិន្នន័យរបស់ខ្លួន ។ ទិន្នន័យទាំងនេះមិនត្រូវបានផ្ទៀងផ្ទាត់ឱ្យស៊ីគ្នាទេ ហើយជាលទ្ធផល ក្រសួងផ្សេងគ្នាចេញគោលនយោបាយ និងយុទ្ធសាស្ត្រខុសគ្នា ដោយផ្អែកលើតួលេខខុសគ្នាសំរាប់រឿងដូចគ្នា ។ តំរូវការបង្កើតការិយាល័យស្ថិតិកណ្តាលមួយដែលទទួលបន្ទុកប្រមូលចងក្រង និងបន្សីគ្នានូវទិន្នន័យដែលបានប្រមូលហើយ គឺជាការសំខាន់ខ្លាំងណាស់ ។ នៅប្រទេសឯទៀតៗ ការិយាល័យបែបនេះ បំរើឱ្យស្ថាប័នរដ្ឋាភិបាល និងអង្គការជាប់ពាក់ព័ន្ធទាំងអស់ ព្រមទាំងបោះពុម្ពផ្សាយ និងលក់ទិន្នន័យទៀតផង ។ គំរូនេះគួរតែយកមកអនុវត្តនៅកម្ពុជាផងដែរ ។

កំរិតអក្ខរកម្មនៅកម្ពុជា មិនសូវខ្ពស់ទេ ហើយវាមានកំរិតទាបនៅតាមជនបទ ជាពិសេសចំពោះប្រជាជនវ័យចំណាស់ និងស្ត្រី ។ ប្រជាជនភាគច្រើននៅក្នុងភូមិ មិនដឹងអំពីច្បាប់ និងមិនសូវយល់អំពីនីតិវិធីនៃការចុះបញ្ជី ការផ្ទេរ និងការបន្តមរតកដីធ្លី ។ នៅភូមិមួយនៅក្នុងស្រុកកំពត ប្រជាជននិយាយថា ផ្នែកសំខាន់ៗនៃច្បាប់ភូមិបាលជាអាទិ៍ នីតិវិធី ការបង់កំរៃសំរាប់សេវាផ្សេងៗ និងនីតិវិធីប្តឹងតវ៉ា គួរសរសេរដាក់លើផ្ទាំងក្តារដែលដាក់តាំងនៅតាមកន្លែងសមស្របនៅក្នុងភូមិ ។ គួរមានការប្រជុំភូមិជាពិសេសសំរាប់ការពន្យល់អំពីចំនុចសំខាន់ៗនៅក្នុងច្បាប់ និងនីតិវិធី ដែលជាប់ទាក់ទិននឹងដំណើរការធ្វើប័ណ្ណប្លង់ដី និងបញ្ហាផ្សេងៗទៀត ។ NGOs និងសមាសភាពផ្សេងទៀតនៃសង្គមស៊ីវិល គួរចូលរួមនៅក្នុងការអប់រំសាធារណៈផងដែរ ។ ឯមធ្យោបាយដែលមានប្រសិទ្ធិភាពខ្ពស់ជាងគេក្នុងការផ្សព្វផ្សាយពត៌មាន គឺប្រហែលជាវិទ្យុ និងទូរទស្សន៍ ពីព្រោះនៅក្នុងតំបន់ដាច់ស្រយាលក៏មានរបស់ទាំងនេះដែរ ។

## ជំពូក ៧

# ការសន្និដ្ឋានរួម

កម្ពុជាបានចាប់ផ្តើមធ្វើកំណែទំរង់ដីធ្លីក្រោយគេ ដូច្នេះហើយមានអំណោយផលមួយដោយអាចរៀនសូត្រពីបទពិសោធន៏របស់ប្រទេសផ្សេងៗទៀត ។ នៅកន្លែងដទៃ គេបានធ្វើកំហុសខ្លះដែលបណ្តាលអោយប្រទេសទាំងនោះខាតបង់សន្តិសុខស្បៀងជាមូលដ្ឋាន (ឧទាហរណ៏ នៅអាហ្វ្រិក) ហើយដែលកម្ពុជាអាចចៀសវាងបាន ។ ខុសពីទសវត្សរ៏១៩៥០ និង ១៩៦០, សព្វថ្ងៃមានបទពិសោធន៏ ព្រមទាំងសៀវភៅក្បួនដ៏លំអិតស្តីពីរូបភាពផ្សេងៗនៃកំណែទំរង់ដីធ្លី ។ ដូច្នេះ វាជាការសំខាន់ណាស់ដែលអ្នកធ្វើផែនការ និងមន្ត្រីពាក់ពន្ធ័អាចបានដឹង បានស្គាល់ពីឯកសារពាក់ព័ន្ធទាំងនេះ ។

ប្រទេសកម្ពុជា មានរបៀបរបបប្រើប្រាស់ដីធ្លីច្រើនបែបយ៉ាង ។ របៀបប្រើប្រាស់សំរាប់តែការបំពេញក្រពះ មានច្រើនជាងរបៀបផ្សេងៗទៀតទាំងអស់ ទោះបីកំលាំងទីផ្សាររីកដុះដាលក៏ដោយ ។ ដោយសារការបើកចំហភ្លាមៗទៅរកសេដ្ឋកិច្ចទីផ្សារ កសិករដែលកំពុងជួបឧបសគ្គនៃអនក្ខរភាព និងភាពឯកោនោះ ក៏ត្រូវប្រឈមមុខនឹងតំរូវការជាច្រើនចំពោះដីធ្លីដែលជាមធ្យោបាយតែមួយគត់ សំរាប់ពួកគេរកចិញ្ចឹមក្រពះ ។ ជាលទ្ធផល កសិករជាច្រើនបានអស់ដីធ្លី ឬកំពុងតស៊ូរក្សាការកាន់កាប់ដីធ្លីជាបន្តទៀត ។ ទំនាស់ដែលកើតមានឡើង ត្រូវបានដោះស្រាយតាមវិធីច្រើនបែបយ៉ាងដែលមិនប្រាកដថារលូននឹងគ្នាល្អ ឬត្រឹមត្រូវតាមច្បាប់នោះទេ ។ ក្នុងនេះ ប្រព័ន្ធរដ្ឋបាលដែលភាគច្រើនមានលក្ខណៈការិយាធិបតេយ្យ ពីលើចុះក្រោម ពុំមានលទ្ធភាពដោះស្រាយសភាពការណ៏ជាក់ស្តែងដែលកើតមានឡើងនៅថ្នាក់មូលដ្ឋានអោយបានពេញលេញទេ ។ ក្នុងកិច្ចបំពេញការងារប្រព័ន្ធនេះខ្វះខាតសព្វបែបយ៉ាងទាំងខាងហិរញ្ញវត្ថុ និងធនធានមនុស្ស ។ មន្ត្រីជាច្រើននៃរដ្ឋបាលនេះ ដោយសារគ្មានការប៉ះប៉ូវអ្វីថែមពីរដ្ឋាភិបាល ក៏ត្រូវបានអូសទាញឱ្យទទួលយកអត្ថប្រយោជន៏ផ្សេងៗក្រៅផ្លូវការ ។ ចំពោះអ្នកគ្មានលទ្ធភាពចំណាយ បែបនេះ (ដូចជាអ្នកក្រ) ពួកគេត្រូវទទួលការខាតបង់ជាដរាប ។

គួរតែមានការបែងចែកអោយច្បាស់ រវាងអ្នកពាក់ព័ន្ធនឹងដី (stakeholders in land) និងអ្នកពាក់ព័ន្ធនៅក្នុងគំរោង (stakeholders in the project) ។ ចំពោះអ្នកពាក់ព័ន្ធនឹងដី ក្រៅពីកសិករ គឺមានអ្នកជំនួញ និងអ្នកទិញដីទុកលក់យកចំណេញ មន្ត្រីរាជការ យោធា និងម្ចាស់ក្រុមហ៊ុនសម្បទាន ។ តំរូវការដីធ្ងន់ធ្ងរ កើតមានឡើងនៅក្នុងតំបន់ទីក្រុង តាមបណ្តោយផ្លូវបានអភិវឌ្ឍន៏រួចតាមដងទន្លេ និងនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៏ពាណិជ្ជកម្ម ។ អ្នកពាក់ព័ន្ធនៅក្នុងគំរោងគឺមានមន្ត្រីរាជការ និងអ្នកនយោបាយដែលអាចមានផលប្រយោជន៏ខាងដីធ្លី ។ ការបែងចែកគ្នាមិនច្បាស់លាស់ រវាងផលប្រយោជន៏រួម និងផលប្រយោជន៏ផ្ទាល់ខ្លួន អាចមានផលប៉ះពាល់មិនល្អដល់អព្យាក្រិត្យភាពនៃការិយាធិបតេយ្យ និងអាចធ្វើឱ្យមានទំនាស់ជាយថាហេតុ ។ យន្តការដោះស្រាយទំនាស់ត្រូវបានដាក់ឱ្យដំណើរការហើយ ប៉ុន្តែភាពមិនលំអៀង និងតំលាភាពនោះ មិនបានកើតមានក្នុងគ្រប់យន្តការទេ ។ លើសពីនេះទៀត ការងារមានច្រើនលើសចំណុះ ចំណែកឯថវិកាក៏មានមិនគ្រប់គ្រាន់ ។ ម្យាងវិញទៀត ក៏រិតធនធានមិនស្មើគ្នា និងលក្ខណៈដែលអ្នកពាក់ព័ន្ធនឹងដីធ្លីផ្សេងៗ

ហើយអ្នកពាក់ព័ន្ធនៅក្នុងគំរោងខ្វះខាតលទ្ធភាពក្នុងការទទួលបាន ពតិមានគ្រប់គ្រាន់ វាធ្វើឱ្យប្រព័ន្ធមិនសូវយុត្តិធម៌ល្អសំរាប់ទាំងអស់គ្នាទេ ជាពិសេសនៅពេលណាមានទំនាស់ផលប្រយោជន៍គ្នា ។ កសិករ គឺជាអ្នកចាញ់ដោយចៀសមិនរួច ។

ដូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ នៅកម្ពុជាជាធម្មតាស្ត្រីមានតួនាទីទាបជាងបុរស ។ ពួកគេគ្មាន កម្មសិទ្ធិលើដីធ្លីទេ (លើកលែងតែស្ត្រីជាមេគ្រួសារ) មានការអប់រំតិចជាងបុរស និងមិនសូវដឹងអំពីច្បាប់ទេ ។ ជាលទ្ធផល ស្ត្រីមានអំណាចតិចជាងបុរស ។ ការចូលរួមពលកម្មរបស់ស្ត្រីគឺមានកំរិតខ្ពស់បើពិនិត្យមើលនៅក្នុងបរិបទអន្តរជាតិ ប៉ុន្តែលក្ខណៈ និងគុណភាពនៃការចូលរួមរបស់ស្ត្រីកម្ពុជានៅក្នុងទីផ្សារពលកម្ម វាមានរូបភាពខុសប្លែកពីគេ ។ ដើម្បីកែលំអតុល្យភាពតួនាទី បុរស-ស្ត្រីនៅក្នុងកម្មសិទ្ធិដីធ្លី ការផ្តល់ប័ណ្ណប្លង់ដីត្រូវផ្តោតជាពិសេសចំពោះលទ្ធភាពចុះបញ្ជីដីធ្លី ដោយដាក់ឈ្មោះរួមគ្នា ទាំង បុរស និងស្ត្រី ។

ដើម្បីដោះស្រាយបញ្ហាខាងលើ ឯកសារនេះបានសង្កត់ធ្ងន់ទៅលើវិមជ្ឈការនៃកម្មវិធី ក្នុងនេះមានទាំងយន្តការដោះ ស្រាយទំនាស់ផង ។ ការធ្វើដូច្នេះនឹងនាំអោយមានតំលាភាព និងការគ្រប់គ្រងលើកម្មវិធីដោយថ្នាក់មូលដ្ឋាន ព្រមទាំងធ្វើឱ្យ កសិករមានទំនុកចិត្តច្រើនថែមទៀត ។ ឯកសារនេះផ្តល់អនុសាសន៍ថា ចំពោះក្រុមប្រឹក្សាឃុំ គេគួរពង្រឹងសមត្ថភាពឱ្យថែម ទៀត និងឱ្យទទួលខុសត្រូវលើការងារគ្រប់គ្រងទំនាស់ និងការស៊ើបអង្កេតផ្សេងទៀតនៅថ្នាក់មូលដ្ឋាន ។ ចំពោះការផ្តល់ប័ណ្ណ ប្លង់ដី គួរយកស្រុកធ្វើជាមជ្ឈមណ្ឌលស្នូល ។ មួយចំណែកទៀត នៅតាមតំបន់ជនបទ គេឃើញមានប្រើប្រាស់ប្រពៃណី និង ទំនៀមទំលាប់តាមមូលដ្ឋានច្រើននៅឡើយ ។ ដូច្នេះ ការខិតខំធ្វើឱ្យរលូនគ្នាល្អរវាងប្រព័ន្ធផ្លូវការ និងរបៀបរបបគ្រប់គ្រងនៅ ក្នុងមូលដ្ឋាន នឹងអាចផ្តល់ផលចំណេញបានយ៉ាងច្រើន ។

តំរូវការកសាងសមត្ថភាពនៅគ្រប់ថ្នាក់ទាំងអស់ ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ហើយ ។ តំរូវការនេះ មានកំរិតខុសៗ គ្នាទៅតាមថ្នាក់នីមួយៗ ។ នៅថ្នាក់មូលដ្ឋាន ការបណ្តុះបណ្តាលពីច្បាប់ ការផ្សព្វផ្សាយពីបទប្បញ្ញត្តិ និងវិធានផ្សេងៗ និងការ ផ្សះផ្សារទំនាស់ មានសារៈសំខាន់ជាសារវន្ត ។ នៅថ្នាក់ខាងលើ ជំនាញខាងអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងទំនាស់អាច មានប្រយោជន៍ច្រើន ។ ការបណ្តុះបណ្តាលអំពីបច្ចេកទេសអង្កេតដីធ្លី និងការបកស្រាយរូបភាពឌីជីថល អាចមានប្រយោជន៍ សំរាប់គ្រប់ថ្នាក់ទាំងអស់ ។ ដូចគ្នានេះដែរ ថវិកាសំរាប់គ្រឿងបរិក្ខារ សោហ៊ុយធ្វើដំណើរ និងចំណាយប្រតិបត្តិការផ្សេងទៀត ត្រូវតែដោះស្រាយជាចាំបាច់ដើម្បីឱ្យការអនុវត្តន៍កម្មវិធីសំរេចបានជោគជ័យ និងមានចីរភាព ។

# ឯកសារយោង


Acharya, S. (2001), "Poverty Reduction in Cambodia – Some Reflections," Cambodia Development Review, Volume 5, Issue 2

Biddulph, R. (2000), Making the Poor Visible (Phnom Penh: Cambodia Land Project, Oxfam GB)

Boserup, E. (1965), The Conditions for Agricultural Growth (Chicago: Aldine)

Bray, F. (1986), The Rice Economy (London: Basil Blackwell)

Chan S, S Tep and S Acharya (2001), Land Tenure in Cambodia: A Data Update, Working Paper 19, Phnom Penh: Cambodia Development Resource Institute

Chandler, D. (1993), A History of Cambodia (Chaing Mai: Silkworm Books)

Curtis, G. (1998), Cambodia Reborn? (Washington: Brookings Institution Press, and Geneva: United Nations Research Institute for Social Development)

Godfrey M, S So, S. Tep, C Katz and D. Pon 2001, S Acharya, SD Chanto and H Thoraxy (2001), A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis, in Development Analysis Network (DAN) (Ed.) Labour Market in Transitional Economies and Southeast Asia and Thailand, Phnom Penh

Hanks L 1972, Rice and Man: Agricultural Ecology in Southeast Asia, Honolulu: University of Hawaii Press

ILO (International Labour Organisation) 1999, Reconstruction and Employment-Intensive Investment: From Crisis to Development, Geneva

Jose A.V 1986, Agrarian Class Formation in Asia, Research Paper, The Hague: Indo-Dutch Programme on Alternatives in Development

Kato E 1999, Where Has All the Land Gone? Land Rights and Access in Cambodia, Phnom Penh: Cambodia Land Project, Oxfam (GB)

Meijers H 1994, Land Tenure and Agriculture in Cambodia, Bangkok: Asian Institute of Technology

Ministry of Environment (1998), Cambodia: National Environment and Action Plan, Phnom Penh: Ministry of Environment

Murshid KAS (1997), Food Security in an Asian Transitional Economy: The Cambodian Experience, Working Paper 6, Phnom Penh: Cambodia Development Research Institute

NIS (National Institute of Statistics) 1999, General Population of Cambodia, Phnom Penh

RGC (Royal Government of Cambodia) 1999, Cambodia Poverty Assessment, Phnom Penh: Ministry of Planning

RGC (Royal Government of Cambodia) 2000, Sub-Decree on the Procedure of Establishing Cadastral Index Map and Land Register, Phnom Penh: Ministry of Land Management, Urban Planning and Construction, The General Department of Cadastre and Geography

Sida (Swedish International Development Agency) 2000, Cambodia: An Overview of the Land Sector, Phnom Penh

Sik Boreak (2000), Land Ownership, Sales and Concentration in Cambodia, Working Paper 16, Phnom Penh: Cambodia Development Research Institute

Thion S 1993, Watching Cambodia, Bangkok: White Lotus

van Acker F 1999, Hitting a Stone with an Egg? Cambodia's Rural Economy and Land Tenure in Transition, Discussion Paper, Antwerp: Centre for Asian Studies, University of Antwerp

Williams S 1999, Review of Secondary Sources Relating to Land Tenure and Access Issues', Phnom Penh: Cambodia Land Project, Oxfam (GB)

Williams S 2000, A Study of the Capacity of Five Provinces to Resolve Conflicts over Land, Phnom Penh: Cambodia Land Project, Oxfam (GB)

# ករណីសិក្សា និងរបាយការណ៍
# សិក្ខាសាលាអ្នកជាប់ពាក់ព័ន្ធ

ករណីសិក្សានៅប្រាំភូមិ និងកន្លែងតាំងទីលំនៅមានចំណូលទាបមួយកន្លែងនៅទីក្រុងភ្នំពេញ និងរបាយការណ៍សិក្ខាសាលាអ្នកពាក់ព័ន្ធនឹងការតាំងទីលំនៅក្នុងទីក្រុង :

១. ភូមិកំពង់ព្រីង ខេត្តកណ្តាល

២. ភូមិកំពង់ត្នោត ខេត្តកំពត

៣. ភូមិបាបោង ខេត្តព្រៃវែង

៤. ភូមិ៤ ខេត្តកំពង់ស្ពឺ

៥. ភូមិផ្សារ និងតាអង ខេត្តរតនគីរី

៦. កន្លែងតាំងទីលំនៅអនាធិបតេយ្យ ក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ

៧. របាយការណ៍សិក្ខាសាលាអ្នកពាក់ព័ន្ធៈ ការតាំងទីលំនៅក្នុងទីក្រុង

## ១. ករណីសិក្សានៅភូមិកំពង់ព្រីង ខេត្តកណ្តាល

*សេចក្តីផ្តើម*

ខេត្តកណ្តាល គឺជាខេត្តមួយមានកំរិតធ្វើនគរូបនីយកម្ម និងពាណិជ្ជកម្មដ៏ខ្ពស់នៅក្នុងប្រទេសកម្ពុជា ។ តាមជំរឿនឆ្នាំ ១៩៩៨ ខេត្តនេះមានប្រជាជនច្រើនជាងគេបន្ទាប់ពីខេត្តកំពង់ចាម គឺមាន ២០៦.១៨៩គ្រួសារ ត្រូវជា ១.០៧៥.១២៥នាក់ ។

ស្រុកស្អាងដែលយើងចុះសិក្សា មានប្រជាជន ៣២.៤៥៧គ្រួសារ និងមានការអភិវឌ្ឍន៍ខ្ពស់គួរសមបើធៀបនឹងស្រុកឯទៀតក្នុងខេត្តកណ្តាល ។ ដោយនៅជិតនឹងទីរួមខេត្ត (តាខ្មៅ) និងទីក្រុងភ្នំពេញ ស្អាងក៏មានសកម្មភាពពាណិជ្ជកម្មផងដែរ ក្រៅពីសកម្មភាពក្នុងវិស័យសេដ្ឋកិច្ចបឋម (primary sector activities) ដូចជា ការដាំដុះស្រូវ ដំណាំអនុផល និងការនេសាទ ។ សកម្មភាពទិញលក់ដីធ្លីកំពុងប្រែប្រួលជីវភាពប្រជាជនមូលដ្ឋាន និងកំពុងចូលរួមផ្លាស់ប្តូរលំនាំនៃរបបចិញ្ចឹមជីវិតពីការធ្វើកសិកម្មជីវព្រឹត្តិមកជាការងារក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ។ ក្នុងចំណោម ១៦ឃុំនៃស្រុកនេះ មាន ៣ឃុំដែលមានការអភិវឌ្ឍន៍គ្រាន់បើ គឺឃុំរការខ្ពស់ ឃុំសិត្បូ និងឃុំស្វាយរំលំ ដែលមានរោងចក្រកាត់ដេរជាច្រើន បានផ្លាស់ប្តូរសកម្មភាពសេដ្ឋកិច្ចក្នុងមូលដ្ឋានក្នុងកំរិតមួយគួរអោយកត់សំគាល់ ។ ស្ត្រីរាប់ពាន់នាក់ កំពុងផ្លាស់ប្តូរពីការងារផ្ទះគ្មានប្រាក់កំរៃ ទៅធ្វើការងារមានប្រាក់កំរៃនៅក្នុងរោងចក្រ ។

ដោយសារមានការអភិវឌ្ឍន៍ខាងពាណិជ្ជកម្ម, អ្នកពាក់ព័ន្ធបានផុសឡើងកាន់តែច្រើន ហើយទំនាស់ដីធ្លីក៏មានកាន់តែច្រើនដែរ ។ នៅខេត្តកណ្តាល ទំនាស់ដីធ្លីបានកើតឡើងតាំងពីពេលមានការប្តូរមកជាសេដ្ឋកិច្ចទីផ្សារ ។ ក្នុងចំណោម ៣២ករណីដែលគណៈកម្មការដោះស្រាយបាតុភាពដីធ្លី បានទទួលក្នុងឆ្នាំ២០០០ មានតែ ១៦ករណីប៉ុណ្ណោះដែលត្រូវបានដោះស្រាយនៅថ្នាក់ខេត្ត ឯ ១០ករណីទៀតត្រូវបានបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីសំរេច ។

### *ភូមិកំពង់ព្រីង*

ភូមិកំពង់ព្រីងដែលយើងបានចុះទៅធ្វើការសិក្សាវាយតំលៃសង្គម មានប្រវែង ២,៥គ.ម នៅតាមដងទន្លេបាសាក់ខាងត្បូងក្រុងតាខ្មៅ ក្នុងឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ។ ភូមិកំពង់ព្រីងមានកំរិតលូតលាស់ខ្ពស់ខាងនគរូបនីយកម្ម និងពាណិជ្ជកម្ម ហើយវាជាឃុំមួយក្នុងចំណោមឃុំទាំងបីដែលជឿនលឿនជាងគេក្នុងស្រុកស្អាង ។ ក្នុងឆ្នាំ២០០១ ភូមិនេះមានប្រជាជន ៣៣៦គ្រួសារ ត្រូវជា ២.៤៩២នាក់ (កើនពី ២២០គ្រួសារនៅពាក់កណ្តាលទសវត្សរ៍១៩៨០) ។ គេរាយការណ៍ថា កំណើនវាផុសចេញពីគ្រួសារទើបរៀបការថ្មី និងជនមាតុភូមិនិវត្តន៍[១] ។ ភូមិនេះមាន ៣០គ្រួសារស្ត្រីមេគ្រួដែលជាទូទៅមានផ្ទៃដីកសិកម្មតូចជាងគ្រួសារបុរសមេគ្រួ ។

ភូមិកំពង់ព្រីងមានផ្ទៃដីប្រហែល ៥៩០ហិកតា ក្នុងនេះ ១០០ហិកតា ជាដីលំនៅដ្ឋាន និង ១៦០ហិកតា ជាដីកសិកម្ម (៤០ហិកតា ជាដីស្រែប្រាំង, ១០៧ហិកតា ជាដីស្រែវស្សា និង ១២ហិកតាជាដីចំការ) ។ គេបានប្រាប់ថា ដីសាធារណៈ និងបឹងត្រូវបានអាជ្ញាធរមូលដ្ឋានលក់ទៅអោយឯកជនអស់ហើយ ។ ថ្លៃដីមានកំរិតខុសៗគ្នាទៅតាមទីតាំង និងសក្តានុពលសេដ្ឋកិច្ច ។ ដីចាប់ឡើងថ្លៃយ៉ាងខ្លាំងនៅឆ្នាំ១៩៩៦ គឺដីមួយក្បាលទទឹង ១៥ម៉ែត្រ បណ្តោយ ១០០ម៉ែត្រ មានតំលៃពី ៥.០០០-១០.០០០ដុល្លារ ។ កាលពីដើមទសវត្សរ៍១៩៩០ ដីធុននេះមានតំលៃត្រឹមតែ ៣៥០-៧៥០ដុល្លារប៉ុណ្ណោះ ។ ដីចំការមានតំលៃ ១-២ដុល្លារក្នុងមួយម៉ែត្រគារ៉េ ។ ដីស្រែជាទូទៅមានតំលៃ ០,៣ដុល្លារក្នុងមួយម៉ែត្រគារ៉េ ។

### *ជីវភាពរស់នៅ*

សកម្មភាពជួញដី (ចាប់ពីដើមទសវត្សរ៍១៩៩០) និងការសាងសង់រោងចក្រកាត់ដេរ (តាំងពីឆ្នាំ១៩៩៦) បានផ្លាស់ប្តូរជីវភាពសេដ្ឋកិច្ចនៃសហគមន៍នៅក្នុងភូមិ និងផ្លាស់ប្តូរលំនាំប្រើប្រាស់ដីនៅក្នុងតំបន់ទាំងមូល ។ សព្វថ្ងៃ ប្រហែល ៤៥% នៃគ្រួសារក្នុងភូមិ គេពឹងផ្អែកលើកសិកម្ម (ដូចជាដាំស្រូវ ធ្វើចំការ និងនេសាទ) ធៀបនឹងប្រហែល ៩៥% កាលពីពាក់កណ្តាលទសវត្សរ៍១៩៨០ ។ ក្នុងទសវត្សរ៍ទើបកន្លងទៅនេះ ដីដាំដុះមួយចំនួនធំត្រូវបានលក់ទៅអោយក្រុមហ៊ុន និងអ្នកទិញទុកលក់យកចំនេញ ។ ការងារក្រៅពីកសិកម្ម មានសុវត្ថិភាព ហើយបានចំណូលខ្ពស់ជាង ។ រោងចក្រកាត់ដេរនៅក្នុងភូមិបានជួលកម្មករធ្វើការប្រហែល ៥,០០០នាក់ ហើយម្នាក់ៗបានប្រាក់កំរៃជាមធ្យម ៥០ដុល្លារក្នុងមួយខែ ។ រោងចក្រក៏បានទាក់ទាញកម្មករមកពីខេត្តផ្សេងទៀតផងដែរ ។ ដោយកម្មករមកពីក្រៅត្រូវការស្នាក់នៅ អ្នកភូមិក៏មានឳកាសរកចំណូលបន្ថែមតាមរយៈការជួលផ្ទះក្នុងតំលៃ ១០-១៥ដុល្លារម្នាក់ក្នុងមួយខែ ហើយអាចមានលទ្ធភាពដាក់បាយខែទៀតផង ។ ម្ចាស់ផ្ទះជាច្រើនបានបោះបង់ការងារស្រែចំការ ដោយបែរមកប្រកបរបរធ្វើបាយទឹកសំរាប់ពួកអ្នកជួលផ្ទះនៅ ។ ជាលទ្ធផល មាននៅសល់ដីកសិដ្ឋានជាច្រើនសំរាប់ជួលអោយគ្រួសារនានាដែលបន្តមុខរបរកសិកម្ម ហើយថ្លៃជួលដីចុះទាបជាងពីមុនផង ។ ទោះបី តំរូវការពលកម្មនៅក្នុងកសិកម្មបានធ្លាក់ចុះអស់ ៥០%ហើយក៏ដោយ ក៏ពលករកសិកម្មអាចទារថ្លៃបានខ្ពស់ជាងមុន (៥០០០-៦០០០រៀលក្នុងមួយថ្ងៃធៀបនឹងត្រឹម ៣.០០០រៀលកាលពីដើមទសវត្សរ៍១៩៩០) ពីព្រោះពលករមួយចំនួនបានប្តូរទៅធ្វើការងារក្រៅកសិកម្មវិញ[២] ។

---

១ គេរាយការណ៍ថា ជនមាតុភូមិនិវត្តន៍មាន ១៨គ្រួសារក្នុងឆ្នាំ១៩៩០ ។

២ គេមិនច្បាស់ទេថា ចំនួននេះវាច្រើនជាងមុនពិតមែនឬយ៉ាងណា ពីព្រោះប្រាក់រៀលបានចុះថ្លៃធៀបនឹងប្រាក់ដុល្លារ ។ គ្មានអ្នកណាដឹងច្បាស់ដែរថា ការធ្លាក់ថ្លៃប្រាក់រៀលនេះវាបានប៉ះពាល់ប៉ុណ្ណាដល់ថ្លៃម្ហូបអាហារនៅមូលដ្ឋាន ។

### *ការកាន់កាប់ដី និងភាពគ្មានដី*

គ្រួសារទាំងអស់ទទួលបានដី ទាំងដីលំនៅដ្ឋាន និងដីកសិកម្ម កាលពីចុងទសវត្សរ៍១៩៨០ ។ គ្រួសារនីមួយៗបានដីលំនៅដ្ឋានទំហំ ១៥ម x ១០០ម ។ ទំហំដីកសិកម្មដែលគេចែកអោយ ប្រែប្រួលទៅតាមចំនួនមនុស្សពេញវ័យ ចាស់ជរា និងកុមារនៅក្នុងគ្រួសារ ។ ជាមធ្យម ក្នុងមួយគ្រួសារទទួលបានដី ០,៥ហិកតា ។ បន្ទាប់ពីការបែងចែកដីជាលើកដំបូងនេះ គ្រួសារដែលមានពលកម្មបុរស និងមានសត្វអូសទាញបានរានដីច្រើនថែមទៀត ដើម្បីពង្រីកទំហំកសិដ្ឋានរបស់ពួកគេ ។

ដីកសិកម្មជាមធ្យមមានទំហំតូចមែន ប៉ុន្តែគេរាយការណ៍ថា គ្រួសារមួយចំនួនតូចមានដីកសិកម្មធំជាងនេះ គឺរហូតដល់៣ហិកតា ។ម្យ៉ាងវិញទៀត មានគ្រួសារជិត ៤០% បានប្រាប់ថា ពួកគេគ្មានដីកសិដ្ឋានទេ ។ ប៉ុន្តែភាពគ្មានដីមិនមែនជាបញ្ហាចំបងទេ ពីព្រោះអ្នកភូមិយល់ថា ការងារក្រៅពីកសិដ្ឋានទទួលបានកំរៃច្រើនជាង ។ តំលៃដីដែលអ្នកទិញដីទុកលក់កំណត់អោយបានជំរុញគ្រួសារមួយចំនួនលក់ដីរបស់ខ្លួន ។ អ្នកទិញដីទុកលក់យកចំណេញ ជាពិសេសមកពីភ្នំពេញ និងខ្មែរនៅក្រៅប្រទេសមួយចំនួន បានទិញដីនៅក្នុងភូមិ ដោយជួនកាលដាក់ឈ្មោះបងប្អូនជាអ្នកកាន់កាប់ ។ ចំណាកស្រុកចេញពីភូមិក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ មានកំរិតមិនខ្ពស់ទេ ទោះបីជាអត្រាគ្មានដីធ្លីមានតួលេខខ្ពស់ក៏ដោយ ។

### *ចុងសន្លឹក និងការចុះបញ្ជី*

ប្រហែល ៩៥% នៃគ្រួសារក្នុងភូមិ មានប័ណ្ណកាន់កាប់ដីលំនៅដ្ឋាន (ទំហំ ១៥ម x ១០០ម) ដែលគេបានចេញអោយកាលពីឆ្នាំ១៩៩២ ។ ចំពោះដីកសិកម្ម គេបានចេញអោយតែបង្កាន់ដៃប៉ុណ្ណោះ ហើយគ្មានការចេញប័ណ្ណកាន់កាប់អោយតាមក្រោយទេ ។ ដីលំនៅដ្ឋានដែលមានទំហំ ១៥ម x ១០០ម នៅជាប់ផ្លូវ ហើយមានប័ណ្ណត្រឹមត្រូវ មានតំលៃពី ៥.០០០ ទៅ ១០.០០០ដុល្លារ ។ អ្នកធូរធារជាពិសេសមកពីភ្នំពេញ ទទួលស្គាល់សារៈសំខាន់នៃប័ណ្ណកាន់កាប់ជាងអ្នកនៅមូលដ្ឋាន ។ ដើម្បីធានាអោយមានកម្មសិទ្ធិស្របច្បាប់ ពួកគេបានជ្រើសរើសយកការធ្វើប័ណ្ណត្រឹមត្រូវ ។ ប៉ុន្តែ មានអ្នកទិញច្រើននាក់ដែរ ដែលបានរំលងថ្នាក់ភូមិ និងឃុំ ហើយទៅទាក់ទងអាជ្ញាធរខាងលើផ្ទាល់តែម្តង ។ ចំណែកឯប្រជាជននៅមូលដ្ឋាន គេបានពឹងផ្អែកទាំងស្រុងទៅលើអាជ្ញាធរភូមិ និងឃុំ សំរាប់ក្រដាសស្នាមដីធ្លី និងការលក់ដូរ ។ ពួកគេមិនទៅថ្នាក់លើទេ ដើម្បីចៀសវាងការបង់ពន្ធខ្ពស់ និងការបង់កំរៃក្រៅផ្លូវការ (២០០-៥០០ដុល្លារ) នៅថ្នាក់រដ្ឋបាលផ្សេងៗ ។ កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលមិនត្រឹមត្រូវតាមផ្លូវច្បាប់ ត្រូវបានធ្វើឡើងរវាងអ្នកលក់ និងអ្នកទិញ ដោយមានសាក្សីបញ្ជាក់ដឹងឮ ។ ការផ្ទេរកម្មសិទ្ធិក្រៅផ្លូវការបែបនេះ ចំណាយអស់តែ ៤ ឬ ៥ម៉ឺនរៀលប៉ុណ្ណោះ (ប្រហែល ១០ដុល្លារ) ។

តាមរបៀបស្រដៀងគ្នានេះដែរ ឪពុកម្តាយដែលមិនចេះអក្សរ បានចែកដីកេរ្តិ៍របស់ខ្លួន អោយទៅកូនចៅតាមការនិយាយផ្ទាល់មាត់ ឬជួនកាលមានសរសេរលិខិតជាលាយលក្ខណ៍អក្សរដោយដៃ ហើយចុះហត្ថលេខាដោយមានអ្នកជិតខាងជួយដឹងឮ ។ នៅក្នុងករណីទាំងនេះ ឈ្មោះឪពុកម្តាយ នៅតែមាននៅក្នុងដីនោះដដែល ទោះបីជាគាត់បានស្លាប់ទៅហើយក្តី ។ នៅមានសេចក្តីរាយការណ៍មួយចំនួនថា ការអនុវត្តន៍បែបនេះ បានបង្កអោយមានទំនាស់ដីធ្លីមួយចំនួន រវាងបងប្អូន និងបងប្អូនក្រោយពេលឪពុកម្តាយបានស្លាប់ទៅ ។

បញ្ហាមួយទៀតដែលទំនងជាផុសឡើងនៅពេលមានគំរោងចុះបញ្ជីដីធ្លីក្នុងពេលខាងខាងមុខ គឺទំហំមិនច្បាស់លាស់នៃដីធ្លីដែលបុគ្គលកាន់កាប់ ។ បញ្ហាពីរដែលទំនងជាពិបាកដោះស្រាយគឺ ទី១ ទំហំដីកសិកម្មមិនបានកត់ត្រាច្បាស់លាស់នៅលើបង្កាន់ដៃទេ (ចេញអោយកាលពីដើមទសវត្សរ៍១៩៩០) ពីព្រោះម្ចាស់ដីចង់ចៀសវាងការបង់ពន្ធខ្ពស់ ។ ទី២ គ្រួសារជាច្រើនបានរុករានយកដីបន្ថែមនៅក្រោយផ្ទះខ្លួន ដែលធ្វើអោយទំហំដីដែលពួកគាត់កាន់កាប់បច្ចុប្បន្ន ធំជាងទំហំដីដែលគេបានផ្តល់អោយកាលពីមុន ។ ប៉ុន្តែហេតុការណ៍ទាំងនេះពុំមានការកត់ត្រាជាផ្លូវការទេ ។

### *ទំនាស់ដីធ្លី និងយន្តការដោះស្រាយ*

ទំនាស់ដែលបានកើតឡើងនៅក្នុងសហគមន៍គឺមាន ទំនាស់ពីព្រំប្រទល់ ទំនាស់រវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានអំពីដីសាធារណៈ ដីលិចទឹក... និងទំនាស់រវាងអ្នកមូលដ្ឋាន និងជនជាតិភាគតិចអំពីការកាន់កាប់ដី ។ កម្មវិធីផ្តល់ប័ណ្ណប្លង់ដី ត្រូវបានប៉ះពាល់ដោយសារទំនាស់ព្រំដីនៅមូលដ្ឋាន ។ គេបានប្រាប់ថា ម្ចាស់ដីប្រហែល ៥% មិនទាន់បានទទួលប័ណ្ណប្លង់ដីទេ ពីព្រោះមានបញ្ហាព្រំប្រទល់ ។ ប៉ុន្តែប្រជាជនភាគច្រើនជឿថា អាជ្ញាធរមូលដ្ឋានអាចដោះស្រាយទំនាស់ព្រំប្រទល់ទាំងនេះបានដោយងាយ ។

ការប្រមូលផ្តុំដីដោយអ្នកមកពីក្រៅដែលច្រើនតែធ្វើរបងឥដ្ឋ ឬបោះបង្គោលស៊ីម៉ង់ បាននាំមកនូវបញ្ហាមួយថ្មីនៅក្នុងកម្មសិទ្ធិអចលនទ្រព្យ ។ ប្រជាជនមូលដ្ឋានភាគច្រើនមិនបានធ្វើរបងជិតឈឹងព័ទ្ធជុំវិញដីលំនៅដ្ឋានរបស់ខ្លួនទេ ។ ក្នុងករណីជាច្រើន របងបានរារាំងសិទ្ធិប្រើប្រាស់ផ្លូវឆ្លងកាត់ទៅដីផ្សេងទៀត (រួមទាំងដីឯកជន) ឬផ្លូវទៅកាន់ប្រភពទឹក និងព្រៃឈើ ។ នេះជាប្រភពមួយនៃទំនាស់ ។

គេបានរាយការណ៍ថា ប្រធានភូមិ ដោយរួមគំនិតជាមួយនឹងមេឃុំ បានលក់ដីក្រុមសាមគ្គីទៅអោយឯកជននៅចុងទសវត្សរ៍១៩៨០ ដោយមិនបានប្រាប់សហគមន៍ ឬបែងចែកថ្លៃលក់ដីអោយប្រជាជនទេ ។ ដោយមូលហេតុនេះ ជនមាតុភូមិនិវត្តន៍ជាច្រើននាក់ក៏មិនអាចទទួលបានដីធ្លី ហើយសព្វថ្ងៃពួកគេត្រូវរស់នៅក្នុងកន្លែងតាំងទីលំនៅខុសច្បាប់ ។ អ្នកភូមិបានធ្វើបាតុកម្មមួយប្រឆាំងនឹងទង្វើនេះ ។ ភាពស្របច្បាប់នៃអ្នកដឹកនាំមូលដ្ឋានបានចុះអាប់អោន ហើយភាពតឹងតែងខ្លះៗបានកើតមានឡើងរវាងគ្រួសារមាតុភូមិនិវត្តន៍ និងអាជ្ញាធរមូលដ្ឋាន ។

ប្រព័ន្ធតុលាការ និង LDSC គឺជាស្ថាប័នផ្លូវការរបស់រដ្ឋាភិបាល ប៉ុន្តែប្រជាជនមូលដ្ឋានដែលឆ្លើយសំភាសន៍ គេស្គាល់តែតុលាការប៉ុណ្ណោះ ។ នៅថ្នាក់ភូមិ ប្រជាជនទៅរកប្រធានភូមិ និងមេឃុំដើម្បីឱ្យជួយដោះស្រាយទំនាស់ ។ អ្នកមូលដ្ឋានភាគច្រើននិយាយថា ទំនាស់អាចដោះស្រាយក្នុងបរិយាកាសយោគយល់គ្នាតែនៅថ្នាក់មូលដ្ឋានប៉ុណ្ណោះ ។ ពួកគេយល់ថា នៅរដ្ឋអំណាចថ្នាក់លើៗ សោហ៊ុយចំណាយវាខ្ពស់ហួសពេក ហើយមានបរិយាកាសគួរឱ្យបារម្ភថែមទៀត ។ ក្នុងករណីជាច្រើន អ្នកក្រមិនហ៊ានទាំងឈ្លោះទៀតផង ។ ពួកគេបោះបង់ចោលការប្តឹងផ្តល់ ហើយទៅពឹងពាក់លើកម្មផល *"អ្នកធ្វើអាក្រក់នឹងទទួលបាបកម្មនៅជាតិក្រោយ"* ។ កន្លងមកនៅក្នុងភូមិ មានការរំលោភយកដីរបស់គ្រួសារមានស្ត្រីជាមេគ្រួយ៉ាងតិច ៣ករណី ។ ស្ត្រីទាំងនេះបានឆ្លើយសំភាសន៍ប្រាប់ថា ការប្តឹងតវ៉ាទៅថ្នាក់លើ មិនត្រឹមតែអស់ប្រាក់ច្រើនទេ ប៉ុន្តែត្រូវចោលការងារទៀត ដូច្នេះមិនបានរកស៊ីអ្វីទេនៅពេលទៅឆ្ងាយពីផ្ទះ ។

អសមត្ថភាពរបស់តុលាការដើម្បីដាក់អនុវត្តន៍សេចក្តីសំរេចនៅក្នុងករណីមួយចំនួន បានធ្វើអោយប្រជាជនកាន់តែបាត់ជំនឿលើប្រព័ន្ធផ្លូវការ ។ ឧទាហរណ៍ ក្នុងករណីមួយ តុលាការបានកាត់ក្តីឱ្យប្រគល់ដីទៅជនជាតិភាគតិចមួយក្រុមវិញ ប៉ុន្តែគេមិនបានអនុវត្តតាមសាលក្រមនេះទេ ។ ករណីទាំងនេះត្រូវបានលើកមកជាសំអាងនៅពេលប្រជាជននិយាយថា ភាពត្រឹមត្រូវយុត្តិធម៌មិអាចរកបានតែនៅក្នុងសហគមន៍ ហើយវាគ្មានទេនៅឯខាងក្រៅ ។

ការសង្កេតរបស់អ្នកពាក់ព័ន្ធលើការធ្វើប័ណ្ណប្លង់ដី ការទទួលស្គាល់កម្មសិទ្ធិដីធ្លីជាផ្លូវការ មានសារៈសំខាន់ជាសារវន្ត ។ អ្នកឆ្លើយសំភាសន៍បានឱ្យតំលៃប័ណ្ណប្លង់ដីថា:

១. ជា "មាស" ដែលគេទុកសំរាប់ដូរយកជាប្រាក់ ឬសំរួលដល់ការលក់ដីអោយបានថ្លៃខ្ពស់
២. ជាភស្តុតាងបង្ហាញពីកម្មសិទ្ធិដីធ្លីត្រឹមត្រូវដែលអាចជួយការពារដីធ្លី ទប់ទល់នឹងអ្នករំលោភយកដី ។ លិខិតស្នាមដីធ្លី ក៏ជួយក្នុងការលើកកំពស់សមត្ថភាពប្រជាជនមូលដ្ឋានផងដែរ, ធ្វើអោយការលក់ដូរមានតម្លាភាព, និងបង្ការសកម្មភាពគ្រប់គ្រងដីសាធារណៈមិនត្រឹមត្រូវ និង

៣. ជួយកាត់បន្ថយទំនាស់ដីធ្លី ។

អ្នកឆ្លើយសំភាសន៍នៅតាមមូលដ្ឋាន មិនបានដឹង អំពីការចុះបញ្ជីជាប្រព័ន្ធដែលអាចផ្តល់ប័ណ្ណប្លង់ដីដោយគ្មានយកប្រាក់កំរៃទេ ។ គ្រួសារកសិករព្រមបង់ ៥.០០០-១០.០០០រៀលសំរាប់ប័ណ្ណមួយ ។ ចំពោះក្រុមអ្នកជំនួញដែលគ្មានក្រដាសស្នាម ពួកគេសុខចិត្តបង់ច្រើនជាងនេះទៀត ។

## ២. ករណីសិក្សានៅភូមិកំពង់ត្នោត ខេត្តកំពត

*សេចក្តីផ្តើម*

ខេត្តកំពតស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ហើយដូចគ្នានឹងកែប និងកំពង់សោមដែរ ខេត្តនេះត្រូវបានកំណត់ថាជាតំបន់កសិកម្មមានអាកាសធាតុឆ្នេរសមុទ្រដោយឡែក ។ របរចិញ្ចឹមជីវិតរបស់ប្រជាជនពឹងពាក់ទៅលើព្រៃឈើខ្លះ និងសមុទ្រខ្លះ ពីព្រោះឈូងសមុទ្រថៃនៅពីខាងនិរតី និងមានព្រៃច្រើនតាំងពីដើមមក ។ ខេត្តកំពតមាន ៨ស្រុក ចែកជា ៨០ឃុំ និង ៤៦០ភូមិ និងមានប្រជាជនសរុប ៥២៨.៤០៥នាក់ ត្រូវជា ១០៤.៩៩៣គ្រួសារ (តួលេខជំរឿនឆ្នាំ១៩៩៨) ។ សកម្មភាពកសិកម្ម មានផលិតកម្មស្រូវផង និងដំណាំក្រៅពីស្រូវ (ចំការ) ផង ។ ផ្ទៃដីធំៗច្រើនកន្លែងត្រូវបានផ្តល់ជាដីសម្បទាន ។ មនុស្សជាច្រើនយល់ថា នេះជាមូលហេតុនៃការដណ្តើមកម្មសិទ្ធិដីធ្លី ។ ទំនាស់មួយបានកើតឡើង ដោយសារយោធាដែលបានកាន់កាប់ដីមួយចំនួនធំតាំងពីឆ្នាំ១៩៩០-៩៥ បានយកដីទាំងនោះទៅលក់ ឬជួលឱ្យក្រុមហ៊ុនឯកជន នៅពេលសង្គ្រាមបានចប់ទៅ ។ សហគមន៍កសិករនៅមូលដ្ឋានបានអះអាងសិទ្ធិប្រើប្រាស់លើដីនេះជាយូរមកហើយ ទោះបីក្នុងមួយរយៈពេលចុងក្រោយ ពួកគេមិនបានដាំដុះលើដីទាំងនេះក៏ដោយ ។

ស្រុកកំពតដែលយើងបានចុះទៅសិក្សា គឺជាស្រុកមួយមិនសូវជឿនលឿនទេ នៅក្នុងខេត្តកំពត ។ ស្រុកនេះ មានសកម្មភាពពាណិជ្ជកម្មតិចតួច ប៉ុន្តែដោយសារនៅជិតឈូងសមុទ្រ ហើយមានស្ទឹង ប្រជាជនជាច្រើនបានទៅនេសាទនៅសមុទ្រផង និងធ្វើនេសាទទឹកសាបផង ។ ស្រុកនេះមានផ្ទៃដី ១១១.៦៩១ហិកតា ក្នុងនេះ ១៥.១៥០ ហិកតាជាដីស្រែ, ៤.៦០០ហិកតាជាស្រែអំបិល, ៤៣.៧៥០ហិកតាជាដីព្រៃ, និង ២៧.១៩១ហិកតាជាដីសម្បទាន ។ ស្រុកនេះមានដីទុកចោលទំនេរជាច្រើនដែលអាចយកមកប្រើប្រាស់នៅពេលគោលនយោបាយដីធ្លីមានសកម្មភាព ។ តាមពិត ដីទុកចោលទំនេរ គឺមានឯកជន ឬស្ថាប័នរដ្ឋកាន់កាប់ ហើយវាជាប្រភពទំនាស់នៅក្នុងស្រុកនេះ ។

ទាំងនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត គឺមានទំនាស់ និងបញ្ហាដីធ្លីជាច្រើនដែលជាប់ទាក់ទងនឹងដំណើរការនៃអង្គភាពរដ្ឋ ។ ឧទាហរណ៍ មានទំនាស់រវាងយោធា ក្រុមហ៊ុន និងសហគមន៍ ពាក់ព័ន្ធនឹងដីធ្លីមិនប្រើប្រាស់ ហើយក៏មានទំនាស់រវាងសហគមន៍ និងអាជ្ញាធរ អំពីដីមិនប្រើប្រាស់នេះដែរ ។ សព្វថ្ងៃយ៉ាងតិចមាន ១០ករណីដែលកំពុងទើរនៅ LDSC ថ្នាក់ខេត្ត និងប្រហែល ១០០ករណីនៅទើរត្រឹមតុលាការ ។ មន្ត្រីរាជការយល់ឃើញថា ទំនាស់កំពុងតែកើនឡើង ។ ក្នុងករណីសិក្សានេះ យើងលើកឡើងពីបញ្ហានៅក្នុងភូមិមួយតែប៉ុណ្ណោះ ។

*ភូមិកំពង់ត្នោត*

ភូមិកំពង់ត្នោត ស្ថិតនៅក្នុងឃុំកូនសត្វ (ឃុំនេះមាន ៦ភូមិ) និងជាភូមិអន់ថយមួយ ទោះបីគេហាក់ដូចឃើញមានកសិកម្ម និងអាកាសធាតុល្អ និងមានស្រទាប់រុក្ខជាតិគ្របដីធ្លីយ៉ាងល្អក៏ដោយ ។ ភូមិនេះគ្មានសកម្មភាពពាណិជ្ជកម្មធំដុំទេ ។ ដីមានតំលៃទាប គឺពី ១០០-១៥០ដុល្លារក្នុងមួយហិកតា ហើយកសិកម្មទាំងអស់មានលក្ខណៈជីវព្រឹត្តិ ។ ក្នុងមួយទសវត្សរ៍កន្លងមកនេះ ដីធ្លីមិនសូវមានការលក់ដូរទេ ហើយការផ្ទេរកម្មសិទ្ធិកំរមានណាស់ (តាមការចងចាំរបស់ប្រជាជន) ។ ក្រៅពីកសិកម្ម ប្រជាជនប្រកបរបរនេសាទ និងធ្វើកម្មករស្រែអំបិល ។ ខុសពីស្រុកកំពត ជារួមភូមិនេះគ្មានដីនៅសល់ចោលទំនេរទេ ។ មុខរបរ

ចំបងនៅក្នុងភូមិគឺ ការធ្វើស្រែ និងចំការ (បន្លែ និងផ្លែឈើ) និងការនេសាទនៅសមុទ្រ និងស្ទឹង ។ ប្រជាជនខ្លះគ្មានផ្ទះនៅទេ ហើយក្នុងករណីមួយចំនួនតូច គេឃើញមានច្រើនគ្រួសាររស់នៅក្នុងផ្ទះតែមួយរួមគ្នា ។

ភូមិនេះមានភូមិសាស្ត្រធំទូលាយ គឺមានជាង ៤០០គ្រួសាររស់នៅពង្រាយគ្នាតាមបណ្តោយដងផ្លូវប្រវែង ២-៣គីឡូម៉ែត្រ ដោយបែងចែកចេញជា ១៨ក្រុម ដើម្បីធានាអោយមានការសំរបសំរួលល្អខាងរដ្ឋបាល ។ ក្រុមនីមួយៗមានប្រធានក្រុមម្នាក់ ក្នុងនេះប្រធានក្រុមជាស្ត្រីមានតែមួយនាក់ប៉ុណ្ណោះ ។ ប្រធានភូមិថ្មីដែលទើបឡើងកាន់តំណែងមិនចេះអក្សរទេ ហើយបានប្រគល់ការទទួលខុសត្រូវមួយភាគធំទៅអោយកូនប្រុសគាត់ដែលចេះអាន ចេះសរសេរ ។ គេឃើញមានគ្រួសារស្ត្រីមេគ្រួច្រើន (ប្រហែល ១២០គ្រួសារ) ពីព្រោះសំបូរស្ត្រីមេម៉ាយ ឬស្ត្រីប្តីចុះចោល ។ គ្រួសារស្ត្រីមេគ្រួភាគច្រើន មានដីតូចៗ ឬគ្មានដីទេ ។ សាលាបឋមសិក្សានៅចំងាយ ២គីឡូម៉ែត្រពីភូមិ រីឯមន្ទីរពេទ្យស្ថិតនៅឯទីរួមស្រុក ។

### *ជីវភាពរស់នៅ*

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញមានចំណាកស្រុកចូលតែបន្តិចបន្តួចប៉ុណ្ណោះ ហើយដោយសារភូមិធ្លោតមានជីវភាពក្រីក្រ អ្នកភូមិខ្លះបានធ្វើចំណាកស្រុកចេញទៅរកការងារធ្វើនៅក្រៅភូមិ ។ ប្រជាជនភាគច្រើនយល់ថា ដោយសារកំណើនប្រជាជន អនាគតនឹងត្រូវពឹងពាក់លើសកម្មភាពដែលទាក់ទងនឹងសមុទ្រ និងអំបិល មិនមែនពឹងលើដីធ្លីដែលកាន់តែពុះច្រៀកតូចទៅៗនោះទេ ។

ប្រជាជនមានជួលពលកម្ម ហើយការប្រវាស់ពលកម្មក៏មានអនុវត្តជាទូទៅដែរ ។ មនុស្សចំណាស់ (ពិសេស ស្ត្រី) តែងជួលពលកម្មមកធ្វើការដាំដុះនៅលើដីខ្លួន ។ អ្នកគ្មានដីដែលជួលដីគេមកដាំដុះ ក៏តែងជួលពលកម្មដូចគ្នា ។ ការប្រើប្រាស់ គោក្របីរបស់អ្នកដទៃដើម្បីភ្ជួររាស់ក៏មានច្រើនដែរ ពីព្រោះមានកង្វះខាតសត្វអូសទាញ ។ តាមពិតដីធ្លីប្រើមិនទាន់អស់លទ្ធភាពទេ ពីព្រោះខ្វះធាតុចូលផ្សេងៗដូចជាសត្វអូសទាញជាដើម ។

កសិករភាគច្រើន មិនអាចប្រើប្រាស់ប្រព័ន្ធស្រោចស្រពទេ ពីព្រោះប្រភពទឹកវានៅឆ្ងាយម្ខាងទៀត ហើយគេមិនអាចជីកប្រឡាយនាំទឹកមកបានដោយខ្លាចខូចផ្លូវ ។ ជាមធ្យម ដីស្រែក្នុងមួយគ្រួសារមានទំហំ ២០កុង[៣] ។ ក្នុងភូមិមានដីចំការជាច្រើន ហើយដំណាំចំការក៏ឃើញមានដាំយ៉ាងច្រើននៅលើដីលំនៅដ្ឋានដែរ ។ ដោយសារនៅក្បែរសមុទ្រ ដីភូមិមានជាតិប្រៃបន្តិចដែលប៉ះពាល់មិនល្អដល់ដំណាំស្រូវ ។ កង្វះឥណទានវាស្តែងចេញជាការប្រើប្រាស់ធាតុចូលកសិកម្មយ៉ាងតិចតួច ។ គ្មានឥណទាន ACLEDA[៤] នៅក្នុងភូមិទេ ។ មានឥណទានឯកជនខ្លះដែរ ដែលមានការប្រាក់ ៤-៥%ក្នុងមួយខែ ។ ដើម្បីទទួលបានឥណទានកសិករមិនចាំបាច់យកដីទៅបញ្ចាំទេ គឺគ្រាន់តែមានមនុស្សពីរនាក់ជួយធានាឥណទាន ឬក៏អ្នកខ្ចីមានប័ណ្ណគ្រួសារ ។

### *ការកាន់កាប់ដី និងភាពគ្មានដី*

ជាទូទៅប្រជាជននៅក្នុងភូមិមានជីវភាពក្រីក្រ ។ សំរាប់គ្រួសារភាគច្រើន ដីកាន់កាប់ជាមធ្យមក្នុងមួយគ្រួសារមិនលើសពី ០,៥ហិកតាទេ ។ មានពីរ-បីគ្រួសារប៉ុណ្ណោះដែលមានដីធំជាងនេះ ។ មានគ្រួសារថ្មីមួយចំនួន បានមកកាន់កាប់ដីក្នុងភូមិចាប់តាំងពីដើមទសវត្សរ៍១៩៩០ ហើយបានទទួលដីតាមការបើកឱ្យកាន់កាប់កន្លែងថ្មីៗ ។ ប៉ុន្តែសព្វថ្ងៃ ការអនុវត្តន៍បែបនេះបានបញ្ចប់ហើយ ។

ភូមិនេះគ្មានជនមាតុភូមិនិវត្តន៍ទេ ។ នៅចុងទសវត្សរ៍១៩៧០ ប្រជាជនត្រូវបានជំលៀសទៅភូមិក្បែរៗ ហើយក្រោយមកក៏ត្រលប់ចូលភូមិវិញ ។ ៣០% នៃគ្រួសារក្នុងភូមិគ្មានដីទេ ។ ពួកគេធ្វើការនៅស្រែអំបិល ឬនេសាទ ។ គ្រួសារមួយចំនួន

---

៣ នៅកំពត ១កុង ស្មើនឹងមួយភាគមួយរយនៃហិកតា (ដូចនេះ ១កុង = ១០ម x ១០ម) ។

៤ ACLEDA គឺជា NGO ដែលបានប្តូរទៅជាធនាគារមីក្រូឥណទាន ។ នេះជាស្ថាប័នមួយក្នុងចំនោមស្ថាប័នឥណទានដ៏តិចតួច ដែលកសិករអាចទៅទាក់ទងសុំខ្ចីប្រាក់ ។

តូចដែលគ្មានដី គឺជាសាច់ញាតិមករស់នៅជាមួយប្រជាជនដែលនៅក្នុងភូមិតាំងពីយូរហើយ ។ អ្នកចំណូលថ្មីទាំងនេះ មិនបានទទួលដីតាមការបែងចែកនៅចុងទសវត្សរ៍១៩៨០ ទេ ។ កម្មករស្រែអំបិល ក៏មិនបានទទួលចំណែកដីដែរ ដោយគេសំអាងថា មុខងារចំបងរបស់អ្នកទាំងនេះមិនមែនកសិកម្មទេ ។ ភាពអត់ដីបានកើនឡើង ក៏ដោយសារឪពុកម្តាយចែកដីដ៏តូចឱ្យទៅកូនទី១ ឬទី២, ឯកូនឯទៀតគឺគ្មានដី ។ ដូចនេះ ការនេសាទក៏ក្លាយជាសកម្មភាពចំបងមួយនៅក្នុងភូមិ ហើយវាជារឿងធម្មតាទេដែលប្រជាជនមានមុខរបរច្រើនដើម្បីរស់ ។

នៅពេលបែងចែកដីក្នុងទសវត្សរ៍១៩៨០ មនុស្សពេញវ័យម្នាក់ទទួលបានដីកសិកម្ម ១០កុង, វ័យជំទង់ម្នាក់បាន ៧កុង, ដូច្នេះមួយគ្រួសារទទួលបានជាមធ្យម ០,៥ហិកតា ។ បង្កាន់ដៃសំរាប់ដីទាំងអស់ត្រូវបានចេញអោយនៅក្នុងទសវត្សរ៍១៩៨០ ។

សព្វថ្ងៃទំហំផ្ទៃដីជាមធ្យមក្នុងមួយគ្រួសារ (បើសិនកុំគិតពីគ្រួសារមួយចំនួនតូចដែលកាន់កាប់ដីច្រើន) បានថយមកត្រឹម ១០-១៥កុង ។ អ្នកគ្មានដីគឺ កម្មករស្រែអំបិល អ្នកចំណូលថ្មី (ច្រើនជាសាច់ញាតិអ្នកភូមិ) និងគ្រួសារទើបរៀបការថ្មី ។ ជួនកាលប្រជាជនបានលក់ដីដើម្បីទិញទ្រព្យសម្បត្តិក្រៅពីកសិកម្ម ដូចជាម៉ូតូ ទូក... គឺបានក្លាយជាអ្នកគ្មានដីដោយស្ម័គ្រចិត្ត ។ គ្មានសេចក្តីរាយការណ៍អំពីការរំលោភយកដីទេ ។ នៅក្នុងភូមិ គ្មានអ្នកណាមួយបានបាត់បង់ដី ដោយខ្លួនមិនបានយល់ព្រមនោះទេ ។ កត្តាប្រជាសាស្ត្រ គឺជាមូលហេតុចំបងនៃភាពគ្មានដីធ្លី ។ នៅឆ្នាំ១៩៨៤-១៩៨៥ ប្រជាជនបានទទួលដីលំនៅដ្ឋានផង និងដីកសិកម្មផង ។ ការគណនាច្បោល១បង្ហាញថា ភាគច្រើននៃគ្រួសារប្រហែល ៣០% ដែលគ្មានដីធ្លីក្នុងពេលសព្វថ្ងៃ (ក្រៅពីកម្មករស្រែអំបិល) បានអស់ដីធ្លីដោយសារកំណើនប្រជាជន ។

មានករណីទំនាស់ដីធ្លីតែមួយគត់ដែលបានប្តឹងដល់តុលាការ និងដែលជាប់ទាក់ទិននឹងស្ត្រីម្នាក់ដែលមានដី នៅក្នុងភូមិកាលពីមុនឆ្នាំ១៩៧៩ (នេះជាទំនាស់មួយមិនសមហេតុផល ពីព្រោះច្បាប់បច្ចុប្បន្នមិនទទួលស្គាល់កម្មសិទ្ធិមុនឆ្នាំ១៩៧៩ ទេ) ។ ប្រធានភូមិ/អ្នកចាស់ទុំ ជាអ្នកដោះស្រាយទំនាស់តូចតាចដែលកើតឡើងដោយសារបញ្ហាព្រំដី ឬការបន្តមរតក ។

នៅក្នុងភូមិនេះ ការលក់ដូរដីតាមផ្លូវការ ឬក្រៅផ្លូវការសឹងតែគ្មានសោះ គឺមានតែការពុះចែកដី ។ ឯការដាក់ដីបញ្ចាំដើម្បីខ្ចីប្រាក់គេឃើញមានច្រើន ។

ជំងឺ គឺជារឿងធម្មតា មានតែម្ចាស់ដីតូចៗប៉ុណ្ណោះដែលបានលក់ដី ពីព្រោះគ្មានមធ្យោបាយអ្វីផ្សេងដើម្បីរកប្រាក់បង់ថ្លៃព្យាបាល ។ ករណីលក់ដីដើម្បីបង់ថ្លៃព្យាបាល គេរាយការណ៍ថាមានតិចតួចណាស់ ឯការបញ្ចាំដីឃើញមានច្រើនជាង ។ ភាគច្រើននៃការបញ្ចាំដី គឺធ្វើនៅក្នុងភូមិតាមរបៀបក្រៅផ្លូវការ ហើយដីអាចយកមកវិញភ្លាម ក្រោយពីបានសងបំនុលអស់ហើយ ។

### *បង្កាន់ដៃ និងការចុះបញ្ជី*

មានអគ្គិភ័យមួយបានកើតឡើងនៅដើមទសវត្សរ៍១៩៩០ នៅក្នុងការិយាល័យស្រុក និងឃុំ ដែលធ្វើអោយលិខិតស្នាមស្តីពីដីធ្លីនៅក្នុងតំបន់ត្រូវឆេះអស់[៥] ។ តាំងពីពេលនោះមកកសិករមិនបានខិតខំធ្វើលិខិតឡើងវិញទេ ។ អ្នកភូមិនិយាយថា ម្នាក់ៗស្គាល់ដីរបស់អ្នកផ្សេងហើយ ដូច្នេះគ្មានការឈ្លោះដណ្តើមដីគ្នាទេ ។ គ្មានរបាយការណ៍ពីទំនាស់ព្រំដីអ្វីធំដុំទេ ។ ទំនាស់តិចតួចដែលកើតឡើង ត្រូវបានដោះស្រាយនៅក្នុងភូមិ ។ គ្មានវិវាទដីធ្លីឡើងដល់តុលាការទេ លើកលែងតែករណីមួយដែលបានរៀបរាប់នៅខាងលើ ។

រឿងឯកសារឆេះអស់ដោយអគ្គិភ័យមានវែងឆ្ងាយជាងនេះបន្តិចទៀត ។ គេរាយការណ៍ថា កាលពី៧ឆ្នាំមុន (ដើមទសវត្សរ៍១៩៩០) ប្រធានភូមិជំនាន់នោះបានយកបង្កាន់ដៃដីធ្លីពីអ្នកភូមិជាមួយនឹងប្រាក់ ១.៥០០រៀលក្នុងមួយគ្រួសារ ដោយសន្យាថា នឹងធ្វើប័ណ្ណប្លង់ដីឱ្យ ។ បន្ទាប់មកក៏មានភ្លើងឆេះបំផ្លាញឯកសារអស់ទៅ ។ អាជ្ញាធរស្រុកបានប្រាប់ថា មានការធ្វើប័ណ្ណ

៥ គេរាយការណ៍ថា ខ្មែរក្រហមជាអ្នកដុត ។

ឱ្យសាជាថ្មី រួមទាំងភូមិកំពង់ត្នោតផង ហើយប័ណ្ណថ្មីទាំងនេះប្រធានភូមិចាស់ គាត់រក្សាទុកអស់រយៈច្រើនឆ្នាំមកហើយ។ក្រុមស្រាវជ្រាវក៏បានឃើញប័ណ្ណនៅនឹងគាត់មែន ។ ប័ណ្ណភាគច្រើនត្រូវកណ្តៀរស៊ី ហើយបើសិនមិនរក្សាទុកវាឱ្យបានត្រឹមត្រូវទេ វានឹងខូចចោលទាំងស្រុង ។ អតីតប្រធានភូមិនិយាយថា អ្នកភូមិជំពាក់សោហ៊ុយដែលគាត់ចំណាយទៅលើការធ្វើប័ណ្ណសាថ្មី ឯអ្នកភូមិមិនចង់បង់ "ប្រាក់ក្រៅផ្លូវការ" ទេ ដូច្នេះហើយក៏នៅស្ងៀមត្រឹមនេះទៅ ។ រឿងនេះបានបង្ហាញជាសំខាន់ថា តំរូវការឯកសារដីធ្លីមានកំរិតទាបណាស់ ។ ដីធ្លីគ្រាន់តែជាមធ្យោបាយមួយសំរាប់ទ្រទ្រង់ជីវភាព មិនមែនជាវត្ថុសំរាប់លក់ដូរឡើយ (លើកលែងតែក្នុងពេលមានវិបត្តិប៉ុណ្ណោះ) ។

គ្មានរបាយការណ៍ពីការចុះបញ្ជីដីធ្លីតាមរបៀបចោះៗ (sporadic) នៅក្នុងភូមិត្នោតទេ ហើយរឿងនេះវាបញ្ជាក់គាំទ្រដល់មតិអះអាងអំពីកង្វះតំរូវការប័ណ្ណប្លង់ដី ។

ប្រជាជននិយាយថា ពួកគេយល់ដឹងពីរឿងធ្វើប័ណ្ណប្លង់ដី ប៉ុន្តែតាមពិតភាគច្រើនមិនបានដឹងទេ ។ ប្រជាជនជាច្រើនបានយល់ច្រឡំថាបង្កាន់ដៃគឺជាប័ណ្ណប្លង់ដី ។ ទោះយ៉ាងនេះក៏ដោយ ពួកគេស្វាគមន៍ការធ្វើប័ណ្ណប្លង់ដី ពីព្រោះអាចផ្ទេរដីធ្លីទៅអោយកូនដោយស្របច្បាប់បាន ។ ប៉ុន្តែពួកគេមិនចង់ចំណាយលុយច្រើនលើសពី ១.០០០រៀល សំរាប់ដីមួយកន្លែងទេ ។ មានមួយក្រុមតូចប៉ុណ្ណោះដែលព្រមអោយច្រើនជាងនេះ គឺ ៥.០០០-១០.០០០រៀល ។ ក្នុងករណីត្រូវពុះចែកដី (ដូចជាចែកអោយកូន) ក៏មានការរារែកមិនចង់បង់ថ្លៃផ្ទេរដីដែរ ។ ប្រជាជននិយាយថា ពួកគេទុកចិត្តលើភ្នាក់ងារបច្ចុប្បន្នដែលកំពុងធ្វើការងារនេះ ប៉ុន្តែពួកគេចង់បានអាជ្ញាធរថ្នាក់ខ្ពស់ ដូចជា ថ្នាក់ស្រុកជាដើម ជាជាងថ្នាក់មូលដ្ឋាន ។ ម្យ៉ាងវិញទៀត កំរិតជំនាញរបស់អាជ្ញាធរមូលដ្ឋាន ក៏មានបញ្ហាចោទដែរ ។ ពួកគេបានដាក់សេចក្តីទុកចិត្តខ្ពស់បំផុតទៅលើ NGOs ទោះបីជាគ្មានបទពិសោធន៍ជាមួយអង្គការក៏ដោយ (ពីព្រោះគ្មានអង្គការទៅធ្វើការនៅតំបន់នោះ) ។

ក្រសួង MLMUPC ដោយមានជំនួយបច្ចេកទេសពី GTZ បានផ្តើមធ្វើកម្មវិធីផ្តល់ប័ណ្ណប្លង់ដីនៅឃុំស្រែចាំងតែមិនទាន់បានធ្វើនៅក្នុងឃុំកូនសត្វនៅឡើយ ។

ប្រជាជនមិនបានដឹងពីច្បាប់ភូមិបាលទេ ។ ពួកគេចង់ដឹងពីច្បាប់នេះអោយបានច្រើន ។ ការផ្សព្វផ្សាយពត៌មាននៅក្នុងភូមិស្តីពីច្បាប់ភូមិបាល វាមានប្រយោជន៍ខ្លាំងណាស់ ។ អ្នកដឹកនាំក្រុម (មាន ១៨នាក់) អាចជាមនុស្សសំខាន់ក្នុងការផ្សព្វផ្សាយនេះ ។ ការបិទប្រកាស/ខិតប័ណ្ណនៅលើក្តារខៀនក្នុងភូមិ ការស្តាប់ការបកស្រាយពីច្បាប់ដែលប្រើពាក្យសំដីសាមញ្ញៗ ត្រូវបានគេស្នើឡើងថា ជាវិធីសាស្ត្រដ៏ល្អសំរាប់ផ្សព្វផ្សាយខ្លឹមសារច្បាប់សំខាន់ៗ ។

### *បញ្ហា និងទំនាស់ផ្សេងៗ*

គេបានរាយការណ៍ពីករណីជាច្រើនដែលមេឃុំ និងប្រធានភូមិបានលក់ដីក្រុមសាមគ្គី ដោយគ្មានការអនុញ្ញាតពីសមាជិក ឬបែងចែកប្រាក់បានមកពីថ្លៃលក់ដីទៅអោយសមាជិកទេ ។ ទង្វើបែបនេះបានកើតឡើងនៅចុងទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ ហើយបានធ្វើឱ្យប្រជាជនមួយចំនួនលែងទុកចិត្តលើថ្នាក់ដឹកនាំមូលដ្ឋាន ។

ទំនាស់មួយបែបទៀតកើតមានឡើង ដោយសារមានជនចំណាកស្រុកបានមកសុំស្នាក់នៅជាមួយបងប្អូន ហើយក្រោយមកក៏ទាមទារចំណែកដីធ្លី ។ ជនចំណាកស្រុកចូលទាំងនេះ ពីដំបូងស្វែងរកកន្លែងមានសន្តិសុខ ហើយបន្ទាប់មកបន្តស្នាក់នៅជាអចិន្ត្រៃយ៍តែម្តង ។ ក្នុងវិស័យកសិកម្ម ទំនាស់កើតចេញពីដីមិនប្រើប្រាស់ ។ ប្រជាជនបានដណ្តើមគ្នាយកដីទុកចោលទំនេរ តែបច្ចុប្បន្នដីធ្លីប្រភេទនេះមានម្ចាស់កាន់កាប់ និងប្រើប្រាស់អស់ហើយ ។ ទំនាស់ក្នុងភូមិកើតឡើងជាសំខាន់រវាងគ្រួសារ និងគ្រួសារ ពីព្រោះនៅភូមិនេះគ្មានភាគីមកពីក្រៅ ដូចនៅកន្លែងផ្សេងក្នុងស្រុក ឬក្នុងខេត្តនោះទេ ។ ក្នុងករណីខ្លះដែលដីធ្លីត្រូវបានពុះចែកជាចំណែកតូចៗពេក ជាញឹកញយ ការជំទាស់តវ៉ាពីរឿងព្រំដីបានកើតមានឡើង ហើយក៏ក្លាយជាប្រភពទំនាស់មួយរវាងកសិករតូចតាច ។

មានដីព្រៃមួយចំនួននៅជិតមាត់សមុទ្រ (ជារបស់រដ្ឋ) ហើយកសិករទៅរកឧសនៅទីនោះ ។ ក្នុងករណី ចំឡែកមួយគឺ មានការប៉ះទង្គិចគ្នារវាងអ្នកភូមិ និងអាជ្ញាធរគ្រប់គ្រងព្រៃ និងក្នុងករណីមួយចំនួនតូចទៀត គឺប៉ះទង្គិចជាមួយសម្បទានិក ។

ប្រជាជនទទួចចង់ឱ្យការដោះស្រាយទំនាស់ទាំងអស់ត្រូវបានធ្វើឡើងនៅត្រឹមស្រុក គឺបានន័យថាវាមិនមែននៅនឹងមូលដ្ឋាន តែក៏មិនឆ្ងាយពេកពីភូមិ ។

មានការផ្តល់មតិថា កម្មវិធីផ្តល់ប័ណ្ណប្លង់ដីថ្មី គួរអនុវត្តតាមលំដាប់ដូចខាងក្រោម:

១. ដីលំនៅដ្ឋាន
២. ដីកសិកម្ម (ស្រែ)
៣. ដីចំការ

ប្រជាជនរាយការណ៍ថា ក្រៅពីមេឃុំ កំរមានមន្ត្រីរដ្ឋាភិបាលចុះមកដល់ភូមិណាស់ ។ មានពេលខ្លះ ពួកគេបានឃើញមនុស្សមកវាស់វែងដីធ្លី ប៉ុន្តែមិនដឹងថាដើម្បីធ្វើអ្វីទេ ។

*យោបល់ស្តីពីការធ្វើប័ណ្ណប្លង់ដី*

តាមសភាពការណ៍ដែលបានរៀបរាប់រួចមកហើយ ទោះបីជាអ្នកផងយល់ថាការធ្វើប័ណ្ណប្លង់ដីវាមានប្រយោជន៍ក៏ដោយ ក៏នៅក្នុងតំបន់ធ្វើកសិកម្មមួយគ្រប់ហួបបែបនេះ អ្នកចង់បានប័ណ្ណប្រហែលពុំសូវមានច្រើនប៉ុន្មានទេ ឯការជំរុញអោយប្រជាជនបង់ថ្លៃសេវា វាកាន់តែលំបាកថែមទៀត ។ ប្រជាជនមិនមកយកប័ណ្ណប្លង់ដីដោយសារមិនចង់បង់ប្រាក់ត្រឹមពីរ-បីពាន់រៀល គឺជាភស្តុតាងបញ្ជាក់ច្បាស់ពីរឿងនេះ (ទាំងចំពោះដីលំនៅដ្ឋាន និងដីកសិកម្ម) ។ ចម្លើយសត្យានុម័តគឺថា ការផ្តល់ប័ណ្ណប្លង់ដីតែមួយមុខមិនអាចដោះស្រាយបញ្ហាភាពក្រីក្រ និងកសិកម្មជីវព្រឹត្តិរបស់ប្រជាជនបានទេ: ត្រូវធ្វើទំនើបភាវូបនីយកសិកម្មអោយបានព្រមគ្នានឹងដំណើការផ្តល់ប័ណ្ណប្លង់ដីផង ។

ខុសពីករណីសិក្សាឯទៀតដែលឆ្លុះបញ្ចាំងពីចលនាផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងទំនាស់ជាប់ពាក់ព័ន្ធ ករណីសិក្សានេះគឺបង្ហាញពីស្ថានភាពរបស់ភូមិ និងកសិករមួយចំនួនធំនៅក្នុងតំបន់វាលទំនាបធ្វើស្រែខុសៗគ្នានៅកម្ពុជា ។ វាបានបង្ហាញថា ទំនាស់តែមួយមុខមិនមែនជាឧបសគ្គរាំងការធ្វើប័ណ្ណប្លង់ដីទេ ។ នៅមានបញ្ហាច្រើនទៀត ដែលសំខាន់ប្រហែលគ្នាដែរ ដូចជា ភាពក្រីក្រ និងភាពអន់ថយខាងកសិកម្មជាដើម ដែលត្រូវយកចិត្តទុកដាក់ ។

## ៣. ករណីសិក្សានៅភូមិបាធាង ក្នុងខេត្តព្រៃវែង

*សេចក្តីផ្តើម*

ខេត្តព្រៃវែង ក៏ដូចជាខេត្តភាគច្រើនឯទៀតដែលនៅតាមដងទន្លេ គឺជាតំបន់ធ្វើកសិកម្មជាចំបង ។ តាមជំរឿនប្រជាជនឆ្នាំ១៩៩៨, ៨៣% នៃកំលាំងពលកម្មប្រកបរបរកសិកម្ម ។ ដីកសិកម្មមានសរុប ៣១០.០០០ហិកតា ក្នុងនេះ ២៣៨.០០០ហិកតាជាដីស្រែវស្សា, ៦០.០០០ហិកតាជាដីស្រែប្រាំង និង ១២.០០០ហិកតាជាដីចំការ ។ ផ្ទៃដីមានប្រព័ន្ធស្រោចស្រពតំណាងឱ្យ ៣០% នៃដីកសិកម្មទាំងអស់ ។ នៅឆ្នាំ២០០០ ដីព្រៃបំរុងនៅសល់តែ ៥.៦០០ហិកតា គឺថយចុះពី ៤០.០០០ហិកតាកាលពីមុនឆ្នាំ១៩៧០ ដោយសារការចាប់យកដីអនាធិបតេយ្យនៃពួកយោធា និងកំណើនប្រជាជន ។ ដែននេសាទមាន ២១៧.៤៨៧ហិកតា ក្នុងនេះ ១៣៤.០៩៩ហិកតា ជាឡូត៍នេសាទ និង ៨៣.៣៨៨ហិកតា ជាដែននេសាទសាធារណៈ ។ នៅក្នុងរដូវចាប់ត្រីចាប់ពីខែតុលាដល់មិថុនា ផ្ទៃដីភាគច្រើនត្រូវបានប្រើប្រាស់ធ្វើស្រូវប្រដេញទឹក និងដំណាំផ្សេងទៀត ។ តាមគោលការណ៍នៃកំណែទំរង់ជលផលថ្មីរបស់រាជរដ្ឋាភិបាល ទំហំឡូត៍នេសាទសម្បទាននឹងថយមកត្រឹម ៥០.៧១១ហិកតាប៉ុណ្ណោះនៅរដូវនេសាទឆ្នាំក្រោយ ។

ស្រុកពាមរក៍ ដែលក្រុមស្រាវជ្រាវបានចុះសិក្សា មានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ និងជាស្រុករីកចំរើនគួរសមក្នុងចំណោមស្រុកទាំង១២ នៃខេត្តព្រៃវែង ។ ស្រុកនេះស្ថិតនៅតាមបណ្តោយទន្លេមេគង្គ ដូច្នេះមានអំណោយផល សំរាប់ការនេសាទ ស្រូវ និងដំណាំចំការ ។ ស្រុកមានដីកសិកម្មសរុប ១២.០០០ហិកតា (ក្នុងនេះ ៧.៩២៨ហិកតា ជាដីស្រែប្រាំង, ២.៧៥៤ ហិកតាជាដីស្រែវស្សា, និង ១.៣១៨ហិកតាជាដីចំការ) និងមានផ្ទៃទឹកសរុប ៣.២៨៧ ហិកតា ។ ស្រុកពាមរក៍មានប្រជាជនរស់នៅ ១២.០៦៩គ្រួសារត្រូវជា ៦៦.៣៦២នាក់ ។

ទំនាស់ដីធ្លីបានកើតមានតាំងពីដើមទសវត្សរ៍១៩៩០ ហើយសព្វថ្ងៃវាជាចំណុចគួរបារម្ភជាងគេ ទោះបីជាក្រុមស្រាវជ្រាវបានទទួលពត៌មានថា នៅស្រុកឯទៀតៗក៏មានវិវាទដីធ្លីធ្ងន់ធ្ងរដូច្នេះដែរ ។ ឧទាហរណ៍ នៅក្នុងស្រុកព្រះស្តេច មានទំនាស់រវាងយោធា នគរបាល និងអាជ្ញាធរមូលដ្ឋាន/សហគមន៍ ពីរឿងដីកាប់រានថ្មី តែសព្វថ្ងៃគេបានដោះស្រាយរួចរាល់អស់ហើយ ។ គេរាយការណ៍អំពីទំនាស់ពីរថែមទៀតនៅក្នុងស្រុកបាភ្នំ ។ ទំនាស់ទី១ ជាប់ពាក់ព័ន្ធជាមួយនឹងយោធា មន្ទីររុក្ខាប្រមាញ់ខេត្តព្រៃវែង និងសហគមន៍កសិករមូលដ្ឋាន ។ មន្ទីររុក្ខាប្រមាញ់បានដាំដើមឈើលើដី ៦៣០ហិកតានៅជិតភ្នំឈើកាច់ កាលពីពាក់កណ្តាលទសវត្សរ៍១៩៨០ ។ បន្ទាប់មកក្រុមប្រឹក្សារដ្ឋមន្ត្រី បានសំរេចប្រគល់ដីព្រៃបំរុងនេះចំនួន ៣០០ហិកតាទៅអោយយោធានៅឆ្នាំ១៩៨៩ ។ ប៉ុន្តែខាងយោធាបានកាន់កាប់ដីច្រើនជាងនេះ ដែលធ្វើឱ្យសហគមន៍មូលដ្ឋានមានការអាក់អន់ចិត្ត ។ ទំនាស់ទី២ ទាក់ទងជាមួយនឹងក្រុមហ៊ុនមួយ (មានយោធានៅពីក្រោយ) បានបង្ខំអោយប្រជាជនលក់ដីស្រែ ទៅអោយក្រុមហ៊ុនដែលកំពុងជួសជុលផ្លូវជាតិលេខ១ ។ ក្រុមហ៊ុន បានជីកយកដីខ្សាច់ចំនួន ១៦កន្លែង ហើយរំលោភ និងកាន់កាប់លើដីស្រែចំនួន ៥០ហិកតាថែមទៀតដែលមិនមែនជារបស់ក្រុមហ៊ុន ។

### *ភូមិបាបោង*

ក្នុងឆ្នាំ២០០១ ភូមិបាបោងមានប្រជាជន ២.៥៤២នាក់ ត្រូវជា ៥៣៦គ្រួសារ (៣៨គ្រួសារជាជនជាតិភាគតិចដែលប្រកបរបរនេសាទជាសំខាន់) គឺកើនពី ៤៣៤គ្រួសារកាលពីពាក់កណ្តាលទសវត្សរ៍១៩៨០ ។ ប្រជាជនកើនឡើងជាសំខាន់ដោយសារគ្រួសាររៀបការថ្មី ប៉ុន្តែមានជនមាតុភូមិនិវត្តន៍ពីរ-បីគ្រួសារផងដែរ ។

ភូមិមានផ្ទៃដីប្រហែល ៧៤២ហិកតាក្នុងនេះ ២៤ហិកតា ជាដីលំនៅដ្ឋាន, ២៣ហិកតា ជាផ្ទៃទឹក, និង ៦៩៥ហិកតា ជាដីស្រែប្រាំង (១៩០ហិកតាមានប្រព័ន្ធស្រោចស្រព) ។ ដីនៅភូមិបាបោងមានជីជាតិល្អដោយបានទទួលល្បាប់ដែលទឹកទន្លេមេគង្គហូរនាំមកជារៀងរាល់ឆ្នាំ ។ ចាប់ពីចុងទសវត្សរ៍១៩៨០ មក មានការប្រើជីគីមីជាទូទៅ ដើម្បីដាំពូជស្រូវមានទិន្នផលខ្ពស់ ។ ទិន្នផលស្រូវជាមធ្យមគឺ ៣-៤តោន/ហិកតា តែបើមិនប្រើជីគីមីទេ បានតែ ២តោន/ហិកតាប៉ុណ្ណោះ ។ កំណើនប្រជាជនបានដាក់សម្ពាធលើតំរូវការដីធ្លី ហើយបច្ចុប្បន្នគ្មាននៅសល់ដីរួម ឬដីព្រៃលិចទឹកទៀតទេ ។ ផ្ទៃដីព្រៃលិចទឹកជាង ២០ហិកតាត្រូវបានកាប់រានធ្វើស្រែអស់តាំងពីចុងទសវត្សរ៍១៩៨០ ។

### *ជីវភាពរស់នៅ*

របរធ្វើស្រែគឺជាប្រភពចំណូលដ៏ចំបងសំរាប់ប្រហែល ៤៨០គ្រួសារនៅក្នុងភូមិ ។ របរធ្វើស្រែមិនគ្រាន់តែផ្តល់ចំណូលតាមរដូវដល់អ្នកក្រីក្រនៅក្នុងភូមិ (ប្រហែល ២០%នៃកំលាំងពលកម្មកសិកម្ម) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការងារអោយពលករកសិកម្មចំណាកស្រុកប្រហែល ៤០០នាក់ ដែលមកពីស្រុក និងខេត្តជិតខាងនានាចាប់ពីខែកុម្ភៈ ដល់ខែមេសា ជារៀងរាល់ឆ្នាំ ។ ពលករម្នាក់អាចរកបាន ៥.០០០រៀលក្នុងមួយថ្ងៃសំរាប់ការងារប្រមូលផល ។ ម្ចាស់ត្រាក់ទ័រនៅក្នុងភូមិ និងមកពីក្រៅភូមិ អាចរកបានពី ៨០.០០០-១០០.០០០រៀល សំរាប់ការភ្ជួររាស់ដីមួយហិកតា ។ ចំណាយជាមធ្យមក្នុងការដាំស្រូវមួយហិកតាអស់ប្រហែល ៧៥០.០០០រៀល ដោយមិនគិតស្រូវពូជរបស់ខ្លួនឯង និងពលកម្មក្នុងគ្រួសារទេ ។ កសិករជាច្រើនពុំមានទុនខ្លួនឯង សំរាប់ដាំស្រូវទេ ហើយតាមធម្មតាត្រូវខ្ចីប្រាក់គេ ក្នុងអត្រាការប្រាក់យ៉ាងខ្ពស់ដល់ ១០-៣០% ក្នុងមួយរដូវ ។

ក្រៅពីធ្វើស្រែ កសិករក៏ធ្វើនេសាទផងដែរ ។ នៅរដូវវស្សា ឡូត៍នេសាទគ្របដណ្តប់ផ្ទៃដីស្រែប្រាំងភាគច្រើន ។ ឡូត៍នេសាទត្រូវបានផ្តល់ឱ្យឯកជនគ្រប់គ្រងតាំងពីពាក់កណ្តាលទសវត្សរ៍១៩៨០ ។ គេអនុញ្ញាតឱ្យកសិករធ្វើនេសាទតែក្នុងបរិវេណ ១០០-១៥០ម៉ែត្រពីភូមិប៉ុណ្ណោះ ។ ដោយជីវភាពភាពក្រីក្រ អ្នកភូមិជាច្រើនបានចេញនេសាទលើសពីដែនកំណត់ ហើយបើសិនគេចាប់បាន នឹងត្រូវម្ចាស់ឡូត៍ឃាត់ខ្លួន និងឱ្យបង់ប្រាក់ពិន័យពី ៥.០០០-៥០.០០០រៀល ឬក៏រឹបអូសយកឧបករណ៍នេសាទ ។ ក្នុងសេចក្តីប្រកាសរបស់រដ្ឋាភិបាលស្តីពីកំណែទំរង់ជលផលនាពេលថ្មីៗ ឡូត៍នេសាទនៅភូមិនេះ នឹងត្រូវប្រគល់អោយសហគមន៍ក្នុងភូមិវិញនៅខែមិថុនា ឆ្នាំ២០០១[៦] ។ កសិករ មានចិត្តរីករាយនឹងកំណែទំរង់ណាស់ ហើយសង្ឃឹមថា នឹងអាចកែលំអជីវភាពរបស់ខ្លួនបានមួយកំរិត ។

### *ការកាន់កាប់ដី និងភាពគ្មានដីធ្លី*

ថ្វីបើភូមិនេះផលិតស្រូវលើសពីតំរូវការហូបចុកក៏ដោយ ក៏អ្នកភូមិភាគច្រើននៅតែក្រ ។ គ្រួសារកសិករនីមួយៗ មានដីជាមធ្យម ១-១,៥ហិកតា ។ ដីធ្លីបានប្រមូលផ្តុំទៅលើគ្រួសារមួយចំនួនតូច ដោយសារការលក់ដី ដោយមានធុរៈបន្ទាន់ ការបញ្ចាំ និងល្បែងស៊ីសង ។ ម្យ៉ាងទៀត កសិករងាយរងគ្រោះ (ដូចជា អ្នកគ្មានសំភារៈកសិកម្ម និង/ឬ មធ្យោបាយសំរាប់ទិញធាតុចូលកសិកម្ម) បានបាត់បង់ដីសំរាប់ផលិត ដោយសារថ្លៃស្រូវឡើងចុះមិនអាចកំណត់បានក្នុងរយៈពីរ-បីឆ្នាំចុងក្រោយ ។ ដោយមូលហេតុនេះ គ្រួសារមួយចំនួនតូចមានដីលើសពី ១០ហិកតា ចំណែកឯ ៤០%នៃគ្រួសារក្នុងភូមិគឺគ្មានដីស្រែអ្វីទៀតទេ ក្រៅពីដីដែលបញ្ចាំអស់ហើយ ។

កាលពីនៅចុងទសវត្សរ៍១៩៨០ គ្រួសារនីមួយៗទទួលបានដី ១-២ហិកតា អាស្រ័យទៅតាមចំនួនសមាជិកគ្រួសារ និងលទ្ធភាពរានដីបាន ។ ដីរដ្ឋត្រូវបានបែងចែកអោយគ្រួសារនានាក្នុងកំរិត ០,១២ហិកតាសំរាប់មនុស្សមានកំលាំងពលកម្មខ្សោយ ឬមធ្យមម្នាក់ និង ០,១៦ហិកតាសំរាប់អ្នកកំលាំងពេញម្នាក់ ។ ក្នុងពេលជាមួយគ្នាដែរ ប្រជាជនបានចាប់យកដីភូមិដែលជាដីកេរ្តិ៍របស់ខ្លួនកាលពីមុនឆ្នាំ១៩៧៩ មកវិញ ។ នៅចុងទសវត្សរ៍១៩៨០ ជនជាតិភាគតិច (វៀតណាម) បានចូលមករស់នៅតាមទូកតាមដងទន្លេ តែពួកគេពុំមានដីទេ ។ ដោយគ្មានដីនៅសល់ ជនមាតុភូមិនិវត្តន៍ដែលមកពីជំរំនៅព្រំដែនថៃ ហើយដែលចូលមករស់នៅក្នុងភូមិកាលពីដើមទសវត្សរ៍១៩៩០ គឺមានតែពីរ-បីគ្រួសារប៉ុណ្ណោះដែលបានទទួលដីធ្លី និងមានច្រើនគ្រួសារទៀតបានទិញដីលំនៅដ្ឋាននៅក្នុងភូមិ ។

### *ការចុះបញ្ជី និងបង្កាន់ដីធ្លី*

នៅក្នុងឆ្នាំ១៩៩១ មន្ត្រីសុរិយោដីស្រុកដោយរួមសហការជាមួយអ្នកដឹកនាំឃុំ បានបំផុសអោយប្រជាជនដាក់ពាក្យសុំប័ណ្ណប្លង់ដី សំរាប់ដីលំនៅដ្ឋាន និងដីកសិកម្ម ។ ថ្វីបើសឹងតែគ្រប់គ្រួសារទាំងអស់ បានដាក់ពាក្យសុំប័ណ្ណប្លង់ដីនៅការិយាល័យឃុំបាបោងរួចហើយក៏ដោយ ប៉ុន្តែមានប្រហែលតែ ៨៥% នៃគ្រួសារនៅក្នុងភូមិប៉ុណ្ណោះ ដែលបានទទួលប័ណ្ណប្លង់ដី សំរាប់ដីលំនៅដ្ឋានរបស់ខ្លួន ។ ចំពោះដីកសិកម្មវិញ មានតែពីរបីប័ណ្ណប៉ុណ្ណោះ ដែលបានចេញអោយហើយ ចំណែកឯប្រជាជនទូទៅគឺមានត្រឹមតែបង្កាន់ដៃប៉ុណ្ណោះ ។

គ្រួសារប្រហែល ១០% (ដែលសុទ្ធតែជាអ្នកធូរធារ) បានដាក់ពាក្យសុំ និងបានទទួលប័ណ្ណនៅចុងទសវត្សរ៍ ១៩៩០ ។ គ្រួសារដែលទិញដីទាំងនេះ ចង់បានប័ណ្ណប្លង់ដីយ៉ាងឆាប់ ដើម្បីបញ្ជាក់សិទ្ធិជាម្ចាស់របស់ខ្លួន ពីព្រោះដីមួយចំនួនត្រូវបានម្ចាស់មុនលក់អោយក្នុងស្ថានភាពមានធុរៈបន្ទាន់ ដោយសារត្រូវចំណាយច្រើនពេកលើការព្យាបាលជំងឺ ឬក៏ត្រូវកាត់សងបំណុលដែលមានការប្រាក់ខ្ពស់ (១០-៣០% ក្នុងមួយខែ ឬមួយរដូវ ទៅតាមសភាពការណ៍បន្ទាន់ ឬធ្ងន់ធ្ងរខ្លាំង) ។ ប័ណ្ណប្លង់ដីមួយ មានតំលៃ ១០០-២០០ដុល្លារអាមេរិក ។ ដើម្បីធ្វើ និងទទួលបានបង្កាន់ដៃសំរាប់ដីមួយកន្លែងៗដែលទើបរានថ្មី ប្រជាជនត្រូវចំណាយប្រាក់

---

៦ ក្រុមស្រាវជ្រាវបានទទួលពត៌មាននេះ នៅពេលចុះសិក្សាដល់កន្លែងក្នុងខែមិនា ឆ្នាំ២០០០ ។

៥០.០០០-១០០.០០០រៀល (ប្រហែល ១៣ ទៅ ២៦ដុល្លារអាមេរិក) ដែលភាគច្រើន ជាចំណាយក្រៅផ្លូវការនៅការិយាល័យសុរិយោដីស្រុក ។

មកដល់បច្ចុប្បន្ន ការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីភាគច្រើន ត្រូវបានធ្វើឡើងតាមរយៈការលក់ដូរក្រៅផ្លូវការនៅក្នុងភូមិ ។ ដើម្បីធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីតាមផ្លូវការ ត្រូវបង់ពន្ធ ១០% នៃតំលៃដីលក់សរុប ។ សំរាប់កិច្ចសន្យាក្រៅផ្លូវការ មានផ្តិតស្នាមមេដៃអ្នកលក់ (ប្តី និងប្រពន្ធ) និងអ្នកទិញ (ប្តី និងប្រពន្ធ) និងមានប្រធានភូមិ ធ្វើសាក្សីដឹងឮ គេត្រូវចំណាយប្រាក់តែ ១០.០០០-៣០.០០០រៀលប៉ុណ្ណោះ ។ តាមការអនុវត្តន៍ជាក់ស្តែង បង្កាន់ដៃដីត្រូវបានផ្ទេរពីអ្នកលក់ ទៅអោយអ្នកទិញដែលជាម្ចាស់កម្មសិទ្ធិថ្មី ។

ឪពុកម្តាយ ឬសាច់ញាតិចាស់ទុំដែលមិនចេះអក្សរជាច្រើននាក់ បានធ្វើការផ្ទេរដីទៅអោយកូនចៅ ឬសាច់ញាតិខ្លួនតាមរយៈការផ្តាំផ្ញើផ្ទាល់មាត់ នៅចំពោះមុខសាក្សីដែលជាញាតិមិត្ត ឬអ្នកជិតខាង ។ ក្នុងករណីខ្លះ មានធ្វើលិខិតបណ្តាំប្រគល់មរតកក្រៅផ្លូវការ ដោយមានការផ្តិតស្នាមមេដៃជាភស្តុតាង ។ ទង្វើបែបនេះ គឺសំដៅចៀសវាងការចំណាយច្រើន ហើយពួកគេក៏មានជំនឿផងដែរថា ក្រដាសស្នាមអាចផ្តល់សុខសន្តិភាពអោយកូនចៅជាន់ក្រោយ ។ ក្រុមស្រាវជ្រាវរកឃើញថា ប្រជាជនទាំងនេះមិនយល់ពីច្បាប់ទេ ។ ដូច្នេះគ្មានអ្វីគួរអោយឆ្ងល់ឡើយដែលដីមរតកទាំងអស់ ស្ថិតនៅក្នុងឈ្មោះឪពុកម្តាយជាផ្លូវការនៅឡើយ ។

ទាំងបង្កាន់ដៃ និងប័ណ្ណប្លង់ដី ត្រូវបានប្រើប្រាស់ជារបស់ដាក់បញ្ចាំសំរាប់ទទួលឥណទាន ។ ដើម្បីខ្ចីប្រាក់គេ ត្រូវធ្វើលិខិតក្រៅផ្លូវការមួយ ដែលជាញឹកញយតែងមានសាក្សីដឹងឮម្នាក់ផង ។ កសិករក្រីក្រត្រូវបង្ខំចិត្តធ្វើកិច្ចសន្យាប្រគល់សិទ្ធិប្រើប្រាស់ដីរបស់ខ្លួនទៅអោយអ្នកចងការក្នុងរយៈពេល ២-៣ឆ្នាំ សំរាប់ទឹកប្រាក់ប្រហែល ១៧៥-៣៥០ដុល្លារអាមេរិក ។ ចំនួនឥណទានជាក់ស្តែងអាស្រ័យទៅតាមទំហំផ្ទៃដី ។ កសិករជាច្រើននាក់បានខ្ចីប្រាក់ មានការប្រាក់ខ្ពស់ (១០-៣០%ក្នុងមួយខែ) សំរាប់ដោះស្រាយកង្វះស្បៀងក្នុងគ្រួសារ ការព្យាបាលជំងឺ ឬទិញ ធាតុចូលកសិកម្ម ។ កង្វះខាតចំណូលគ្រួសារបណ្តាលមកពីការឡើងចុះថ្លៃស្រូវអង្ករស្ថានមិនត្រូវ ការប្រមូលផលមិនបានល្អ និងបំណុលដ៏ច្រើន (សរុបទាំងការទាំងដើម) ត្រូវបានគេរាយការណ៍ថាជាដើមហេតុចំបងនៃការបាត់បង់ដីសំរាប់ផលិត ។

### *ទំនាស់ និងយន្តការដោះស្រាយ*

ទំនាស់ដីធ្លីបានកើតមានតាំងពីដើមទសវត្សរ៍១៩៩០ និងកំពុងតែកើនឡើងជាលំដាប់ ។ ទំនាស់ភាគច្រើនកើតចេញពីទំនាស់ព្រំដី, បញ្ហានានាជាប់ទាក់ទិននឹងការលក់ដីដោយមានធុរៈបន្ទាន់, ការបញ្ចាំ, ការបន្តមរតក, និងការរំលោភយកដីដោយសាច់ញាតិដែលជាអ្នកមាន ។ ទំនាស់ព្រំដីកើនខ្ពស់បំផុតនៅពេលមានកម្មវិធីផ្តល់ប័ណ្ណប្លង់ដីនាឆ្នាំ១៩៩១ ។ បច្ចុប្បន្ន មូលហេតុទំនាស់ចំបងគេគឺ ការលក់ដីដោយមានធុរៈបន្ទាន់ ដែលអ្នកចងការប្រាក់បង្ខំអោយធ្វើ ។ ទំនាស់កើតឡើងនៅពេលបំណុលដល់កំណត់ត្រូវសងប៉ុន្តែអ្នកខ្ចីពុំមានប្រាក់សង ឬក្នុងករណីត្រូវពុះចែកដីឱ្យអ្នកចងការប្រាក់ដើម្បីកាត់សងបំណុល ។ គេរាយការណ៍ថាទំនាស់បែបនេះស្ទើរតែទាំងអស់ ឬទំនាស់ពាក់ព័ន្ធនឹងការបន្តមរតក ត្រូវបានដោះស្រាយនៅកំរិតភូមិ ។ ប្រធានភូមិ ចាស់ទុំ និងសាក្សី ដើរតួយ៉ាងសំខាន់ក្នុងការដោះស្រាយទំនាស់ទាំងនេះ ។ ទោះជាយ៉ាងនេះក្តី ការដោះស្រាយទំនាស់មិនសុទ្ធតែបានត្រឹមត្រូវគ្រប់ពេលនោះទេ ។ អ្នកក្រជាញឹកញយទទួលបានដំណោះស្រាយមិនសូវយុត្តិធម៌ទេ ។

គេរាយការណ៍ថា កន្លងមកមានទំនាស់ធំៗចំនួន ៨ គឺ ទំនាស់ព្រំដីមាន ៣, ទំនាស់ដីបញ្ចាំមាន ៣, និង ២ករណីនៃការរំលោភយកដីដោយសាច់ញាតិជាអ្នកមាន ។ ប្រធានភូមិបានជួយដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការខ្ចីបុលទាំងអស់ ដោយកែប្រែឥណទានរយៈពេលខ្លី អោយទៅជាឥណទានរយៈពេលវែងវិញ ។ អាជ្ញាធរស្រុកបានជួយផ្សះផ្សាទំនាស់ព្រំដីនានា ។ ទំនាស់មួយចំនួនទៀតកំពុងប្តឹងតវ៉ាគ្នានៅតុលាការ ។ សរុបមក យន្តការនៅមូលដ្ឋាន ហាក់ដូចជដំណើរការបានល្អ ។

ក្នុងករណីមួយស្ត្រីម្នាក់បានកាប់ឆ្ការរានដីលិចទឹកមួយអំពកកាលពីចុងទសវត្សរ៍១៩៨០ ហើយនាងមានបង្កាន់ដៃសំគាល់ដីនេះ ។ នាងបានប្រគល់ដីនេះឱ្យប្អូនប្រុសធ្វើស្រែអស់ពីរ-បីឆ្នាំ ។ ក្រោយការបោះឆ្នោតកំរិតជាតិឆ្នាំ១៩៩៣ បងប្រុសរបស់នាងបានទាមទារយកដីនេះ នៅពេលប្អូនប្រុស សំរេចប្រគល់ដីទៅអោយបងស្រីវិញ ដោយសុំយកតែមាស ១ជី (ប្រហែលជា ៣៦ដុល្លារអាមេរិក) និងអង្ករ ២០០គីឡូក្រាម ។ ទោះបីជាមានសាក្សីពីភូមិ ឃុំ និងស្រុក បញ្ជាក់ពីការផ្ទេរសិទ្ធិប្រើប្រាស់ដីកាលពីមុន និងបញ្ជាក់ថាដីនេះជារបស់ប្អូនស្រីក៏ដោយ ក៏តុលាការ (ក្រោយបានពន្យាការកាត់ក្តីអស់ប្រហែលបួនឆ្នាំ) បានកាត់ក្តីអោយដីនេះទៅខាងបងប្រុស ។ បងប្រុសត្រូវបានគេរំលឹកថា បើគាត់បានបំពានយកដីប្អូនស្រីខ្លួនមែន គាត់នឹងទទួលកម្មពៀរនៅជាតិក្រោយ! អ្នកដឹកនាំសហគមន៍ក៏បានរាយការណ៍ផងដែរពីករណីផ្សេងៗទៀតដែលពុំមានយុត្តិធម៌ ។ រឿងរ៉ាវទាំងនេះបានប៉ះពាល់មិនល្អដល់ទំនុកចិត្តរបស់ប្រជាជនចំពោះការកាត់ក្តីនៅអាជ្ញាធរថ្នាក់លើៗ ។

### *ទស្សនៈរបស់ប្រជាជនស្តីពីអត្ថប្រយោជន៍នៃការចុះបញ្ជីដីធ្លី*

គេរាយការណ៍ថា ប័ណ្ណប្លង់ដីមានសារៈសំខាន់ណាស់ចំពោះសហគមន៍ ។ ទីមួយ វាអាចបញ្ជាក់យ៉ាងច្បាស់នូវកម្មសិទ្ធិលើដីនីមួយៗដែលអាចបង្ការទំនាស់ដីធ្លី និងការរំលោភយកដីបាន ហើយវាផ្តល់អោយប្រជាជននូវអត្ថប្រយោជន៍ខាងផ្លូវចិត្ត និងផ្លូវសេដ្ឋកិច្ចថែមទៀត ។ គេរាយការណ៍ថា ការប្តឹងផ្តល់តាមផ្លូវតុលាការ វារំខានដល់ការរកចំណូល និងមានតំលៃខ្ពស់ណាស់ ។ ទីពីរ ប័ណ្ណប្លង់ដី មានតំលៃដូចមាសដែរ ព្រោះអាចប្រើប្រាស់ ដាក់បញ្ចាំយកឥណទាន ឬក៏លក់យកប្រាក់សំរាប់ដោះស្រាយធុរៈបន្ទាន់ក្នុងគ្រួសារ ។

ថ្វីបើមានអត្ថប្រយោជន៍ច្រើនដូច្នេះក៏ដោយ ក៏ប្រជាជនហាក់ដូចជាមិនសូវចង់បានប័ណ្ណប៉ុន្មានទេ ពីព្រោះវាមានតំលៃខ្ពស់ពេក បើធៀបទៅនឹងលទ្ធភាពរកចំណូលបច្ចុប្បន្នរបស់ពួកគេ ។ អ្នកភូមិដែលបានឆ្លើយសំភាសន៍ប្រាប់ថា សុខចិត្តបង់ប្រាក់ ៤.០០០-៥.០០០រៀលសំរាប់ប័ណ្ណប្លង់ដីមួយ ។ ចំណុចព្រួយបារម្ភមួយទៀតគឺ ប្រជាជនយល់ថា កម្មវិធីធ្វើប័ណ្ណប្លង់ដីថ្មី នឹងទទួលស្គាល់ទំហំដីដែលកត់ត្រានៅក្នុងបង្កាន់ដៃចេញឱ្យគ្រួសារនីមួយៗ ។ ប៉ុន្តែគ្រួសារ ជាច្រើនបានកាប់រានដីបន្ថែមបន្ទាប់ពីបានទទួលបង្កាន់ដៃក្នុងឆ្នាំ១៩៩១ ដូច្នេះទំហំដីកត់ត្រាក្នុងបង្កាន់ដៃ វាតូចជាងទំហំដីជាក់ស្តែងដែលគេមាន ។ ពួកគេព្រួយបារម្ភថា នឹងត្រូវបាត់បង់ដីដោយសារការចុះបញ្ជីដីធ្លីថ្មីនេះ ។ ពួកគេ ក៏បារម្ភដែរថា នឹងត្រូវបង់ពន្ធច្រើនថែមទៀត ។ ប្រជាជនច្រើននាក់បារម្ភថា ទំនាស់ព្រំដីនឹងផុសឡើងម្តងទៀត នៅពេលមានការចុះបញ្ជីដីធ្លី គឺដូចកាលពីឆ្នាំ១៩៩១ ។

## **៤. ករណីសិក្សានៅភូមិ៤ ក្នុងខេត្តកំពង់ស្ពឺ**

### *សេចក្តីផ្តើម*

ខេត្តកំពង់ស្ពឺស្ថិតក្នុងតំបន់កណ្តាលនៃប្រទេសកម្ពុជា, មាន ៨ស្រុក, និងមានប្រជាជនសរុប ៥៩៨.៨៨២នាក់ ។ ប្រជាជន ភាគច្រើនរស់នៅតាមបណ្តោយផ្លូវជាតិលេខ៤ ដែលភ្ជាប់ទីក្រុងភ្នំពេញទៅក្រុងព្រះសីហនុ ។ ទីរួមខេត្តក៏ស្ថិតនៅតាមបណ្តោយ ផ្លូវនេះដែរ ។ តំបន់មួយចំនួននៅភាគខាងជើងនៃខេត្ត និងនៅតាមបណ្តោយផ្លូវជាតិបានទាក់ទាញការអភិវឌ្ឍន៍ឧស្សាហកម្ម ក្នុងកំរិតខ្ពស់ណាស់ ។ ឆ្ងាយពីនេះបន្តិច វិនិយោគលើការអភិវឌ្ឍន៍ភាគច្រើនមានរូបភាពជាដីសម្បទានដាំដំណាំកសិកម្ម ។ ក្នុង ពេលជាមួយគ្នា តំបន់នេះបានទាក់ទាញអ្នកវិនិយោគទុនមកពីភ្នំពេញដែលជាអ្នកប្រមូលទិញដីទុកលក់យកចំនេញ និងធ្វើចំការ ។ សកម្មភាពផុសផុលធ្វើរបងស៊ីមង់ត៍ព័ទ្ធជុំវិញ ដីទុកចោលមិនប្រើប្រាស់នៅតាមបណ្តោយផ្លូវជាតិ គឺជាភស្តុតាងជាក់ស្តែងនៃការប្រមូលផ្តុំដីធ្លី និងកំណើនតំលៃដី នៅក្នុងទីផ្សារដីធ្លីដែលទើបផុសឡើង ។ អតីតម្ចាស់ដីតូចៗបានធ្វើចំណាកស្រុកទៅកាន់តំបន់ផ្សេងទៀតក្នុងខេត្ត ឬក្នុងប្រទេសដើម្បីធ្វើកសិកម្ម ឬទៅភ្នំពេញដើម្បីលក់ពលកម្មក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម ។ តំបន់នៅឆ្ងាយពីផ្លូវជាតិលេខ៤, មិនទាន់មានការអភិវឌ្ឍន៍ទេ ហើយពឹងផ្អែកជាមូលដ្ឋានលើកសិកម្មជីវព្រឹត្តិ ។ ដីនៅជិតភ្នំឱរ៉ាល់

ជាដីព្រៃ និងដីភ្នំ និងមានប្រជាជនតិចតួច ។ ដីនៅទីនោះមានតំលៃទាប ហើយទីផ្សារដីមិនទាន់មានសកម្មភាពច្រើននៅឡើយ ។

ក្រោយពីរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ០៣ នៅឆ្នាំ១៩៨៩ ដែលបានអនុញ្ញាតអោយមានទូវការកាន់កាប់ដីជាលក្ខណៈឯកជន, ក្នុងចំណោមអ្នកមានដីធ្លី គេឃើញមានតែ ១០-១៥%ប៉ុណ្ណោះដែលបានដាក់ពាក្យសុំប័ណ្ណប្លង់ដី ។ តាំងពីពេលនោះមកប្រហែលតែ ៥% នៃដីទាំងអស់នៅក្នុងខេត្តប៉ុណ្ណោះដែលមានប័ណ្ណប្លង់ដី ។ ការដាក់ពាក្យសុំ និងការចេញប័ណ្ណប្លង់ដីមានចំនួនតិចតួច ដោយសារស្ថានការណ៍អសន្តិសុខ ។ ក្នុងរយៈពេលពីឆ្នាំ១៩៨៩-៩៧ មន្ត្រីរដ្ឋាភិបាលមិនអាចចុះធ្វើអង្កេតសុរិយោដីបានទេ ហើយជាលទ្ធផល ការផ្តល់ប័ណ្ណប្លង់ដីគឺធ្វើតែក្នុងឃុំណាដែលមានសន្តិសុខល្អ ។ ទោះជាយ៉ាងនេះក្តី ក្នុងអំឡុងឆ្នាំ១៩៩៣-៩៧ ចំនួនពាក្យសុំប័ណ្ណបានកើនឡើង គឺស្របគ្នានឹងការកែលំអបរិយាកាសសន្តិសុខបន្ទាប់ពីមានវត្តមានអ៊ុនតាក់ ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៩៧ មក ចំនួនពាក្យសុំប័ណ្ណបានថយចុះវិញ ពីព្រោះប្រជាជនយល់ថា ពួកគេបានប្រើប្រាស់ដីជាយូរមកហើយ ដូច្នេះមិនចាំបាច់ទាមទារសិទ្ធិជាផ្លូវការអ្វីទេ ។ ចំនួនអ្នកវិនិយោគមកពីខាងក្រៅក៏បានធ្លាក់ចុះដែរ បន្ទាប់ពីមានព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ ។ តាមសេចក្តីនេះ ទីផ្សារដីធ្លីក្នុងតំបន់បានប្រែប្រួលយ៉ាងខ្លាំងទៅតាមស្ថានការណ៍នយោបាយ ។ សំខាន់ជាងនេះទៀត ប្រជាជនរារែកមិនចង់ធ្វើប័ណ្ណ ពីព្រោះការធ្វើប័ណ្ណកម្មសិទ្ធិនីមួយៗត្រូវចំណាយក្រៅផ្លូវការច្រើនក្រាស់ណាស់ពី ៣០០-៥០០ដុល្លារអាមេរិក អាស្រ័យទៅតាមទីកន្លែង និងកាលៈទេសៈ ។

### *ភូមិ ៤*

ភូមិ៤ ស្ថិតនៅក្នុងស្រុកភ្នំស្រួច ខាងប៉ែកនិរតីនៃទីក្រុងភ្នំពេញ និងនៅតាមដងផ្លូវជាតិលេខ៤ ដោយត្រូវជិះរថយន្តពីភ្នំពេញប្រហែល ១ម៉ោង៥០នាទី ទើបដល់ ។ ភូមិ៤ ស្ថិតក្នុងចំណោមភូមិតូចៗនៅជិតៗគ្នាចំនួន៦ នៅក្បែរចំណុចប្រសព្វគ្នានៃផ្លូវជាតិលេខ៤ និងផ្លូវចូលទៅឧទ្យានជាតិគីរីរម្យ ។ នៅឆ្នាំ១៩៨២ មាន ៩៣គ្រួសារបានត្រឡប់មករស់នៅតំបន់នេះវិញ បន្ទាប់ពីខ្មែរក្រហមបានជំលៀសពួកគេទៅកន្លែងផ្សេងមួយរយៈ ។ ពីឆ្នាំ១៩៨២-៩៧ គឺមុនពេលកងទ័ពខ្មែរក្រហមបានផ្តាច់ខ្លួនចូលមកខាងរដ្ឋាភិបាល តំបន់នេះជាកន្លែងប្រទាញប្រទង់ក្តៅគគុក ។ កាលនោះ កងពលតូចលេខ៤៤ គ្រប់គ្រងដីធ្លីក្នុងតំបន់ដែលភាគច្រើនស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ។ ដីធ្លីទាំងនេះត្រូវបានប្រើប្រាស់សំរាប់ធ្វើមូលដ្ឋានកងទ័ព សាលាយោធា និងកន្លែងរស់នៅរបស់គ្រួសារទាហាន ។ ចាប់ពីពេលនោះមក យោធាបានបន្តគ្រប់គ្រងកាន់កាប់ដីធ្លី ដោយបានបែងចែកមួយចំនួនទុកធ្វើជាតំបន់អភិវឌ្ឍន៍យោធាសំរាប់បំរើគោលដៅផ្សេងៗ ដូចជាកន្លែងតាំងទីលំនៅដ្ឋានរបស់យោធិនរំសាយជាដើម ។

សព្វថ្ងៃនេះ ភូមិ៤ មានប្រជាជន ៤៨៦គ្រួសារ ។ ក្រៅពីគ្រួសារអ្នកភូមិចាស់ មានអ្នកចំនូលថ្មីជាច្រើនដែលជាទាហានរដ្ឋាភិបាល ក្រុមគ្រួសាររបស់គេ ដែលបានមកនៅក្នុងតំបន់នេះតាំងពីដើមទសវត្សរ៍១៩៨០ ព្រមទាំងជនចំណាកស្រុក ដូចជាកសិករ អ្នករកស៊ីតូចតាច... មកពីតំបន់នានាក្នុងខេត្តកំពង់ស្ពឺ និងខេត្តផ្សេងទៀត ។ កំណើនប្រជាជនមានសន្ទុះយ៉ាងលឿននាឆ្នាំ១៩៩៧ នៅពេលខ្មែរក្រហមបានផ្តាច់ខ្លួនចូលមកខាងរដ្ឋាភិបាល ហើយស្ថានការណ៍សន្តិសុខក្នុងតំបន់ ក៏បានល្អប្រសើរយ៉ាងខ្លាំងវិញ ។ បច្ចុប្បន្ន មានអតីតខ្មែរក្រហម ១.០៣៣គ្រួសារ រស់នៅក្នុងឃុំត្រែងត្រយឹងដែលតំណាងអោយប្រហែលមួយភាគបីនៃប្រជាជនសរុប ។ ភូមិនេះមានភាពងាយស្រួល ក្នុងការធ្វើដំណើរទៅភ្នំពេញ និងក្រុងព្រះសីហនុ ហើយនៅជិតឧទ្យានជាតិគីរីរម្យ ដូច្នេះបានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកវិនិយោគជាច្រើនមកពីទីក្រុងភ្នំពេញ ។

### *លំនាំនៃការប្រើប្រាស់ដីធ្លី*

ការវិវត្តន៍នៃលំនាំប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍ទីផ្សារដីធ្លី មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងស្ថានការណ៍សន្តិសុខក្នុងតំបន់ក្នុងរយៈពីរទសវត្សរ៍កន្លងមក ។ អ្នកភូមិដែលរស់នៅទីនេះតាំងពីដើមបានប្រាប់ថា តាំងពីទសវត្សរ៍១៩៨០ មក ពួកគេបានធ្វើកសិកម្មផ្លាស់ទី និងពឹងផ្អែកលើព្រៃឈើដើម្បីចិញ្ចឹមជីវិត ។ ប្រជាជនបានសំរបការធ្វើកសិកម្មរបស់ខ្លួនទៅតាមសភាពការណ៍សន្តិសុខ ។ នៅពេលនោះ កត្តាសន្តិសុខបានធ្វើអោយទីផ្សារដីធ្លីគ្មានសកម្មភាព ឯដីធ្លីក៏មានតំលៃទាបណាស់ ។

ប៉ុន្តែចាប់ពី ពេលខ្មែរក្រហមបានផ្តាច់ខ្លួនក្នុងឆ្នាំ១៩៩៧ មក តំរូវការដីធ្លី និងតំលៃដីធ្លីបានកើនឡើងយ៉ាងខ្លាំង ។

កំណើនសកម្មភាពទីផ្សារដីធ្លីដែលមានការប្រកួតប្រជែងគ្នា បានធ្វើអោយមានការផ្លាស់ប្តូរពីការធ្វើកសិកម្មផ្លាស់ទី ទៅជាការធ្វើស្រូវស្រែវិញ ការដាំដំណាំពាណិជ្ជកម្មក្នុងទ្រង់ទ្រាយតូចៗ និងការវិនិយោគទ្រង់ទ្រាយធំ ដោយអ្នកទិញដីទុកលក់យកចំណេញ និងការផ្តល់ដីសម្បទានធ្វើចំការធំៗ ។ សំរាប់រយៈពេលយូរអង្វែង កសិករផ្លាស់ទីជីវព្រឹត្តិ (subsistence swidden farmers) ដែលមិនអាចផ្លាស់ប្តូរទៅដាំដំណាំពាណិជ្ជកម្ម ឬធ្វើស្រូវស្រែតាមធម្មតាបាន នឹងត្រូវរកចំណូលបន្ថែមទៅលើផលិតកម្មផ្លាស់ទីរបស់ខ្លួន ដោយធ្វើការងារក្រៅពីកសិកម្ម ឬបោះបង់ការងារកសិកម្ម ហើយធ្វើចំណាកស្រុកទៅកាន់ទីក្រុង ។ ប្រធានភូមិប្រាប់ថា ប្រជាជនក្នុងភូមិមិនអាចពង្រីកដី កសិកម្មបានទៀតទេ ពីព្រោះអតីតខ្មែរក្រហម រដ្ឋាភិបាល យោធា ក្រុមហ៊ុននានា និងអ្នកមានអំណាច បានគ្រប់គ្រងដីក្នុងតំបន់នេះអស់ហើយ ។

អាស្រ័យដោយការរ៉ាយរ៉ាប់នេះ ទីផ្សារពលកម្មក្នុងភូមិ៤ ក៏ដូចជានៅកន្លែងឯទៀតក្នុងឃុំត្រែងត្រយឹងដែរ បានបង្ហាញនូវការប្រជែងគ្នារវាងពួកអ្នកភូមិតាំងពីដើម អ្នកចំណូលថ្មី អ្នកទិញដីធ្លីមកពីក្រុងភ្នំពេញ ក្រុមហ៊ុនម្ចាស់ដីកសិកម្មសម្បទាន អង្គភាពយោធា អតីតទាហានខ្មែរក្រហម និងក្រុមគ្រួសារ ។

### *ប័ណ្ណប្លង់ដី និងការផ្តល់ប័ណ្ណប្លង់ដី*

ប្រជាជនក្នុងឃុំត្រែងត្រយឹងប្រហែល ៦០% មានបង្កាន់ដៃសំរាប់ដីលំនៅដ្ឋាន ប៉ុន្តែមានប្រជាជន ២-៣% ប៉ុណ្ណោះដែលមានប័ណ្ណប្លង់ដី ។ សំរាប់ដីកសិកម្មវិញក៏ដូចគ្នាដែរ ប្រជាជនច្រើនណាស់មានបង្កាន់ដៃ ប៉ុន្តែប័ណ្ណប្លង់ដីមិនទាន់មានចេញអោយនៅឡើយទេ ។ ក្នុងភូមិ៤ ដីកសិកម្មប្រហែល ១០% មានបង្កាន់ដៃទទួលពាក្យសុំកម្មសិទ្ធិ ។ គេបានរាយការណ៍ថា ៥៣% នៃដីលំនៅដ្ឋានក្នុងភូមិមានប័ណ្ណប្លង់ដី ។ ក្នុងតួលេខនេះ ភាគច្រើនគឺប្រហែលជាប្រជាជនរស់នៅក្នុងភូមិតាំងពីយូរមកហើយ (អ្នកបានដាក់ពាក្យសុំតាំងពីដើម នៅពេលដីមានតំលៃទាបនៅឡើយ) ចំណែកឯអ្នកចំណូលថ្មី គឺប្រហែល ១០% ប៉ុណ្ណោះដែលមានបង្កាន់ដៃ ។ ប្រធានភូមិបានពន្យល់ថា ដើម្បីធ្វើប័ណ្ណប្លង់ដីមួយ គេត្រូវចំណាយអស់ច្រើនណាស់ ។ បង្កាន់ដៃមួយមានតំលៃ ៣០-៤០ដុល្លារអាមេរិក ឯប័ណ្ណប្លង់ដីមួយអាចមានតំលៃ ៣៥០-៤០០ដុល្លារអាមេរិក ។ បើធៀបទៅនឹងកំរិតជីវភាពវិញ គឺវាខ្ពស់ហួសពេក ពីព្រោះត្រូវស្មើនឹងផលិតកម្មចំនួនបីឆ្នាំរបស់កសិករផ្លាស់ទី (ធ្វើស្រូវ) ឬផលិតកម្មចំនួនពីរឆ្នាំរបស់កសិករដាំដំណាំចំការ ។ ជាទូទៅ មានតែអ្នកធូរធារទេដែលអាចសុំប័ណ្ណប្លង់ដីបាន ដូចជាអ្នកទីក្រុងមកទិញដីពីកសិករមូលដ្ឋានជាដើម ។ ពួកនេះអាចធ្វើរបងព័ទ្ធជុំវិញដី ដើម្បីពង្រឹងសិទ្ធិកាន់កាប់របស់ខ្លួនទៀតផង ។

### *ទំនាស់ដីធ្លី*

ទំនាស់ដីធ្លីមានតិចតួចបំផុត នៅក្រោមរបបធ្វើកសិកម្មផ្លាស់ទីជីវព្រឹត្តិដែលមានប្រជាជនតិច ។ ការទាមទារកម្មសិទ្ធិជាន់គ្នាលើដីតែមួយអាចដោះស្រាយបានតាមរយៈការចរចាដោយផ្ទាល់ ដោយអាចមានជំនួយពីភាគីទីបី ដូចជាប្រធានភូមិ ឬមេឃុំជាដើម ។ នៅពេលបច្ចុប្បន្ននេះ ទំនាស់ព្រំដីកំពុងតែកើតឡើង ដោយសារតែប្រជាជនអ្នកលក់ដីនៅតាមមូលដ្ឋានត្រូវបំពេញលក្ខខណ្ឌកំណត់ព្រំដីច្បាស់លាស់អោយគេ ។ ក្នុងករណីមួយចំនួនអ្នកធ្វើចំការធំៗ ឬកសិករប្រកបរបរធ្វើស្រូវស្រែ កាលពីដំបូងអាចរំលោភយកដីដែលកសិករផ្លាស់ទីតូចតាចទុកចោលទំនេរជាបណ្តោះអាសន្ន ហើយបន្ទាប់មកក៏ចាប់ពង្រីកវាតយកដីបន្ថែមបន្តពីដីនោះមកទៀត ។ ការរំលោភយកដីមួយបែបទៀត កើតឡើងនៅលើដីទុកចោលមិនប្រើប្រាស់ដែលជារបស់អ្នកមកពីក្រៅ គឺនៅពេលមានជនចំណាកស្រុក ឬប្រជាជនមូលដ្ឋាន ទៅសង់ផ្ទះ និង/ឬដាំដុះលើដីនោះ ។ អ្នកមកពីក្រៅអះអាងថាបានទិញដីនោះ និងអាចមានប័ណ្ណប្លង់ដីជាសំអាងផង ចំណែកអ្នកកំពុងកាន់កាប់ដីជាក់ស្តែង សំអាងលើការប្រើប្រាស់ដីធ្វើផលិតកម្ម ។ ដូច្នេះ ស្ថានភាពមានកម្មសិទ្ធិដីធ្លី តែមិនបានប្រើប្រាស់ដីជាក់ស្តែង វាជាបាតុភូតថ្មីមួយសំរាប់ប្រជាជនដែលរស់នៅតាមជនបទ ដែលមានការយល់ឃើញតាមបែបប្រពៃណីថា សិទ្ធិគ្រប់គ្រងដី វាផ្អែកជាសំខាន់លើការប្រើប្រាស់ដី មិនមែនលើកិច្ច

សន្យាទេ ។

ទំនាស់ដីធ្លីផ្សេងទៀតពាក់ព័ន្ធនឹង ដីគ្រប់គ្រងដោយយោធា ។ ដោយឡែកករណីមួយដែលធ្វើអោយ LDSC មានកង្វល់យ៉ាងខ្លាំង គឺអ្នកភូមិ ១០៨គ្រួសារបានអះអាងថា ដីរបស់ខ្លួនត្រូវបានរំលោភយកដោយក្រុមហ៊ុនកូរ៉េមួយដែលកំពុងដំណើរការសម្បទានកសិកម្ម ។ ខាងយោធាក៏ហាក់ដូចជាមានជាប់ពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីទាំងនេះដែរ ។ អ្នកភូមិបានប្រាប់ថាការប្រឹងប្រែងរបស់ពួកខ្លួនដើម្បីយកដីមកវិញបានបរាជ័យ ទោះបីបានទៅតវ៉ានៅភ្នំពេញ និងបានធ្វើបាតុកម្មនៅមុខរដ្ឋសភាក៏ដោយ ។ ប្រជាជនបានលើកមតិថា ដំណោះស្រាយដោយយុត្តិធម៌មួយ គឺត្រូវប្រគល់ដីអោយពួកខ្លួនវិញ ឬផ្ដល់សំណងជាដីមានទំហំប្រហាក់ប្រហែលគ្នានៅក្នុងតំបន់ដដែល ។

ករណីមួយទៀត គឺវិវាទមួយប្រភេទដែលឃើញមាននៅកន្លែងដទៃដែរ ។ គេរាយការណ៍ថា កាលពីមុន មេទាហានខ្លះបានអនុញ្ញាតអោយប្រជាជនធ្វើស្រែលើដីដែលយោធាគ្រប់គ្រង ។ នៅពេលមេបញ្ជាការមុនផ្លាស់ចេញទៅមេបញ្ជាការថ្មីបានសំរេចលែងអនុញ្ញាតឱ្យប្រជាជនប្រើប្រាស់ដីទៀត ។ ក្នុងស្ថានភាពបែបនេះ គ្រួសារនានាដែលបានដាំដុះលើដីនោះអស់មួយរយៈពេលមកហើយ យល់ថាខ្លួនទទួលបានសិទ្ធិស្របច្បាប់លើដីធ្លី ហើយក៏មានទំនាស់គ្នាជាមួយនឹងសិទ្ធិគ្រប់គ្រងរបស់យោធានៅលើដីដដែលនោះ ។

ទំនាស់មួយប្រភេទទៀតដែលពាក់ព័ន្ធនឹងទាហាន ដែលបានតាំងទីលំនៅលើដីរបស់អង្គភាពយោធាតាំងពីដើមទសវត្សរ៍ ១៩៩០ ។ គ្រួសារមួយចំនួនយល់ថា ការទាមទារដីលំនៅដ្ឋាន និងដីនៅជាប់គ្នានោះ គឺជាការត្រឹមត្រូវ ដោយសំអាងថាពួកខ្លួនបានរស់នៅ និងប្រើប្រាស់ដីធ្វើផលិតកម្មជាយូរមកហើយ ដូចជា ដាំដើមឈើ និងធ្វើស្រែជាដើម ។ តែអង្គភាពយោធាបានប្រាប់ពួកគេថា ត្រូវតែចាកចេញពីដីនេះក្នុងពេលឆាប់ៗខាងមុខ ។ គ្រួសារទាហានយល់ថា ពុំមានយុត្តិធម៌ទេ ហើយពួកគេនឹងប្ដឹងទៅ LDSC បើសិនត្រូវបង្ខំអោយចាកចេញ ។

ទំនាស់ប្រភេទចុងក្រោយដែលបានពិនិត្យឃើញ ពាក់ព័ន្ធនឹងអ្នកភូមិមួយក្រុមដែលទាមទារយកដីកំពុងប្រើប្រាស់ដោយសាលាយោធាហ្វឹកហ្វឺនកងកាំភ្លើងធំ ។ LDSC បានពិនិត្យករណីទំនាស់ និងបានបញ្ជាក់គាំទ្របុព្វសិទ្ធិរបស់យោធាក្នុងការបន្តប្រើប្រាស់ដីធ្លីជាប់ទាក់ទិន ដើម្បីបំរើគោលដៅរបស់ខ្លួន ។ ប្រជាជនអ្នកតវ៉ាបាននិយាយថា នឹងធ្វើការតស៊ូតទៅទៀត ប៉ុន្តែមិនទាន់ដឹងថាត្រូវធ្វើយ៉ាងដូចម្ដេចទេ ។

### *ការដោះស្រាយទំនាស់*

ការវិវត្តន៍នៃលំនាំប្រើប្រាស់ដីធ្លី វាកំណត់ចរិតនៃទំនាស់ដីធ្លី, ហើយការវិវត្តន៍នៃទំនាស់ដីធ្លី វាកំណត់ពីបែបបទនៃដំណើរការដោះស្រាយទំនាស់ ។ ឧទាហរណ៍ ប្រធានតុលាការខេត្តបានបញ្ជាក់ថា វិធីសាស្ត្រដែលនិយមប្រើសំរាប់ដោះស្រាយទំនាស់ គឺការចរចា ពីព្រោះតុលាការ និង LDSC ពុំមានអំណាចពិតប្រាកដ ដើម្បីចាប់បង្ខំអោយអនុវត្តច្បាប់ទេ ។ ចំពោះករណីវិវាទរវាងគ្រួសារ ដូចជាទំនាស់ព្រំដី ឬការទាមទារដីមួយកន្លែងជាន់គ្នា ជាធម្មតាអាចដោះស្រាយបានតាមរយៈការចរចាសំរុះសំរួល ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រធានតុលាការបានពិនិត្យឃើញថា នៅពេលករណីទំនាស់មានជាប់ពាក់ព័ន្ធនឹងបុគ្គល/ស្ថាប័នមានអំណាច វាជាការពិបាកសំរាប់តុលាការខេត្ត ក្នុងការដាក់បង្ខំអោយអនុវត្តសាលក្រមតុលាការ ។ ជាទូទៅ តុលាការច្រើនតែ ដោះស្រាយទំនាស់រវាងគ្រួសារ រីឯ LDSC ច្រើនតែទទួលសំរបសំរួលផ្សះផ្សាវិវាទធំៗដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ឬស្ថាប័នរដ្ឋ ហើយដែលអាចក្លាយជារឿងនយោបាយបាន ។ ដូច្នេះគោលដៅរបស់ LDSC គឺបំបែកករណីនានាដែលអាចមានផលប៉ះពាល់ខាងនយោបាយ ។ ឧទាហរណ៍ សមាជិក LDSC ម្នាក់បានលើកថា មានក្រុមខ្លះអាចមកជំរុញថែមនូវទំនាស់មួយចំនួនដើម្បីឆ្លៀតយកចំណេញខាងនយោបាយ ។

អាជ្ញាធរស្រុក និងខេត្តបញ្ជាក់ថា ជារឿយៗពួកគេមិនអាចគ្រប់គ្រង និងដោះស្រាយបញ្ហា ឬទំនាស់ដីធ្លីផ្សេងៗបានទេ

ពីព្រោះពុំមានដែនសមត្ថកិច្ចច្បាស់លាស់ក្នុងរឿងខ្លះៗ ។ ឧទាហរណ៍ អាជ្ញាធរស៊ីវិលបាននិយាយថា ពួកគេមិនបានដឹងពីការប្រើប្រាស់ និងតំរូវការដីធ្លីរបស់យោធាទេ ។ វាហាក់ដូចជា សេចក្តីសំរេចនានាស្តីពីការប្រើប្រាស់ និងបែងចែកដីធ្លី គឺត្រូវបានធ្វើឡើងដោយថ្នាក់លើៗនៅឯភ្នំពេញ ឯសេចក្តីសំរេចស្តីពីការផ្ទេរសិទ្ធិកាន់កាប់ អាចធ្វើបាននៅថ្នាក់មូលដ្ឋាន ។ ក្នុងករណីពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីពីយោធាទៅអោយក្រុមហ៊ុនឯកជន រដ្ឋអំណាចមូលដ្ឋានរាយការណ៍ថា ពួកគេមិនអាចធ្វើអន្តរាគមន៍បានទេ ទោះបីដឹងថាអាចមានទំនាស់ទៅថ្ងៃក្រោយក៏ដោយ ពីព្រោះពុំមានសិទ្ធិអំណាចក្នុងរឿងនេះ ។ ដូច្នេះ គឺពុំឃើញមានស្ថាប័នណាមួយដែលមានសិទ្ធិអំណាចដាច់ណាត់ និងជាទៀតទាត់ ក្នុងការគ្រប់គ្រងសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីទេ ។

ឧទាហរណ៍មួយទៀតនៃភាពមិនច្បាស់លាស់ ឬការប្រទាំងប្រទើសគ្នានៃដែនសមត្ថកិច្ច គឺមានអតីតខ្មែរក្រហមផ្តាច់ខ្លួនមួយក្រុមរស់នៅតំបន់មួយក្នុងឃុំត្រែងត្រយឹង (នៅជិតព្រំប្រទល់ខេត្តកំពត) បានបង្កើតឃុំស្វយ័តរបស់ពួកគេមួយ ។ ពួកគេមានរបៀបរបបគ្រប់គ្រងរដ្ឋបាលដោយឡែក រួមទាំងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីផងដែរ ។ តាមច្បាប់ តំបន់នេះស្ថិតក្រោមការត្រួតត្រារបស់ប្រធានឃុំត្រែងត្រយឹង តែជាក់ស្តែងគាត់មិនបានត្រួតត្រាវាទេ ។ ប៉ុន្តែនៅពេលមានទំនាស់កើតឡើង គេរំពឹងថាគាត់នឹងទៅធ្វើអន្តរាគមន៍ ។

*សេចក្តីសង្កេត*

ជាការពិតមែន គេពិបាកនឹងផ្តល់យោបល់ពីទិដ្ឋភាពខាងផ្លូវច្បាប់នៃការអះអាងកម្មសិទ្ធិទំនាស់គ្នាផ្សេងៗ ប៉ុន្តែវាជាការសំខាន់ដែលត្រូវកត់សំគាល់ថា ទំនាស់ទាំងនេះតំណាងអោយករណីដ៏ពិបាកៗនៃផលប្រយោជន៍ដែលប្រឆាំងគ្នា ជាពិសេសនៅពេលដែលយោធាគឺជាសមាជិកមួយនៃ LDSC ។

ទំនាស់ទាំងនេះបានគូសបញ្ជាក់ផងដែរពីស្ថានភាពនៃក្រសួងខុសៗគ្នាដែលមានផលប្រយោជន៍ផ្សេងៗគ្នា បែរជាមានដែនសមត្ថកិច្ចជាន់គ្នាក្នុងការធ្វើផែនការ និងការគ្រប់គ្រងការប្រើប្រាស់ដីធ្លី ។ ដូច្នេះហើយ ការដោះស្រាយទំនាស់ដីធ្លីបានចោទជាបញ្ហាលំបាកយ៉ាងច្រើនដល់យន្តការដោះស្រាយទំនាស់ផ្សេងៗដែលមានស្រាប់ ។

ប្រភពដ៏សំខាន់មួយនៃតំរូវការដីធ្លី គឺអង្គភាពយោធា ។ តំរូវការផុសឡើងចាប់តាំងពីពេលមានបង្កើតមូលដ្ឋានកងទ័ពនៅក្នុងតំបន់ ដើម្បីប្រយុទ្ធជាមួយនឹងកងកំលាំងខ្មែរក្រហមដែលធ្វើសកម្មភាពនៅតំបន់គិរីរម្យ ។ ស្របគ្នានឹងដំណើរការកាត់បន្ថយទ័ព ទាហានចូលនិវត្តន៍មានតំរូវការដីធ្លីកាន់តែច្រើនឡើងដើម្បីតាំងទីលំនៅដ្ឋាន ហើយតំរូវការដីធ្លីប្រហែលប្រមូលផ្តុំនៅក្នុងតំបន់នេះ ពីព្រោះភាគច្រើនបានឈរជើងនៅទីនេះជាច្រើនឆ្នាំមកហើយ ។ រួមសេចក្តីមក រឿងរ៉ាវជាច្រើនពាក់ព័ន្ធនឹងដីធ្លីគឺផ្សារភ្ជាប់ទៅនឹងសន្តិសុខ និងសន្តិភាពដែលបានកើតមានឡើងនៅក្នុងតំបន់ នៅក្រោយពេលនៃការផ្តាច់ខ្លួនរបស់កងកំលាំងខ្មែរក្រហមក្នុងឆ្នាំ១៩៩៧ ។

## ៥. ករណីសិក្សានៅភូមិផ្សារក់ និងភូមិតាអងក្នុងខេត្តរតនគិរី

ខេត្តរតនគិរីស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសឡាវ និងខាងកើតជាប់នឹងប្រទេសវៀតណាម ។ ខេត្តមានផ្ទៃដីសរុបប្រហែល ១,១៦លានហិកតា និងចែកចេញជា ៤តំបន់ កសិកម្ម-អេកូឡូស៊ីធំៗ ។ ប្រជាជនសរុបមានប្រហែល ៩៤.០០០នាក់ ក្នុងនេះប្រហែល ៧៥% ជាប្រជាជនដើមភាគតិចប្រាំបីក្រុមដែលរកចិញ្ចឹមជីវិតជាប្រពៃណីដោយធ្វើកសិកម្មផ្លាស់ទី និងបំពេញបន្ថែមដោយការបរបាញ់ នេសាទ និងប្រមូលអនុផលព្រៃឈើ ។ កសិកម្មផ្លាស់ទីមានវដ្តរយៈពេល ៦-៧ឆ្នាំ វិលចុះឡើងរវាងការដាំដុះលើដី និងការទុកដីអោយទំនេរ ។ ក្នុងពេលជាមួយគ្នានេះ ប្រជាជនក៏ធ្វើប្រមាញ់ និងប្រមូលអនុផលព្រៃឈើ ។ ជានិច្ចជាកាល ខេត្តរតនគិរី គឺជាគោលដៅរបស់ជនចំណាកស្រុកដែលស្វែងរកដីធ្វើកសិកម្ម និងឱកាសប្រកបរបររកស៊ីផ្សេងទៀត ។ ថ្មីៗនេះដោយសារសេរីភាវូបនីយកម្មនៃសេដ្ឋកិច្ច និងការបើកឱកាសក្នុងសង្គម

ខេត្តរតនគីរីមានការលូតលាស់ច្រើនណាស់ ដែលបានបង្កើនតំរូវការដីធ្លី ។ កំណើនតំរូវការដីធ្លីភាគច្រើន គឺផុសចេញពីកសិករចំណាកស្រុកមកពីខេត្តផ្សេងៗ ប្រជាជនមកពីទីក្រុង និងកំណើនធម្មជាតិនៃប្រជាជនមូលដ្ឋាន ។ ជនចំណាកស្រុក និងអ្នកវិនិយោគទុនមកពីទីរួមខេត្តបានលុង និងទីផ្សារដទៃទៀត គេស្វែងរកដីនៅតាមបណ្តោយផ្លូវធំៗ ដែលរហូតមកដល់ពេលថ្មីៗនេះប្រជាជនមូលដ្ឋានជាអ្នកគ្រប់គ្រង ។ លើសពីនេះទៀត តំរូវការដីធ្លីកើតចេញពីសកម្មភាពទិញដីទុកលក់យកចំណេញ សម្បទានព្រៃឈើ កសិកម្ម និងសំណង់វារីអគ្គិសនី ។ ដូច្នេះហើយ សន្ទុះទីផ្សារដីធ្លីនៅខេត្តរតនគីរី កើតចេញពីកំណើននៃការប្រកួតប្រជែងរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចធ្វើឡើងដោយអ្នកមកពីខាងក្រៅ និងតំរូវការដីធ្លីរបស់ប្រជាជនដើម ។ ការវិវត្តន៍នៃទីផ្សារដីធ្លី វាឆ្លុះបញ្ចាំងពីភាពខុសគ្នាជាមូលដ្ឋាននៃទស្សនះស្តីពីតួនាទី និងការប្រើប្រាស់ដីធ្លីសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចក្នុងខេត្ត ហើយវាជះឥទ្ធិពលច្រើនណាស់ទៅលើទស្សនះរបស់ក្រុមមនុស្សផ្សេងៗស្តីពីការប្រើប្រាស់ដីសិទ្ធិកាន់កាប់ និងគ្រប់គ្រងដី និងវិធីដោះស្រាយទំនាស់ដីធ្លី ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (DLMUPCC) បានរាយការណ៏ថា បានចេញ ៤៤ប័ណ្ណប្លង់ដីក្នុងឆ្នាំ២០០០ ។ ពួកគេបានសង្កេតឃើញថា ហេតុផលមួយនៃការចេញប័ណ្ណបានតិចតួច (ធៀបនឹងចំនួនជាក់ស្តែងនៃការលក់ដូរដីធ្លី) គឺសោហ៊ុយចំណាយយ៉ាងខ្ពស់នៃតំរូវការបញ្ជូនពាក្យសុំប័ណ្ណប្លង់ដីទៅភ្នំពេញ ដើម្បីសុំការយល់ព្រម ។ មន្ទីរពន្ធដាខេត្តរាយការណ៏ថា មន្ទីរប្រមូលពន្ធពីការលក់ដូរដីធ្លីបានតែ ៦,៩លានរៀលប៉ុណ្ណោះតាំងពីឆ្នាំ១៩៩៧ មក ។ ដោយសារមានការលក់ដូរដីធ្លីយ៉ាងច្រើននៅក្នុងខេត្ត តួលេខបានបង្ហាញនូវការខាតបង់ចំណូលរដ្ឋយ៉ាងច្រើន ។ គណៈកម្មការដោះស្រាយបាតុភាពដីធ្លី (LDSC) ត្រូវបានបង្កើតឡើងនាឆ្នាំ១៩៩៨ និងបានចាប់ផ្តើមធ្វើការងារនៅឆ្នាំ២០០០ ។ ក្នុងឆ្នាំទី១ LDSC បានទទួលប្រហែល ២០ពាក្យបណ្តឹងថ្មី ជាបន្ថែមលើ ១៣ករណី "ចាស់" ។ ក្នុងឆ្នាំ២០០០នេះដែរ តុលាការខេត្តបានកាត់ក្តីលើប្រហែល ៥០ពាក្យបណ្តឹង ក្នុងនេះមួយចំនួនជាវិវាទដីធ្លី ។ ករណីមួយនាពេលថ្មីៗ ពាក់ព័ន្ធនឹងប្រជាជន ២៤៧គ្រួសាររស់នៅក្នុង ៣ភូមិ នៅស្រុកបរកែវ ដែលបានលក់ដីទៅអោយភ្នាក់ងារម្នាក់ធ្វើការក្នុងនាមអ្នកភ្នំពេញម្នាក់ទៀត ។ ក្នុងករណីនេះ LDSC មិនអាចជួយសំរុះសំរួលតាមរយៈការចរចាទេ ហើយក៏បញ្ជូនបន្តទៅទីក្រុងភ្នំពេញដែលមិនអាចដោះស្រាយបានដូចគ្នា ។ បន្ទាប់មក ករណីវិវាទត្រូវបានបញ្ជូនទៅអោយតុលាការខេត្តវិញដែលបានកាត់ក្តីអោយអ្នកទិញឈ្នះ ទោះបីមានសេចក្តីបញ្ជាក់ជាច្រើនថាមានអំពើបោកប្រាសនៅក្នុងប្រតិបត្តិទិញ-លក់ដីនេះក៏ដោយ ។

*ភូមិផ្សាក់*

ភូមិផ្សាក់ (ក្នុងឃុំតាអង) ស្ថិតនៅតាមបណ្តោយផ្លូវជាតិចំងាយប្រហែល ១០គីឡូម៉ែត្រពីខាងកើតទីរួមស្រុកកូនមុំដែលស្ថិតនៅតាមណ្តោយផ្លូវជាតិទៅកាន់ទីរួមខេត្តបានលុងដូចគ្នា ។ ប្រជាជនក្នុងភូមិជាជនជាតិភាគតិចគ្រឹង ។ ប្រជាជនទាំងអស់មាន ៧៨គ្រួសារ (៤០០នាក់) ក្នុងនេះមានជនមាតុភូមិនិវត្តន៍ ៣គ្រួសារមកពីអន្លង់វែង ។

ដូចនៅតំបន់ផ្សេងៗទៀតនៃខេត្តរតនគីរីដែរ របៀបធ្វើកសិកម្មចំបងក្នុងភូមិគឺ កសិកម្មផ្លាស់ទី (swidden farming) ។ ក្នុងនេះគ្រួសារគឺជាអង្គភាពផលិតជាមូលដ្ឋាននៅក្នុងសង្គម ។ លក្ខខណ្ឌខាងអេកូឡូស៊ី (ជីជាតិដី) និងកំលាំងពលកម្មក្នុងគ្រួសារគឺជាកត្តាចំបងដែលកំណត់បរិមាណផលិតកម្មតាមគ្រួសារ ។ គ្រួសារនីមួយៗ ជាទូទៅធ្វើស្រែចំការ និងដាំដំណាំចំការដែលយកផលបានច្រើនឆ្នាំមួយចំនួន ។ ដើម្បីបំពេញកង្វះខាតស្បៀងតាមរដូវកាល គ្រួសារប្រជាជនក៏បានបេះប្រមូលផលពីដីធ្លីនៅជុំវិញភូមិថែមទៀត ។ មធ្យោបាយនេះ បានជួយអោយពួកគេអាចរកប្រាក់កាសបន្ថែមខ្លះៗ សំរាប់ដោះស្រាយតំរូវការផ្សេងៗក្នុងគ្រួសារ ។ ក្នុងការធ្វើកសិកម្មផ្លាស់ទី កសិករប្តូរកន្លែងទៅធ្វើនៅតំបន់ថ្មីមួយទៀត នៅពេលជីជាតិដីថយចុះ ។ វដ្តនៃការទុកដីអោយនៅទំនេរ ជាទូទៅមានរយៈពេល ៦-៧ឆ្នាំសំរាប់កន្លែងថ្មី ។ សិទ្ធិប្រើប្រាស់ដីធ្លីរបស់គ្រួសារនីមួយៗ ត្រូវបានសមាជិកឯទៀតក្នុងសហគមន៍ទទួលស្គាល់ ដោយអនុលោមទៅតាមទំនៀមទំលាប់ប្រពៃណី ។ ក្នុងនេះចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍

បង្ខំឱ្យភាគីទំនាស់នានា គោរពសិទ្ធិប្រើប្រាស់ដីធ្លី ។ ក្នុងពេលថ្មីៗ ប្រធានភូមិក្នុងនាមគាត់ជាតំណាងរដ្ឋាភិបាល បានទទួលសិទ្ធិអំណាចក្នុងការដាក់បង្ខំអោយអនុវត្តច្បាប់ ។ ប្រធានភូមិមានសិទ្ធិអំណាចផងដែរក្នុងការចាត់ចែងគ្រប់គ្រងការប្រើប្រាស់សម្បត្តិ រួមនៅក្នុងតំបន់ត្រួតត្រារបស់ភូមិ ។ ប្រធានភូមិប្រាប់ថា ភូមិគាត់គ្រប់គ្រងដីប្រហែលមួយពាន់ហិកតា ហើយគ្រួសារនីមួយៗ ទទួលបានចំណែកដីប្រហែល ៥ហិកតា ។

តាមមើលទៅមានអ្នកភូមិច្រើនគ្នា (ឬអាចទាំងអស់គ្នា) បានលក់ដីទៅអោយអ្នកមកពីក្រៅសហគមន៍ ដែលភាគច្រើនជាប្រជាជនមកពីទីរួមខេត្តបាត់ដំបង ឬកសិករចំណាកស្រុកមកពីខេត្តផ្សេងៗ ។ សព្វថ្ងៃ ជាក់ស្តែងអ្នកមកពីខាងក្រៅភូមិកាន់កាប់គ្រប់គ្រងដីទាំងអស់នៅតាមបណ្តោយផ្លូវលេខ១៩ ដែលកាលពីមុនកុលសម្ព័ន្ធគ្រឹង នៅភូមិផ្សាក់បានអះអាងកម្មសិទ្ធិ ។ ការលក់ដូរដីធ្លីជាច្រើនត្រូវបានសំរបសំរួលដោយកិច្ចសន្យាជាលាយលក្ខណ៍អក្សរនៅលើក្រដាសធម្មតាមួយសន្លឹក រវាងអ្នកលក់ និងអ្នកទិញ ។ ការលក់ដូរភាគច្រើនធ្វើឡើងដោយការស្ម័គ្រចិត្ត ប៉ុន្តែមានច្រើនករណីដែរដែលគេរាយការណ៍ថា មានពាក់ព័ន្ធនឹងការរំលោភយកដីធ្លី និង/ឬការលក់ និងផ្ទេរសិទ្ធិកាន់កាប់ធ្វើឡើងដោយសារការបារម្ភថា ដីនៅតាមបណ្តោយផ្លូវនឹងត្រូវរដ្ឋយកវិញ បើសិនមិនលក់អោយគេទេ ។ ប្រជាជនក៏ត្រូវបានជំរុញអោយលក់ដីធ្លីផងដែរ ពីព្រោះត្រូវការប្រាក់សំរាប់ប្រើការផ្សេងៗដូចជា ថែទាំសុខភាព សាងសង់ផ្ទះ និងទិញសំភារៈប្រើប្រាស់ផ្សេងៗ (ម៉ូតូ សំលៀកបំពាក់...) ។ គ្រួសារខ្លះបានប្រើប្រាស់ប្រាក់លក់ដីបានមួយចំណែក សំរាប់វិនិយោគលើការធ្វើស្រែមានភ្លឺទប់ទឹកវិញ (លើដីនៅសល់របស់ខ្លួន) តាមរយៈការទិញ គោក្របី និងរទេះជាដើម ។

ប្រធានភូមិ និងមេឃុំបានបញ្ជាក់លើកិច្ចសន្យាលក់ដីធ្លីជាច្រើនដែលខុសប្លែកយ៉ាងឆ្ងាយពីនីតិវិធីជាផ្លូវការ ។ ជនចំណាកស្រុកមកពីខេត្តកំពង់ចាមម្នាក់បានរាយការណ៍ថា កាលពីឆ្នាំ២០០០ គាត់បានចំណាយមាស ១៥ជី (ប្រហែល ៥១០ដុល្លារអាមេរិក) ដើម្បីទិញដី ៣ប្លង់ និងបានចំណាយប្រាក់ក្រៅផ្លូវការមួយចំនួនទៅឱ្យប្រធានភូមិ មេឃុំ និងមន្ត្រីធំម្នាក់នៅថ្នាក់ស្រុក ។ ទាំង LDSC និងតុលាការខេត្ត បានបញ្ជាក់ថា កិច្ចសន្យាទាំងនេះជាភស្តុតាង មានតំលៃគ្រប់គ្រាន់ ពីព្រោះប្រធានភូមិ និងមេឃុំគឺជារដ្ឋអំណាច ។ ជាលទ្ធផល កិច្ចសន្យាបែបនេះត្រូវយកជាបានការក្នុងករណីមានទំនាស់ដីធ្លី ទោះបីមិនទាន់មានលក្ខណៈវិនិច្ឆ័យ អ្វីស្តីពីសុពលភាពនៃកិច្ចសន្យាពិតប្រាកដក៏ដោយ ។ ថ្វីបើមានការលក់ដូរដីធ្លីយ៉ាងច្រើននៅក្នុងសហគមន៍ ប៉ុន្តែប្រធានភូមិបាន រាយការណ៍ថា ពុំមានការចេញប័ណ្ណប្លង់ដីឱ្យទេនៅក្នុងភូមិគាត់ ។ មេឃុំក៏បានបញ្ជាក់ដែរថា មិនដែលមានចេញប័ណ្ណប្លង់ដីឱ្យសោះនៅក្នុងឃុំទាំងមូល ។

ក្រោយពីបានលក់ដីធ្លីហើយ អ្នកភូមិបានប្តូរកន្លែងទៅដាំដុះនៅឆ្ងាយៗពីផ្លូវ ។ គ្រួសារភាគច្រើនបានបន្តធ្វើកសិកម្មផ្លាស់ទីនៅឯតំបន់អូរចេង ។ ប៉ុន្តែ គ្រួសារមួយចំនួនបានអភិវឌ្ឍដីស្រែវស្សា (មានភ្លឺទប់ទឹក) នៅក្នុងតំបន់មួយផ្សេងទៀតឈ្មោះ អូរខ្មៅ ប្រហែលប្រើទុនដែលបានមកពីការលក់ដី ។ ជនមាតុភូមិនិវត្តន៍ពីរគ្រួសារ (ក្នុងចំណោមបីគ្រួសារ) បានរាយការណ៍ថា ដីធ្លីក្នុងសហគមន៍ ហាក់ដូចជាកាន់តែក្រឡើងៗ ហើយសព្វថ្ងៃនេះ ពួកខ្លួនកំពុងដាំដុះលើដីធ្លីរបស់បងប្អូន ពីព្រោះប្រធានភូមិមិន ទាន់អនុញ្ញាតអោយរានដីថ្មីទេ ។ ប៉ុន្តែគ្រួសារទាំងនេះទើបនឹងវិលត្រឡប់មកវិញទេ ដូច្នេះអាចខ្វះកំលាំងពលកម្មផងដែរសំរាប់ ការរានដីថ្មី ។

### *ភូមិតាអង ១*

នៅភូមិតាអង ១ (៤៨គ្រួសារ) ដែលនៅជិតគ្នា, អ្នកដឹកនាំភូមិបានបង្ហាញពីសភាពការណ៍ខុសគ្នាមួយទៀតនៃការលក់ដូរដីធ្លី និងផលប៉ះពាល់របស់វា ។ ពួកគេរាយការណ៍ថា ក្នុងឆ្នាំ១៩៩៧, ១៧គ្រួសារបានបាត់បង់ដីធ្លីនៅតាមបណ្តោយផ្លូវ ដោយសារអ្នកក្រៅបានទាមទារយកដោយសំអាងថា ដីធ្លីត្រូវបានទុកចោលមិនប្រើប្រាស់នៅពេលនោះ ។ ក្នុងពីរ-បីករណីពីដំបូងអ្នក

ក្រោបានមកសុំការអនុញ្ញាតពីអ្នកភូមិដើម្បីប្រើប្រាស់ដីធ្លីដាំដើមស្វាយចន្ទី ។ ប៉ុន្តែ នៅពេលពួកគេបានគ្រប់គ្រងដីនោះហើយ ក៏យកធ្វើជាសម្បត្តិផ្ទាល់ខ្លួនតែម្តង ។ ក្នុង ៣ករណីទៀត ប្រជាជនបានស្ម័គ្រចិត្តលក់ដីនៅតាមបណ្តោយផ្លូវ ។ អ្នកភូមិម្នាក់បាននិយាយថា ពីមុនគ្រួសារគាត់មានជីវភាពគ្រប់គ្រាន់ ប៉ុន្តែក្រោយពីការរំលោភយកដី គ្រួសារគាត់ជួបការលំបាក ពីព្រោះត្រូវទៅដាំដុះនៅកន្លែងឆ្ងាយៗដែលមិនសូវបានផល ។ ១២គ្រួសារទៀតបានលក់ដីអស់ជាច្រើនឆ្នាំមកហើយ រីឯ ៣គ្រួសារផ្សេងទៀតអាចរក្សាដីធ្លីរបស់ខ្លួននៅតាមបណ្តោយផ្លូវបាន ពីព្រោះបានដាំដើមស្វាយចន្ទីពីមុនមក ។

ក្នុងឆ្នាំ១៩៩៩ គ្រួសារជាច្រើនក្នុងភូមិនេះបានទាមទារយកដីនៅឡាបាំង ១ ដោយអះអាងថាពួកខ្លួនបានធ្វើចំការលើដីនោះក្នុងជំនាន់ប៉ុលពត ប៉ុន្តែបានទុកដីចោលចាប់ពីឆ្នាំ១៩៨១ មក ដោយសារខ្វះខាតសត្វអូសទាញ ហើយក៏បានត្រឡប់មករស់នៅភូមិកំណើតវិញ ។ ពួកគេបានបញ្ជូនពាក្យបណ្តឹងទៅអាជ្ញាធរស្រុក រីឯប្រជាជនភូមិឡាបាំង១ បានប្តឹងទៅខេត្ត ។ នៅចុងបញ្ចប់អាជ្ញាធរខេត្តបានកំណត់ថា ការទាមទាររបស់ប្រជាជនភូមិតាអង១ មិនត្រឹមត្រូវទេ ។ ក្នុងអំឡុងពេលនោះដែរ ប្រជាជនខ្លះនៅភូមិឡាបាំង១ បានចរចាលក់ដីអោយគ្រួសារមួយចំនួននៅភូមិតាអង១ ប៉ុន្តែគ្រួសារទាំងនោះមិនព្រមទិញដីទេ ដោយសំអាងថាដីទាំងនោះជារបស់ពួកគេស្រាប់ហើយ ។ ផ្អែកលើភស្តុតាងដែលមានស្រាប់ គេមិនអាចផ្តល់យោបល់ពីភាពយុត្តិធម៌ ឬក៏ភាពត្រឹមត្រូវតាមច្បាប់នៃសេចក្តីសំរេចនេះទេ ។ ប៉ុន្តែចំណុចសំខាន់ដែលគួរកត់សំគាល់ គឺការបាត់បង់ដីនៅតាមបណ្តោយផ្លូវហាក់ដូចបានជះឥទ្ធិពលអាក្រក់ធ្វើអោយប្រជាជនទាមទារដីពីគ្នាទៅវិញទៅមក ហើយរដ្ឋអំណាចប្រហែលជានឹងត្រូវគេសំណូមពរអោយជួយធ្វើអន្តរាគមន៍ជាភាគីទីបី ដើម្បីដាក់បង្ខំការអនុវត្តច្បាប់ក្នុងករណីមានទំនាស់រវាង ២ភូមិបែបនេះ ។ តួនាទីនេះវាសមស្របល្អហើយ ដោយមិនបាច់និយាយដល់ចំណុចពិសេសៗនៃករណីជាក់ស្តែងផង ។ នាពេលអនាគត រដ្ឋាភិបាលប្រហែលជានឹងត្រូវចូលជួយសំរបសំរួលករណីទំនាស់បែបនេះកាន់តែច្រើនថែមទៀត ពីព្រោះប្រជាជនសព្វថ្ងៃមានអត្រាកំណើនខ្ពស់ ដែលធ្វើអោយតំរូវការដីធ្លីដាំដុះកើនឡើងដូចគ្នា ។

*ករណីផ្តល់កម្មសិទ្ធិដីសហគមន៍*

សេចក្តីព្រៀងច្បាប់ភូមិបាលថ្មី មានមាត្រាចែងពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីរួម/សហគមន៍ ដែលគួរលើកមករើកញែកខ្លះជាពិសេសចំណុចពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី និងសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាជនដើម ។ គំរូមានជោគជ័យល្អមួយនៃវិធីសាស្ត្រនេះ ត្រូវបានដាក់អនុវត្តសាកល្បងដោយអង្គការក្រៅរដ្ឋាភិបាលអនុផលព្រៃឈើ (NGO Non-Timber Forest Produce) ។ គំរូនេះបង្ហាញថា ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍អាចធ្វើបាន និងជាវិធីដ៏សមស្របមួយសំរាប់ជំនួសការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាលក្ខណៈបុគ្គល ពីព្រោះវាជួយការពារលទ្ធភាពប្រើប្រាស់ដីរួមរបស់អ្នកភូមិទាំងអស់ និងជួយការពារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។ ប៉ុន្តែដំណើរការនេះប្រហែលត្រូវការចំណាយពេល និងកំលាំងយ៉ាងច្រើន និងត្រូវមានការជួយណែនាំច្រើនណាស់ពីស្ថាប័នខាងក្រៅមួយដែលធ្វើការងារ ដោយរួមសហការគ្នាជាមួយអាជ្ញាធរជាប់ពាក់ព័ន្ធ ។ ដូច្នេះហើយ ដំណើរការនេះពិបាកយកទៅអនុវត្តក្នុងកម្មវិធីទ្រង់ទ្រាយធំណាស់ លើកលែងតែអាជ្ញាធរ និងសហគមន៍មានធនធានច្រើនថែមទៀត និងមានកិច្ចសហការគ្នាល្អរវាងវិស័យឯកជន និងវិស័យសាធារណៈ (ដូចជាអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល) ។

## ៦. ករណីសិក្សានៅតំបន់អនាធិបតេយ្យក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

*សាវតារ*

ប្រជាជនដែលរស់នៅក្នុងតំបន់អនាធិបតេយ្យក្នុងក្រុងភ្នំពេញ បានផុសឡើងចាប់តាំងពីចុងទសវត្សរ៍១៩៨០ ។ ពីដំបូងគឺតំបន់មាត់ទន្លេ ដែលមានជនចំណាកស្រុកមកពីខេត្តផ្សេងៗ និងមកពីប្រទេសជិតខាងមករស់នៅ ។ បន្ទាប់មក ប្រជាជនប្រភេទនេះបានកើនឡើងជាលំដាប់ ។ ក្នុងពេលបច្ចុប្បន្ននេះ អាជ្ញាធរបានទទួលស្គាល់ថាជាតំបន់អនាធិបតេយ្យមានយ៉ាងតិច ២០កន្លែងក្នុងទូទាំងក្រុងភ្នំពេញ ។ ករណីសិក្សានេះ ធ្វើលើការតំបន់អនាធិបតេយ្យមួយកន្លែងនៅក្នុងខ័ណ្ឌចំការមន នៅជិត

មាត់ទន្លេបាសាក់ ។

តំបន់តាំងទីលំនៅបណ្តោះអាសន្ននេះចែកចេញជាពីរភូមិ: ភូមិ១៤ និងភូមិ១៥ (ថ្វីបើភូមិទាំងពីរស្ថិតក្នុងតំបន់ទីក្រុងក៏ដោយ) ។ ភូមិទាំងពីរស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន និងជាតំបន់អនាធិបតេយ្យធំជាងគេបំផុត ក្នុងចំណោមតំបន់អនាធិបតេយ្យទាំង ២០កន្លែងក្នុងក្រុងភ្នំពេញ ។ ភូមិ១៤ មានប្រជាជន ២.០២៤គ្រួសារ (បូកទាំងជនជាតិភាគតិចប្រហែល ៤០០គ្រួសារ) ត្រូវជា ៩.៨៥៣នាក់ តាមការកត់ត្រាជាផ្លូវការក្នុងឆ្នាំ២០០០ ។ ភូមិ១៥ មានប្រជាជនសរុប ១.៤៥៥គ្រួសារ (៦.៦៤០នាក់) គឺបូកទាំងជនជាតិភាគតិច ៩៥គ្រួសារ ត្រូវជា ៤៥៩នាក់ផង ។ ភូមិទាំងពីរទទួលប្រជាជនមួយក្រុមទៀត ដែលជាជនចំណាកស្រុកបណ្តោះអាសន្នពីជនបទមកទីក្រុង និងដែលមកជួលផ្ទះ ឬបន្ទប់ស្នាក់នៅៗក្នុងភូមិទាំងពីរ ។ មនុស្សក្នុងក្រុមនេះ មានចំនួនប្រហែលជាពាក់កណ្តាលនៃចំនួនប្រជាជនសរុបក្នុងតំបន់អនាធិបតេយ្យទន្លេបាសាក់ ប៉ុន្តែរហូតមកទល់សព្វថ្ងៃ មិនទាន់បានធ្វើស្ថិតិជាក់លាក់ទេ ។

នៅពាក់កណ្តាលទសវត្សរ៍១៩៨០ មានប្រជាជនប្រហែល ៧៤គ្រួសារប្រកបរបរដាំពោត និងបន្លែនៅតាមមាត់ទន្លេ ។ កន្លែងនោះគឺជាបរិវេណភូមិ១៤ បច្ចុប្បន្ន ។ ក្រោយមកប្រជាជនកើនដល់ប្រហែល ៣០០នាក់ ដោយសារកំណើនធម្មជាតិ និងប្រជាជនចំណូលថ្មីមកពីខេត្តផ្សេងៗ ។ នៅដើមទសវត្សរ៍១៩៩០ យោធិនវិសាយ និងប៉ូលីសមូលដ្ឋានបានចាប់យកដីនៅទីនេះ ហើយបានបែងចែកជាដីឡូត៍តូចៗ រួចលក់ទៅឱ្យប្រជាជនក្នុងតំលៃ ៧០-៨០ដុល្លារអាមេរិកក្នុងមួយឡូត៍ ។ ក្នុងសម័យអ៊ុនតាក់ ជនចំណាកស្រុកមកពីខេត្តផ្សេងៗ ជនជាតិភាគតិចមកពីកន្លែងផ្សេងទៀត និងជនមានសមាសភាពមិនល្អ បានចូលមកសង់ផ្ទះខុសច្បាប់នៅទីនេះ ។ លំហូរចូលនៃជនចំណាកស្រុក បានកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៥/៩៦ ។ ភាពក្រីក្រ ភាពគ្មានដីធ្លី អសន្តិសុខស្បៀង និងឱកាសរកចំណូលមានតិចតួចនៅឯភូមិកំណើត បានបង្កឱ្យមានចំណាកស្រុកចូលក្រុង ។ ក្រៅពីនេះ នៅមានប្រជាជនក្រីក្រមួយចំនួនតូចដែលបានលក់ផ្ទះសំបែងនៅឯកន្លែងផ្សេងទៀតនៃទីក្រុងភ្នំពេញ ហើយចូលមកស្នាក់នៅទីនេះ ។

***ជីវភាពរស់នៅ***

មុខរបរនៃអ្នកស្នាក់នៅក្នុងតំបន់ក្រីក្រនេះរួមមាន: ១. កម្មកររកចំណូលប្រចាំថ្ងៃ: កម្មករសំណង់ កាត់ដេរ អ្នកធាក់ស៊ីក្លូ... ២. អ្នកលក់ដូរ ៣. ស្ត្រីរកស៊ីផ្លូវភេទ និង ៤. មន្ត្រីរាជការ: មន្ត្រីស៊ីវិល ប៉ូលីស ទាហាន... ។ សមាជិកគ្រួសារស្ទើរតែទាំងអស់ធ្វើការរកចំណូល ហើយម្នាក់ៗអាចរកចំណូលបានពី ៣.០០០-៨.០០០រៀលក្នុងមួយថ្ងៃ លើកលែងតែមន្ត្រីរាជការ និងស្ត្រីរកស៊ីផ្លូវភេទ ដែលមានកំរិតប្រាក់ចំណូលប្រែប្រួលខុសគ្នាយ៉ាងខ្លាំង ។ គេជឿថា ប្រហែល ៤០% នៃគ្រួសារនៅទីនេះមានចំណូលបន្ថែមទៀតពីការជួលផ្ទះ (ផ្ទះ/បន្ទប់ទំហំ ៣ម x ៦ម ជួលបាន ២០.០០០-៣០.០០០រៀល/ខែ ឬបានច្រើនជាងនេះទៀត បើសិននៅជិតផ្លូវធំ និង/ឬមានសក្តានុពលខាងពាណិជ្ជកម្ម) ។

***ភាពជាម្ចាស់ និងការសាងសង់ផ្ទះ***

គ្រួសារស្ទើរតែទាំងអស់នៅក្នុងភូមិ រួមទាំងគ្រួសារជនជាតិវៀតណាមផង មានសៀវភៅស្នាក់នៅ ដែលអាជ្ញាធរខ័ណ្ឌចំការមនបានចេញអោយ ។ ប្រជាជនដឹងថា ពួកគេពុំមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើដីធ្លីដែលពួកគេកំពុងកាន់កាប់ទេ ។ ដីនេះជារបស់សាលាក្រុងភ្នំពេញ និងទុកសំរាប់ធ្វើជាសួនសាធារណៈក្នុងក្រុងភ្នំពេញ ។ ប៉ុន្តែ ប្រជាជនបានទទួលការអនុញ្ញាតអោយរស់នៅបណ្តោះអាសន្នក្នុងភូមិនេះតាំងពីឆ្នាំ១៩៩២-៩៣ ។ គេនិយាយថា គណបក្សនយោបាយនីមួយៗចង់បានសន្លឹកឆ្នោតច្រើន ដូច្នេះហើយក៏ធ្វើមិនដឹងមិនឮចំពោះការតាំងទីលំនៅមិនស្របច្បាប់ទាំងនេះ ។

ពីឆ្នាំ១៩៩៣-៩៤ មកដល់ដើមឆ្នាំ១៩៩៩ រដ្ឋអំណាចមូលដ្ឋានបានអនុញ្ញាតអោយសាងសង់ផ្ទះឈើ ។ តែបច្ចុប្បន្នការសង់ផ្ទះថ្មី (ឈើ ឬស៊ីម៉ង់) ឬសូម្បីការពង្រីកផ្ទះក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែការជួសជុលផ្ទះប៉ុណ្ណោះ ។ សព្វថ្ងៃឈើមានតំលៃខ្ពស់ណាស់ ដូច្នេះហើយប្រជាជនក៏ចាប់ផ្តើមសង់ផ្ទះពីស៊ីម៉ង់តិដោយស្ងាត់ៗ ។ អាជ្ញាធរដែនដីសារភាពថា

មិនដឹងធ្វើដូចម្តេចក្នុងរឿងនេះទេ ក្រៅពីរំលឹកម្ចាស់ផ្ទះទាំងនោះ ពីការឯកភាពគ្នាដែលមានចុះក្នុងកិច្ចសន្យានៅពេលសង់ផ្ទះពីដំបូង ។ ផ្ទះភាគច្រើនប្រក់សង្កសី និងមានជញ្ជាំងឈើ/ថែប ។ ផ្ទះនីមួយៗមានទំហំ ១៥ម៉ែត្រការ៉េ និងមានមនុស្សស្នាក់នៅជាមធ្យម ៥នាក់ ។

កាលពីឆ្នាំ២០០០ គ្រួសារនីមួយៗត្រូវសុំអនុញ្ញាតពីភូមិ និងសង្កាត់ទន្លេបាសាក់ ដើម្បីសាងសង់ផ្ទះ ។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលមានតំលៃ ១០.០០០-២០.០០០រៀល ត្រូវបានធ្វើឡើងរវាងអាជ្ញាធរមូលដ្ឋាន និងម្ចាស់ផ្ទះ ដោយមានចុះបញ្ជាក់ច្បាស់ថា អនុញ្ញាតអោយសង់តែផ្ទះឈើ ហើយម្ចាស់ផ្ទះពុំមានសិទ្ធិធ្វើជាម្ចាស់ លើដីធ្លីដែលខ្លួនបានសង់ផ្ទះពីលើនោះទេ ។

ដើម្បីជួសជុលផ្ទះ ម្ចាស់ផ្ទះគ្រាន់តែសុំការអនុញ្ញាតដោយផ្ទាល់មាត់ពីប្រធានភូមិ ។ តាមធម្មតាម្ចាស់ផ្ទះនីមួយៗស្ម័គ្រចិត្តជូនប្រាក់ ៥.០០០-៦.០០០រៀល និងបារីមួយកញ្ចប់ ទៅប្រធានភូមិដែលផ្តល់ការអនុញ្ញាត ។ តាមពិតទង្វើនេះបើកឱកាសអោយម្ចាស់ផ្ទះអាចធ្វើកំរាលស៊ីម៉ង់ត៍ និងជញ្ជាំងឥដ្ឋបាន ។

### *តំលៃដី និងការផ្ទេរកម្មសិទ្ធិ*

ទាហានបានចាប់យក និងចែកដីជាឡូត៍តូចៗ ហើយលក់ទៅអោយជនចំណាកស្រុកក្រីក្រមកពីខេត្តនានាក្នុងតំលៃ ៧០-៨០ដុល្លារអាមេរិក/ដីមួយឡូត៍ ។ អ្នកទិញដីពីដំបូងមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរដោយមានស្នាមមេដៃរវាងអ្នកទិញ និងអ្នកលក់ ។ ដីស្ទើរតែទាំងអស់បានផ្ទេរម្ចាស់ច្រើនលើកច្រើនសារមកហើយ ។ ក្នុងឆ្នាំ២០០០ ដីមួយឡូត៍មានផ្ទះឈើ/ថែប មានតំលៃពី ២០០-៣.៥០០ដុល្លារអាមេរិក ទៅតាមទំហំដី និងទីតាំងជិតផ្លូវធំ ឬសក្តានុពលពាណិជ្ជកម្ម ។

សៀវភៅស្នាក់នៅដែលខ័ណ្ឌចំការមនចេញឱ្យ ត្រូវបានគេប្រើប្រាស់សំរាប់ធ្វើការផ្ទេរសិទ្ធិជាម្ចាស់ផ្ទះពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ប្រធានភូមិប្តូរឈ្មោះម្ចាស់ផ្ទះចាស់ដាក់ឈ្មោះម្ចាស់ថ្មីវិញ ដោយមានការឯកភាពជាបន្តបន្ទាប់ពីប្រធានសង្កាត់ និងខ័ណ្ឌ ។ ជាទូទៅការលក់ផ្ទះមួយលើកៗត្រូវចំណាយអស់ ២០-២៥ដុល្លារអាមេរិកក្នុងការបង់ប្រាក់កំរៃក្រៅផ្លូវការ ។ ថ្វីបើប្រជាជនដឹងថា នឹងត្រូវដេញចេញក្នុងពេលឆាប់ៗក៏ដោយ ក៏ការលក់ដូរដីធ្លីនៅតែមានសកម្មភាព ។ ជាទូទៅ ការលក់ដូរដី-ផ្ទះកើតមានឡើងនៅពេលម្ចាស់ផ្ទះត្រូវបង្ខំចិត្តលះបង់វាដើម្បីសងបំណុលគេ ។

### *ការយកប្រជាជនចេញពីតំបន់អនាធិបតេយ្យ*

សាលាក្រុងភ្នំពេញ គ្រោងយកអ្នកស្នាក់នៅបណ្តោះអាសន្នចេញពីទីនេះទាំងអស់នៅឆ្នាំ២០០៣ ។ ក្នុងខែតុលា ឆ្នាំ១៩៩៩ ក្នុងជំហានទី១ នៃការកំណត់តំបន់ឡើងវិញ, ៣៤៤គ្រួសារ (២៩៤គ្រួសារក្នុងភូមិ១៤ និង ៥០គ្រួសារក្នុងភូមិ១៥) ត្រូវបានរុះរើអោយទៅតាំងទីលំនៅថ្មីនៅវាលវេញ ចំការដូងប្រេងរបស់ឧកញ៉ា ម៉ុង រិទ្ធី និងនៅភូមិទួលសំបូរ ជាយក្រុងភ្នំពេញ ។ បច្ចុប្បន្នមានភាពរយាលបន្តិចក្នុងការយកប្រជាជនអ្នកស្នាក់នៅបណ្តោះអាសន្នចេញពីភូមិ១៥ ពីព្រោះអាទិភាព គឺត្រូវរុះរើផ្លាស់លំនៅប្រជាជនក្នុងភូមិ១៤ សិន ។ គេគ្រោងថា ក្នុងជំហានទី២ ប្រជាជន ១៩៣គ្រួសារ និងក្នុងជំហានទី៣ ប្រជាជន ១៣៣គ្រួសារថែមទៀត នឹងត្រូវរុះរើចេញពីភូមិទៅតាំងទីលំនៅឡើងវិញនៅក្នុងឃុំព្រៃស ខ័ណ្ឌដង្កោ និងកន្លែងផ្សេងទៀត ។

ក្នុងតំបន់តាំងទីលំនៅថ្មី គ្រួសារនីមួយៗបានទទួលដីមួយឡូត៍ (ទំហំ ៨ម x ១៥ម) បង្គន់អនាម័យមួយ ធុងទឹកធំមួយ ស័ង្កសីមួយចំនួនតង់មួយ និងអង្ករមួយចំនួន ។ ពួកគេក៏ទទួលបានការជួយដឹកជញ្ជូនទៅកាន់កន្លែងរស់នៅថ្មីនោះដែរ ។

បន្ទាប់ពីបានទៅតាំងទីលំនៅ នៅក្នុងតំបន់ថ្មីទាំងនោះមក គ្រួសារជាច្រើនបានវិលមកវិញ ដោយជួលបន្ទប់ស្នាក់នៅក្នុងតំលៃ ២០.០០០-៣០.០០០រៀលក្នុងមួយខែ ។ គេរាយការណ៍ថា ជីវភាពរស់នៅគឺជាមូលហេតុចំបងនៃការវិលត្រលប់ ។ មានតែគ្រួសារមានបុរសជាមេគ្រួទេ ដែលបានវិលមករកស៊ីនៅទីនេះវិញ ។ គ្រួសារ/ជនចំណាកស្រុកដែលវិលមកវិញបានត្អូញត្អែរថា ការទៅរស់នៅកន្លែងថ្មីមិនបានជួយកែលំអជីវភាពរស់នៅទេ ហើយពួកគេកាន់តែងាយរងគ្រោះជាងមុនទៀត ជាពិសេសស្ត្រី និង

កុមារ ដោយសារកង្វះខាត ការងារ សន្តិសុខស្បៀង ការថែទាំសុខភាព និងសាលារៀន ។ គេបានជីកអណ្តូងអោយមួយចំនួននៅព្រៃស ប៉ុន្តែទឹកមិនអាចប្រើប្រាស់បានទេ ពីព្រោះមានជាតិជូរ និងមិនស្អាត ។ ដោយមូលហេតុនេះ សាលាក្រុងបានដឹកទឹកពីរស៊ីទែនធំៗ ទៅចែកអោយប្រជាជនជារៀងរាល់ថ្ងៃ ។ ជាការពិតណាស់ ស្ថានភាពបែបនេះមិនអាចធានាបានរហូតទេ ។

យុទ្ធនាការរបស់សាលាក្រុងមើលទៅហាក់ដូចជាការរើកចក ។ ប្រជាជនសឹងទាំងអស់ជាជនក្រីក្រ ។ អ្នករកចំនូលម្នាក់ពិបាករកចិញ្ចឹមសមាជិកម្នាក់ទៀតក្នុងគ្រួសារណាស់ ។ ដូច្នេះសមាជិកគ្រួសារម្នាក់ៗត្រូវមានការងារធ្វើ ដើម្បីអាចរស់បាន ។ ជាងនេះទៅទៀត អ្នកវិលត្រឡប់មកវិញបាននិយាយថា តំរូវការជួលបន្ទប់មួយសំរាប់ស្នាក់នៅ បានបង្កើនសោហ៊ុយចំណាយក្នុងការរស់នៅ ប៉ុន្តែចំណូលរបស់ពួកគេមិនបានកើនឡើងទេ ហើយក្នុងករណីខ្លះវាបានធ្លាក់ចុះទៀតផង ។

### *ទំនាស់ដីធ្លី និងយន្តការដោះស្រាយ*

រហូតមកដល់ពេលនេះ ទំនាស់រវាងគ្រួសារ និងគ្រួសារមិនចោទបញ្ហាច្រើនទេ ពីព្រោះប្រជាជនដឹងថា ពុំមានសិទ្ធិធ្វើម្ចាស់ដី ។ ប៉ុន្តែមានបញ្ហាធំៗបួនក្នុងតំបន់នេះ ។ ទីមួយ ការចោលកាកសំណល់សំរាមតាមគ្រួសារ ប៉ុន្តែបញ្ហានេះភាគច្រើនតែងត្រូវបានដោះស្រាយនៅនឹងមូលដ្ឋាន ។ ទីពីរ ការការពារអគ្គីភ័យ គឺជាក្តីកង្វល់មួយយ៉ាងសំខាន់ ពីព្រោះផ្ទះស្ទើរតែទាំងអស់ធ្វើពីឈើ ។ រហូតមកដល់ពេលនេះ គេមិនទាន់មានវិធានការការពារអគ្គីភ័យនៅឡើយ ក្រៅពីការក្រើនរំលឹកគ្នាទៅវិញទៅមកឱ្យប្រុងប្រយ័ត្នរឿងភ្លើងចង្ក្រាន និងគ្រឿងឆេះផ្សេងៗ ។ តាមពិត មានឧប្បត្តិហេតុអគ្គីភ័យតូចៗបានកើតឡើងជាញឹកញាប់ ។ ថ្មីៗនេះ មានអគ្គីភ័យធំៗបី ដែលបានបំផ្លាញផ្ទះយ៉ាងហោចណាស់ក៏ ១០ខ្នងដែរក្នុងមួយលើកៗ ។ ទីបី ការពិនិត្យរកជនសមាសភាពមិនល្អ ដែលព្យាយាមប្រើតំបន់នេះសំរាប់លាក់ខ្លួន ក្រោយពីបានប្រព្រឹត្តបទល្មើសនៅកន្លែងផ្សេង ។ អាជាធរមូលដ្ឋានបាននិយាយថា ពួកគេបានសហការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរសង្កាត់ និងនគរបាល ដើម្បីពិនិត្យរកសមាសភាពជាប់សង្ស័យទាំងនេះ ។ រូបថតរបស់អ្នកមកជួលផ្ទះស្នាក់នៅ ត្រូវបានគេរក្សាទុកតាំងពីឆ្នាំ១៩៩៩ មក ។ ជាលទ្ធផល គេអាចគ្រប់គ្រងបទល្មើសខាងព្រហ្មទណ្ឌផ្សេងៗបានកាន់តែប្រសើរឡើង ។ ទីបួន គឺបញ្ហាលើកទឹកចិត្តអោយគ្រួសារនានារុះរើចេញពីតំបន់ ។ បច្ចុប្បន្នប្រជាជនក្នុងភូមិ១៥ មានអារម្មណ៏ធូរស្រាលបន្តិចវិញ ពីព្រោះគោលដៅបន្ទាន់របស់អាជ្ញាធរគឺ ធ្វើការរុះរើតាំងទីលំនៅថ្មីអោយប្រជាជននៅភូមិ១៤ ជាមុនសិន ដែលធ្វើឱ្យអ្នកស្នាក់នៅបណ្តោះអាសន្នក្នុងភូមិ ១៤ មានការបារម្ភកាន់តែច្រើនឡើង ។

ទំនាស់សឹងតែទាំងអស់ លើកលែងតែករណីព្រហ្មទណ្ឌនៅក្នុងភូមិចេញ ត្រូវបានដោះស្រាយនៅនឹងមូលដ្ឋាន ។ ដោយប្រជាជនដឹងថា ពួកខ្លួនត្រូវបានចាត់ទុកជា "អ្នកស្នាក់នៅបណ្តោះអាសន្នស្របច្បាប់" និងពុំអាចទាមទារកម្មសិទ្ធិដីនៅទីនេះបានដូច្នេះពុំឃើញមានទំនាស់ដីធ្លីអ្វីធ្ងន់ធ្ងរទេ ។ សង្កាត់ទន្លេបាសាក់បានជួយដោះស្រាយវិវាទមួយចំនួន ហើយរហូតមកដល់ពេលនេះពុំមានទំនាស់ណាមួយឡើងដល់តុលាការទេ ។ បច្ចុប្បន្ន គេឃើញមានតែការទាមទារសំណងប៉ះប៉ូវរបស់សហគមន៍ពីសាលាក្រុងភ្នំពេញ ។

### *ទស្សនះរបស់ប្រជាជនចំពោះការតាំងទីលំនៅថ្មី*

គ្មានគ្រួសារណាហ៊ានជំទាស់នឹងផែនការរបស់រដ្ឋាភិបាលទេ ប៉ុន្តែ ពួកគេទាមទារសំណងប៉ះប៉ូវពីរដ្ឋាភិបាលអោយបានសមរម្យ ។ ពួកគេចង់ទៅរស់នៅក្នុងតំបន់ជិតផ្លូវ រ៉េង ស្រេង ឬក៏កន្លែងណាមួយដែលមិនឆ្ងាយពេកពីរាជធានីភ្នំពេញ ។ ទីតាំងនៅជិតកន្លែងធ្វើការងារ គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់មួយសំរាប់ការតាំងទីលំនៅថ្មី ។ កត្តាសេដ្ឋកិច្ច និងអសន្តិសុខស្បៀង ក៏បានជំរុញអោយពួកគេចាកចេញពីភូមិកំណើតមក ។ ពួកគេមិនចង់ត្រឡប់ទៅវិញទេ ពីព្រោះគេមិនឃើញមានច្រកណាមួយអាចប្រកបរបរចិញ្ចឹមជីវិតបាន ។ ប្រជាជនបានបង្ហាញអោយដឹងថែមទៀតថា ការតាំងទីលំនៅថ្មីទៅតំបន់វាលរេញ/ចំការឧកញ៉ាម៉ុង រិទ្ធី មិនអាចធានាដល់ជីវភាពរស់នៅបានទេ ហើយតាមមតិរបស់អ្នកខ្លះនិយាយថា ជីវភាពរស់នៅរបស់ស្ត្រី និងកុមារ បានធ្លាក់ចុះថែមទៀតផង ។

## ៧. របាយការណ៍សិក្ខាសាលាអ្នកពាក់ព័ន្ធ: ការតាំងទីលំនៅក្នុងទីក្រុង[៧]

### *សេចក្តីផ្តើម*

ក្រុងភ្នំពេញមានផ្ទៃដី ៣៧៥គីឡូម៉ែត្រការ៉េ និងចែកចេញជា ៧ខ័ណ្ឌរដ្ឋបាល ត្រូវជា ៧៦សង្កាត់ ។ មាន ៤សង្កាត់ដែលតំណាងអោយមជ្ឈមណ្ឌលកណ្តាលទីក្រុង និងដែលមានផ្ទៃដីសរុប ២៨គីឡូម៉ែត្រការ៉េ ។ ក្រុងភ្នំពេញ មានប្រជាជនសរុប ១៦៥.១៩១គ្រួសារ (ប្រហែលមួយលាននាក់) ដែលរស់នៅជាអចិន្ត្រៃយ៍ ក្នុងនេះមិនបានរាប់បញ្ចូលអ្នកកាន់កាប់ដីខុសច្បាប់ទេ (អ្នករស់នៅតាមតំបន់/សំណង់អនាធិបតេយ្យ) ។

មានតែ ២៥% នៃម្ចាស់ផ្ទះ/ដីប៉ុណ្ណោះ ដែលមានប័ណ្ណសំគាល់សិទ្ធិជាផ្លូវការ ។ ការចុះបញ្ជីដីធ្លី និងផ្ទះសំបែងត្រូវបានកំណត់ថា មានសារៈសំខាន់ចំពោះកម្មសិទ្ធិឯកជន ក៏ដូចជាកម្មសិទ្ធិរដ្ឋ ពីព្រោះវាជួយដល់ការកសាងផែនការប្រើប្រាស់ដីធ្លី ជួយដោះស្រាយទំនាស់ដីធ្លី និងជួយកែលំអការគ្រប់គ្រងដីសាធារណៈ ។ ការចុះបញ្ជីដីធ្លី គឺជាឧបករណ៍ដ៏សំខាន់ សំរាប់ការកែលំអអភិបាលកិច្ច ដើម្បីសំរេចបាននូវការអភិវឌ្ឍន៍មានចីរភាពខាងសង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថាន ។

សិក្ខាសាលាបានពិភាក្សាលើ ៤ប្រធានបទធំៗដូចតទៅ: ការកំណត់តំបន់ និងការប្រើប្រាស់ដីធ្លីនៅក្នុងទីក្រុង, ការហូរចូលនៃជនចំណាកស្រុក និងកំណើនតំបន់/សំណង់អនាធិបតេយ្យនៅក្នុងក្រុង, ការពង្រីកទីក្រុង, និងសមត្ថភាពមន្ត្រីដែលមានស្រាប់ដើម្បីគ្រប់គ្រងដំណើរការចុះបញ្ជីដីធ្លី និងទិដ្ឋភាពផ្សេងទៀតនៃការអភិវឌ្ឍន៍ទីក្រុង ។

### *ការកំណត់តំបន់*

ផែនការស្តារទីក្រុងភ្នំពេញ ត្រូវបានកសាងឡើងជាលើកទី១ នៅពាក់កណ្តាលទសវត្សរ៍១៩៨០ ។ នេះជាការងារដ៏ធំធេងមួយ ពីព្រោះឯកសារមានតំលៃទាំងអស់ត្រូវបានបំផ្លាញចោលនៅក្នុងជំនាន់ប៉ុលពត ។ ក្រោយពីការជំលៀសប្រជាជនចេញពីក្រុងក្នុងអំលុងចុងទសវត្សរ៍១៩៧០ ប្រជាជនត្រូវបានលើកទឹកចិត្តឱ្យចូលមករស់នៅក្នុងក្រុងវិញចាប់ពីឆ្នាំ១៩៧៩ ដល់ដើមទសវត្សរ៍១៩៨០ ។ ពេលនោះ ប្រហែល ៧០% នៃអ្នករស់នៅក្នុងក្រុងបានចូលមកពីខេត្តផ្សេងៗ ។ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក្រុងត្រូវបានស្តារដោយមានជំនួយបច្ចេកទេសពីវៀតណាម ហើយជាលទ្ធផល ក្រុងភ្នំពេញអាចទទួលឱ្យប្រជាជនស្នាក់នៅបានប្រហែលកន្លះលាននាក់នៅពាក់កណ្តាលទសវត្សរ៍១៩៨០ ។ បច្ចុប្បន្ន ប្រជាជនបានកើនឡើងដល់ជាងមួយលាននាក់ហើយ ។

អ្នកចូលរួមបានរាយការណ៍ថា ពួកគេមិនដឹងពីការកំណត់តំបន់ ឬការធ្វើផែនការប្រើប្រាស់ដីធ្លី សំរាប់ក្រុងភ្នំពេញនាពេលថ្មីៗនេះទេ ។ បើសិនផែនការទាំងនេះមានមែន ច្បាស់ជាមិនបានផ្សព្វផ្សាយជាសារធារណៈឡើយ ទើបពួកគេមិនបានដឹង ។ អ្នកចូលរួមបានសង្កេតឃើញថា អវត្តមាននៃផែនការកំណត់តំបន់ និងអភិវឌ្ឍន៍ទីក្រុង បានជំរុញឱ្យមានកំហុសឆ្គងក្នុងការគ្រប់គ្រង និងរៀបចំទីក្រុង ។ ដីធ្លី និងអគារសាធារណៈជាច្រើន ត្រូវបានគេលក់ដោយខុសច្បាប់ ដែលធ្វើអោយនៅសល់សំណង់ និងដីធ្លីតែបន្តិចបន្តួច សំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្គត់ផ្គង់សាធារណៈ ។ មានដីធ្លីជាច្រើនដែលគេកាន់កាប់សំរាប់គោលដៅពាណិជ្ជកម្ម ហើយដែលមិនត្រូវបានប្រើប្រាស់ឱ្យមានផលិតភាព គឺគេគ្រាន់តែរក្សាទុកសំរាប់លក់យកចំណេញ ។ ចំណូលពន្ធពីដីធ្លីទាំងនេះ មានតិចតួចណាស់ ពីព្រោះអត្រាពន្ធមានកំរិតទាប ហើយអត្រាមិនបង់ពន្ធមានកំរិតខ្ពស់ណាស់ ។ ដូច្នេះរដ្ឋបានបាត់បង់ចំណូលយ៉ាងច្រើនសំបើម ។ គេបញ្ជាក់ថា ប្រាក់កំរៃផ្លូវការដ៏ខ្ពស់នៃការធ្វើប័ណ្ណប្លង់ដី និងការផ្ទេរកម្មសិទ្ធិ គឺជាមូលហេតុចំបងដែលរារាំងប្រជាជនក្នុងការសុំកម្មសិទ្ធិផ្លូវការលើដីធ្លី និងផ្ទះ ។ វាបានជំរុញឱ្យមានការកាន់កាប់ មិនស្របច្បាប់ និងការធ្វើប័ណ្ណក្លែងក្លាយ ។ សោភណភាព និងបរិស្ថានក្នុងទីក្រុង ក៏កំពុងខូចខាតដោយសារតែការប្រមូលផ្តុំយ៉ាងខ្លាំងនៃសកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់ដ៏តូចចង្អៀត និងវត្តមាននៃសំណង់មិនស្របច្បាប់ផ្សេងៗ ។

---

៧ សិក្ខាសាលានេះចូលរួមដោយសិក្ខាកាម ៤០នាក់មកពីសាលាក្រុង ខ័ណ្ឌ សង្កាត់ និងអាជ្ញាធរអភិវឌ្ឍន៍ក្រុងនៃក្រុងភ្នំពេញ, ព្រមទាំង NGOs ដែលធ្វើសកម្មភាពនៅភ្នំពេញ នៅលើបញ្ហាផ្សេងៗខាងទីក្រុង ។

ទីក្រុងនីមួយៗត្រូវមានផែនការ និងយន្តការអនុវត្តន៍ច្បាស់លាស់ ដើម្បីធានាឱ្យទីក្រុងនោះមានការរីកលូតលាស់ប្រកបដោយសណ្តាប់ធ្នាប់ល្អ និងប្រសិទ្ធិភាពខ្ពស់ ។ បើមិនដូច្នោះទេ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគរបស់វិស័យឯកជន នឹងត្រូវយឺតយ៉ាវ ។ អ្នកចូលរួមបានឯកភាពថា គួរមានការកំណត់តំបន់ និងការធ្វើផែនទីប្រើប្រាស់ដីធ្លីឱ្យបានច្បាស់លាស់ ដើម្បីធានាដល់ការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ចនិងសង្គមកិច្ច និងការរក្សាអោយមានសណ្តាប់ធ្នាប់ល្អ ។ គេយល់ថា ការរៀបចំដែនដី ការចុះបញ្ជីដីធ្លី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ គឺជាលក្ខខណ្ឌត្រូវបំពេញអោយបានជាមុន ដើម្បីសំរេចគោលដៅទាំងនេះបាន ។ ការសិក្សាពីផលប៉ះពាល់ដល់សង្គម និងបរិស្ថាននៃការដាក់អនុវត្តន៍ផែនការកំណត់តំបន់ និងផលវិបាកនៃការផ្លាស់ប្តូរលំនាំប្រើប្រាស់ដីធ្លីក្នុងទីក្រុងភ្នំពេញ ត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីអាចកំណត់ចេញនូវវិធានការសំរុះសំរួលផ្សេងៗដែលត្រូវអនុវត្ត ។ លទ្ធផលនៃការសិក្សាពីការរុះរើផ្លាស់កន្លែងសំណង់/តំបន់ស្នាក់នៅមិនស្របច្បាប់នានា ត្រូវតែកត់បញ្ចូលនៅក្នុងផែនការប្រើប្រាស់ដីធ្លីសំរាប់រយៈពេលខ្លី និងរយៈពេលវែង ។

រហូតមកដល់ពេលនេះ ថ្នាក់ដឹកនាំសង្កាត់ និងខ័ណ្ឌ ត្រូវបានគេដាក់កំហុសចំពោះការគ្រប់គ្រងដីធ្លីក្នុងក្រុង និងការជំរុញអោយមានកំណើនសំណង់/តំបន់តាំងទីលំនៅមិនស្របច្បាប់មិនត្រឹមត្រូវ ។ ប៉ុន្តែអ្នកចូលរួមដែលបំរើការនៅតាមសង្កាត់ និងខ័ណ្ឌនានាបានត្អូញត្អែរថា ពួកគេមិនដែលមានឱកាសកសាងផែនការសំរាប់តំបន់ដែលខ្លួនគ្រប់គ្រងទេះ ការធ្វើផែនការអភិវឌ្ឍន៍ទីក្រុងទាំងមូល វាខ្ពស់ហួសសមត្ថភាពពួកគេឆ្ងាយណាស់ ។ តាមពិត ដោយសារដែនសមត្ថកិច្ចដ៏តូច និងជួនកាលកំណត់មិនច្បាស់លាស់ផង ពួកគេពិបាកនឹងគ្រប់គ្រងឱ្យបានសក្តិសិទ្ធនូវការប្រើប្រាស់ដីធ្លី និងទប់ស្កាត់សកម្មភាពសាងសង់មិនស្របច្បាប់នៅក្នុងតំបន់របស់ពួកគេ ។

គេបានលើកថា ដំណើរការមានការចូលរួម និងតម្លាភាពក្នុងការធ្វើផែនការកំណត់តំបន់អភិវឌ្ឍន៍ នឹងជួយអភិវឌ្ឍន៍សមត្ថភាពដឹកនាំនៅមូលដ្ឋាន ផ្តល់ការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព និងលុបបំបាត់អំពើអនាធិបតេយ្យ ។ ប៉ុន្តែការនិយាយ វាងាយជាងការអនុវត្តន៍ជាក់ស្តែង ។ ឧទាហរណ៍ ភស្តុតាងមួយនៃការខ្វះឆន្ទៈ និងការប្តេជ្ញាចិត្ត គឺនៅពេលដែលទីធ្លាសាធារណៈជាច្រើនត្រូវបានលក់ដូរ ឬចាប់យកដោយអ្នកមកស្នាក់នៅមិនស្របច្បាប់ និងជនចំណាកស្រុកផ្សេងៗ, គេមិនឃើញមានការចាត់វិធានការអ្វីដើម្បីដោះស្រាយបញ្ហាទាំងនេះទេ ។ ការកសាងផែនការកំណត់តំបន់សំរាប់ទីក្រុងភ្នំពេញតែមួយមុខ នឹងមិនអាចដោះស្រាយបញ្ហាកំណើនប្រជាជននៅក្នុងទីក្រុងបានទេ ។ ដូចគ្នាដែរ គេត្រូវកសាងផែនការសំរាប់ការតាំងទីលំនៅ និងត្រូវគិតគូរពីឱកាសមានការងារធ្វើសំរាប់ប្រទេសទាំងមូល ។ ក្នុងគោលដៅនេះ ការចុះបញ្ជីអចលនទ្រព្យរបស់ឯកជន និងរដ្ឋ គឺជាចំណុចចាប់ផ្តើមមួយដ៏ល្អណាស់ ។

*កំណើនប្រជាជន និងចំណាកស្រុកចូល*

ការអភិវឌ្ឍន៍ពុំមានតុល្យភាពរវាងតំបន់ទីក្រុង និងជនបទ កំពុងតែជំរុញលំហូរជនចំណាកស្រុកពីជនបទមកទីក្រុង ។ ប្រជាជនធ្វើចំណាកស្រុកមកកាន់ទីក្រុង ជាពិសេសមកភ្នំពេញ ដើម្បីស្វែងរកការងារធ្វើ និងជីវភាពល្អប្រសើរ ពីព្រោះភាពក្រីក្រនៅតំបន់ជនបទកាន់តែកើនឡើង ជាពិសេសកង្វះការងារធ្វើនៅឯភូមិកំណើត ។ នេះគឺជាការផ្ទេរភាពក្រីក្រពីតំបន់ជនបទមកទីក្រុងភ្នំពេញ ។ សាលាក្រុងភ្នំពេញទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរ ក្នុងបញ្ហាស្នាក់នៅរបស់ជនចំណាកស្រុកទាំងនេះ ។ គេប៉ាន់ស្មានថា មានតំបន់តាំងទីលំនៅមិនស្របច្បាប់ ៤៧២កន្លែងដែលមានប្រជាជន ៣៥.១៦៥គ្រួសារ ត្រូវជា ១៧៥.៨២៥នាក់ ( មិនរាប់បញ្ចូលអ្នកគ្មានផ្ទះសំបែង និងជនចំណាកស្រុកតាមរដូវកាលពីជនបទមកទីក្រុងទេ) ។ ពួកគេរស់នៅតាមមាត់ទន្លេ ក្នុងទីធ្លាសាធារណៈជុំវិញបឹង និងលើចិញ្ចើមថ្នល់ ។ ប្រជាជនទាំងនេះមកពីខេត្តនានា និងពីប្រទេសជិតខាង ។ សមត្ថភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធលូទឹកស្អុយ និងការបង្កើតការងារនៅមានកំរិតទាបខ្លាំងណាស់ បើធៀបនឹងតំរូវការដែលផុសឡើងពីលំហូរចូលនៃជនចំណាកស្រុក ។

ការតាំងទីលំនៅមិនស្របច្បាប់ទាំងនេះ មួយចំណែកគឺជាលទ្ធផលនៃការគ្រប់គ្រង និងការចាត់ចែងខ្សោយរបស់ថ្នាក់ដឹកនាំសង្កាត់ និងខ័ណ្ឌ (ប៉ុន្តែមន្ត្រីសង្កាត់ និងខ័ណ្ឌ បានតវ៉ានឹងការដាក់កំហុសនេះ) ហើយក្នុងករណីខ្លះៗ គឺបណ្តាលមកពីសំពាធនយោបាយ ។ ឧទាហរណ៍ គេរាយការណ៍ថា គ្មានគណបក្សនយោបាយណាមួយបានយកចិត្តទុកដាក់ទប់ស្កាត់សកម្មភាពអនាធិបតេយ្យចាប់យកដីធ្លី និងអគារសាធារណៈឡើយ ក្នុងអំលុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតក៏រិតជាតិលើកក្រោយនេះ ។

បច្ចុប្បន្ន សាលាក្រុងភ្នំពេញកំពុងអនុវត្តផែនការរុះរើតាំងទីលំនៅថ្មីមួយ សំរាប់ប្រជាជននៅក្នុងតំបន់តាំងទីលំនៅមិនស្របច្បាប់នានា ដើម្បីកែលំអសោភ័ណភាព និងដោះស្រាយបញ្ហាសង្គមនៅក្នុងទីក្រុង ។ ប៉ុន្តែកម្មវិធីនេះ (តាមលំនាំដែលបានរៀបចំហើយ) វាមានតំលៃខ្ពស់ និងទំនងជាមិនសូវបានជោគជ័យទេ ។ ប្រជាជនតាំងទីលំនៅមិនស្របច្បាប់ច្រើនរយគ្រួសារត្រូវរុះរើទៅតាំងទីលំនៅជាថ្មីនៅវាលរេញ ទួលសំបូរ កោះរំដួល និងពូនភ្នំ ប៉ុន្តែក្នុងនេះមានជាច្រើនគ្រួសារបានត្រឡប់មកវិញ ដោយសារហេតុផលខាងសេដ្ឋកិច្ច និងជីវភាពរស់នៅ ។ មន្ត្រីមកចូលរួមមានជំនឿថា តំបន់តាំងទីលំនៅថ្មីត្រូវបំពាក់អោយបានគ្រប់គ្រាន់នូវហេដ្ឋារចនាសម្ព័ន្ធល្អៗ ការផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ... និងជាពិសេសឱកាសល្អខាងសេដ្ឋកិច្ចសំរាប់ប្រជាជនដែលរុះរើទៅតាំងទីលំនៅថ្មី ។ ក្នុងរឿងនេះ កង្វះថវិកាគ្រប់គ្រាន់ គឺជាបញ្ហាធំបំផុត ។

អ្នកដែលរស់នៅក្នុងតំបន់អនាធិបតេយ្យ អ្នកគ្មានផ្ទះសំបែង និងអ្នករស់នៅតាមដងផ្លូវ ត្រូវបានអ្នកផងចាត់ទុកថាជាសមាសភាពមិនល្អនៅក្នុងសង្គម និងត្រូវគេចោទថាជាអ្នកប្រព្រឹត្តអំពើចោរកម្ម បទឧក្រិដ្ឋ និងអំពើអសីលធម៌ផ្សេងៗ ។ រហូតមកទល់សព្វថ្ងៃ សាលាក្រុងដោយមានការឧបត្ថម្ភពី NGOs បានព្យាយាមប្រមូលកុមាររស់នៅតាមចិញ្ចើមថ្នល់ទៅដាក់នៅក្នុងមណ្ឌលកុមារកំព្រា ប៉ុន្តែការប្រឹងប្រែងនេះមិនសូវបានជោគជ័យទេ ពីព្រោះមន្ត្រីសង្កាត់/ខ័ណ្ឌ បានសង្កេតឃើញកុមារជាច្រើនវិលទៅរស់នៅតាមចិញ្ចើមថ្នល់វិញ ក្រោយពីបានយកទៅដាក់នៅក្នុងមណ្ឌលកុមារកំព្រាហើយ ។ មូលហេតុចំបងដែលគេបានរាយការណ៍ គឺការគ្រប់គ្រងមិនល្អនៃមណ្ឌលកុមារកំព្រា និងការថែទាំកុមារមិនបានដិតដល់ ។ រហូតមកដល់សព្វថ្ងៃ រដ្ឋាភិបាលពុំមានផែនការ ឬទីកន្លែង ដើម្បីផ្តល់កន្លែងថ្មីអោយប្រជាជនគ្មានផ្ទះសំបែងតាំងទីលំនៅទេ ។ ដោយសារកង្វះថវិកា និងដីធ្លី មន្ត្រីភាគច្រើនដែលមកពីសង្កាត់/ខ័ណ្ឌ បានជជែកវែកញែកថា ការអនុវត្តវិធានការរដ្ឋបាលតឹងរឹង ដូចជាការបញ្ជូនដោយបង្ខំនូវជនចំណាកស្រុកទៅភូមិកំណើតវិញជាដើម អាចខ្វះមេត្តាធម៌បន្តិច ប៉ុន្តែអាចធ្វើកើត ។

ទោះបីសមត្ថភាពខាងរដ្ឋបាល និងហិរញ្ញវត្ថុ របស់សង្កាត់/ខ័ណ្ឌ នៅមានក៏រិតក៏ដោយ ក៏មន្ត្រីអ្នកចូលរួមបានបញ្ជាក់ថា ពួកគេបន្តធ្វើការកត់ត្រា និងរាយការណ៍ពីការតាំងទីលំនៅមិនស្របច្បាប់នៅក្នុងសង្កាត់/ខ័ណ្ឌរៀងៗខ្លួនទៅអោយថ្នាក់លើ ។ ប៉ុន្តែ ចំពោះបញ្ហានេះ ប្រហែលពុំមានដំណោះស្រាយអ្វីដែលបានយូរអង្វែងនោះទេ ពីព្រោះចំណាកស្រុកគឺជាបញ្ហាថ្នាក់ជាតិ ហើយសាលាក្រុងភ្នំពេញតែឯងមិនអាចកែលំអស្ថានការណ៍បានទេ ។ ក្នុងនេះ ត្រូវមានកិច្ចសហប្រតិបត្តិការអន្តរខេត្ត ជាពិសេសក្នុងការងារកាត់បន្ថយគំលាតខាងសេដ្ឋកិច្ច និងសង្គមកិច្ចរវាងតំបន់ជនបទ និងទីក្រុង ។ ក្នុងរឿងនេះ ការអភិវឌ្ឍន៍ជនបទត្រូវបានគេមើលឃើញថា មានសារៈសំខាន់ក្នុងការកាត់បន្ថយគំលាត ប៉ុន្តែការអភិវឌ្ឍន៍តាមកន្លែង (ការអភិវឌ្ឍន៍ក្រុងតូចៗក្នុងទូទាំងប្រទេស) ក៏មានសារៈសំខាន់ដូចគ្នាដែរ ។

### *ភូមិសាស្ត្រសំរាប់ពង្រីកទីក្រុង*

ក្រុងភ្នំពេញកំពុងប្រឈមមុខនឹងកំនើនប្រជាជនយ៉ាងរហ័ស កំណើនសំណង់ថ្មីៗ កំណើនការប្រមូលផ្តុំខាងពាណិជ្ជកម្ម, ហើយទាំងអស់នេះកំពុងបង្កើតតំរូវការយ៉ាងធ្ងន់ធ្ងរទៅលើការស្នាក់នៅ, ផ្គត់ផ្គង់សាធារណៈ និងសេវាសាធារណៈ ។ កំណើនទាំងនេះកំពុងមានផលប៉ះពាល់អវិជ្ជមានចំពោះចរាចរ ប្រព័ន្ធបង្ហូរ/រំដោះទឹក សោភ័ណភាព បរិស្ថាន និងសន្តិសុខសង្គម ។

ផែនការពង្រីកទីក្រុង កំពុងតែកសាងឡើងហើយ ។ គេបានគ្រោងថា ការអភិវឌ្ឍន៍ទីក្រុងត្រូវធ្វើទៅទិសខាងលិច ពីព្រោះតំបន់នោះមិនលិចទឹកនៅរដូវវស្សា ឯទឹកទន្លេក៏មិនអាចជន់លិចដល់ដែរ ។ ពាក់ព័ន្ធនឹងការពង្រីកក្រុង គេមានជំរើសវិធី

អភិវឌ្ឍន៍បីបែប ដោយគេបានកំណត់សក្តានុពលខាងសង្គមកិច្ច និងសេដ្ឋកិច្ច និងហានិភ័យ សំរាប់វិធីនីមួយៗរួចហើយ ។ ទី១ ភ្នំពេញនៅមានតំបន់ដែលអាចពង្រីកបាន ជាពិសេសផ្ទៃដី ៣៨៧គីឡូម៉ែត្រការ៉េនៅក្នុងខ័ណ្ឌជាយក្រុងទាំងបី ។ ខ័ណ្ឌដង្កោស្ថិតក្នុងចំណោមខ័ណ្ឌទាំងបីនេះ ហើយបច្ចុប្បន្នកំពុងត្រូវបានអភិវឌ្ឍន៍នៅក្នុងកម្មវិធីរុះរើតាំងទីលំនៅជាថ្មីឡើងវិញ (ប៉ុន្តែមិនសូវបានជោគជ័យទេ) ។ ផែនការនេះគួរត្រូវបានអនុវត្តឱ្យបានដិតដល់ថែមទៀត ។ ទី២ ការបង្កើតទីក្រុងរណបអោយបានច្រើនថែមទៀត អាចជាមធ្យោបាយមួយសំរាប់ដោះស្រាយបញ្ហាបច្ចុប្បន្ន ។ អ្នកចូលរួមសិក្ខាសាលាភាគច្រើនបានឯកភាពថា ការលើកទឹកចិត្តអោយប្រជាជនទៅរស់នៅទីក្រុងផ្សេងទៀតមិនចោទបញ្ហាទេ បើសិននៅទីនោះមានហេដ្ឋារចនាសម្ព័ន្ធ និងការងារល្អៗ ។ ទី៣ បើសិនសកម្មភាពពាណិជ្ជកម្ម និងឧស្សាហកម្ម ត្រូវបានបែងចែកស្មើៗគ្នាទៅតាមទីរួមខេត្តនានា វានឹងធ្វើអោយគំរូវការអភិវឌ្ឍន៍ទីក្រុងមានតុល្យភាពហើយ ។

អ្នកចូលរួមភាគច្រើនយល់ឃើញថា ឯកសារផែនការមេគួរតែផ្សព្វផ្សាយជាសាធារណៈ និងយកមកជជែកវែកញែកដោយមានតម្លាភាពដើម្បី:

១. លើកកំពស់អភិបាលកិច្ចល្អ និងចៀសវាងការគ្រប់គ្រងខុសឆ្គងលើការប្រើប្រាស់ដីធ្លីនៅគ្រប់ថ្នាក់ ។
២. ធានាឱ្យមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន ដើម្បីការពារផលប្រយោជន៍ក្នុងមូលដ្ឋាន និងអត្ថប្រយោជន៍របស់ពួកគេ និង
៣. កាត់បន្ថយការកេងយកចំណេញខាងនយោបាយ ពីសំណាក់គណបក្សនយោបាយផ្សេងៗ ។

## *សមត្ថភាពនៃរដ្ឋបាលបច្ចុប្បន្ន*

គេយល់ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិ និងការចុះបញ្ជីដីធ្លី គឺជាលក្ខខណ្ឌត្រូវបំពេញអោយបានជាមុន និងជាឧបករណ៍សំរាប់ការធ្វើផែនការអភិវឌ្ឍន៍ទីក្រុង ។ ចំនួនបុគ្គលិកសំរាប់ធ្វើការងារនេះមិនចោទបញ្ហាទេ ប៉ុន្តែសមត្ថភាពបច្ចេកទេសមានការខ្វះខាត ជាពិសេសនៅថ្នាក់សង្កាត់ និងខ័ណ្ឌ ។ បុគ្គលិកភាគច្រើនពុំមានបទពិសោធន៍ ក្នុងការធ្វើផែនការអភិវឌ្ឍន៍ទីក្រុងទេ ។ លើសពីនេះទៀត អ្នកចូលរួមបានឯកភាពថា មន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងស្ថាប័នរដ្ឋ ពុំមានសំភារៈ និងថវិកាគ្រប់គ្រាន់ទេ ។

ដំបូងបំផុត គេត្រូវកសាងផែនការមេមួយ (សំរាប់ការកំណត់តំបន់/ការប្រើប្រាស់ដីធ្លី និងការពង្រីកទីក្រុង) ។ បន្ទាប់មកត្រូវផ្តល់ការបំពាក់បំប៉នបច្ចេកទេសដើម្បីអនុវត្តផែនការមេ ក៏ដូចជាតាមដានត្រួតពិនិត្យ និងវាយតំលៃលទ្ធផលនៃការអនុវត្តន៍ផែនការ ។ ត្រូវលើកកំពស់សហប្រតិបត្តិការរវាងក្រសួងផ្សេងៗ NGOs, និងវិស័យឯកជន, ដើម្បីធានាឱ្យដំណើរការមានចីរភាព និងអាចទទួលយកបានខាងផ្នែករដ្ឋបាល ។

NGOs មួយចំនួន និងអង្គការអន្តរជាតិ ដូចជា UNHCR, Action Nord-Sud និង USG បានចូលរួមយ៉ាងសកម្មជួយដល់សហគមន៍ក្នុងតំបន់អនាធិបតេយ្យនៅក្នុងកម្មវិធីរុះរើតាំងទីលំនៅជាថ្មីរបស់សាលាក្រុងភ្នំពេញ ។ សកម្មភាពទាំងនេះ គួរបន្សុំគ្នាជាមួយនឹងសកម្មភាពរបស់រដ្ឋាភិបាល ដើម្បីឱ្យមានប្រសិទ្ធិភាពកាន់តែខ្ពស់ ។

ដូចខេត្តដទៃទៀតដែរ ភ្នំពេញបានជួបទំនាស់ដីធ្លីជាច្រើនប្រភេទ ប៉ុន្តែនៅទីនេះទំនាស់វាជំពាក់ជំពិនយ៉ាងខ្លាំងជាមួយនឹងរឿងនយោបាយ ។ ការប្រទាំងប្រទើសគ្នារវាងការតាំងទីលំនៅមិនស្របច្បាប់ និងកម្មវិធីស្តារកសាងហេដ្ឋារចនាសម្ព័ន្ធ គឺជាចំណុចមួយគួរព្រួយបារម្ភ ។ ឧទាហរណ៍ គំរោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវពន្យាពេល ពីព្រោះមានការតាំងទីលំនៅមិនស្របច្បាប់នៅរាំងស្ទះ ។ ប្រព័ន្ធច្បាប់នាពេលបច្ចុប្បន្នមិនអាចដោះស្រាយបញ្ហាទាំងនេះបានទេ ។ ទោះជា LDSC ត្រូវបានបង្កើតឡើងសំរាប់សរបសំរួល និងផ្សះផ្សាទំនាស់នានាក៏ដោយ ក៏ទំនាស់ភាគច្រើនមានរឿងនយោបាយមកចូលលាយឡំ ហើយជាញឹកញយត្រូវបញ្ជូនដល់អាជ្ញាធរថ្នាក់លើៗ ។ ដូច្នេះ LDSC និងស្ថាប័នប្រហាក់ប្រហែល ពុំមានឱកាសធ្វើការផ្សះផ្សាទំនាស់ទាំងនេះទេ ។

ធ្ងន់ធ្ងរជាងនេះទៅទៀត ដីធ្លីនៅជុំវិញភ្នំពេញទាំងអស់មានគេកាន់កាប់អស់ហើយ និងមានតំលៃខ្ពស់ណាស់ ។ ទាំងសាលាក្រុងភ្នំពេញ ទាំងរដ្ឋាភិបាល គឺពុំមានធនធានគ្រប់គ្រាន់សំរាប់អនុវត្តកម្មវិធីរុះរើតាំងទីលំនៅថ្មីឡើងវិញនេះទេ ។ គេបានបញ្ជាក់ថា កង្វះថវិកាបានចោទបញ្ហានៅគ្រប់ថ្នាក់ ។ អ្នកចូលរួមក្នុងសិក្ខាសាលា ហាក់ដូចជាមាននិន្នាការពឹងផ្អែកលើជំនួយហិរញ្ញវត្ថុពីខាងក្រៅជាជាងរកវិធីបង្កើនចំណូលរដ្ឋ ។

# សេចក្ដីណែនាំសំរាប់ធ្វើសំភាសន៍គុណភាព

## ១. បញ្ហានៅតាមជនបទ

(១)ទិន្នន័យត្រូវប្រមូលសំរាប់ការវាយតំលៃសង្គមៈ ពតិមានប្រមូលបានពីមន្ត្រីរដ្ឋាភិបាល ស្ថាប័ន និងជនសំខាន់ៗ

| | | ខេត្ត | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|---|---|
| ១ | ចំនួនប្រជាជន | | | | |
| ២ | ចំនួនគ្រួសារ | | | | |
| ៣ | អត្រាប្រជាជនពឹងផ្អែកលើកសិកម្ម (%) | | | | |
| ៤ | អត្រាអ្នកចេះអក្សរ (%) | | | | |
| ៥ | អត្រាអ្នកគ្មានដី (%) | | | | |
| ៦ | ប្រជាជន (ចំណាកស្រុកចូល) ថ្មី (ក្នុងរយៈមួយឆ្នាំកន្លងមក) | X | X | | |
| ៧ | តើពួកគេជាអ្នកណា? (យោងតាមសំនួរទី៦ ខាងលើ) | X | X | | |
| ៨ | ចំនួនជនចំណាកស្រុកចេញ និងពួកគេជាអ្នកណា? | X | X | | |
| ៩ | ភាគរយនៃផ្ទៃដីដាំដុះ | | | | |
| ១០ | ភាគរយនៃផ្ទៃដីព្រៃ | | | | |
| ១១ | ភាគរយនៃផ្ទៃទឹក/ដែននេសាទ | | | | |
| ១២ | ភាគរយនៃដីសម្បទាន | | | | |
| ១៣ | ភាគរយនៃដីរដ្ឋ | | | | |
| ១៤ | ភាគរយនៃដីឯកជន | | | | |
| ១៥ | ភាគរយនៃដីរួម (សមូហភាព) | | | | |
| ១៦ | ដីគ្របដណ្តប់ដោយប្រព័ន្ធស្រោចស្រព (%) | | | | |
| ១៧ | ទិន្នផលស្រូវ (ត.ក/ហិកតា) | X | X | | |
| ១៨ | ទំហំដីជាមធ្យមក្នុងមួយគ្រួសារ (ហិកតា) | X | X | | |
| ១៩ | ទំហំនៃការធ្វើកសិកម្មដោយប្រើគ្រឿងចក្រ | X | X | | |
| ២០ | តំលៃដី (ដុល្លារ/ហិកតា) | X | X | | |
| ២១ | ផ្ទៃដីផ្លូវ | X | | | |
| ២២ | ការបែងចែកដី (នៅឆ្នាំណា?) | | | | |
| ២៣ | មានទំនាស់ដីធ្លីច្រើន (មែន/មិនមែន) | | | | |
| ២៤ | យន្តការដោះស្រាយ | | | | |
| ២៥ | ភាគរយនៃករណីទំនាស់ដីធ្លីបានដោះស្រាយ | | | | |
| ២៦ | ចំនួនគ្រួសារគ្មានផ្ទះសំបែង | X | X | X | |

(២) ពត៌មានត្រូវប្រមូលបានពីការជួបពិភាក្សាជាមួយនឹងអាជ្ញាធរថ្នាក់ខ្ពស់ (អភិបាលស្រុក មេឃុំ មន្ត្រីផ្សេងទៀត និងជំរើសពត៌មានមួយចំនួនត្រូវប្រមូលពីអភិបាល/អភិបាលរងខេត្ត-ក្រុង ។ សំណួរដែលមានសញ្ញាផ្កាយ អាចសាកសួរទៅដល់អភិបាល/អភិបាលរងខេត្ត-ក្រុងផងដែរ) ។

*កំណត់សំគាល់: ពត៌មានទាំងអស់ពាក់ព័ន្ធនឹងដីកសិកម្ម និងដីលំនៅដ្ឋាន ទាំងពីរប្រភេទ ។ សូមកត់ត្រាចម្លើយទៅតាមប្រភេទដីដែលអ្នកឆ្លើយសំភាសន៍គេចង់ប្រាប់ ។*

*ពត៌មានទូទៅ*

១. នៅក្នុងតំបន់នេះ តើមានប្រជាជនប៉ុន្មានភាគរយដែលមានជីវភាពពឹងផ្អែកជាសំខាន់លើដីធ្លី?

២. ក្រៅពីធ្វើជាដីលំនៅដ្ឋាន តើដីធ្លីត្រូវបានប្រើប្រាស់ជាក់ស្តែងធ្វើអ្វីខ្លះ?
ក. ព្រៃឈើ ខ. វាលស្មៅ គ. ដីកសិកម្ម ឃ. ផ្ទៃទឹកទូទៅ ង. ចំការ ច. ដីសម្បទាន ។ សូមផ្តល់ជាតួលេខផង ។

៣. នៅក្នុងតំបន់នេះ តើការប្រើប្រាស់ជាក់ស្តែងនូវដីមួយប្រភេទៗ វាស្របតាមគោលការណ៍ដែលកំណត់ហើយបានប៉ុណ្ណាដែរ?
ក. ដីកសិកម្ម ខ. ព្រៃឈើ គ. ព្រៃសម្បទាន ឃ. ផ្ទៃទឹកទូទៅ (ឡូត៍នេសាទ) ង. ផ្សេងៗ (សូមពន្យល់)

*៤. ក្នុងតំបន់នេះ តើនរណាខ្លះជាភាគីសំខាន់ៗដែលពាក់ព័ន្ធនឹងដីធ្លី? ពិភាក្សារឿងនេះឱ្យបានល្អិតល្អន់ ដើម្បីបានពត៌មានពី អ្នកពាក់ព័ន្ធនឹងដីធ្លីដោយផ្ទាល់ និងដោយប្រយោល ។

៥. តើម្ចាស់ដីធំៗកំពុងតែកើនឡើងដែរឬទេនៅក្នុងតំបន់នេះ? សូមពន្យល់ពីការប្រមូលផ្តុំដីធ្លីនៅក្នុងតំបន់ ។

៦. ក្នុងតំបន់នេះ តើធ្លាប់មានការបះបោរដែរឬទេ? បើមាន តើធ្ងន់ធ្ងរប៉ុណ្ណា? តើគេមានវិធានការអ្វីខ្លះសំរាប់ទប់ទល់? នរណាជាអ្នកកាន់អាវុធ?

*៧ តើអ្នកមានយោបល់យ៉ាងណាដែរ ចំពោះការប្រមូលផ្តុំដីសំរាប់ការធ្វើកសិកម្មទំនើប?

*៨ តើមានដីនៅសល់សំរាប់ពង្រីកដីកសិកម្មដែរឬទេ? សូមពន្យល់ ។

៩. តើភាពគ្មានដីធ្លី និងការផ្ទេរកម្មសិទ្ធិដីធ្លីមានការប្រែប្រួលឬទេ ក្នុងពេលថ្មីៗកន្លងមកនេះ?

*១០ តើមានករណីលក់ដីដោយខុសច្បាប់ធ្វើឡើងដោយមន្ត្រីមូលដ្ឋាន នៅក្នុងតំបន់របស់អ្នកដែរឬទេ?

*សំនួរជាក់លាក់*

*១១ ក្នុងតំបន់របស់អ្នក តើការចុះបញ្ជីដីធ្លីគួរធ្វើតាមលំដាប់ដំជាក់លាក់មួយ ឬធ្វើជាទូទៅ?

*១២ សូមអ្នកបញ្ជាក់តាមការយល់ឃើញផ្ទាល់ខ្លួនអំពីការទទួលខុសត្រូវពិតប្រាកដនៃស្ថាប័នផ្សេងៗ ដូចជា MLMUPC, ក្រសួងកសិកម្ម ខេត្ត ឃុំ... ក្នុងការងារបែបវិមជ្ឈការ ។

*១៣ តើ NGOs អាចជួយបានឬទេ? បើបានតើតាមវិធីណា?

*១៤ តើអ្នកដឹងអំពីបទពិសោធន៍ការងារនៃអង្គការ *FinnMap* ឬ GTZ ដែរឬទេ? តើអ្នកមានមតិអ្វីទេ?

*១៥ តើគួរដោះស្រាយបែបណា ដើម្បីផ្តល់ដីធ្លីទៅអោយទាហានរំសាយនាពេលថ្មីៗ?

*១៦ តើអ្នកយល់ថា គួរមានគោលការណ៍ណែនាំអ្វីខ្លះដើម្បីអោយមានការគិតគូរពីតួនាទីបុរស-ស្ត្រី នៅក្នុងការងាររៀបចំឯកសារកម្មសិទ្ធិដីធ្លី ការប្រមូលពត៌មាន និងការអនុវត្តន៍កម្មវិធី?

*១៧ តើអ្នកចង់ឱ្យមានការកែលំអអ្វីខ្លះនៅក្នុងច្បាប់ ដើម្បីដោះស្រាយបញ្ហាមិនស្មើភាពរវាងស្ត្រី និងបុរស? (កម្មសិទ្ធិរួម សិទ្ធិបានទទួលចំណែកពីថ្លៃលក់ដីបាន ការយកដីដាក់ធានា ការបែងចែកទ្រព្យនៅពេលលែងលះគ្នា...)

១៨ តើការផ្ទេរពីដីសាធារណៈទៅជាដីឯកជន គួរធ្វើឡើងដោយរបៀបណា? (លក្ខខណ្ឌទាក់ទិននឹងការចាប់ផ្តើមកម្មវិធី ការទទួលខុសត្រូវ តំលៃ តម្លាភាព វិធីផ្ទេរ...)

១៩ តើពតិមានខាងផ្លូវច្បាប់ ត្រូវផ្សព្វផ្សាយយ៉ាងដូចម្តេច?

២០ តើមានករណីផ្ទេរ/ធ្វើកម្មសិទ្ធិជាន់គ្នាច្រើនប៉ុណ្ណា តាមដែលអ្នកធ្លាប់បានជួបប្រទះ? តើរឿងនេះអាចដោះស្រាយយ៉ាងដូចម្តេចបាន?

២១ តើគួរផ្តល់សំណងប៉ះប៉ូវយ៉ាងដូចម្តេច (ប្រាក់គោលនយោបាយ) ទៅអ្នកក្រីក្រដែលបានចាប់យកដី ?

២២ តើគួរតាមដានពិនិត្យដំណើរការផ្តល់ប័ណ្ណសំគាល់សិទ្ធិលើដីធ្លីដែរឬទេ? តើត្រូវធ្វើយ៉ាងដូចម្តេច?

២៣ ចំពោះយន្តការដោះស្រាយបណ្តឹងតវ៉ា តើអ្នកមានសំណូមពរអ្វីខ្លះ? តើត្រូវបង្កើត/ពង្រឹងយ៉ាងដូចម្តេច?

២៤. តើយន្តការដោះស្រាយបណ្តឹងនៅកំរិតណាដែលមានលក្ខណៈល្អបំផុត ហើយតើត្រូវពង្រឹងយ៉ាងដូចម្តេចខ្លះ ដើម្បីឱ្យវាមានប្រសិទ្ធិភាព តម្លាភាព និងយុត្តិធម៌?

២៥ តើអ្នកមានអារម្មណ៍ថា ស្ថាប័នមានស្រាប់សំរាប់ធ្វើការផ្តល់ប័ណ្ណសំគាល់សិទ្ធិលើដីធ្លី គឺមានជំនាញគ្រប់គ្រាន់ដើម្បីបំរើការងាររបស់ខ្លួនឬទេ?

២៦ តើត្រូវធ្វើអ្វីខ្លះ ដើម្បីបង្កើនសមត្ថភាពមន្ត្រីថ្នាក់ខេត្ត ស្រុក និងឃុំ នៅក្នុងការងារផ្តល់ប័ណ្ណសំគាល់សិទ្ធិលើដីធ្លី? (ការបណ្តុះបណ្តាល តម្លាភាព ការចូលរួមរបស់ NGOs, ការពិគ្រោះយោបល់ច្រើនថែមទៀតជាមួយកសិករ/អ្នកជាប់ពាក់ព័ន្ធនានា ការដោះស្រាយបញ្ហាដោយការប្រជុំនៅថ្នាក់ភូមិ វិធីផ្សេងទៀត)

២៧. តាមមតិរបស់អ្នក តើដំណើរការផ្តល់ប័ណ្ណសំគាល់សិទ្ធិដីធ្លីអាចមានប៉ះពាល់អាក្រក់អ្វីខ្លះ ហើយតើគេអាចធ្វើអ្វីខ្លះដើម្បីកាត់បន្ថយផលប៉ះពាល់នេះជាអតិបរមា?

***អំពីដំណោះស្រាយ***

២៨ ក្នុងការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ តើគេត្រូវកំណត់អាទិភាពយ៉ាងដូចម្តេច? ដីរដ្ឋ ដីឯកជន ដីកសិកម្ម ដីលំនៅដ្ឋាន ដីព្រៃ ដីរួម...?

២៩ តើ MLMUPC ក្រសួងកសិកម្ម និងក្រសួងផ្សេងទៀត ត្រូវមានគំនិតផ្តួចផ្តើមអ្វីខ្លះ ដើម្បីអោយការងារមានប្រសិទ្ធិភាពជាអតិបរមា?

៣០ តើគំរោងនេះ អាចបំពេញសេចក្តីសង្ឃឹមរបស់ក្រុមប្រជាជនផ្សេងៗ ដូចជាពួកយោធិនរំសាយជាដើមបានយ៉ាងដូចម្តេច?

៣១ តើអ្នកយល់ថា MLMUPC មានលទ្ធភាពបំពេញការងារនេះបានឬ? តើស្ថាប័នអ្វីខ្លះដែលមានលទ្ធភាព ហើយតើត្រូវមានស្ថាប័នប៉ុន្មានដែលត្រូវធ្វើការរួមគ្នា?

៣២ តើត្រូវធ្វើអ្វីខ្លះដើម្បីលើកកំពស់សមត្ថភាពបុគ្គលិកថ្នាក់ខេត្ត ស្រុក និងឃុំ?

៣៣ តើគួរផ្តល់សំណងប៉ះប៉ូវយ៉ាងដូចម្តេច (ប្រាក់គោលនយោបាយ) ទៅអោយអ្នកក្រីក្រដែលបានចាប់យកដី?

៣៤ តើគួរតាមដានពិនិត្យដំណើរការផ្តល់ប័ណ្ណសំគាល់សិទ្ធិលើដីធ្លីដែរឬទេ? តើត្រូវធ្វើយ៉ាងដូចម្តេច?

៣៥ តើអ្នកមានគំនិតអ្វីដើម្បីជួយដល់គ្រួសារគ្មានផ្ទះសំបែង? តើគួរផ្តល់ដីឡូត៍អោយពួកគេឬយ៉ាងណា?

***ការយកចិត្តទុកដាក់ចំពោះប្រជាជនដើម (ខេត្តរតនគិរី)***

៣៦ ក្នុងរឿងដីធ្លី តើស្ត្រីមានសិទ្ធិយ៉ាងដូចម្តេច តាមទំលាប់ជាប្រពៃណី និងតាមផ្លូវច្បាប់? តើកម្មសិទ្ធិរួមគ្នាត្រូវបានអនុញ្ញាតដែរឬទេ? តើស្ត្រីបានទទួលការការពារដែរឬទេក្នុងករណីមានការលែងលះ ករណីប្តីបោះបង់ចោល ឬប្តីស្លាប់?

៣៧ តើសព្វថ្ងៃគេតែងអនុវត្តដូចម្តេច ដើម្បីធ្វើសេចក្តីសំរេចផ្សេងៗស្តីពីរឿងដីធ្លីផ្ទះសំបែង? តើវាជាសេចក្តីសំរេចរួមគ្នារបស់បុគ្គលម្នាក់ ឬតាមបែបបទណាមួយផ្សេងទៀត? តើស្ត្រីបានចូលរួមដែរឬទេ?

៣៨ តើបុគ្គលនានា (រួមទាំងស្ត្រីផង) មានសិទ្ធិស្មើគ្នាឬទេ ក្នុងការធ្វើសេចក្តីសំរេចផ្សេងៗប្រចាំថ្ងៃទាក់ទិននឹងដីធ្លី?

៣៩ តើមានអ្វីទំនាស់គ្នាឬទេរវាងច្បាប់ដីធ្លីជាប្រពៃណី និងច្បាប់ដីធ្លីជាផ្លូវការ?

៤០ ក្នុងច្បាប់ដីធ្លីជាប្រពៃណី តើមានសេចក្តីចែងអ្វីខ្លះដែលមានដូចគ្នានៅក្នុងច្បាប់ស្តីពីទ្រព្យសម្បត្តិរបស់ប្តី ប្រពន្ធ ហើយដែលពុំមានឆ្លុះបញ្ចាំងនៅក្នុងប័ណ្ណសំគាល់សិទ្ធិ ឬឯកសារចុះបញ្ជីដីធ្លី?

**(៣) បញ្ជីសំនួរសំរាប់ក្រុមពិភាក្សាតូចៗនៅតាមភូមិ**

*(ប្រមូលពត៌មានស្តីពីសមាសភាពក្រុមៈ ការបែងចែកតាមភេទ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច អាយុ ការអប់រំ ចំនួនឆ្នាំស្នាក់នៅក្នុងភូមិ... ។ ក្រុមពិភាក្សាគួរមានប្រហែល ៩-១០នាក់ និងច្រើនបំផុត ២០-២៥នាក់ ។ ក្នុងក្រុមពិភាក្សា ត្រូវមានស្ត្រី និងកសិករតូចតាចចូលរួមផង ។ ក្នុងករណីមានក្រុមពិភាក្សាធំ គួររៀបចំការពិភាក្សាតាមវិធីផ្សេង-គួរធ្វើតាមរបៀបការវាយតំលៃតំបន់ជនបទដោយមានការចូលរួមអោយបានច្រើនជាងរបៀបប្រើក្នុងក្រុមពិភាក្សាតូចៗ) ។*

*កំណត់សំគាល់ៈ ពត៌មានទាំងអស់ជាប់ទាក់ទងនឹងដីកសិកម្ម និងដីលំនៅដ្ឋានទាំងពីរមុខ ។ សូមកត់ត្រាចម្លើយទៅតាមប្រភេទដីដែលអ្នកឆ្លើយសំភាសន៍គេចង់ប្រាប់ ។*

***ពត៌មានទូទៅ***

១. ក្នុងរយៈពេលកន្លងទៅថ្មីៗនេះ តើមានការប្រែប្រួលអ្វីខ្លះនៅក្នុង ភាពគ្មានដីធ្លី និងការផ្ទេរដីធ្លី ? មូលហេតុៈ ក. ប្រជាសាស្ត្រ/គ្រួសារទើបរៀបការថ្មី ខ. ការបែងចែកច្រើនហួសកំរិត គ. ការបែងចែកមិនត្រឹមត្រូវ ឃ. ការរំលោភយកដី (ដោយសារដីឡើងថ្លៃ ពីព្រោះនៅជិតផ្លូវធ្វើថ្មី នៅជិតប្រព័ន្ធស្រោចស្រព ឬនៅជិតតំបន់ធ្វើទំនើបភាវូបនីយកម្ម) ។

២. តើមានប្រជាជនប៉ុន្មានភាគរយដែលត្រូវបង្ខំចិត្តលក់ដី? សូមបញ្ជាក់មូលហេតុ ។

៣. តើមូលហេតុចំបងៗនៃការជំពាក់បំណុលមានអ្វីខ្លះ? អ្នកណាខ្លះជាម្ចាស់បំណុល? តើមានលក្ខខណ្ឌអ្វីខ្លះ សំរាប់ការខ្ចីប្រាក់?

៤. អ្នកណាជាអ្នកពាក់ព័ន្ធសំខាន់ៗក្នុងរឿងដីធ្លី? ពិភាក្សាអោយបានលំអិតដើម្បីរកភាគីពាក់ព័ន្ធនឹងដីធ្លីដោយផ្ទាល់ និងដោយប្រយោល ។

៥. តើការចាប់យកដីមានច្រើនប៉ុណ្ណា? អ្នកណាជាអ្នកប្រព្រឹត្តិ តើចាប់យកប៉ុន្មាន នៅកន្លែងណា?

៦. តើទំនាស់ព្រំដីកសិដ្ឋានមានច្រើនប៉ុណ្ណា និងមានចរិតយ៉ាងដូចម្តេច?

៧. តើមានទំនាស់មានច្រើនប៉ុណ្ណា គិតតាមមូលហេតុនៃទំនាស់?

៨. ដីកសិកម្មមួយកន្លែងៗមានទំហំជាមធ្យមប៉ុណ្ណា? តើទំហំនេះសមស្របសំរាប់ការធ្វើកសិកម្មតាមធម្មតាឬទេ?

៩. មតិស្តីអំពីកសិកម្មទំនើបដើម្បីបង្កើនផលិតភាព: តើការប្រមូលផ្តុំដីធ្លីមានសារៈសំខាន់ឬទេ? តើវានឹងធ្វើអោយប្រជាជនមួយចំនួនក្លាយជាអ្នកគ្មានដីធ្លីឬយ៉ាងណា? ហើយតើត្រូវដោះស្រាយយ៉ាងដូចម្តេច?

១០. នៅក្នុងក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន តើគេអាចបែងចែកដីធ្លីមិនប្រើប្រាស់យ៉ាងដូចម្តេចបាន ដើម្បីបំរើផលប្រយោជន៍របស់ប្រជាជនភាគច្រើន?

១១. តើគេអាចពង្រីកដីដាំដុះថែមបានឬទេ?

ក. ការរានដីព្រៃ ខ. ការរានដីព្រៃល្បោះ គ. ឯកជនភាវូបនីយកម្មដីរួម...

១២. តើគេអាចធ្វើយ៉ាងណា ដើម្បីឱ្យមន្ត្រីថ្នាក់មូលដ្ឋានមានការទទួលខុសត្រូវច្រើនជាងមុនចំពោះអំពើរបស់ខ្លួន?

១៣. តើត្រូវធ្វើអ្វីខ្លះ ដើម្បីអោយការផ្តល់ប័ណ្ណកម្មសិទ្ធិមានលក្ខណៈគាំពារអ្នកក្រ?

១៤. តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យប្រជាជនទូទៅមានលទ្ធភាពច្រើនជាងមុនក្នុងការប្រើប្រាស់ប្រព័ន្ធតុលាការ?

១៥. ក្នុងតំបន់អ្នក តើបញ្ហាអ្នកប្រមូលកាន់កាប់ដីច្រើនៗមានសភាពយ៉ាងណាដែរ? វាកើនឡើងដែរឬទេ?

១៦. តើមានអ្នកគ្មានដីលំនៅដ្ឋានដែរឬទេ? ពួកគេជានរណា? ហេតុអ្វីបានជាគេគ្មានដីផ្ទះ ហើយតើអាចជួយគេយ៉ាងដូចម្តេចបាន?

*ផ្នែកច្បាប់*

១៧. តើត្រូវផ្សព្វផ្សាយពតិមានផ្សេងៗខាងច្បាប់ដោយរបៀបណា?

១៨. ការកាត់ទោសមន្ត្រីប្រព្រឹត្តខុសច្បាប់

១៩. តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យតុលាការមានលក្ខណៈវិជ្ជាជីវៈ មានប្រសិទ្ធិភាពខ្ពស់ និងមានចំណាយតិច?

២០. តើមានយន្តការសំខាន់ៗអ្វីខ្លះ សំរាប់ដោះស្រាយទំនាស់ដីធ្លី នៅក្នុងតំបន់នេះ?

២១. តើយន្តការទាំងនេះមានប្រសិទ្ធិភាពប៉ុណ្ណា?

២២. តើយន្តការទាំងនេះមានជំហរអព្យាក្រិត្យ ឬនិយមបក្សពួក? តើគេនិយមបក្សពួកខាងណា? សូមឱ្យ ឧទាហរណ៍

២៣. តើឃើញមានករណីនៃការបែងចែកដីជាន់ឈ្មោះគ្នាច្រើនប៉ុណ្ណា?

*សិទ្ធិជាម្ចាស់ និងការចុះបញ្ជី*

២៤. ក្នុងតំបន់អ្នក តើការគ្រប់គ្រងដីតាមទំនៀមទំលាប់មានស្ថានភាពយ៉ាងដូចម្តេច? (បញ្ជាក់ពីសិទ្ធិ និងការទទួលខុសត្រូវ)

២៥. តើការថែរក្សា និងការបន្តមរតកដីធ្លី ធ្វើដោយរបៀបណា? តើរដ្ឋាភិបាលមានតួនាទីអ្វីខ្លះក្នុងរឿងនេះ?

២៦. តើមានភស្តុតាងអ្វីសំរាប់បញ្ជាក់កម្មសិទ្ធិលើដីធ្លី (ដីកសិកម្ម និងលំនៅដ្ឋាន) ដែលអ្នកកំពុងកាន់កាប់សព្វថ្ងៃ?

២៧. តាមមតិរបស់អ្នកផ្ទាល់ តើអ្នកមានសុវត្ថិភាពប៉ុណ្ណាដែរក្នុងការកាន់កាប់ដីធ្លីនាពេលបច្ចុប្បន្ន? បើសិនគិតថា គ្មានសុវត្ថិភាព (ទោះបីមានសំបុត្រស្នាមក៏ដោយ) សូមអ្នកពន្យល់មូលហេតុ ។

២៨. តើអ្នកបានទទួលភស្តុតាងសំគាល់កម្មសិទ្ធិនេះតាមរបៀបណា?

២៩. ចំពោះអ្នកបានទទួលប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី តាមរយៈប្រព័ន្ធចុះបញ្ជីដោយចោះៗរបស់រដ្ឋាភិបាលៈ តើគេបានដឹងពីការសុំប័ណ្ណសំគាស់សិទ្ធិនេះតាមរបៀបណា? តើត្រូវចំណាយប្រាក់ និងពេលវេលាប៉ុន្មាន? តើមានជួបប្រទះបញ្ហា និងការលំបាកអ្វីខ្លះ?

៣០. ចំពោះអ្នកមិនបានដាក់ពាក្យសុំប័ណ្ណសំគាស់សិទ្ធិដីធ្លី តើឧបសគ្គអ្វីបានបន្ទុចបង្អាក់ដល់ការដាក់ពាក្យសុំនេះ?

*ភាពគ្មានដីធ្លី និងទំនាស់ផ្សេងៗ*

៣១. ដោយសារតែស្ថានភាពគ្មានដីធ្លី តើមានជនចំណាកស្រុកចេញច្រើនឬទេ នៅក្នុងតំបន់នេះ?

៣២. តើកំណើនប្រជាជនយ៉ាងឆាប់រហ័ស និងកំណើនតំរូវការដីធ្លី កំពុងតែបណ្តាលឱ្យមានអ្នកអត់ដីឬយ៉ាងណា?

៣៣. តើអ្នកណាខ្លះជាអ្នកអត់ដី? ហេតុអ្វីបានជាគេក្លាយជាអ្នកអត់ដី?

៣៤. តើពួកគេជួលដីឯកជន ប្រើប្រាស់ដីរដ្ឋ ឬកំពុងធ្វើការដាំដុះដោយខុសច្បាប់?

៣៥. ចំពោះអ្នកជួលដីគេ ឬធ្វើស្រែប្រវាស់ តើពួកគេត្រូវបង់ថ្លៃឈ្នួលឱ្យអ្នកណា? តើមានលក្ខខណ្ឌអ្វីខ្លះ? តើត្រូវបង់ញឹកញាប់ប៉ុណ្ណា?

៣៦. តើការជួលដីធ្លីមានសុវត្ថិភាពប៉ុណ្ណា?

៣៧. តើការបង់ប្រាក់ អាចផ្តល់ភាពស្របច្បាប់ឬទេ ចំពោះការស្នាក់ និងដាំដុះនៅលើដីធ្លី?

៣៨. តើមានប្រជាជនប៉ុន្មាននាក់បានបាត់បង់ដី? តើបាត់បង់ដោយរបៀបណា និងទៅលើអ្នកណា?

៣៩. តើមានដីធ្លីកំពុងមានទំនាស់ដែរឬទេ? សូមពន្យល់ពីប្រភេទនៃទំនាស់ ភាគីពាក់ព័ន្ធ មូលហេតុ និងផលវិបាក ។

៤០. តើយន្តការដោះស្រាយទំនាស់មានអ្វីខ្លះ មានប្រសិទ្ធិភាព និងយុត្តិធម៌ប៉ុណ្ណា?

៤១. បើសិនទំនាស់នោះនៅបន្តទៀត តើមកពីមូលហេតុអ្វី? សូមពន្យល់ ។

៤២. តើអ្នកយល់ថា យន្តការថ្នាក់ណាសមស្របៈ ថ្នាក់មូលដ្ឋាន/ឃុំ ថ្នាក់ស្រុក ថ្នាក់លើៗទៀត? តើអ្នកណាទទួលខុសត្រូវលើយន្តការថ្នាក់នេះ?

*កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ*

៤៣. តើពួកគេបានដឹងពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋាភិបាលដែរឬទេ? តើពួកគេបានដឹងដោយរបៀបណា? តើកម្មវិធីមានអ្វីខ្លះ?

៤៤. តើកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះ មានប្រយោជន៍ក្នុងការធានាសុវត្ថិភាព និងគុណភាពនៃការរស់នៅរបស់អ្នកដែរឬទេ? ក. សំរាប់ដីកសិកម្ម ខ. ដីលំនៅដ្ឋាន គ. ដីផ្សេងៗ ។

៤៥. តើកម្មវិធីនេះមានផលប៉ះពាល់អវិជ្ជមានដែរឬទេសំរាប់ប្រភេទដីនិមួយៗ (៤៤)? សូមពន្យល់ ។

៤៦. តើសហគមន៍ និងភូមិអាចជួយដល់កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីតាមរបៀបណា? សំរាប់ដីកសិកម្ម/លំនៅដ្ឋាន?

៤៧. តើអ្នកសុខចិត្តចំណាយប៉ុន្មាន ដើម្បីបានប័ណ្ណកម្មសិទ្ធិដីធ្លីមួយ? ក. ដីកសិកម្ម ខ. ដីលំនៅដ្ឋាន

៤៨. តើកន្លងមកសហគមន៍មានលទ្ធភាពចងក្រងរៀបចំប្រជាជនដែរឬទេ ដើម្បីកែលំអលទ្ធភាពមានដីប្រើប្រាស់ និងដើម្បីប្រកាសសិទ្ធិកាន់កាប់ដីធ្លី?

៤៩. បើសិនមានលទ្ធភាព តើស្ថាប័នរដ្ឋណាខ្លះបានជួយពួកគេ?

៥០. តាមគំនិតអ្នក តើស្ថាប័នណាមួយមានសមត្ថភាព និងមានទំនុកចិត្តថា អាចអនុវត្តកម្មវិធីនេះបានជោគជ័យ?

៥១. តើអ្នកមើលឃើញការលំបាកអ្វីខ្លះ ក្នុងការធ្វើអោយកម្មវិធីនេះមានភាពរីកចំរើន?

៥២. តើអ្នកសំណូមពរយ៉ាងណាខ្លះ ដើម្បីពង្រឹងកម្មវិធីនេះបន្ថែមទៀត?

ក. ការបំពាក់បំប៉ន ខ. តម្លាភាព គ. ការចូលរួមរបស់ NGOs ឃ. ការប្រជុំដោះស្រាយភូមិ

៥៣. តើគួរមានគោលនយោបាយអ្វីខ្លះសំរាប់ដីលំនៅដ្ឋាន? តើប្រជាជនគួរត្រូវបានផ្តល់ដីលំនៅដ្ឋាន អោយគ្រប់ៗគ្នា ដោយឈរលើគោលការណ៍មួយនាក់បានទទួលការចែកដីមួយដងឬយ៉ាងណា?

## ២. បញ្ហានៅទីក្រុង

*( ប្រមូលពត៌មានស្តីពីសមាសភាពក្រុម: ការបែងចែកតាមភេទ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច អាយុ ការអប់រំ, ចំនួនឆ្នាំស្នាក់នៅក្នុងភូមិ ... ។ ក្រុមពិភាក្សាគួរមានប្រហែល ៩-១០នាក់ និងច្រើនបំផុត ២០-២៥នាក់ ។ ក្នុងក្រុមពិភាក្សា ត្រូវមានស្ត្រី និងកសិករតូចតាចចូលរួមផង ។ ក្នុងករណីមានក្រុមពិភាក្សាធំ គួររៀបចំការពិភាក្សាតាមវិធីផ្សេង គួរធ្វើតាមរបៀបការវាយតំលៃតំបន់ជនបទដោយមានការចូលរួម អោយបានច្រើនជាងរបៀបប្រើក្នុងក្រុមពិភាក្សាតូចៗ) ។*

*ពត៌មានទូទៅ*

១. តើពួកគេរស់នៅក្នុងទីក្រុងភ្នំពេញតាំងពីដើម ឬក៏ទើបមករស់នៅ? តើពួកគេអាចប្រាប់យើងបានទេថា ពួកគេមកនៅទីនេះប៉ុន្មានឆ្នាំហើយ?

២. តើមានហេតុផលអ្វីខ្លះបានជាមកនៅទីនេះ?

៣. តើពួកគេមានដីនៅទីនេះឬទេ? បើគ្មានទេ តើអ្នកណាជាម្ចាស់ដីដែលពួកគេសង់ផ្ទះនេះ?

៤. តើនៅទីនេះមានផ្ទះប្រភេទអ្វីខ្លះ? (ពិនិត្យ និងបញ្ជាក់ពីសំភារៈសង់ ការប្រើប្រាស់អគ្គិសនី ទឹក បង្គន់ ជាដើម) ។

៥. បើសិនជាពួកគេមិនមែនជាម្ចាស់ដី តើអ្នកណាជាម្ចាស់ដី? តើហេតុអ្វីបានជាពួកគេអាចរស់នៅទីនេះបាន?

ក. ជួលដីផ្ទះគេ ខ. នៅជាមួយសាច់ញាតិ/មិត្តភក្តិ គ. ចាប់យកដីរដ្ឋ/ដីផ្សេងៗ

៦. តើគេបានវិនិយោគទុនថែមទៀតឬទេនៅលើផ្ទះ-ដីជួលនេះ?

៧. តើអ្នកគិតថា ការស្នាក់នៅរបស់ពួកគេវាស្របច្បាប់ ឬមិនស្របច្បាប់? សូមពន្យល់ពីអ្វីដែលស្របច្បាប់ និងអ្វីដែលមិនស្របច្បាប់ ។

៨. តើពួកគេដែលជួបការបណ្តេញ ឬគំរាមឱ្យចេញឬទេ? ប្រសិនបើមាន តើដោយអ្នកណា និងញឹកញាប់ប៉ុណ្ណា?

៩. តើពួកគេគិតថាមានសុវត្ថិភាពប៉ុណ្ណាក្នុងការស្នាក់នៅបច្ចុប្បន្ននេះ? តើពួកគេគិតថា នឹងត្រូវដេញចេញក្នុងពេលឆាប់ៗឬទេ? សូមពិនិត្យមើលប្រតិកម្មរបស់ប្រជាជនដែលមាន និងគ្មានប័ណ្ណ/ឯកសារផ្សេងៗ ។

១០. ប្រសិនបើគេផ្តល់ជំរើសអោយរុះរើទៅនៅកន្លែងថ្មីដែលមានក្រដាសស្នាមត្រឹមត្រូវ តើអ្នកដែលគ្មានក្រដាសស្នាមនឹងចេញទៅដែរឬទេ? បើសិនសុខចិត្ត តើអ្នកទាមទារចង់បានលក្ខខណ្ឌអតិបរិមាអ្វីខ្លះសំរាប់ការរុះរើចេញនេះ?

១១. តើពួកគេសុខចិត្តចំណាយប្រាក់ថែមទៀតឬទេ ដើម្បីអោយដីរបស់ពួកគេបានត្រឹមត្រូវតាមច្បាប់ និងដើម្បីមានសុវត្ថិភាពក្នុងការកាន់កាប់?

*បទពិសោធន៍របស់សហគមន៍ និងការពាក់ព័ន្ធជាមួយស្ថាប័នដទៃ*

១២. តើពួកគេមានសមាគមក្នុងសហគមន៍ដែរឬទេ?

១៣. តើសមាគមនេះបានដោះស្រាយបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពមានដីធ្លី ផ្ទះសំបែង និងប្រព័ន្ធផ្សេងៗដែលសំរួលការរស់នៅដែរឬទេ?

១៤. តើសមាគមមានសមាជិកភាពគ្របដណ្តប់ប្រជាជនបានប៉ុណ្ណា? តើពួកគេជួបគ្នាញឹកញាប់ដែរឬទេ?

១៥. តើសមាគមមានសកម្មភាពអ្វីខ្លះ?

១៦. តើការខិតខំចងក្រងរៀបចំប្រជាជននេះ អាចជួយប្រជាជនបានសក្តិសិទ្ធិប៉ុណ្ណា?

១៧. តើគេជួបប្រទះបញ្ហាអ្វីខ្លះក្នុងការចងក្រងរៀបចំប្រជាជន?

*បើសិនគ្មានសមាគម*

១៨. តើពួកគេមានអារម្មណ៍ថា គួរចងក្រងគ្នាបង្កើតជាសមាគមឡើងដែរឬទេ?

១៩. តើពួកគេយល់ថា ការចងក្រងគ្នាជាសមាគម នឹងអាចផ្តល់សន្តិសុខបានច្រើនថែមទៀតដែរឬទេ?

*កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ*

២០. តើពួកគេបានដឹងពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋាភិបាលដែរឬទេ? តើពួកគេបានដឹងដោយរបៀបណា? តើកម្មវិធីមានអ្វីខ្លះ?

២១. តើកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះ មានប្រយោជន៍ក្នុងការធានាសុវត្ថិភាព និងគុណភាពនៃការរស់នៅរបស់ពួកគេដែរឬទេ?

២២. តើកម្មវិធីនេះមានផលប៉ះពាល់អវិជ្ជមានដែរឬទេ? សូមពន្យល់ ។

២៣. តើសហគមន៍អាចជួយក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះតាមរបៀបណា?

២៤. តើពួកគេសុខចិត្តចំណាយប៉ុន្មាន ដើម្បីបានប័ណ្ណកម្មសិទ្ធិសំរាប់ដីលំនៅដ្ឋាន?

២៥. តើកន្លងមកសហគមន៍មានលទ្ធភាពចងក្រងរៀបចំប្រជាជនដែរឬទេ ដើម្បីកែលំអលទ្ធភាពមានដីប្រើប្រាស់ និងដើម្បីប្រកាសសិទ្ធិកាន់កាប់ដីធ្លី?

២៦. បើសិនមានលទ្ធភាព តើស្ថាប័នរដ្ឋណាខ្លះបានជួយពួកគេ?

២៧. តាមគំនិតអ្នក តើស្ថាប័នណាមួយមានសមត្ថភាព និងមានទំនុកចិត្តថា អាចអនុវត្តកម្មវិធីនេះបានជោគជ័យ?

២៨. តើអ្នកមើលឃើញនូវការលំបាកអ្វីខ្លះ ក្នុងការធ្វើអោយកម្មវិធីនេះមានភាពរីកចំរើន?

២៩. តើអ្នកសំណូមពរយ៉ាងណាខ្លះ ដើម្បីពង្រឹងកម្មវិធីនេះបន្ថែមទៀត?

ក. ការបំពាក់បំប៉ន ខ. តម្លាភាព គ. ការចូលរួមរបស់ NGOs ឃ. ការប្រជុំដោះស្រាយក្នុងសហគមន៍

៣០. តើគួរមានគោលនយោបាយអ្វីខ្លះសំរាប់ដីលំនៅដ្ឋាន? តើប្រជាជនគួរត្រូវបានផ្តល់ដីលំនៅដ្ឋានគ្រប់ៗគ្នា ដោយឈរលើគោលការណ៍មួយនាក់បានទទួលការចែកដីមួយដងឬយ៉ាងណា?

## ៣. កំណត់ហេតុនៃសិក្ខាសាលាសំរាប់អ្នកពាក់ព័ន្ធនឹងបញ្ហាដីធ្លីនៅក្នុងទីក្រុងភ្នំពេញ

រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្តកំណែទំរង់សំខាន់ៗ ដើម្បីសំរេចឱ្យបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយចិរភាព ។ ក្នុងកំណែទំរង់ទាំងនេះ ក្របខ័ណ្ឌគោលនយោបាយដីធ្លីថ្មី គឺជាចំនុចចំបងមួយក្នុងចំណោមគោលដៅសំខាន់ៗ ។ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ការផ្តល់មូលដ្ឋានផលិត (អចលនវត្ថុសំរាប់ផលិត) ដល់ប្រជាជនក្រីក្រ គឺជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយភាពក្រីក្រ ។ ដោយដីធ្លីជាសម្បត្តិមានតំលៃបំផុតនៅក្នុងបរិបទកម្ពុជា គោលនយោបាយដីធ្លីសមស្របសំដៅកាត់បន្ថយភាពគ្មានដីធ្លី និងធានាសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី នឹងជួយបានច្រើនណាស់ដល់ការធ្វើអោយចំណូលរបស់ប្រជាជនមានស្ថិរភាព និងមានកំណើន ។ ហេតុនេះហើយ ជាចំណែកមួយនៃគោលនយោបាយដីធ្លីថ្មីរបស់ខ្លួន រាជរដ្ឋាភិបាលមានបំណងធ្វើការផ្តល់កម្មសិទ្ធិ និងចុះបញ្ជីដីធ្លី ដោយផ្អែកតាមផែនទី ។

តាមធម្មតា បញ្ហាដីធ្លី គឺផ្តោតតែទៅលើវិស័យកសិកម្ម ប៉ុន្តែដោយសារមានកំណើនសេដ្ឋកិច្ច និងកំណើនប្រជាជននៅក្នុងទីក្រុង បញ្ហាដីធ្លីក្នុងទីក្រុងក៏ជាចំនុចសំខាន់ដូចគ្នា ។ កំណើនជនចំណាកស្រុកចូល និងកំណើនយ៉ាងឆាប់រហ័សនៃតំបន់អនាធិបតេយ្យនៅក្នុងក្រុង គឺជាភស្តុតាងជាក់ស្តែងក្នុងរឿងនេះ ។ ស្ថានភាពនៅទីក្រុងក៏មានសារៈសំខាន់ណាស់ដែរ ពីព្រោះដីធ្លីក្នុងក្រុងមានគោលដៅប្រើប្រាស់ច្រើនយ៉ាងដូចជា ការសាងសង់ផ្ទះ ហេដ្ឋារចនាសម្ព័ន្ធសង្គម ឧស្សាហកម្ម ពាណិជ្ជកម្ម អគាររដ្ឋបាល... ។ ដូច្នេះ គេចាំបាច់ត្រូវធានាអោយការប្រើប្រាស់ដីធ្លីមានលក្ខណៈចំណេញ និងត្រឹមត្រូវបំផុត ដើម្បីអោយមានចិរភាព ។ ក្រសួង MLMUPC ដោយមានជំនួយបច្ចេកទេសពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) កំពុងធ្វើការវាយតំលៃសង្គមទាក់ទងនឹងស្ថានភាពដីធ្លីក្នុងទីក្រុង (ដោយយកក្រុងភ្នំពេញមកសិក្សា) ដើម្បីស្រង់យកបទពិសោធន៍ និងមតិរបស់អ្នកពាក់ព័ន្ធនានាស្តីពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ និងចុះបញ្ជីដីធ្លី ។

ការវាយតំលៃសង្គមមានគោលដៅសំខាន់ៗមួយចំនួនៈ កំណត់ឱ្យបាននូវអ្នកជាប់ពាក់ព័ន្ធនានា និងការប្រើប្រាស់ដីធ្លីរបស់ពួកគេនៅទីក្រុង វិធីសាស្ត្រដែលអ្នកជាប់ពាក់ព័ន្ធប្រើប្រាស់ក្នុងការដោះស្រាយទំនាស់ សមត្ថភាពរដ្ឋបាលក្នុងការវិនិច្ឆ័យ/ដាក់អនុវត្តន៍ច្បាប់ និងសមត្ថភាពផ្សេងៗដែលអាជ្ញាធរ និងសហគមន៍ត្រូវកសាងបន្ថែម ។ គោលដៅទាំងនេះអាចសំរេចតាមរយៈការសិក្សាពីសហគមន៍មានចំណូលទាប និងការធ្វើសិក្ខាសាលាដើម្បីប្រមូលមតិយោបល់របស់អ្នកពាក់ព័ន្ធ ។ អត្ថបទនេះផ្តល់នូវគោលគំនិតខ្លះរបស់សិក្ខាសាលា ។

ចំនុចសំខាន់ៗដែលត្រូវពិភាក្សានៅក្នុងសិក្ខាសាលាមានដូចតទៅ :

*ក. លំនាំនៃការប្រើប្រាស់ដី និងការកំណត់តំបន់នានានៅក្នុងទីក្រុង និងនៅតំបន់ជាយក្រុងៈ* ក្នុងនេះចំនុចសំខាន់គឺត្រូវស្វែងយល់ពីលំនាំនៃការប្រើប្រាស់ដីធ្លីបច្ចុប្បន្ន និងបញ្ហាជាប់ពាក់ព័ន្ធនានា ជាពិសេស តំរូវការរបស់ក្រុមប្រជាជនផ្សេងៗ ។ ពត៌មានខាងលើនឹងជួយដល់ការកំណត់តំបន់ ពីព្រោះក្នុងការងារនេះ គេត្រូវការតួលេខដង់ស៊ីតេប្រជាជន និងទំហំប៉ាន់ស្មាននៃដីធ្លីសំរាប់កសាងសេវាផ្គត់ផ្គង់សាធារណៈ ដូចជាអគ្គិសនី ទឹក ប្រព័ន្ធលូ និងទំហំដីទុកសំរាប់ធ្វើទីធ្លាសាធារណៈ ។ គេត្រូវលើកមកពិភាក្សាផងដែរនូវផលប៉ះពាល់នៃការកំណត់តំបន់ទៅលើការរស់នៅរបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន ។ ការប្រើប្រាស់សិទ្ធិមិនត្រឹមត្រូវ ដូចជា សំណង់ខុសច្បាប់ និងការកាន់កាប់ដីធ្លីដោយគ្មានការអនុញ្ញាត គឺជាចំណែកមួយនៃការពិភាក្សានេះដែរ[១] ។

---

១ គេចាំបាច់ត្រូវញែកអោយដាច់ រវាងការរំលោភច្បាប់ដើម្បីបានចំណេញច្រើនថែមទៀត, និងការចាប់យកដីធ្វើឡើងដោយប្រជាជនក្រីក្រដើម្បីរស់ (មានពិភាក្សានៅក្នុងកថាខ័ណ្ឌបន្ទាប់) ។

*ខ. កំណើនប្រជាជន និងជនចំណាកស្រុកចូល:* បុរស និងស្ត្រីមកពីខេត្តផ្សេងៗ កំពុងតែបន្តចូលមកក្នុងក្រុងភ្នំពេញជាបន្ថែមទៅលើកំណើនធម្មជាតិនៃប្រជាជនដែលមានស្រាប់ (ប្រហែល ២,៥%ក្នុងមួយឆ្នាំ) ។ ដោយសារថា ភាគច្រើននៃជនចំណាកស្រុកពីជនបទមកទីក្រុងមិនមែនចេញមកពីស្រទាប់ប្រជាជនអ្នកធូរធារទេ ដូច្នេះភាពគ្មានផ្ទះសំបែង និងអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី គឺមិនមែនជារឿងចំលែកទេ ។ កន្លងមកនេះ ប្រជាជនបានមករស់នៅលើទូកតាមដងទន្លេ និងសង់ផ្ទះតាមចិញ្ចើមថ្នល់ ។ ចំនួនអ្នកគ្មានផ្ទះសំបែងអាចកើនឡើងជាបន្តបន្ទាប់ ដោយការងារក្នុងទីក្រុងបានទាក់ទាញប្រជាជនកាន់តែច្រើនឡើងៗឱ្យចូលមកទីក្រុង ។ស្ថានភាពនៅភ្នំពេញ អាចធ្លាក់យ៉ាប់យ៉ឺនយ៉ាងឆាប់រហ័ស ព្រោះនៅកម្ពុជាទីក្រុងធំមានតែមួយគត់ ។ ទីក្រុងធំទី២ គឺតូចជាងភ្នំពេញដល់ទៅ ១០ដង ។ តើគួររៀបចំគោលនយោបាយសំរាប់គ្រប់គ្រងប្រជាជនយ៉ាងដូចម្តេច ចំណាកស្រុក លំនៅដ្ឋាន ឬវិមជ្ឈការនគរូបនីយកម្ម ដើម្បីឱ្យបានសមស្របបំផុត? តើគួរមានគោលនយោបាយអ្វីសំរាប់អ្នកមករស់នៅតាមតំបន់អនាធិបតេយ្យ និងលើចិញ្ចើមថ្នល់ក្នុងទីក្រុង? នេះជាសំនួរចំនួនដែលអាចក្លាយជាប្រធានបទសំរាប់ការពិភាក្សា ។

*គ. ភូមិសាស្ត្រសំរាប់ការពង្រីកទីក្រុង:* សំនួរសំខាន់ៗមួយចំនួនដូចជា តើទីក្រុងត្រូវពង្រីកទៅទិសណា? តើការពង្រីកនេះអាចគ្រប់គ្រងបានឬទេ? តើដីអ្វីដែលអាចកាត់បញ្ចូលមកក្នុងបរិវេណទីក្រុង? សំនួរទាំងនេះមិនគ្រាន់តែមានសារៈសំខាន់សំរាប់ការកំណត់តំបន់ប៉ុណ្ណោះទេ ប៉ុន្តែក៏សំខាន់សំរាប់ការអភិវឌ្ឍន៏ផ្លូវ និងមធ្យោបាយដឹកជញ្ជូនផងដែរ ។

*ឃ. សមត្ថភាពនៃរដ្ឋបាលបច្ចុប្បន្ន:* តើរដ្ឋបាលបច្ចុប្បន្នមានលទ្ធភាពគ្រប់គ្រាន់ឬទេ ដើម្បីអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស? តើយន្តការដែលសហគមន៏ និងរដ្ឋបាល កំពុងប្រើប្រាស់សំរាប់ដោះស្រាយទំនាស់ដីធ្លី វាមានលក្ខណៈសមស្រប និងមានចីរភាពដែរឬទេ? តើបុគ្គលិកមានចំនួនគ្រប់គ្រាន់ មានការបំពាក់បំប៉ន និងមានបរិក្ខារគ្រប់គ្រាន់ដែរឬទេ? តើមានកង្វះចំណេះដឹង និងជំនាញអ្វីខ្លះ និងនៅកំរិតណា?

សិក្ខាសាលានេះមានគោលដៅប្រមូលពតិមាន និងមតិផ្សេងៗពីអ្នកចូលរួម ។ គេសង្ឃឹមថា អ្នកចូលរួមនឹងបង្ហាញពីបទពិសោធន៏ស្ថាប័ន និងបទពិសោធន៏ផ្ទាល់ខ្លួន ចំពោះបញ្ហាជាក់លាក់ ក៏ដូចជាបញ្ហាទូទៅ ហើយនិងលើកសំណូមពរនានាឡើង ។

## ៤. ចំណុចសំរាប់ពិភាក្សានៅក្នុងសិក្ខាសាលាអំពីទីក្រុង

*ក្រុមទី ១ - ការកំណត់តំបន់*

១. កាលបរិច្ឆេទនៃការកំណត់តំបន់នៅក្នុងទីក្រុងលើកក្រោយបង្អស់ដែលបានធ្វើឡើង ។ ការផ្លាស់ប្តូរផ្សេងៗនៃទីក្រុង តាំងពីពេលនោះមក ។

២. ការបន្សុីគ្នារវាងផែនការរៀបចំទីក្រុង (ដែលបានស្នើឡើង ឬបានអនុម័តហើយ) និងរចនាសម្ព័ន្ធរូបវ័ន្តដែលមានស្រាប់ (ដោយគិតគូរដល់ការចាប់យកដីសាធារណៈ និងសាងសង់គ្មានច្បាប់អនុញ្ញាត) និងផលប៉ះពាល់ផ្សេងៗ ។

៣. បញ្ហារៀបចំកន្លែងតាំងលំនៅអនាធិបតេយ្យទាំងចាស់ទាំងថ្មីអោយស្របច្បាប់ និងផលប៉ះពាល់ផ្សេងៗ (ជាពិសេសបញ្ហាថា តើសំណង់ និងអ្នកស្នាក់នៅគ្មានច្បាប់អនុញ្ញាត នឹងត្រូវរុះរើចេញមួយភាគធំ ឬទាំងអស់?)

៤. បញ្ហានៃការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លី ពីគោលដៅមួយ ទៅបំរើគោលដៅមួយទៀត (ដូចជា ការប្តូរពីដីសំរាប់ធ្វើកសិកម្ម ទៅជាដីលំនៅដ្ឋាន, ឬពីដីលំនៅដ្ឋាន ទៅជាកន្លែងពាណិជ្ជកម្ម) និងផលប៉ះពាល់ផ្សេងៗ ។

៥. បញ្ហាស្តីពីដីសំរាប់ទីធ្លាសាធារណៈ សាលារៀន មន្ទីរពេទ្យ សេវាផ្គត់ផ្គង់សាធារណៈ ផ្លូវថ្នល់ ប្រព័ន្ធដឹកជញ្ជូន...

៦. ការកំនត់ពីចំនួនប្រជាជន និងដង់សុីតេលំនៅដ្ឋាននៅក្នុងទីក្រុង (ដង់សុីតេនៃការសាងសង់) តើមានកត្តាអ្វីខ្លះដែលគួរពិចារណា?

៧. ចំណោទនៃការទទួលស្គាល់សំណង់អនាធិបតេយ្យ និងការពង្រីកបន្ថែមផ្សេងៗ?

*ក្រុមទី ២ - កំណើនប្រជាជន និងលំហូរចូលនៃជនចំណាកស្រុក*

១. កំណើនជនចំណាកស្រុកចូល និងចំណោទទៅលើដីធ្លីនៅក្នុងទីក្រុង ( ប្រវត្តិនៃចលនាប្រជាជននៅក្នុងក្រុង) ។

២. ភាពគ្មានលំនៅដ្ឋានក្នុងចំណោមអ្នកក្រ/អ្នកចំណូលថ្មី, និងសន្ទុះប្រែប្រួលនៃប្រជាជនប្រភេទនេះ ។

៣. អ្នករស់នៅលើចិញ្ចើមថ្នល់ សិទ្ធិតាំងទីលំនៅរបស់ពួកគេ និងសន្ទុះប្រែប្រួលនៃប្រជាជនប្រភេទនេះ ។

៤. ទីកន្លែងសំរាប់អ្នករកស៊ីដែលមានទីតាំងមិនស្របច្បាប់ (ផលប៉ះពាល់នៃការទទួលស្គាល់សកម្មភាពទាំងនេះ និង ដីធ្លីសំរាប់ដោះស្រាយអោយពួកគេ) ។

៥. បញ្ហាពាក់ព័ន្ធនឹងការជួលដីធ្លី និងទីកន្លែង ។

៦. ចំណោទនៃការខុសគ្នាខ្លាំងពេករវាងប្រាក់ចំណូលនៅក្នុងទីក្រុង និងតំលៃដីធ្លី ។

៧. បញ្ហាទីកន្លែងសំរាប់បំរើគោលដៅសង្គមកិច្ចជូនប្រជាជនក្រីក្រ ( ផ្លូវថ្នល់ ការអប់រំ សុខភាព សុខមាលភាព)

*ក្រុមទី៣ - ភូមិសាស្ត្រនៃការពង្រីកទីក្រុង*

១. តើទីក្រុងត្រូវពង្រីកទៅទិសខាងណា និងល្បឿនប៉ុណ្ណា?

២. ផលប៉ះពាល់នៃគំរូអភិវឌ្ឍន៍ "មានទីក្រុងធំមួយ" ទៅលើការស្ទះចរាចរ អគ្គិសនី ទឹក ប្រព័ន្ធលូ ការដឹកជញ្ជូន... ?

៣. តើមានលទ្ធភាពពង្រីកទីក្រុងភ្នំពេញទៀតដែរទេ ឬក៏ត្រូវបង្កើនទីក្រុងរណបដូចដែលប្រទេសផ្សេងទៀតជាច្រើន បានធ្វើ ដើម្បីស្រូបយកកំណើនប្រជាជន?

៤. ផលប៉ះពាល់នៃការពង្រីកទីក្រុង ទៅលើការប្រើប្រាស់ដីធ្លីសំរាប់ធ្វើរោងចក្រ ពាណិជ្ជកម្ម និងលំនៅដ្ឋាន ( តំលៃដី លទ្ធភាពអាចរកដីបាន ចីរភាព) ជាពិសេសការផ្ទេរដីចេញពីកសិកម្ម ។ តើរឿងនេះវាមានន័យថា ដីធ្លីដែលទិញ មកពីកសិករក្នុងតំលៃថោក នឹងត្រូវផ្ទេរទៅបំរើតំរូវការដីធ្លីក្នុងគោលដៅមិនមែនកសិកម្មក្នុងតំលៃខ្ពស់ឬយ៉ាង ណា? តើវាមានផលប៉ះពាល់អ្វីខ្លះចំពោះរបាយប្រាក់ចំណូល/ទ្រព្យសម្បត្តិ?

៥. លទ្ធភាព និងតំរូវការនៃការរៀបចំតាមគំរូធ្វើនគររូបនីយកម្មមានទីក្រុងស្នូលច្រើន ។ តើគំរោងរៀបចំទីក្រុងស្នូល បួននាបច្ចុប្បន្ន ( ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងប៉ៃលិន និងក្រុងកែប) វាគ្រប់គ្រាន់ហើយឬនៅ ឬក៏ត្រូវមាន ទីក្រុងច្រើនថែមទៀត?

៦. ការផ្តល់ហិរញ្ញវត្ថុដើម្បីពង្រីកទីក្រុង ។

*ក្រុមទី ៤ - សមត្ថភាពរបស់រដ្ឋបាលបច្ចុប្បន្ន*

១. តើបុគ្គលិកមានចំនួនគ្រប់គ្រាន់ឬទេសំរាប់ការងារចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី? តើបុគ្គលិកទាំងនេះមាន សមត្ថភាពគ្រប់គ្រាន់ដែរឬទេ?

២. តំរូវការខាងឧបករណ៍ សំភារៈ និងជំនួយទ្រទ្រង់ថវិកា ។

៣. ចំនួនបុគ្គលិកនៅតាមទីប្រជុំជន និងទីក្រុងផ្សេងទៀត ។

៤. បញ្ហាខាងផ្គត់ផ្គង់ (logistic problem): ដែលប៉ះពាល់ដល់/ពាក់ព័ន្ធនឹងកិច្ចសហការរវាងអន្តរក្រសួង ឬអន្តរ នាយកដ្ឋាន ក៏ដូចជាកិច្ចសហប្រតិបត្តិការរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ។

៥. យន្តការសំរាប់ដោះស្រាយទំនាស់ និងផ្សះផ្សាវិវាទរវាង ប្រជាជន និងប្រជាជន, ប្រជាជន និងអាជ្ញាធរ ។

៦. ផែនការរុះរើរៀបចំការតាំងលំនៅជាថ្មី ។

៧. កិច្ចសហការរវាងរដ្ឋាភិបាល និង NGOs ក្នុងការអនុវត្តន៍កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីជាក់ស្តែង ។

# ឯកសារយោង

Acharya, S. (2001), "Poverty Reduction in Cambodia – Some Reflections," Cambodia Development Review, Volume 5, Issue 2

Biddulph, R. (2000), Making the Poor Visible (Phnom Penh: Cambodia Land Project, Oxfam GB)

Boserup, E. (1965), The Conditions for Agricultural Growth (Chicago: Aldine)

Bray, F. (1986), The Rice Economy (London: Basil Blackwell)

Chan S, S Tep and S Acharya (2001), Land Tenure in Cambodia: A Data Update, Working Paper 19, Phnom Penh: Cambodia Development Resource Institute

Chandler, D. (1993), A History of Cambodia (Chaing Mai: Silkworm Books)

Curtis, G. (1998), Cambodia Reborn? (Washington: Brookings Institution Press, and Geneva: United Nations Research Institute for Social Development)

Godfrey M, S So, S. Tep, C Katz and D. Pon 2001, S Acharya, SD Chanto and H Thoraxy (2001), A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis, in Development Analysis Network (DAN) (Ed.) Labour Market in Transitional Economies and Southeast Asia and Thailand, Phnom Penh

Hanks L 1972, Rice and Man: Agricultural Ecology in Southeast Asia, Honolulu: University of Hawaii Press

ILO (International Labour Organisation) 1999, Reconstruction and Employment-Intensive Investment: From Crisis to Development, Geneva

Jose A.V 1986, Agrarian Class Formation in Asia, Research Paper, The Hague: Indo-Dutch Programme on Alternatives in Development

Kato E 1999, Where Has All the Land Gone? Land Rights and Access in Cambodia, Phnom Penh: Cambodia Land Project, Oxfam (GB)

Meijers H 1994, Land Tenure and Agriculture in Cambodia, Bangkok: Asian Institute of Technology

Ministry of Environment (1998), Cambodia: National Environment and Action Plan, Phnom Penh: Ministry of Environment

Murshid KAS (1997), Food Security in an Asian Transitional Economy: The Cambodian Experience, Working Paper 6, Phnom Penh: Cambodia Development Research Institute

NIS (National Institute of Statistics) 1999, General Population of Cambodia, Phnom Penh

RGC (Royal Government of Cambodia) 1999, Cambodia Poverty Assessment, Phnom Penh: Ministry of Planning

RGC (Royal Government of Cambodia) 2000, Sub-Decree on the Procedure of Establishing Cadastral Index Map and Land Register, Phnom Penh: Ministry of Land Management, Urban Planning and Construction, The General Department of Cadastre and Geography

Sida (Swedish International Development Agency) 2000, Cambodia: An Overview of the Land Sector, Phnom Penh

Sik Boreak (2000), Land Ownership, Sales and Concentration in Cambodia, Working Paper 16, Phnom Penh: Cambodia Development Research Institute

Thion S 1993, Watching Cambodia, Bangkok: White Lotus

van Acker F 1999, Hitting a Stone with an Egg? Cambodia's Rural Economy and Land Tenure in Transition, Discussion Paper, Antwerp: Centre for Asian Studies, University of Antwerp

Williams S 1999, Review of Secondary Sources Relating to Land Tenure and Access Issues', Phnom Penh: Cambodia Land Project, Oxfam (GB)

Williams S 2000, A Study of the Capacity of Five Provinces to Resolve Conflicts over Land, Phnom Penh: Cambodia Land Project, Oxfam (GB)

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រេចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេរ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជីម-ចរិយា ស្រ៊ុន-ពិច្ចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដួរីណា និងរ៉ូប៊ីន-ប៊ីដឺលវឺ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.000រៀល ។

៥. Toshiyasu Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin Godfrey, Toshiyasu Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina Orlova, Per Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.000រៀល ។

៩. តេង-យូតឺ ប៊ុន-ដួរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១0. Gorman, Siobhan, ជាមួយ ប៊ុន-ដួរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១0) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក ប៊ូរ៉ាក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល, សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ, ទេព-សារ៉ាវី, ប៊ុន-ដូរីណា, Claude Katz, Sarthi Acharya, ស៊ីសុវត្ថិ-ឌួងចាន់តូ, និង ហ៊ីង-ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និង ការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។